# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ

## ១១

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារមៀន

ព. ស. ២៥៥៧ គ. ស. ២០១៣

# បរមត្ថទីបនី

## តតិយភាគ

## ១១

ព. ស.

២៥៥៧

គ. ស.

២០១៣

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះថា បញ្ចបករណ៍

## ( កថាវត្ថុ-មហាបដ្ឋាន)

## តតិយភាគ

## ១១

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារម្យេន

ព. ស. ២៥៤៨ គ. ស. ២០១៣

# សេចក្តីបញ្ជាក់

គម្ពីរ **អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ

**១.បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ ***ធម្មសង្គណី***

**២.ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ ***វិភង្គ***

**៣.តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ ***បញ្ចបករណ៍***

តាំងពី ***ធាតុកថា*** រហូតដល់ចប់គម្ពីរ ***បដ្ឋាន*** ទាំងអស់ ។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា ***អភិធម្មបិដក តតិយភាគ ១១*** កើតឡើងដោយស្នាព្រះហស្តនៃ ***ព្រះពុទ្ធឃោសាចារ្យ*** ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ ***សូមបញ្ជាក់*** និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង

នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរងនូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះយើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣

**ខ្ញុំព្រះករុណា ខ្ញុំបាទ *សុន្ទរ៍ សាមឿន***

សូមអរព្រះគុណ និងអរគុណ

តារាងកែតម្រូវ "ឮ"

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

## អដ្ឋកថាតតិយភាគ ១១ នេះ មាន ៖

- ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តធុតង្គ** (ចម្ការដូង) មាន ៩ រូប
- ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តនិគ្រោធវ័ន** មាន ៦ រូប
- ភិក្ខុខន្តិជាតិកោ **ថៃ ភិរក្ស** - ធម្មាចារ្យ ធម្មានន្ទោ **ស្នួន សឿ**
- ភិក្ខុធម្មរក្ខិតោ **គង់ វន** - ភិក្ខុជោតញ្ញាណោ **វ៉ែត សុផាន់**
- ឧបាសក **ពុទ ស៊ីម** - ឧបាសក **ដាំ កុយ**
- ឧបាសក **សំរ៉ង វ័ណ្ណា** - ឧបាសក **វឿង សិរីសុគន្ធ**
- អ្នកគ្រូ **ធី សុធី** - ឧបាសក **ឡូ៉វ សុខុម**
- ឧបាសក **វៀម វដ្ឋា។**

## អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

- ភិក្ខុបញ្ញាបទីបោ **ព្រឿង ប៊ុនធឿន** - ភិក្ខុខន្តិជាតិកោ **ថៃ ភិរក្ស**
- ឧបាសិកា **លី ស៊ីវង្វ** ជាដើម - ឧបាសិកា **ងុន ស៊ូគី** ជាដើម
- លោក **បាន សុផាន** និងភរិយា
- ភិក្ខុសាមណេរ **វត្តគីរីម្យចាស់** ជាដើម
- លោក **ហេង សុវណ្ណារ៉ា** និងក្រុមគ្រួសារ

-ឧបាសក **ស្រុខ ចាន់ណា** និងក្រុមគ្រួសារ

-ឧបាសក **ម៉ៅ ផុន** ហៅ **ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យគម្ពីរនេះចេញជារូបរាងឡើង ។

បន្ទាប់ពីតតិយភាគ ១១ នេះទៅ ខ្ញុំព្រះករុណា ខ្ញុំបាទ នឹងដំណើរការបោះពុម្ពនូវតតិយភាគ ១២ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា ឬថា ចង់ចូលរួមជួយជាមតិយោបល់ ក្នុងន័យស្ថាបនា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៤

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅប្រទេស, ***អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន*** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ ***ហ៊ុន សែន*** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត ***ប៊ុត សាវង្ស*** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

***ដោយអំណាចនៃមហាកុសលជាធម្មទាននេះ សូមឱ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

..............................................................................................................................................................................................

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**តតិយភាគ ១១** ឈ្មោះ ..........................

សម្រាប់បោះពុម្ពលើកទី ៣ អាសយដ្ឋាន ..................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ

## វគ្គទី ១៦

**១.និគ្គហកថា** *សម្ដែងអំពីការសង្កត់សង្កិន* ..... ..... ..... ..... ..... .. ១

**២.បគ្គហកថា** *សម្ដែងអំពីការផ្គងចិត្ត* ..... ..... ..... ..... ...... ..... ៧

**៣.សុខានុប្បទានកថា** *សម្ដែងអំពីការបញ្ជូនសេចក្ដីសុខ* ..... ..... .... ៧

**៤.អធិគ្គយ្ហមនសិការកថា** *សម្ដែងអំពីមនសិការសរុបដោយសង្ខេប* ..... ៨

**៥.រូបំ ហេតូតិកថា** *សម្ដែងអំពីរូបជាហេតុ* ..... ..... ..... ..... ..... ៦

**៦.រូបំ សហេតុកន្តិកថា** *សម្ដែងអំពីរូបជាធម៌មានហេតុ* ..... ..... ..... ៧

**៧.រូបំ កុសលាកុសលន្តិកថា** *សម្ដែងអំពីរូបជាកុសល និងអកុសល* ..... ... ៧

**៨.រូបំ វិបាកោតិកថា** *សម្ដែងអំពីរូបជាវិបាក* ..... ..... ..... ..... ..... ៨

**៩.រូបំ រូបាវចរារូបាវចរន្តិកថា** *សម្ដែងអំពីរូបជារូបាវចរ និងអរូបាវចរ* .. ៩

**១០.រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា** *សម្ដែងអំពីរូបរាគៈរាប់បញ្ចូលក្នុងរូបធាតុជាដើម* ..... ..... ..... ..... ..... ..... ..... ១០

## វគ្គទី ១៧

**១.អត្ថិ អរហតោ បុញ្ញូបចយោតិកថា** *សម្ដែងអំពីព្រះអរហន្ត មានការ*

## បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

*សន្ទរំបុណ្យ* ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១១

**២. នត្ថិ អរហតោ អកាលមច្ចូតិកថា** *សម្ដែងអំពីព្រះអរហន្ត មិនមាន អកាលមរណៈ* ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១២

**៣.សព្វមិទំ កម្មតោតិកថា** *សម្ដែងអំពីវត្ថុទាំងពួងនេះមាន ព្រោះកម្ម* .. ១៥

**៤.ឥន្ទ្រិយពទ្ធកថា** *សម្ដែងអំពីវត្ថុដែលជាប់ដោយឥន្ទ្រិយជាទុក្ខ* ..... ... **១៨**

**៥.ឋបេត្វា អរិយមគ្គន្តិកថា** *សម្ដែងអំពីការវៀរអរិយមគ្គ* ..... ..... ២១

**៦.ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា** *ពាក្យមិនគប្បីពោលថា ព្រះសង្ឃទទួលនូវទក្ខិណាទាន* ..... ..... ..... ..... ..... ..... ..... ២២

**៧. ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា** *ពាក្យមិនគប្បីពោលថា ព្រះសង្ឃញ៉ាំងទក្ខិណាទានឲ្យបរិសុទ្ធ* ..... ..... ..... ..... ..... ..... ២៣

**៨. ន វត្តព្វំ សង្ឃោ ទក្ខិណំ ភុញ្ជតីតិកថា** *ពាក្យមិនគប្បីពោលថា ព្រះសង្ឃឆាន់អាហារជារបស់ធ្វើបុណ្យឲ្យបរិសុទ្ធ* ..... ..... ..... ..... ២៥

**៩. ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា** *ពាក្យមិនគប្បីពោលថា ទានដែលប្រគេនដល់ព្រះសង្ឃមានផលច្រើន* ..... ..... ..... ..... ... ២៦

**១០.ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា** *ពាក្យមិនគប្បីពោលថា*

# បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

*ទានដែលថ្វាយចំពោះព្រះពុទ្ធមានផលច្រើន* ..... ..... ..... ..... ..... ២៨

**១១.ទក្ខិណាវិសុទ្ធិកថា** *សម្តែងអំពីទក្ខិណាវិសុទ្ធិ* ..... ..... ..... ..... ២៩

## វគ្គទី ១៨

**១.មនុស្សលោកកថា** *សម្តែងអំពីមនុស្សលោក* ..... ..... ..... ..... ៣០

**២.ធម្មទេសនាកថា** *ពោលអំពីការសម្តែងព្រះធម៌* ..... ..... ..... ... ៣២

**៣.ករុណាកថា** *សម្តែងអំពីសេចក្តីករុណា* ..... ..... ..... ..... ..... ៣៣

**៤.គន្ធជាតិកថា** *សម្តែងអំពីគន្ធជាតិ* ..... ..... ..... ..... ..... ..... ៣៤

**៥.ឯកមគ្គកថា** *សម្តែងអំពីអរិយមគ្គតែមួយ* ..... ..... ..... ..... .. ៣៤

**៦.ឈានសង្កន្តិកថា** *សម្តែងអំពីការបង្កិត (រំលង) ឈាន* ..... ..... ៣៦

**៧.ឈានន្តរិកកថា** *សម្តែងអំពីឈានជាចន្លោះ* ..... ..... ..... ..... ៣៨

**៨.សមាបន្នោ សទ្ទំ សុណាតីតិកថា** *សម្តែងអំពីអ្នកចូលសមាបត្តិស្តាប់សំឡេងបាន* ..... ..... ..... ..... ..... ..... ..... ..... ..... ៤០

**៩.ចក្ខុនា រូបំ បស្សតីតិកថា** *សម្តែងអំពីមើលឃើញរូបដោយចក្ខុ* ...... ៤២

## វគ្គទី ១៩

**១.កិលេសប្បជហនកថា** *សម្តែងអំពីការលះកិលេស* ..... ..... ..... ៤៥

**២.សុញ្ញតាកថា** *សម្តែងអំពីសុញ្ញតា* ..... ..... ..... ..... ..... ..... ៤៦

## បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

**៣.សាមញ្ញផលកថា** *សម្ដែងអំពីសាមញ្ញផល* ..... ..... ..... ..... .. ៤៨

**៤.បត្តិកថា** *សម្ដែងអំពីបត្តិ គឺការបាន* ..... ..... ..... ..... ..... ... ៤៩

**៥.តថតាកថា** *សម្ដែងអំពីតថតា គឺភាពនៃធម៌ពិត* ..... ..... ..... ... ៥០

**៦.កុសលកថា** *សម្ដែងអំពីកុសល* ..... ..... ..... ..... ..... ..... ...៥១

**៧.អច្ចន្តនិយាមកថា** *សម្ដែងអំពីការទៀងទាត់ដោយចំណែកមួយ* ..... .. ៥២

**៨.ឥន្ទ្រិយកថា** *សម្ដែងអំពីឥន្ទ្រិយ* ..... ..... ..... ..... ..... ...... ៥៦

## វគ្គទី ២០

**១.អសញ្ចិច្ចកថា** *សម្ដែងអំពីការមិនក្លែង* ..... ..... ..... ..... ..... ៥៨

**២.ញាណកថា** *សម្ដែងអំពីញាណ* ..... ..... ..... ..... ..... ..... ... ៦១

**៣.និរយបាលកថា** *សម្ដែងអំពីនាយនិរយបាល* ..... ..... ..... ...... ៦២

**៤.តិរច្ឆានកថា** *សម្ដែងអំពីសត្វតិរច្ឆាន* ..... ..... ..... ..... ..... ... ៦៥

**៥.មគ្គកថា** *សម្ដែងអំពីមគ្គ* ..... ..... ..... ..... ..... ..... ..... ... ៦៦

**៦.ញាណកថា** *សម្ដែងអំពីញាណ* ..... ..... ..... ..... ..... ..... . ៦៨

## វគ្គទី ២១

**១.សាសនកថា** *សម្ដែងអំពីសាសនា* ..... ..... ..... ..... ..... .... ៧០

# បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

**២.អវិវិត្តកថា** *សម្តែងអំពីបុថុជ្ជនដែលមិនស្ងាត់* ..... ..... ..... ... ៧១

**៣.សញ្ញោជនកថា** *សម្តែងអំពីសញ្ញោជនះ* ..... ..... ..... ..... .... ៧២

**៤.ឫទ្ធិកថា** *សម្តែងអំពីឫទ្ធិ* ..... ..... ..... ..... ..... ..... ..... ....៧៣

**៥.ពុទ្ធកថា** *សម្តែងអំពីព្រះពុទ្ធជាម្ចាស់* ..... ..... ..... ..... ..... ...៧៥

**៦.សព្វទិសាកថា** *សម្តែងអំពីព្រះពុទ្ធស្ថិតនៅក្នុងទិសទាំងពួង* ..... ..... ៧៦

**៧.ធម្មកថា** *សម្តែងអំពីធម៌* ..... ..... ..... ..... ..... ..... ..... ...៧៧

**៨.កម្មកថា** *សម្តែងអំពីកម្ម* ..... ..... ..... ..... ..... ..... ..... ...៧៩

## វគ្គទី ២២

**១.បរិនិព្វានកថា** *សម្តែងអំពីការបរិនិព្វាន* ..... ..... ..... ..... ..... ៨១

**២.កុសលចិត្តកថា** *សម្តែងអំពីចិត្តជាកុសល* ..... ..... ..... ..... ... ៨១

**៣.អានេញ្ជកថា** *សម្តែងអំពីអានេញ្ជៈ* ..... ..... ..... ..... ..... .... ៨២

**៤.ធម្មាភិសមយកថា** *សម្តែងអំពីធម្មាភិសម័យ* ..... ..... ..... ..... ៨៤

**៥_៧.តិស្សន្នម្បិ កថានំ** *សម្តែងអំពីកថាទាំង ៣* ..... ..... ..... ..... ៨៥

**៨.អព្យាកតកថា** *សម្តែងអំពីអព្យាក្រឹត* ..... ..... ..... ..... ..... .. ៨៦

**៩.អាសេវនប្បច្ចយតាកថា** *សម្តែងអំពីភាពជាអាសេវនប្បច្ច័យ* ...... ៨៧

**១០.ខណិកកថា** *សម្តែងអំពីធម៌ទាំងពួងប្រព្រឹត្តទៅមួយជួរខណៈ* .... ៨៨

# បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

## វគ្គទី ២៣

**១.ឯកាធិប្បាយកថា** *សម្ដែងអំពីបំណងតែម្យ៉ាង* ..... ..... ..... .... ៩០

**២.អរហន្តវណ្ណកថា** *សម្ដែងអំពីភេទរបស់ព្រះអរហន្ត* ..... ..... .... ៩១

**៣_៧.ឥស្សរិយកាមការិកាកថា** *សម្ដែងអំពីការប្រាថ្នាក្នុងភាពជាធំ* ....... ៩១

**៨.រាគប្បដិរូបកាទិកថា** *សម្ដែងអំពីធម៌ជាគ្រឿងប្រៀបធៀប*

*ដោយរាគៈជាដើម* ..... ..... ..... ..... ..... ..... ..... ..... ..... ៩៣

**៩.អបរិនិប្ផន្នកថា** *សម្ដែងអំពីធម៌ដែលមិនសម្រេចហើយ* ..... ..... ៩៤

**និគមគាថា** ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៩៧

## អដ្ឋកថាយមកៈ

**អារម្ភកថា** ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៩៩

**១.មូលយមកវណ្ណនា** *ពណ៌នាអំពីឧទ្ទេសវារៈ* ..... ..... ..... ..... ១០០

,, ,, *និទ្ទេសវារៈ* ... ..... ..... ...... ១០៦

**២.ខន្ធយមកៈ** *ពណ៌នាអំពីឧទ្ទេសវារៈ* ..... ..... ..... ..... ..... ១១៣

**១.បណ្ណត្តិវារវណ្ណនា**
**ពណ៌នាអំពីនិទ្ទេសវារៈ បទសោធនៈ** ..... ..... ..... ..... .... ១១៨

# បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**


**បទសោធនមូលចក្កវារៈ** ..... ..... ..... ..... ..... ..... ..... .... ១៧០

**សុទ្ធក្ខន្ធវារៈ** ..... ..... ..... ..... ..... ..... ..... ..... ..... .... ១៧១

**សុទ្ធក្ខន្ធមូលចក្កវារៈ** ..... ..... ..... ..... ..... ..... ..... ..... .. ១៧៣

**២.បវត្តិវារវណ្ណនា** ..... ..... ..... ..... ..... ..... ..... ..... ... ១៧៣

**៣.បរិញ្ញាវារវណ្ណនា** ..... ..... ..... ..... ..... ..... ..... ..... .. ១៨៤

**៣.អាយតនយមកៈ**
*១.ពណ៌នាអំពីបញ្ញត្តិខទ្ទេសវារៈ* .... ..... ..... .... ..... ..... ១៨៩

*២. ,, បញ្ញត្តិនិទ្ទេសវារៈ* ... ..... ..... ..... ..... ..... ... ១៥៧

*៣. ,, បវត្តិវារៈ* ... ..... ..... ..... ..... ..... ..... ..... ១៥៣

**៤.ធាតុយមកៈ** ..... ..... ..... ..... ..... ..... ..... ..... ..... ១៦១

**៥.សច្ចយមកៈ**
*១.ពណ៌នាអំពីបញ្ញត្តិវារៈ* ..... ..... ..... ..... ..... ..... ..... ១៦៧

*២. ,, បវត្តិវារៈ* ... ..... ..... ..... ..... ..... ..... ..... ១៦៤

*៣. ,, បរិញ្ញាវារៈ* ..... ..... ..... ..... ..... ..... ..... ១៦៧

**៦.សង្ខារយមកៈ**
**១.***ពណ៌នាអំពីបញ្ញត្តិវារៈ* ..... ..... ..... ..... ..... ..... .... ១៦៨

*២. ,, បវត្តិវារៈ* ..... ..... ..... ..... ..... ..... ..... ..... ១៧៤

# បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**


**៧.អនុសយយមកៈ**
ពណ៌នាអំពីបរិច្ឆេទបរិច្ឆន្នុទ្ទេសវារៈ ..... ..... ..... ..... ..... ១៧៩

**អធិប្បាយអនុសយវារៈ** ..... ..... ..... ..... ..... ..... ..... .... ១៨១

**ពណ៌នាអំពីឧប្បត្តិដ្ឋានវារៈ** ..... ..... ..... ..... ..... ..... ..... ១៨៩

**មហាវារៈ ៧**
១.ពណ៌នាអំពីអនុសយវារៈ ..... ..... ..... ..... ..... ..... ២០០

២. ,, សានុសយវារៈ ..... ..... ..... ..... ..... ..... .... ២០៦

៣. ,, បជហានវារៈ ..... ..... ..... ..... ..... ..... ..... ២០៨

៤. ,, បរិញ្ញាវារៈ ..... ..... ..... ..... ..... ..... ..... .. ២១០

៥. ,, បហីនវារៈ ..... ..... ..... ..... ..... ..... ..... .. ២១១

៧. ,, ធាតុវារៈ និងធាតុវិសជ្ជនាវារៈ ..... ..... ..... .... ២១៤

**៨.ចិត្តយមកៈ**
ពណ៌នាអំពីមាតិកាឋបនវារៈ ..... ..... ..... ..... ..... ..... ២១៨

,, វិសជ្ជនាវារៈ (និទ្ទេស) ..... ..... ..... ..... ..... ... ២២៣

,, អតិក្កន្តកាលវារៈ ..... ..... ..... ..... ..... ..... .... ២២៦

**៩.ធម្មយមកៈ**
១.ពណ៌នាអំពីបញ្ញត្តិឧទ្ទេសវារៈ ..... ..... ..... ..... ..... ... ២២៩

## បរមត្ថទីបនី


**មាតិកាធម៌** ទំព័រ

*២. ,, និទ្ទេសនៃបញ្ញត្តិវារៈ ..... ..... ..... ..... ..... ... ២៣១*

*៣. ,, បវត្តិវារៈ ..... ..... ..... ..... ..... ..... ..... ... ២៣១*

**១០.ឥន្ទ្រិយយមកៈ** ..... ..... ..... ..... ..... ..... ..... ...... ២៣៥

*ពណ៌នាអំពីបវត្តិវារៈ ..... ..... ..... ..... ..... ..... ..... ..... ២៣៧*

*,, បរិញ្ញាវារៈ ..... ..... ..... ..... ..... ..... ..... .... ២៤១*

**និគមគាថា** ..... ..... ..... ..... ..... ..... ..... ..... ..... ... ២៤២


## មហាបដ្ឋានប្បករណ៍


អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ២៤៥

ពណ៌នាអំពីឧទ្ទេសវារៈ ... ... ... ... ... ... ... ... .. ២៤៦


## ពណ៌នាអំពីបច្ចយវិភង្គវារៈ


១.ពាក្យថា ហេតុប្បច្ច័យ ... ... ... ... ... ... ... ... ២៥៤

២. ,, អារម្មណប្បច្ច័យ... ... ... ... ... ... .... ២៥៨

៣. ,, អធិបតិប្បច្ច័យ... ... ... ... ... ... ... ... ២៥៩

៤. ,, អនន្តរប្បច្ច័យ<br>៥. ,, សមនន្តរប្បច្ច័យ } ... ... ... ... ... ២៦០

៦. ,, សហជាតប្បច្ច័យ ... ... ... ... ... ... ... ២៦៣

## បរមត្ថទីបនី

មាតិកាធម៌ ទំព័រ


៧. ពាក្យថា អញ្ញមញ្ញប្បច្ច័យ ... ... ... ... ... ... ... ២៦៤
៨. ,, និស្សយប្បច្ច័យ ... ... ... ... ... ... .... ២៦៤
៩. ,, ឧបនិស្សយប្បច្ច័យ ... ... ... ... ... .... ២៦៥
១០. ,, បុរេជាតប្បច្ច័យ ... ... ... ... ... ... ... ២៧០
១១. ,, បច្ឆាជាតប្បច្ច័យ ... ... ... ... ... ... .... ២៧១
១២. ,, អាសេវនប្បច្ច័យ ... ... ... ... ... .... ២៧១
១៣. ,, កម្មប្បច្ច័យ ... ... ... ... ... ... ... ... ២៧២
១៤. ,, វិបាកប្បច្ច័យ ... ... ... ... ... ... .... ២៧៣
១៥. ,, អាហារប្បច្ច័យ ... ... ... ... ... .... ២៧៤
១៦. ,, ឥន្ទ្រិយប្បច្ច័យ ... ... ... ... ... ..... ... ២៧៤
១៧. ,, ឈានប្បច្ច័យ ... ... ... ... ... ... .... ២៧៥
១៨. ,, មគ្គប្បច្ច័យ ... ... ... ... ... ... .... ២៧៦
១៩. ,, សម្បយុត្តប្បច្ច័យ ... ... ... ... ... .... ២៧៧
២០. ,, វិប្បយុត្តប្បច្ច័យ ... ... ... ... ... .... ២៧៧
២១. ,, អត្ថិប្បច្ច័យ ... ... ... ... ... ... .... ២៧៨
២២. ,, នត្ថិប្បច្ច័យ ... ... ... ... ... ... .... ២៨០

## បរមត្ថទីបនី

មាតិកាធម៌ ទំព័រ


២៣. ,, វិគតប្បច្ច័យ ... ... ... ... ... ... .... ២៨១

២៤. ,, អវិគតប្បច្ច័យ ... ... ... ... ... ... .... ២៨១


## បច្ចយនិទ្ទេស


១.ពណ៌នាអំពីនិទ្ទេសនៃហេតុប្បច្ច័យ ... ... ... ... ... .. ២៨៤

២. ,, ,, អារម្មណប្បច្ច័យ ... ... ... ... ... ២៩៧

៣. ,, ,, អធិបតិប្បច្ច័យ ... ... ... ... ... ៣០៣

៤. ,, ,, អនន្តរប្បច្ច័យ ... ... ... ... ... ៣០៨

៥. ,, ,, សមនន្តរប្បច្ច័យ ... ... ... ... .. ៣១៣

៦. ,, ,, សហជាតប្បច្ច័យ ... ... ... ... ... ៣១៣

៧. ,, ,, អញ្ញមញ្ញប្បច្ច័យ ... ... ... ... ... ៣១៨

៨. ,, ,, និស្សយប្បច្ច័យ ... ... ... ... ... ៣២០

៩. ,, ,, ឧបនិស្សយប្បច្ច័យ ... ... ... .... ៣២២

១០. ,, ,, បុរេជាតប្បច្ច័យ ... ... ... ... .... ៣២៩

១១. ,, ,, បច្ឆាជាតប្បច្ច័យ ... ... ... ... .... ៣៣១

១២. ,, ,, អាសេវនប្បច្ច័យ ... ... ... ... .. ៣៣៣

## បរមត្ថទីបនី

មាតិកាធម៌ ទំព័រ


១៣.ពណ៌នាអំពីនិទ្ទេសនៃកម្មប្បច្ច័យ ... ... ... ... .... ៣៣៧

១៤. ,, ,, វិបាកប្បច្ច័យ ... ... ... ... ... .. ៣៤១

១៥. ,, ,, អាហារប្បច្ច័យ ... ... ... ... ... ៣៤៣

១៦. ,, ,, ឥន្ទ្រិយប្បច្ច័យ ... ... ... ... .... ៣៤៦

១៧. ,, ,, ឈានប្បច្ច័យ ... ... ... ... ... .. ៣៥០

១៨. ,, ,, មគ្គប្បច្ច័យ ... ... ... ... ... .. ៣៥២

១៩. ,, ,, សម្បយុត្តប្បច្ច័យ ... ... ... ... ... ៣៥៤

២០. ,, ,, វិប្បយុត្តប្បច្ច័យ ... ... ... ... ... ៣៥៥

២១. ,, ,, អត្ថិប្បច្ច័យ ... ... ... ... ... ... ៣៥៩

២២. ,, ,, នត្ថិប្បច្ច័យ ... ... ... ... ... .. ៣៦៦

២៣. ,, ,, វិគតប្បច្ច័យ ... ... ... ... ... ៣៦៧

២៤. ,, ,, អវិគតប្បច្ច័យ ... ... ... ... ... ៣៦៨

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថាតតិយភាគ ១១ នេះ

អភិ. = អភិធម្មបិដក

អភិ. ធាតុកថា = អភិធម្មបិដក ធាតុកថា

អំ. តិក. = អង្គុត្តរនិកាយ តិកនិបាត

អំ. ទសក. = អង្គុត្តរនិកាយ ទសកនិបាត

អំ. សត្តក. = អង្គុត្តរនិកាយ សត្តកនិបាត

សំ. ខ. = សំយុត្តនិកាយ ខន្ធវារវគ្គ

សំ. ម. = សំយុត្តនិកាយ មហាវគ្គ

សំ. ស. = សំយុត្តនិកាយ សឡាយតនវគ្គ

សំ. និ. = សំយុត្តនិកាយ

សំ. សឡា. = សំយុត្តនិកាយ សឡាយតនវគ្គ

ម. ម. = មជ្ឈិមនិកាយ មហាវគ្គ

ម. មូ. = មជ្ឈិមនិកាយ មូលបណ្ណាសកៈ

ម. ឧ. = មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

វិនយ. មហាវគ្គ /៦ = វិនយបិដក មហាវគ្គ បឋមភាគ ៦

វិនយ. ៣/(សង្ឃាទិសេសកណ្ឌ) = វិនយបិដក តតិយភាគ ៣(សង្ឃាទិសេសកណ្ឌ)

# បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ ១១

ព. ស. ២៥៥៧

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ

## កថាវត្ថុបករណ៍ (ត)

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## វគ្គទី ១៦

## ១.និគ្គហកថា សម្ដែងអំពីការសង្កត់សង្កិន

*ឥឡូវនេះ ឈ្មោះថា រឿងការសង្កត់សង្កិន ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "អ្នកណាមានកម្លាំង មានអំណាចក្នុងលោក, បើគេមិនគប្បីអាចដើម្បីសង្កត់សង្កិនចិត្តរបស់អ្នកដទៃបានទេ, ការមានកម្លាំងឬការមានអំណាចនឹងមានប្រយោជន៍អ្វីដល់ជនទាំងនោះ, ក៏ព្រោះភាពជាអ្នកមានកម្លាំង និងមានអំណាចរបស់បុគ្គលទាំងនោះ ទើបសង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបាន" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"បុគ្គលដទៃសង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ"*** *ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ បណ្ដាពាក្យទាំងនោះ ពាក្យថា*

***“សង្កត់សង្កិន”*** *បានដល់ ការហាមចិត្តមិនឲ្យធ្លាក់ទៅកាន់សង្កិលេស ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕*

ចប់និគ្គហកថា

## ២.បគ្គហកថា សម្ដែងអំពីការផ្គងចិត្ត

*សូម្បីក្នុងកថាពោលអំពីការផ្គងចិត្ត ក៏មានន័យដូចគ្នានេះដែរ ៕*

## ៣.សុខានុប្បទានកថា

## សម្ដែងអំពីការបញ្ជូនសេចក្ដីសុខ

*ឥឡូវនេះ ឈ្មោះថា រឿងការបញ្ជូនសេចក្ដីសុខ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយហេតុវាទថា “បុគ្គលដទៃបញ្ជូនសេចក្ដីសុខឲ្យដល់បុគ្គលដទៃបាន” ដូច្នោះ ព្រោះអាស្រ័យព្រះសូត្រដែលព្រះឧទាយិត្ថេរពោលទុកថា* ***“ព្រះសាស្ដារបស់យើង ទ្រង់ប្រទានសុខធម៌ទាំងឡាយដល់ជនដ៏ច្រើនហ្ន៎”*** [១] *ជាដើម ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ត្រូវសកវាទីសួរថា* ***“បុគ្គលដទៃបញ្ជូនសេចក្ដីសុខ***

---

[១] ម. ម. ។

***របស់ខ្លួន"*** *ជាដើម សេចក្ដីថា បរវាទីរមែងឆ្លើយបដិសេធដោយពាក្យសម្ដីថា "នរណាមួយ មិនអាចប្រគល់សេចក្ដីសុខរបស់ខ្លួន ឬរបស់អ្នកដទៃឲ្យដល់នរណាមួយបានទេ, ក៏ឈ្មោះថា ការបញ្ជូនសេចក្ដីសុខក្នុងទីនេះ នឹងគប្បីមានបានដូចម្ដេច ?" ចំណែកក្នុងបញ្ហាថា* ***"បុគ្គលដទៃបញ្ជូនសេចក្ដីសុខរបស់ខ្លួនឱ្យដល់បុគ្គលដទៃ ក៏មិនមែន"*** *ជាដើម បរវាទីឆ្លើយតបតាមលទ្ធិថា "ក៏ឈ្មោះថា 'ការបញ្ជូនសេចក្ដីសុខ' ដូច្នេះ មិនអាចមានទេ" ។ ពាក្យថា* ***"ក៏មិនត្រូវពោល"*** *សកវាទីពោលហើយ ព្រោះមិនមានសេចក្ដីសុខដូច្នោះ ។ ព្រះបាលីថា* ***"ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រទានសុខធម៌ទាំងឡាយឱ្យ"*** *ជាដើម រមែងសម្ដែងនូវភាវៈនៃព្រះមានព្រះភាគ ទ្រង់ជាបច្ច័យដើម្បីឲ្យកើតសេចក្ដីសុខដល់ជនទាំងឡាយ, មិនមែនសម្ដែងការបញ្ជូនសេចក្ដីសុខ ឲ្យដល់ជនទាំងឡាយ ដូចការឲ្យរបស់របរផ្សេងៗ មានអាហារជាដើមឡើយ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនខអាង ដូចដែលលើកមកនោះ ដោយប្រការដូច្នេះទេ ។*

ចប់សុខានុប្បទានកថា

# ៤.អធិគ្គយ្ហមនសិការកថា

## សម្ដែងអំពីមនសិការសរុបដោយសង្ខេប

*ឥឡូវនេះ ឈ្មោះថា រឿងមនសិការសរុបដោយសង្ខេប* ***គឺការរួបរួមសង្ខារមកពិចារណា*** *៖*

*ក្នុងរឿងនោះ មនសិការមាន ២ យ៉ាង គឺនយតោ មនសិការ និងអារម្មណតោ មនសិការ ។ ក្នុងមនសិការទាំង ២ នោះ សូម្បីកាលបុគ្គលឃើញសង្ខារតែមួយដោយសភាពជារបស់មិនទៀងហើយ គេរមែងជាអ្នកបានឈ្មោះថា មនសិការក្នុងសង្ខារទាំងឡាយដ៏សេសថា "សង្ខារទាំងពួងមិនទៀង" ដូច្នេះ ឈ្មោះថា* ***នយតោ មនសិការ;*** *ក៏កាលអ្នកណាមនសិការសង្ខារទាំងឡាយ ដែលជាអតីត គេរមែងមិនអាចដើម្បីមនសិការសង្ខារទាំងឡាយ ដែលជាអនាគតបានទេ ។ ព្រោះមនសិការសង្ខារយ៉ាងណាមួយ ក្នុងសង្ខារដែលជាអតីតជាដើម ទើបឈ្មោះថា* ***អារម្មណ-តោ មនសិការ*** *។ បណ្ដាមនសិការទាំងនោះ កាលបុគ្គលមនសិការក្នុងបច្ចុប្បន្ន រមែងមនសិការក្នុងសង្ខារទាំងឡាយ ដោយចិត្តណា, ចិត្តនោះរមែងមិនអាចដើម្បីមនសិការ ក្នុងបច្ចុប្បន្នខណៈបានឡើយ ។*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា "បុគ្គលឈ្មោះថា មនសិការសង្ខារទាំងឡាយ*

ដោយការប្រកាន់យកសរុបសង្ខេប គឺរួបរួមហើយ ទើបមនសិការសង្ខារទាំងពួងជាមួយគ្នា" ដូច្នេះ ព្រោះអាស្រ័យពាក្យថា "***សង្ខារទាំងពួងជារបស់មិនទៀង***" ជាដើម, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទបុគ្គលដែលមនសិការសង្ខារទាំងពួងនោះ ដោយមនសិការរួមគ្នាដោយចិត្ត គប្បីមនសិការនូវចិត្តនោះ ដោយមនសិការនោះឬ ? ទើបពោលពាក្យថា "ដឹងច្បាស់នូវចិត្តនោះ ដោយចិត្តនោះមានឬ ?" ជាដើម ។ ពាក្យឆ្លើយបដិសេធដោយសំដៅយកថា នរណាមួយក៏មិនអាចដើម្បីដឹង ព្រោះធ្វើឲ្យជាអារម្មណ៍ទេ ។ តែឆ្លើយតបដោយសំដៅយកថា "សូម្បីចិត្តនោះរមែងដឹងនុ៎ះឯង ព្រោះសភាពនៃចិត្តនោះ ជាធម្មជាតិដឹងថា 'ចិត្តមានលក្ខណៈយ៉ាងនេះ" ។

ប្រការមួយទៀត បរវាទីរមែងឆ្លើយបដិសេធ ដោយពាក្យថា "ចិត្តនោះឯង មិនជាអារម្មណ៍របស់ចិត្តនោះទេ" , តែរមែងឆ្លើយតបដោយអំណាចនៃលទ្ធិដែលកើតឡើងហើយ ព្រោះអាស្រ័យព្រះបាលីថា "***កាលណាបុគ្គលឃើញដោយបញ្ញាថា 'សង្ខារទាំងពួងមិនទៀង***" ជាដើម ។ សូម្បី ២ បញ្ហាដ៏សេសទៀត ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកក្នុងពាក្យទាំងឡាយថា "ពាល់ត្រូវផស្សៈនោះ ដោយផស្សៈនោះ" ជាដើម បរវាទីកាលមិនឃើញព្រះសូត្រដូច្នោះ ទើបឆ្លើយបដិសេធ ។ ព្រោះហេតុ

នោះឯង ក្នុងបញ្ហាទាំងឡាយ មានអតីតកាលជាដើម បណ្ឌិតគប្បីជ្រាបការបដិសេធ និងពាក្យឆ្លើយតប ដោយន័យដែលពោលហើយក្នុងពេលមុន ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។ ព្រះបាលីថា “សង្ខារទាំងពួង មិនទៀង” ជាដើម លោកពោលទុកសំដៅដល់ការឃើញដោយន័យ, មិនមែនឃើញដោយអារម្មណ៍ក្នុងខណៈជាមួយគ្នាទេ, ព្រោះហេតុដូច្នោះ ពាក្យនោះ ទើបមិនមែនខអាងដែលលើកមកសម្រេចថា ជាការមនសិការដោយអារម្មណ៍ឡើយ ៕

**ចប់អធិគ្គយ្ហមនសិការកថា**

## ៥.រូបំ ហេតូតិកថា សម្តែងអំពីរូបជាហេតុ

ឥឡូវនេះ ឈ្មោះថា រឿងរូបជាហេតុ ៖

ក្នុងរឿងនោះ ពាក្យថា ***“ហេតុ”*** បានដល់ ហេតុដែលជាឈ្មោះរបស់ហេតុមានកុសលមូលជាដើមខ្លះ, ដែលជាឈ្មោះរបស់បច្ច័យយ៉ាងណាមួយខ្លះ ។ ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា “រូបជាហេតុដោយមិនប្លែកគ្នាឡើយ” ព្រោះអាស្រ័យព្រះបាលីថា “មហាភូតរូប ៤ ជាហេតុរបស់ឧបាទាយរូប” ដូច្នេះ ព្រោះមិនញែកអត្ថយ៉ាងនេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា ***“ជាហេតុ គឺលោភៈ”***

*សេចក្តីថា សកវាទីរមែងសួរថា រូបជាអហេតុកហេតុឬ ? បរវាទីឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហាដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។*

*ក្នុងពាក្យថា "មហាភូតរូបទាំងឡាយ ជាហេតុ ព្រោះជាទីអាស្រ័យនៃឧបាទាយរូបទាំងឡាយ" នេះ លោកពោលដល់ភាវៈជាហេតុ ព្រោះអត្ថថា ជាបច្ច័យ មិនបានពោលដល់ភាវៈជាហេតុ ព្រោះអត្ថថា ជាមូលទេ, ព្រោះហេតុដូច្នោះ ព្រះបាលីនុ៎ះ ទើបមិនមែនជាសាធកៈ យល់ព្រមក្នុងបញ្ហានេះឡើយ ៕*

ចប់រូបំហេតូតិកថា

## ៦.រូបំ សហេតុកន្តិកថា

## សម្តែងអំពីរូបជាធម៌មានហេតុ

*ក្នុងការពណ៌នាកថាថា "រូបជាធម៌មានហេតុ" បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះឯងចុះ ៕*

ចប់រូបំសហេតុកន្តិកថា

..................................

## ៧.រូបំ កុសលាកុសលន្តិកថា

## សម្តែងអំពីរូបជាកុសល និងអកុសល

*ឥឡូវនេះ ឈ្មោះថា រឿងរូបជាកុសល និងអកុសល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហិសាសកៈ និងសមិតិយៈថា “កាយវិញ្ញត្តិ និងវចីវិញ្ញត្តិរូប ពោលគឺកាយកម្ម និងវចីកម្មថា ជាកុសលខ្លះ ជាអកុសលខ្លះ” ដោយសំដៅយកព្រះបាលីថា* ***“កាយកម្ម និងវចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មាន”*** *ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“រូបជាកុសលឬ ?”*** *ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទថា “ប្រសិនបើ រូបជាកុសលមែន, រូបនោះ ក៏នឹងគប្បីជាសភាវៈផ្សេងៗ” ដូច្នេះ ទើបពោលពាក្យថា* ***“រូបជាធម៌មានអារម្មណ៍”*** *ជាដើម; សូម្បីក្នុងបញ្ហាសម្ដែងអំពីកុសលខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់រូបំកុសលាកុសលន្តិកថា

........................................

## ៨.រូបំ វិបាកោតិកថា សម្ដែងអំពីរូបជាវិបាក

*ឥឡូវនេះ ឈ្មោះថា រូបជាវិបាក ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈ និងសមិតិយៈថា “រូបណាដែលកើតឡើង ព្រោះធ្វើកម្មទុក សូម្បីរូបនោះ ក៏ជាវិបាក ដូចចិត្ត និងចេតសិកដែលកើតឡើង ព្រោះ*

ធ្វើកម្មទុក” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា **“រូបជាទីតាំងនៃសុខវេទនា”** ជាដើម ដើម្បីចោទថា “បើរូបជាវិបាកមែន, រូបនោះ ក៏គប្បីជាសភាវៈផ្សេងៗ ដូចដែលបានពោលមកនេះ” ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕

ចប់រូបំវិបាកោតិកថា

# ៩.រូបំ រូបាវចរារូបាវចរន្តិកថា

## សម្ដែងអំពីរូបជារូបាវចរ និងអរូបាវចរ

ឥឡូវនេះ ឈ្មោះថា រឿងរូបជារូបាវចរ និងអរូបាវចរ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈថា “រូបណាកើតឡើង ព្រោះធ្វើកម្មដែលជាចំណែកកាមាវចរ រូបនោះ ក៏ជាកាមាវចរ ព្រោះហេតុណា, ព្រោះហេតុនោះ រូបណាដែលកើតឡើង សូម្បីព្រោះធ្វើកម្មដែលជាចំណែករូបាវចរ និងអរូបាវចរ រូបនោះ ក៏គប្បីជារូបាវចរ និងអរូបាវចរ” ដូច្នេះ, ពាក្យសួររបស់សកវាទីថា “រូបជារូបាវចរ និងអរូបាវចរមានឬ ?” ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យ

*តាមដែលបានពោលហើយក្នុងពេលមុននុ៎ះឯង ។*

ចប់រូបរិរូបាវចរារូបាវចរន្តិកថា

..........................................

## ១០.រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា

## សម្តែងអំពីរូបរាគៈរាប់បញ្ចូលក្នុងរូបធាតុជាដើម

*ឥឡូវនេះ ឈ្មោះថា រឿងរូបរាគៈរាប់បញ្ចូលក្នុងរូបធាតុ, អរូបរាគៈរាប់បញ្ចូលក្នុងអរូបធាតុ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈថា "កាមរាគៈ ការត្រេកអរក្នុងកាម រាប់បញ្ចូលក្នុងកាមធាតុព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីរូបរាគៈទាំងឡាយ គឺការត្រេកអរក្នុងរូប ក៏គប្បីរាប់បញ្ចូលក្នុងរូបធាតុ និងអរូបធាតុដែរ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលក្នុងពេលមុននុ៎ះឯង ។ ព្រោះថា ក្នុងបញ្ហានេះ បណ្ឌិតគប្បីជ្រាបបទដែលផ្សេងគ្នាថា "រូបរាគៈរមែងដេកត្រាំក្នុងរូបធាតុ, និងអរូបរាគៈរមែងដេកត្រាំក្នុងអរូបធាតុតែម្យ៉ាង" ។ ក៏លទ្ធិនោះ គប្បីមានដល់និកាយអន្ធកៈទាំងឡាយផង ដល់និកាយសមិតិយៈទាំងឡាយផង, តែបញ្ហានេះ ជារបស់និកាយអន្ធកៈទាំងឡាយប៉ុណ្ណោះ ។*

ចប់រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា

### រួមកថាដែលមានក្នុងវគ្គនេះ គឺ

១.និគ្គហកថា, ២.បគ្គហកថា, ៣.សុខានុប្បទានកថា, ៤.អធិគ្គយ្ហមនសិការកថា, ៥.រូបំហេតូតិកថា, ៦.រូបំសហេតុកន្តិកថា, ៧.រូបំកុសលាកុសលន្តិកថា, ៨.រូបំវិបាកោតិកថា, ៩.រូបំរូបាវចរារូបាវចរន្តិកថា, ១០.រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា ។

**ចប់វគ្គទី ១៦**

## វគ្គទី ១៧

### ១.អត្ថិ អរហតោ បុញ្ញូបចយោតិកថា

### សម្តែងអំពីព្រះអរហន្តមានការសន្សំបុណ្យ

ឥឡូវនេះ ឈ្មោះថា រឿងព្រះអរហន្តមានការសន្សំបុណ្យ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈថា "ការសន្សំបុណ្យរបស់ព្រះអរហន្ត គប្បីមាន ព្រោះអាស្រ័យកម្ម មានការចែករំលែកទាន និងការថ្វាយបង្គំព្រះចេតិយ" ជាដើម, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរថា "ឈ្មោះថាព្រះអរហន្តជាអ្នកមានបុណ្យ និងបាបដែលលះបានហើយ, បើព្រះអរហន្ត

កប្បីធ្វើបុណ្យខ្លះ កប្បីធ្វើបាបខ្លះមែន" ដូច្នេះ ទើបពោលពាក្យថា ***"ព្រះអរហន្ត មានការសន្សំបាបឬ ?"*** បរវាទីកាលមិនឃើញនូវការធ្វើកម្ម មានបាណាតិបាតជាដើម ទើបឆ្លើយបដិសេធ ។ ក្នុងពាក្យថា ***"ព្រះអរហន្តសន្សំបុញ្ញាភិសង្ខារ"*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះកម្មដែលជាហេតុនាំទៅកាន់ភពរបស់ព្រះអរហន្តមិនមានទេ ។

ក្នុងពាក្យថា ***"ព្រះអរហន្តគប្បីឱ្យទាន"*** ជាដើម សកវាទីឆ្លើយតបព្រោះការប្រព្រឹត្តទៅនៃទានជាដើម របស់ព្រះអរហន្ត គប្បីមានដោយកិរិយាចិត្ត; ឯបរវាទីមិនកាន់យកចិត្ត ទើបឡលទ្ធិរបស់ខ្លួនតាំងនៅដោយការសម្តែងត្រឹមតែរឿងរបស់ការធ្វើប៉ុណ្ណោះ ។ សូម្បីយ៉ាងនេះ លទ្ធិនោះ ក៏តាំងនៅមិនបាន ព្រោះតាំងទុកដោយឧបាយមិនឆ្លាត មានប្រការដូច្នេះ ៕

ចប់អត្ថិ អរហតោ បុញ្ញូបចយោតិកថា

.....................................

## ២.នត្ថិ អរហតោ អកាលមច្ចូតិកថា

## សម្តែងអំពីព្រះអរហន្តមិនមានអកាលមរណៈ

ឥឡូវនេះ ឈ្មោះថា រឿងរបស់ព្រះអរហន្តមិនមានអកាលមរណៈ គឺការស្លាប់ក្នុងវេលាដែលមិនសមគួរ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយរាជគិរិកៈ និងសមិតិយៈថា “ឈ្មោះថា ព្រះអរហន្តត្រូវសោយកម្មវិបាកទាំងពួង ហើយទើបបរិនិព្វាន” ដូច្នេះ, ព្រោះកាន់យកអត្ថនៃព្រះសូត្រថា ***“ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលសភាពនៃកម្មដែលប្រព្រឹត្តទៅដោយសញ្ចេតនា ដែលបុគ្គលធ្វើហើយ សន្សំហើយ នឹងអស់ទៅព្រោះមិនបានសោយផល តែកម្មនុ៎ះឯង នឹងឱ្យផលក្នុងទិដ្ឋធម៌មែនពិត ឬក្នុងភពបន្ទាប់ទៅ ឬក៏ក្នុងភពដទៃៗ ទៀត”*** [២] ដូច្នេះ ដោយមិនពិចារណា, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទថា ***“បើអកាលមរណៈរបស់ព្រះអរហន្តមិនមានទេ, ឈ្មោះថា អ្នកសម្លាប់ព្រះអរហន្ត ក៏មិនគប្បីមានដែរ”*** ដូច្នេះ ទើបពោលថា ***“អរហន្តឃាត គឺអ្នកសម្លាប់ព្រះអរហន្តមិនមានឬ ?”*** បរវាទីឆ្លើយបដិសេធ ព្រោះសភាពនៃអនន្តរិយកម្ម និងបុគ្គលដូចនោះឯង គប្បីមានព្រមគ្នា ។ ក្នុងបញ្ហាថា “ថ្នាំពិស... មិនគប្បីជ្រាបចូលទៅក្នុងកាយ” បរវាទីឆ្លើយបដិសេធ ព្រោះលទ្ធិថា “កម្មដែលលោកធ្វើទុកក្នុងកាលមុន នៅមិនទាន់អស់ទៅដរាបណា, ថ្នាំពិស ក៏មិនធ្វើ

---

[២] អំ. ទសក. ។

អន្តរាយដរាបនោះ” ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។

ព្រះសូត្រថា ***“ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលទេ”*** ជាដើម ដែលបរវាទីពោលហើយ សំដៅយកអត្ថនេះថា ព្រះមានព្រះភាគត្រាស់ថា “តថាគតមិនបានពោលសភាពនៃកម្មដែលប្រព្រឹត្តទៅ ដោយសញ្ចេតនា ដែលបុគ្គលធ្វើទុកហើយ សន្សំទុកហើយ នឹងអស់ទៅ ព្រោះមិនបានទទួល មិនបានប្រសព្វ មិនបានសោយផល” គឺសំដៅសេចក្ដីថា ទ្រង់មិនពោលនូវសភាពនៃកម្មទាំងនោះ ជារបស់អស់ទៅដោយវិថីទាំងឡាយ, ក៏កាលបើកម្មដែលឲ្យផលក្នុងទិដ្ឋធម៌ គប្បីមាន, កម្មនោះឯង គប្បីឲ្យផលក្នុងទិដ្ឋធម៌, មិនមែនឲ្យផលក្នុងភពដទៃៗ ឡើយ, កាលបើកម្មដែលឲ្យផលក្នុងភពខាងមុខ គឺភពទី ២ គប្បីមាន កម្មនោះ រមែងឲ្យផលក្នុងភពនោះ, មិនឲ្យផលក្នុងភពដទៃទេ, កាលបើកម្មដែលនឹងឲ្យផលក្នុងភពដទៃៗ គប្បីមានក្នុងកាលណា, កម្មនោះ មានឱកាសឲ្យផលក្នុងកាលនោះ ដោយប្រការដូច្នេះ, ន័យមួយទៀត ក្នុងបរិយាយដទៃ ដែលមានសភាពយ៉ាងនេះ មានអធិប្បាយថា គ្រាកាលប្រព្រឹត្តទៅនៃសង្សារ គឺកាលត្រាច់ទៅ សូម្បីក្នុងទីទាំងពួង គប្បីមាន ប្រទេសរបស់លោកនោះ រមែងមិនវៀរចាកវារៈនៃការឲ្យផលរបស់កម្ម ដោយប្រការដូច្នេះ បុគ្គលនៅក្នុងទីណាៗ រមែងមិនផុតចាក

បាបកម្ម កាលបើមានសភាពយ៉ាងនេះ កម្មយ៉ាងណាមួយដែលនៅសល់ សូម្បីតែមួយ៉ាង ក៏មិនមាន ឱកាសឲ្យផល ក្នុងកាលមុន ព្រះអរហន្ត ក៏គប្បី សោយផលនៃកម្មនោះ ព្រោះហេតុដូច្នោះ ពោលដោយកាលដ៏សមគួរហើយ ការតាំងលទ្ធិថា "ព្រះអរហន្ត មិនមានអកាលមរណៈ" ដូច្នេះ ដែលបរវាទី ធ្វើទុកហើយ ទើបឈ្មោះថា ធ្វើទុកមិនល្អ ដោយប្រការដូច្នេះ ៕

ចប់នត្ថិ អរហតោ អកាលមច្ចុតិកថា

---

## ៣.សព្វមិទំ កម្មតោតិកថា

## សម្តែងអំពីវត្ថុទាំងពួងនេះមាន ព្រោះកម្ម

ឥឡូវនេះ ឈ្មោះថា រឿងវត្ថុទាំងពួងនេះមាន គឺកើតព្រោះកម្ម ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "វត្ថុទាំងពួងនេះ ពោលគឺកម្មវដ្តៈ, កិលេសវដ្តៈ និងវិបាកវដ្តៈ កើតមកព្រោះកម្មមែនពិត" ព្រោះអាស្រ័យ ព្រះសូត្រថា ***"លោករមែងប្រព្រឹត្តទៅតាមកម្ម"*** ដូច្នេះ, ពាក្យសួររបស់ សកវាទីថា វត្ថុទាំងពួងនេះ សំដៅដល់ជនទាំងនេះ, ពាក្យឆ្លើយតបជារបស់ បរវាទី ។ លំដាប់នោះ សកវាទីដើម្បីនឹងចោទដោយពាក្យថា ***"កាលមាន សភាពដូច្នោះ សូម្បីកម្មក៏រមែងកើតអំពីកម្ម"*** ដូច្នេះ ទើបពោលថា ***"សូម្បី***

***កម្មក៏មាន គឺកើតព្រោះកម្មឬ ?”*** *បរវាទីឆ្លើយបដិសេធ ដោយពាក្យថា “បើកម្មមែន ឈ្មោះថា កើតអំពីកម្មពិត, កម្មនោះ ក៏គប្បីជាវិបាក ប៉ុណ្ណោះ” ។ ពាក្យថា* ***“វត្ថុទាំងពួងនេះមាន ព្រោះហេតុដែលធ្វើទុក ក្នុងកាលមុនឬ ?”*** *សកវាទីសួរដើម្បីចោទថា “បើវត្ថុទាំងពួងកើតអំពី កម្ម, វត្ថុក៏គប្បីមានហេតុដែលធ្វើទុកហើយ ក្នុងកាលមុន” ។ បរវាទីឆ្លើយ បដិសេធ ព្រោះខ្លាចលទ្ធិបុព្វេកតហេតុវាទ ។ ពាក្យថា* ***“មានព្រោះវិបាកនៃ កម្មឬ ?”*** *សកវាទីសួរដើម្បីចោទថា “បើវត្ថុទាំងពួង រមែងកើតព្រោះ កម្ម, កម្មណាជាហេតុនៃការប្រព្រឹត្តទៅក្នុងអតីតភព, សូម្បីកម្មនោះ ក៏កើត អំពីកម្មក្នុងភពមុន, ព្រោះហេតុដូច្នោះ កម្មវិបាករមែងសម្រេច, ដោយហេតុ នោះ វត្ថុទាំងពួងរមែងប្រាកដតាមលទ្ធិរបស់លោក ដោយហេតុនោះឬ?”។ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកការកើតអំពីកម្ម របស់ការប្រព្រឹត្ត ទៅក្នុងបច្ចុប្បន្នប៉ុណ្ណោះ ដូចពន្លកនៃពូជ រមែងកើតអំពីពូជ ។ ត្រូវសកវាទី សួរគ្រាទី ២ លោកក៏ឆ្លើយតប ព្រោះសូម្បីសភាពនៃកម្មនោះប្រព្រឹត្តទៅ ព្រោះកម្មក្នុងពេលមុន ដូចពន្លកនៃពូជ រមែងកើតអំពីពូជនៃដើមមុន ។ ពាក្យថា* ***“បុគ្គលគប្បីសម្លាប់សត្វ”*** *ជាដើម សកវាទីពោលដើម្បីចោទថា “បើវត្ថុទាំងពួងកើតអំពីកម្មវិបាកមែន, បុគ្គលក៏គប្បីធ្វើបាណាតិបាតជា*

*ដើម ដោយកម្មវិបាកនោះឯង" ។ បរវាទីឆ្លើយតបតាមលទ្ធិ សូម្បីចេតនាក្នុងភាពជាអ្នកទ្រុស្តសីល ដែលកើតឡើងក្នុងកម្មមុន ក៏ជាវិបាកដោយបរិយាយតែមួយគត់ ។ លំដាប់នោះ ទើបសកវាទីពោលថា* ***"ពាណាតិបាតមានផលឬ?"*** *ដើម្បីចោទថា "បើបាណាតិបាតរមែងសម្រេចអំពីកម្មវិបាក តាមលទ្ធិរបស់លោកមែន, សូម្បីវិបាកក៏មានផលប្រាកដ ដូចបាណាតិបាតដែរ" , បរវាទីកាលឃើញនូវសភាពនៃបាណាតិបាតមានផល ព្រោះជាផលឲ្យកើតក្នុងនរកជាដើម ទើបឆ្លើយតប ។ តែកាលមិនឃើញឋានដែលសកវាទីពោលថា "វត្ថុឈ្មោះនេះ ជាផលវិបាករបស់កម្ម" ទើបឆ្លើយបដិសេធ ។ សូម្បីក្នុង* ***អទិន្នាទាន****ជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ពាក្យថា* ***"គិលានប្បច្ចយភេសជ្ជបរិក្ខារមានផលឬ ?"*** *សេចក្តីថា សកវាទីរមែងសួរថា "ផលនៃការឲ្យទានមានដោយអំណាចនៃទេយ្យធម៌ឬ ?" ។ ព្រះសូត្រថា* ***"លោក គឺសត្វលោកប្រព្រឹត្តទៅ ព្រោះកម្ម"*** *រមែងសម្តែងនូវភាពនៃបុគ្គលប្រកាន់កម្មថា ជារបស់ខ្លួន របស់កម្មវាទីបុគ្គលថា "កម្មគប្បីមាន" ព្រោះបដិសេធអកម្មវាទីបុគ្គលដែល ពោលថា "កម្មមិនគប្បីមាន" ដូច្នេះ, មិនមែនសម្តែងនូវភាពនៃវត្ថុទាំងពួងកើតឡើង*

ព្រោះកម្មឡើយ, ព្រោះហេតុដូច្នោះ ទើបព្រះសូត្រនេះ មិនសម្រេចដូចលទ្ធិនោះឡើយ ។

ចប់សព្វមិទំ កម្មតោតិកថា

# ៩.ឥន្ទ្រិយពទ្ធកថា

## សម្តែងអំពីវត្ថុដែលជាប់ដោយឥន្ទ្រិយជាទុក្ខ

ឥឡូវនេះ ឈ្មោះថា រឿងវត្ថុដែលជាប់ដោយឥន្ទ្រិយជាទុក្ខ ៖

ក្នុងបញ្ហានោះ ទុក្ខមាន ២ គឺឥន្ទ្រិយពទ្ធទុក្ខ គឺវត្ថុដែលជាប់ដោយឥន្ទ្រិយជាទុក្ខ និងអនិន្ទ្រិយពទ្ធទុក្ខ គឺវត្ថុដែលមិនជាប់ដោយឥន្ទ្រិយ ក៏ជាទុក្ខ; ក៏ឥន្ទ្រិយពទ្ធ ឈ្មោះថា ជាទុក្ខ ព្រោះជាវត្ថុនៃទុក្ខ, អនិន្ទ្រិយពទ្ធ ឈ្មោះថា ជាទុក្ខ ព្រោះព្រះមានព្រះភាគទ្រង់សង្គ្រោះទុកក្នុងពាក្យថា ***“វត្ថុណាមិនទៀង វត្ថុនោះ ឈ្មោះថា ជាទុក្ខ”*** ព្រោះអត្ថថា ត្រូវការកើត និងការរលត់គ្របសង្កត់ (បៀតបៀន) ជាដើម ។ ជនទាំងឡាយណា មិនកាន់យកវិភាគនេះ មានការយល់ឃើញខុសដូចលទ្ធិនិកាយហេតុវាទថា “ការប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីកំណត់ដឹងទុក្ខណា, ទុក្ខនោះជាឥន្ទ្រិយពទ្ធទុក្ខនេះប៉ុណ្ណោះ, មិនមែនទុក្ខដទៃ ក្រៅអំពីនេះទេ” ដូច្នេះ,

ពាក្យសួររបស់សកវាទីថា ***"វត្ថុដែលជាប់ដោយ ឥន្ទ្រិយប៉ុណ្ណោះ ជាទុក្ខឬ ?"*** ដើម្បីសម្ដែងនូវភាវៈនៃអនិន្ទ្រិយពទ្ធ គឺវត្ថុដែលមិនជាប់ដោយឥន្ទ្រិយ សូម្បីក្រៅពីនេះ ក៏ជាទុក្ខ ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យជាដើមថា ***"វត្ថុដែលជាប់ដោយឥន្ទ្រិយប៉ុណ្ណោះ មិនទៀង"*** ដូច្នេះ ដើម្បីចោទដោយពាក្យថា "ព្រះមានព្រះភាគត្រាស់ទុកថា 'វត្ថុណា មិនទៀង វត្ថុនោះជាទុក្ខ' ព្រោះហេតុណា, ព្រោះហេតុនោះ ឥន្ទ្រិយពទ្ធទុក្ខប៉ុណ្ណោះ គប្បីមានសភាពមិនទៀងឬ ?" ។ ពាក្យថា ***"វត្ថុដែល មិនជាប់ដោយឥន្ទ្រិយ ក៏មិនទៀង... មិនមែនឬ ?"*** អធិប្បាយថា សូម្បីអនិន្ទ្រិយពទ្ធ ដូចផែនដី ភ្នំ និងថ្មជាដើម ក៏មិនទៀង មិនមែនឬ ?

ក្នុងបញ្ហាថា ***"មិនគប្បីពោលថា 'វត្ថុដែលជាប់ដោយឥន្ទ្រិយប៉ុណ្ណោះ ជាទុក្ខឬ ?"*** ពាក្យឆ្លើយតបថា ***"មែន"*** ជារបស់សកវាទី ។ ពិតមែនឥន្ទ្រិយពទ្ធទុក្ខរមែងជាអារម្មណ៍របស់ទុក្ខទោមនស្សទាំងឡាយ ។ តាមពិតភ្លើងក្នុងរដូវក្ដៅក្ដី ខ្យល់ក្នុងរដូវរងាក្ដី ជាអារម្មណ៍របស់ទុក្ខ, ការវិនាសនៃភោគៈជាដើម ក៏ជាអារម្មណ៍របស់ទោមនស្សដូចគ្នា; ព្រោះហេតុដូច្នោះ សូម្បីវៀរចាកឥន្ទ្រិយពទ្ធទុក្ខចេញហើយ ក៏គប្បីពោលបានថា អនិន្ទ្រិយពទ្ធជាទុក្ខ ព្រោះអត្ថថា ជាសភាវៈមិនទៀង, តែមិនគួរពោលថាជា ***"ទុក្ខ-***

***អរិយសច្ច*”** ដូច្នេះទេ ព្រោះសភាពជាទុក្ខ មិនកើតអំពីកម្ម និងកិលេសទាំងឡាយ និងព្រោះបុគ្គលមិនកំណត់ដឹងបានដោយមគ្គ ។ម្យ៉ាងទៀត ការវិនាសទៅនៃស្មៅ និងដើមឈើជាដើម ឬការវិនាសទៅនៃពូជ ដែលកើតតាមរដូវកាលជាដើម រមែងមិនឈ្មោះថា ជាទុក្ខនិរោធអរិយសច្ច ព្រោះហេតុណា, ព្រោះហេតុនោះ ឥន្ទ្រិយពទ្ធប៉ុណ្ណោះ ជាទុក្ខផង ជាអរិយសច្ចផង, តែអនិន្ទ្រិយពទ្ធនេះ ត្រឹមតែជាទុក្ខប៉ុណ្ណោះ មិនមែនជាអរិយសច្ច ព្រោះហេតុដូច្នោះ សកវាទីដើម្បីសម្ដែងទុក្ខទាំង ២ ដែលផ្សេងគ្នានេះ ទើបឆ្លើយតបថា **“*មែន*”** ។ ព្រះបាលីថា “ដើម្បីកំណត់ដឹងទុក្ខដែលជាប់ដោយឥន្ទ្រិយ” ជាដើម រមែងសម្ដែងដល់ការនៅប្រព្រឹត្តព្រហ្មចរិយៈ ដោយការកំណត់ដឹងឥន្ទ្រិយពទ្ធទុក្ខ ដោយការធ្វើមិនឲ្យកើតឡើងទៀត របស់អ្នកដែលកំណត់ដឹងហើយ ។ ដោយហេតុនោះឯង ទើបសកវាទីបដិសេធក្នុងបញ្ហានោះ ។ តាមពិត នរណាមួយ មិនអាចដើម្បីបដិសេធអនិន្ទ្រិយពទ្ធទុក្ខ ដែលព្រះមានព្រះភាគទ្រង់សង្គ្រោះទុក ដោយពាក្យថា **“*វត្ថុណាមិនទៀង វត្ថុនោះ ឈ្មោះថា ជាទុក្ខ*”** ដូច្នេះទេ, ព្រោះហេតុដូច្នោះ ពាក្យនេះ ទើបមិនមែនជាសាធកៈ (សម្រេច) វត្ថុ ដែលមិនជាប់ដោយឥន្ទ្រិយថា មិនជាទុក្ខទេ ។

## ចប់ឥន្ទ្រិយពទ្ធកថា

## ៥.ឋះបេត្វា អរិយមគ្គន្តិកថា សម្ដែងអំពីការវៀរអរិយមគ្គ

*ឥឡូវនេះ ឈ្មោះថា រឿងវៀរអរិយមគ្គ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយហេតុវាទថា "អរិយមគ្គ ព្រះមានព្រះភាគត្រាស់ហៅថា 'ទុក្ខ-និរោធគាមិនីបដិបទា' ព្រោះហេតុណា, ព្រោះហេតុនោះ វៀរអរិយមគ្គចេញ សង្ខារដ៏សេស ឈ្មោះថា 'ជាទុក្ខ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះសកវាទីពោលថា "សូម្បីទុក្ខសមុទ័យ ក៏ជាទុក្ខឬ ?" ដើម្បីចោទថា "ក៏បើមានសភាពយ៉ាងនេះមែន សូម្បីសមុទ័យ ក៏ត្រូវតែជាទុក្ខ" ។ បរវាទីឆ្លើយបដិសេធ សំដៅយកសមុទ័យនោះ ជាហេតុលក្ខណៈ គឺមានសភាពជាហេតុ ។ កាលត្រូវសកវាទីសួរទៀត ក៏ឆ្លើយតបសំដៅយកសមុទ័យនោះ ជាលោកិយធម៌ មានការកើតរលត់ ។ ក្នុងបញ្ហាទាំងឡាយថា* **"អរិយសច្ចមាន ៣ ប៉ុណ្ណោះឬ ?"** *ទើបឆ្លើយតបដោយអំណាចនៃលទ្ធិ; បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ, ពាក្យដ៏សេសក្នុងទីនេះមានអត្ថងាយស្រួលមែនពិត ៕*

ចប់ឋបេត្វា អរិយមគ្គន្តិកថា

## ៦.៩ ទក្ខិណំ សង្ឃោ ឧក្ខិណំ បដិគ្គណ្ហាតីតិកថា

## ពាក្យមិនគប្បីពោលថា ព្រះសង្ឃទទួលនូវទក្ខិណាទាន

*ឥឡូវនេះ ឈ្មោះថា រឿងមិនគប្បីពោលថា "ព្រះសង្ឃទទួលនូវទក្ខិណាទាន" ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយវេតុល្លកៈ ពោលគឺមហាបុញ្ញវាទីក្នុងខណៈនេះថា "កាលពោលដោយបរមត្ថហើយ ព្រះសង្ឃ ក៏គឺមគ្គ និងផលប៉ុណ្ណោះ, ឈ្មោះថា ព្រះសង្ឃដទៃ ក្រៅអំពីមគ្គ និងផល រមែងមិនមាន, ក៏មគ្គ និងផល នឹងទទួលអ្វីបាន, ព្រោះហេតុដូច្នោះ មិនគួរពោលថា 'ព្រះសង្ឃទទួលទក្ខិណាទាន គឺរបស់ធ្វើបុណ្យទេ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា **"មិនគប្បីពោល"** ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យជាដើមថា **"ព្រះសង្ឃជាអាហុនេយ្យបុគ្គល គឺអ្នកគួរទទួលរបស់បូជាមិនមែនឬ ?"** ដើម្បីចោទថា "បើតាមលទ្ធិរបស់លោក ព្រះសង្ឃមិនគប្បីទទួលទក្ខិណាទានបានមែន, ព្រះសាស្ដា ក៏នឹងមិនគប្បីសរសើរដោយពាក្យថា **"ព្រះសង្ឃជាអ្នកគួរដល់ការបូជា"** ជាដើម ។*

*បទថា **"បុគ្គលពួកខ្លះ ថ្វាយទានដល់ព្រះសង្ឃ"** សកវាទីពោលដើម្បីចោទថា "បុគ្គលទាំងឡាយណា រមែងថ្វាយទានដល់ព្រះសង្ឃ, កាលបើអ្នក*

ទទួលទានមិនមាន, បុគ្គលទាំងនោះ នឹងគប្បីថ្វាយទានដល់អ្នកណាទៅ? ” ។ ព្រះសូត្រថា ***“ដូចភ្លើងទទួលការបូជា”*** ដូច្នេះ លោកនាំមកអំពីលទ្ធិដទៃ ។ ក្នុងពាក្យទាំងនោះ ពាក្យថា ***“មហាមេឃ”*** លោកពោលសំដៅយកមេឃ គឺភ្លៀង; ពិតមែន ផែនដីរមែងទទួលរងទឹកភ្លៀង, មិនមែនទទួលរងមេឃឡើយ ។ ពាក្យថា ***“មគ្គទទួលទក្ខិណាទានបានឬ ?”*** បរវាទីរមែងពោលតាមលទ្ធិថា ***“មគ្គ និងផល ជាព្រះសង្ឃ”*** ដូច្នេះ, តាមពិតមគ្គ និងផលនោះ មិនមែនព្រះសង្ឃទេ, តែបុគ្គល ៨ ពួក ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ឈ្មោះថា ***ព្រះសង្ឃ*** ព្រោះអាស្រ័យខន្ធទាំងឡាយ ដែលបរិសុទ្ធដោយការប្រាកដឡើងនៃមគ្គ និងផល, ព្រោះហេតុដូច្នោះ រឿងនេះ ទើបមិនមែនជាសាធកៈ (សម្រេច) ថា មគ្គ និងផល ជាព្រះសង្ឃឡើយ ៕

ចប់ ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា

---

## ៧.ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

### ពាក្យមិនគប្បីពោលថា “ព្រះសង្ឃញ៉ាំងទក្ខិណាទានឱ្យបរិសុទ្ធ”

ឥឡូវនេះ ឈ្មោះថា រឿងមិនគប្បីពោលថា "ព្រះសង្ឃញ៉ាំងទក្ខិណាទានឲ្យបរិសុទ្ធ គឺធ្វើឲ្យមានផលច្រើន" ៖

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយវេតុល្លកៈនោះឯងថា "មគ្គនិងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃ, ក៏មគ្គ និងផលទាំងនោះ រមែងមិនអាចដើម្បីធ្វើទក្ខិណាឲ្យបរិសុទ្ធបាន, ព្រោះហេតុដូច្នោះ ទើបមិនគប្បីពោលថា 'ព្រះសង្ឃញ៉ាំងទក្ខិណាទានឲ្យបរិសុទ្ធ" ដូច្នេះទេ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ; ពាក្យឆ្លើយតបជារបស់បរវាទី ។

ពាក្យថា "***ជាអ្នកគួរទទួលរបស់បូជា***" ជាដើម សកវាទីពោលដើម្បីសម្ដែងថា "បើព្រះសង្ឃមិនអាចដើម្បីញ៉ាំងទក្ខិណា គឺរបស់ធ្វើបុណ្យឲ្យបរិសុទ្ធបានទេ, ព្រះមានព្រះភាគ ក៏មិនពោលសរសើរព្រះសង្ឃនោះយ៉ាងនេះទេ" ។ ពាក្យថា "***ឱ្យបរិសុទ្ធ***" បានដល់ ធ្វើឲ្យមានផលច្រើន; ពិតមែន ទានមានប្រមាណតិច ដែលគេថ្វាយហើយក្នុងសង្ឃ រមែងជាទានមានផលច្រើន, ទានដែលមានប្រមាណច្រើន ដែលថ្វាយហើយក្នុងសង្ឃក៏រមែងមានផលច្រើនជាង ។ ពាក្យថា "**ទក្ខិណេយ្យោ** = ជាអ្នកគួរទទួលរបស់ធ្វើបុណ្យ" បានដល់ អ្នកគួរដល់ទក្ខិណា គឺសមគួរដល់ទានដែលគេឲ្យ

ដោយសេចក្ដីគោរព, អធិប្បាយថា អ្នកអាចដើម្បីធ្វើទក្ខិណានោះ ឲ្យបរិសុទ្ធ ។ ពាក្យថា ***"សរសើរបុណ្យ គឺទក្ខិណា"*** បានដល់ ឲ្យបុណ្យ គឺទក្ខិណានោះ ដល់ព្រម, អធិប្បាយថា រមែងឲ្យសម្រេចផលដ៏ធំ ដោយទក្ខិណាសូម្បីមានប្រមាណតិច ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យតាមដែលពោលហើយនុ៎ះឯង ៕

ចប់ ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

## ៨. ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

### ពាក្យមិនគប្បីពោលថា "ព្រះសង្ឃឆាន់អាហារ"

ឥឡូវនេះ ឈ្មោះថា រឿងមិនគប្បីពោលថា "ព្រះសង្ឃឆាន់អាហារ" ៖

សូម្បីក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា "មគ្គនិងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃ, ក៏មគ្គនិងផលទាំងនោះ នឹងបរិភោគអ្វីបាន, ព្រោះហេតុដូច្នោះ ទើបមិនគប្បីពោលថា 'ព្រះសង្ឃរមែងឆាន់អាហារ, រមែងផឹក, រមែងទំពានិងរមែងលិទ្ធភ្លក្សរស" ដូច្នេះទេ, ពាក្យសួររបស់សកវាទី សំដៅដល់ជន

ទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទថា "បើព្រះសង្ឃមិនគប្បីឆាន់អាហារមែន, ការធ្វើសង្ឃភត្តជាដើមក៏មិនមានប្រយោជន៍ឡើយ" ដូច្នេះ ទើបពោលពាក្យជាដើមថា ***"បុគ្គលពួកខ្លះ ដែលធ្វើសង្ឃភត្ត... រមែងមាន មិនមែនឬ ?"*** ។

ពាក្យថា ***"គណភោជន"*** ជាដើម គឺការឆាន់អាហារជាពួក សកវាទីពោលហើយដើម្បីចោទថា "បើព្រះសង្ឃមិនគប្បីឆាន់អាហារមែន, ការឆាន់អាហារជាពួកគណៈជាដើម នឹងគប្បីមានដល់អ្នកណាទៅ ?" ; ពាក្យថា ***"បាន: ៨ បានដល់ អដ្ឋបាន"*** នេះ សកវាទីពោលដើម្បីចោទថា "បើព្រះសង្ឃមិនអាចឆាន់បានៈ, ព្រះមានព្រះភាគទ្រង់អនុញ្ញាតបានៈ ៨ យ៉ាងទាំងនោះ ដើម្បីអ្នកណា ?" សូម្បីពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងពេលមុននុ៎ះចុះ ៕

ចប់ ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

## ៩.ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

### ពាក្យមិនគប្បីពោលថា

### "ទានដែលប្រគេនដល់ព្រះសង្ឃមានផលច្រើន"

ឥឡូវនេះ ឈ្មោះថា រឿងមិនគប្បីពោលថា "ទានដែលបុគ្គលប្រគេនដល់ព្រះសង្ឃមានផលច្រើន" ៖

សូម្បីក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយវេតុល្លកៈនោះឯងថា "មគ្គ និងផលប៉ុណ្ណោះ ឈ្មោះថាព្រះសង្ឃ, ក៏នរណាមួយ មិនអាចឲ្យអ្វីៗ ដល់មគ្គ និងផលទាំងនោះបានទេ, ទាំងមគ្គ និងផលនោះ ក៏មិនអាចទទួលអ្វីៗ បានឡើយ, ម្យ៉ាងទៀត ឧបការៈអ្វីៗ ព្រោះការឲ្យដល់មគ្គ និងផលទាំងនោះ ក៏រមែងមិនសមដូចប្រាថ្នា, ព្រោះហេតុដូច្នោះ ទើបមិនគួរពោលថា 'ទានដែលបុគ្គលប្រគេនដល់សង្ឃមានផលច្រើន" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា "**អាហុនេយ្យោ** = ព្រះសង្ឃជាអ្នកគួរទទួលរបស់បូជា" ជាដើម សកវាទីពោលដើម្បីសម្តែងថា "បើទានដែលបុគ្គលប្រគេនដល់សង្ឃ មិនគប្បីមានផលច្រើនមែន, ព្រះមានព្រះភាគ ក៏ទ្រង់មិនសរសើរព្រះសង្ឃនោះឡើយ" ។ ពាក្យដ៏សេសគប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕

**ចប់ ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា**

.................................................

## ១០.៩ ទត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា

### ពាក្យមិនគប្បីពោលថា

### “ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធមានផលច្រើន”

*ឥឡូវនេះ ឈ្មោះថា រឿងមិនគប្បីពោលថា “ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធជាម្ចាស់មានផលច្រើន” ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយវេតុល្លកៈនោះឯងថា “ព្រះមានព្រះភាគត្រាស់ដឹងហើយ រមែងមិនបរិភោគអ្វីៗ, តែរមែងសម្ដែងព្រះអង្គ ដូចជានៅបរិភោគដើម្បីត្រូវការប្រព្រឹត្ត (អនុវត្តិ) តាមសត្វលោក, ព្រោះហេតុដូច្នោះ ទើបមិនគប្បីពោលថា ‘ទានដែលបុគ្គលថ្វាយដល់ព្រះពុទ្ធជាម្ចាស់នោះ មានផលច្រើន ព្រោះមិនមានឧបការគុណ” ដូច្នេះទេ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា* ***“ព្រះពុទ្ធជាកំពូលនៃទ្វិបទ គឺលើសជាងទេវតា និងមនុស្ស”*** *ជាដើម សកវាទីពោលដើម្បីសម្ដែងថា “សូម្បីទានដែលគេឲ្យដល់មនុស្សទ្រុស្តសីល នឹងមានគុណដល់ទៅមួយពាន់ (អត្តភាព), នឹងចាំបាច់ពោលទៅថ្វី ដល់ទានដែលគេថ្វាយដល់អគ្គបុគ្គលដូចនេះទេ” ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះឯងដោយប្រការដូច្នេះ ៕*

ចប់ ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា

## ១១.ទក្ខិណាវិសុទ្ធិកថា សម្តែងអំពីទក្ខិណាវិសុទ្ធិ

*ឥឡូវនេះ ឈ្មោះថា រឿងទក្ខិណាវិសុទ្ធិ គឺបរិសុទ្ធិនៃទក្ខិណា គឺទាន ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយឧត្តរាបថកៈថា "បើទក្ខិណាគប្បីបរិសុទ្ធ គឺមានផលច្រើន ព្រោះបដិគ្គាហកៈ; ដោយប្រការដូច្នេះ បុគ្គលដទៃ ក៏គប្បីធ្វើបុគ្គលដទៃបានដែរ, គឺថា បុគ្គលគប្បីទទួលសុខ និងទុក្ខ ដែលបុគ្គលដទៃធ្វើឲ្យ, អ្នកធ្វើម្នាក់, អ្នកទទួលផលម្នាក់, ព្រោះហេតុដូច្នោះ ទានរមែងបរិសុទ្ធ ព្រោះទាយកប៉ុណ្ណោះ, រមែងមិនបរិសុទ្ធ ព្រោះបដិគ្គាហកៈ, ចិត្តវិសុទ្ធិរបស់ទាយកទាំងនោះ រមែងឲ្យនូវវិបាក" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា* **"អាហុនេយ្យា** *= បដិគ្គាហកៈពួកខ្លះ ដែលជាអ្នកគួរបូជា" ជាដើម សកវាទីពោលដើម្បីសម្តែងថា "បើទានមិនគប្បីបរិសុទ្ធ ព្រោះបដិគ្គាហកៈមែន, ភាពនៃព្រះអរិយបុគ្គលដែលគួរដល់ការបូជាជាដើម នឹងគប្បីធ្វើប្រយោជន៍អ្វីខ្លះ ?" ; ពាក្យថា* ***"អ្នកដទៃ ជាអ្នកធ្វើឱ្យដល់អ្នកដទៃ"*** *អធិប្បាយថា បើទានចេតនារបស់ទាយកដែលបដិគ្គាហកៈ ធ្វើឲ្យប្រពៃហើយមែន; ឯទានចេតនាដែលបរិសុទ្ធរបស់ទាយកនោះ ក៏ត្រូវអាស្រ័យវត្ថុ ពោលគឺបដិគ្គាហកៈហើយទើបបរិសុទ្ធ ព្រោះអត្ថថា មានផល*

*ច្រើន, ព្រោះហេតុដូច្នោះ បញ្ហានោះ ទើបមិនមានការចោទក្នុងពាក្យថា* ***“ទានរមែងបរិសុទ្ធ គឺមានផលច្រើន ព្រោះបដិគ្គាហកៈ”*** *ដោយប្រការដូច្នេះ ៕*

ចប់ទក្ខិណាវិសុទ្ធិកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

*១.អត្ថិ អរហតោ បុញ្ញូបចយោតិកថា, ២.នត្ថិ អរហតោ អកាលមច្ចូតិកថា, ៣.សព្វមិទំ កម្មតោតិកថា, ៤.ឥន្ទ្រិយពទ្ធកថា, ៥.ឋបេត្វា អរិយមគ្គន្តិកថា, ៦.ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា, ៧.ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា, ៨. ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា, ៩.ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា, ១០.ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា, ១១.ទក្ខិណាវិសុទ្ធិកថា ៗ*

**ចប់វគ្គទី ១៧**

## វគ្គទី ១៨

## ១.មនុស្សលោកកថា សម្តែងអំពីមនុស្សលោក

*ឥឡូវនេះ ឈ្មោះថា រឿងមនុស្សលោក ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិ*

និកាយវេតុល្លកៈនោះឯងថា "ព្រះមានព្រះភាគទ្រង់ឧបបត្តិក្នុងសួគ៌ ជាន់តុសិត និងនៅក្នុងតុសិតទេវលោកនោះឯង, រមែងមិនយាងមកកាន់មនុស្សលោកទេ, តែទ្រង់សម្តែងរូបនិម្មិតទុកក្នុងមនុស្សលោកនេះ" ព្រោះមិនពិចារណាកាន់យកព្រះសូត្រដែលពោលទុកថា ***"ព្រះមានព្រះភាគទ្រង់កើតក្នុងលោក ទ្រង់ចម្រើនក្នុងលោក តែទ្រង់គ្របសង្កត់លោក ជាអ្នកដែលលោកមិនប្រឡាក់"***[៣] , ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីឲ្យបរវាទីនោះ ទទួលដឹងផង ឱកាសដែលសួរ និងពិសោធន៍ផង ទើបពោលពាក្យជាដើមថា ***"អារាម វិហារ... រមែងមាន មិនមែនឬ ?"*** ។

ពាក្យថា ***"ទ្រង់កើតក្នុងលោក"*** បរវាទីពោលសំដៅយកសួគ៌ជាន់តុសិត ។ តែពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សំដៅយកមនុស្សលោកនេះប៉ុណ្ណោះ ។ ពាក្យថា ***"ទ្រង់គ្របសង្កត់លោក"*** បរវាទីពោលព្រោះការយល់ថា ទ្រង់គ្របសង្កត់ហើយនូវមនុស្សលោក, តែក្នុងពាក្យនេះ ព្រះមានព្រះភាគទ្រង់គ្របសង្កត់លោក គឺអារម្មណ៍ ។ ពាក្យថា ***"ជាអ្នកដែលលោកមិនប្រឡាក់"*** បរវាទីពោលសំដៅយកការមិនប្រឡាក់ដោយមនុស្ស-

---

[៣] សំ. ខ. ។

*លោក, ការពិតព្រះមានព្រះភាគទ្រង់មិនប្រឡាក់ដោយកិលេស ក្នុងលោកធម៌ទាំងឡាយ; ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនជាខអាងថា ព្រះមានព្រះភាគទ្រង់ឧប្បត្តិឡើងក្នុងតុសិតទេវលោកនុ៎ះទេ៕*

ចប់មនុស្សលោកកថា

..................................

## ២.ធម្មទេសនាកថា ពោលអំពីការសម្ដែងព្រះធម៌

*ឥឡូវនេះ ឈ្មោះថា រឿងធម្មទេសនា គឺការសម្ដែងធម៌ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយវេតុល្លកៈនោះឯងថា "ព្រះមានព្រះភាគ តាំងនៅក្នុងសួគ៌ជាន់តុសិតនឹងទ្រង់បញ្ជូនរូបនិម្មិតទៅដើម្បីត្រូវការសម្ដែងធម៌, ទាំងរូបនិម្មិត និងព្រះអានន្ទ ទទួលធម្មទេសនារបស់ព្រះពុទ្ធជាម្ចាស់ហើយ ទើបសម្ដែង, មិនមែនព្រះមានព្រះភាគត្រាស់ដឹងហើយទ្រង់សម្ដែងទេ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីចោទដោយពាក្យថា "បើរូបនិម្មិតនោះ សម្ដែងធម៌, រូបនិម្មិតនោះ ក៏គប្បីជាព្រះសាស្ដា" ដូច្នេះ ទើបពោលថា* ***"ព្រះពុទ្ធនិម្មិតជាព្រះជិនស្រី"*** *ជាដើម; បរវាទីកាលមិនព្រមទទួលដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត៕*

ចប់ធម្មទេសនាកថា

## ៣.ករុណាកថា សម្តែងអំពីសេចក្តីករុណា

*ឥឡូវនេះ ឈ្មោះថា រឿងសេចក្តីករុណា ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈថា “ធម្មតា សេចក្តីករុណា ក៏គឺរាគៈនោះឯង, រាគៈនោះរមែងមិនមានដល់ព្រះមានព្រះភាគ, ព្រោះហេតុដូច្នោះ សេចក្តីករុណារបស់ព្រះពុទ្ធជាម្ចាស់ ទើបមិនមាន ព្រោះឃើញការប្រព្រឹត្តទៅនៃរាគធម៌ទាំងឡាយ ដែលជាករុណាបដិរូប ដោយអំណាចនៃការគ្រេកអរ ដែលជាហេតុនៃសេចក្តីស្រឡាញ់” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***“មេត្តារបស់ព្រះមានព្រះភាគមិនមានឬ ?”*** *ជាដើម ដើម្បីចោទដោយពាក្យថា “សេចក្តីករុណានោះ មានជាតិស្មើគ្នានឹងធម៌ទាំងឡាយ មានមេត្តាជាដើម ជាធម៌មិនមែនកិលេស ព្រោះមានសត្វជាអារម្មណ៍ ជាចេតោវិមុត្តិ និងជាធម៌មានអានិសង្ស ១១ ប្រការ, ព្រោះហេតុដូច្នោះ បើសេចក្តីករុណារបស់ព្រះមានព្រះភាគមិនមានទេ, សូម្បីធម៌ទាំងឡាយមានមេត្តាជាដើម ក៏មិនគប្បីមានដល់ព្រះពុទ្ធជាម្ចាស់ដែរ” ។ ក្នុងបញ្ហាថា* ***“ករុណារបស់ព្រះមានព្រះភាគមិនមានឬ ?”*** *បរវាទីកាលមិនឃើញវោហារដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់ករុណាកថា

........................

## ៤.គន្ធជាតិកថា សម្តែងអំពីគន្ធជាតិ

ឥឡូវនេះ ឈ្មោះថា រឿងគន្ធជាតិ គឺរបស់ក្រអូប ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈ និងឧត្តរាបថកៈទាំងពួងថា "ឧច្ចារៈ និងបស្សាវៈរបស់ព្រះមានព្រះភាគ មានក្លិនក្រអូបក្រៃលែងជាងគន្ធជាតិដទៃៗ" , ដោយអំណាចនៃការស្រឡាញ់ ក្នុងព្រះមានព្រះភាគ ដោយមិនពិចារណា ដោយហេតុនោះឯង ទើបពោលដល់គន្ធជាតិដែលក្រអូបក្រៃលែងជាង ឧច្ចារៈ និងបស្សាវៈ របស់ព្រះពុទ្ធជាម្ចាស់ មិនមានឡើយ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសគប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕

ចប់គន្ធជាតិកថា

.........................

## ៥.ឯកមគ្គកថា សម្តែងអំពីអរិយមគ្គតែមួយ

ឥឡូវនេះ ឈ្មោះថា រឿងអរិយមគ្គតែមួយ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈ និងឧត្តរាបថកៈពួកខ្លះនុ៎ះឯងថា "ព្រះមានព្រះភាគជាព្រះ

*សោតាបន្ន ជាព្រះសកទាគាមី ជាព្រះអនាគាមី នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះអរហន្ត, ហើយក៏ធ្វើឲ្យជាក់ច្បាស់នូវផល ៤ ដោយអរិយមគ្គតែមួយប៉ុណ្ណោះ" ដោយអំណាចនៃការស្រឡាញ់ក្នុងព្រះមានព្រះភាគ ព្រោះមិនពិចារណា, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា "ជាការប្រជុំនៃផស្សៈ ៤" ជាដើម ដើម្បីចោទដោយអំណាចនៃធម៌ទាំងឡាយម្យ៉ាងៗ ៤ មានផស្សៈ ៤ ជាដើម ដែលកើតឡើងជាមួយផលទាំង ៤ ដោយរួមគ្នាតែមួយ ។*

*ពាក្យថា **"ដោយសោតាបត្តិមគ្គ"** ជាដើម សកវាទីពោលដើម្បីសួរថា "រមែងធ្វើឲ្យជាក់ច្បាស់ **ដោយមគ្គណា ?"** គ្រាបរវាទីឆ្លើយថា **"ដោយអរហត្តមគ្គ"** ទើបសកវាទីចោទដោយអំណាចនៃការលះកិលេសទាំងឡាយ មានសក្កាយទិដ្ឋិជាដើម ។*

*ពាក្យថា **"ព្រះមានព្រះភាគ ជាព្រះសោតាបន្នឬ ?"** សកវាទីឆ្លើយបដិសេធ; ព្រោះថា ព្រះពុទ្ធជាម្ចាស់មិនត្រឹមតែជាព្រះសោតាបន្នឡើយ ។ សូម្បីក្នុងបញ្ហា ២ ខាងមុខ ក៏មានន័យដូចគ្នានេះដែរ; ពាក្យដ៏សេសក្នុងទីនេះគប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕*

ចប់ឯកមគ្គកថា

## ៦.ឈានសង្កន្តិកថា សម្តែងអំពីការបង្វិត ( រំលង) ឈាន

*ឥឡូវនេះ ឈ្មោះថា រឿងបង្វិត (រំលង) ឈាន គឺការប្តូរពីឈានមួយ ទៅកាន់ឈានមួយទៀត ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយមហិសាសកៈ និងនិកាយអន្ធកៈពួកខ្លះថា "យោគីបុគ្គល រមែងបង្វិតពីឈានមកកាន់ឈានមួយទៀត ដោយវៀរចាកការប្រព្រឹត្តទៅនៃឧបចារៈរបស់ឈាននោះៗ" ព្រោះអាស្រ័យការសម្តែងឈាន ដោយលំដាប់នេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ហើយចាកកាមទាំងឡាយមែនពិត ។ល។ ចូលដល់បឋមជ្ឈាន ព្រោះវិតក្កៈ និងវិចារៈស្ងប់ ។ល។ ចូលដល់ទុតិយជ្ឈាន ។ល។ ចូលដល់តតិយជ្ឈាន ។ល។ ចូលដល់ចតុត្ថជ្ឈាន"[៤] ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ប្តូរពីបឋមជ្ឈាន ទៅកាន់ទុតិយជ្ឈាន"*** *ជាដើម ដើម្បីចោទថា "បើបុគ្គលមិនសម្រេចឧបចារៈនៃទុតិយជ្ឈាន រមែងប្តូរពីបឋមជ្ឈាន ចូលកាន់ទុតិយជ្ឈាន ដោយខុសរបៀបបានមែន, បុគ្គលក៏គប្បីឃ្លាតពីបឋមជ្ឈាន*

---

[៤] សំ. ម. ។

*ចូលកាន់តតិយជ្ឈាន ពីទុតិយជ្ឈាន ចូលកាន់សួមម្បីចតុត្ថជ្ឈានបាន"* ។

*ពាក្យថា "ការនឹក... ការតាំងចិត្តឯណា ដើម្បីការកើតឡើងនៃបឋមជ្ឈាន" ជាដើម សកវាទីពោលដើម្បីចោទដោយពាក្យថា "បុគ្គលរមែងចូលទុតិយជ្ឈានបន្ទាប់អំពីបឋមជ្ឈាន, ឬចូលតតិយជ្ឈានជាដើម ដែលតអំពីទុតិយជ្ឈានជាដើមបានមែន, បុគ្គលក៏គប្បីចូលឈានបាន ដោយអាវជ្ជនចិត្តតែមួយ គឺសំដៅសេចក្តីថា ការនឹកតែមួយគ្រា អាចចូលបានគ្រប់ឈាន" ។ ពាក្យថា* ***"អ្នកធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ដោយសេចក្តីជារបស់មានទោស"*** *អធិប្បាយថា កាលព្រះយោគីមនសិការនូវកាមទាំងឡាយ ដោយសេចក្តីជាទោស, បឋមជ្ឈានរមែងកើតឡើងខាងក្រោយ, តែក្នុងខណៈនៃឈាន និមិត្តនោះឯង រមែងជាការធ្វើទុកក្នុងចិត្ត ។*

*ពាក្យថា* ***"បឋមជ្ឈានបែបនោះ"*** *ជាដើម សកវាទីរមែងសួរដើម្បីចោទ ដោយពាក្យថា "បើឈាននោះឯង វៀរខាងដើម និងខាងចុងចេញ គប្បីមានដោយលក្ខណៈមែន, ឈាននោះ ក៏គប្បីកើតបានតាមលំដាប់ ដូចជវនចិត្តទីបំផុតកើត ព្រោះអាស្រ័យជវនចិត្តដួងមុន" ។ គប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយឧបាយនេះចុះ ។ ព្រះសូត្រនេះ រមែងសម្តែងសេចក្តីនៃឈានទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់សម្តែងទុក*

ដោយលំដាប់ មានពាក្យថា "ស្ងាត់ហើយចាកកាមទាំងឡាយមែនពិត" ជាដើម, មិនមែនសម្ដែងដល់ការកើតឡើងនៃឈានដែលជាប់តគ្នាទៅ ដោយវៀរចាកមនសិការទេ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនជាខអាងថា ឧបចារជ្ឈានមិនមានឡើយ ៕

ចប់ឈានសង្កន្តិកថា

## ៧.ឈានន្តរិកកថា សម្ដែងអំពីឈានជាចន្លោះ

ឥឡូវនេះ ឈ្មោះថា រឿងឈានជាចន្លោះ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយសមិតិយៈ និងអន្ធកៈពួកខ្លះថា "អ្នកមិនដឹងឱកាស គឺការប្រាកដនៃសមាធិដែលមិនមានវិតក្កៈ មានតែវិចារៈក្នុងលទ្ធិបញ្ចកន័យ ***ដែលព្រះមានព្រះភាគទ្រង់ចែកឈាន ៥ យ៉ាង, សមាធិទាំងអស់ ទ្រង់លើកឡើងសម្ដែងទុក ៣ យ៉ាង*** នេះឈ្មោះថា ឈានជាចន្លោះក្នុងរវាងឈានទី ១ និងឈានទី ២" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា "***ផស្សៈជាចន្លោះមានឬ ?***" ជាដើម ដើម្បីចោទដោយពាក្យថា "ឈានក្ដី ចេតសិកធម៌ទាំងឡាយ មានផស្សៈជាដើមក្ដី រមែងមាន, ព្រោះហេតុដូច្នោះ

បើឈានជាចន្លោះគប្បីមានមែន, ផស្សៈជាចន្លោះជាដើម ក៏ត្រូវតែមាន" ។

បទថា ***"ឈានជាចន្លោះមាននៅក្នុងរវាងទុតិយជ្ឈាន និងតតិយៈជ្ឈាន"*** សកវាទីពោលដើម្បីចោទថា "បើឈានជាចន្លោះ គប្បីមានមែន, ឈានទាំងឡាយ មានទុតិយជ្ឈាន និងតតិយជ្ឈានជាដើមនុ៎ះឯង រមែងមាន, គឺឈានជាចន្លោះនៃឈានទាំងនោះ ក៏គប្បីមានដែរ" ។ បរវាទីឆ្លើយបដិសេធផង ឆ្លើយយល់ព្រម ព្រោះមិនមានក្នុងលទ្ធិទាំងអស់ ។ ត្រូវសកវាទីសួរថា ***"ឈានជាចន្លោះ ក្នុងរវាងបឋមជ្ឈាន និងទុតិយជ្ឈាន"*** បរវាទីឆ្លើយ តបដោយអំណាចនៃលទ្ធិ ។ ពាក្យថា វិតក្កៈ និងវិចារៈជាដើម សកវាទីពោលដើម្បីចោទដោយពាក្យថា "កាលបើសមាធិសូម្បីទាំង ៣ មានសមាធិដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈប៉ុណ្ណោះ ជាឈានទ្ធិក, សមាធិក្រៅអំពីនេះ មិនមានមែន, ក៏កាលបើដូច្នេះ អ្វីជាហេតុប្លែកគ្នាក្នុងទីនេះ" ។ ពាក្យថា ***"ក្នុងរវាងឈានទាំង ២ កើតរហ័ស"*** សកវាទីសួរសំដៅដល់បឋមជ្ឈាន និងទុតិយជ្ឈាន; បរវាទីឆ្លើយតបដោយលទ្ធិថា "សមាធិដែលមិនមានវិតក្កៈ មានតែវិចារៈក្នុងចន្លោះនៃឈានទាំង ២ នោះ កើតរហ័ស ឈ្មោះថា ជាឈានទ្ធិក" ។

ត្រូវសកវាទីសួរថា ***"បឋមជ្ឈានរលត់ហើយ ទុតិយជ្ឈាន ក៏នៅមិនទាន់កើតឡើង"*** បរវាទីឆ្លើយតប ព្រោះការប្រព្រឹត្តទៅក្នុងខណៈមួយ

នៃឈានទាំង ៣ មិនប្រកបព្រមគ្នា ។

បរវាទីសួរដោយអំណាចនៃចតុក្កន័យថា ***សមាធិមិនមានវិតក្កៈ មានតែវិចារៈជាបឋមជ្ឈាន ។ល។ ជាទុតិយជ្ឈាន ។ល។*** សកវាទីឆ្លើយបដិសេធ ព្រោះការមិនមាននៃឈាននោះ ក្នុងន័យនេះ ។

ក្នុងពាក្យថា ***“ព្រះមានព្រះភាគត្រាស់សមាធិទុក ៣ យ៉ាង មិនមែនឬ ?”*** អធិប្បាយថា បណ្ដាសមាធិ ៣ នោះ សមាធិ ២ ជាឈានតែម្យ៉ាង, មិនមែនជាឈានន្តរិកដូច្នោះ ដោយប្រការដូច្នេះ ៕

ចប់ឈានន្តរិកកថា

---------

## ៨.សមាបន្នោ សទ្ទំ សុណាតីតិកថា

## សម្ដែងអំពីអ្នកចូលសមាបត្តិស្ដាប់សំឡេងបាន

ឥឡូវនេះ ឈ្មោះថា រឿងអ្នកចូលសមាបត្តិស្ដាប់សំឡេងបាន ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយបុព្វសេលិយៈថា ***“ព្រះមានព្រះភាគត្រាស់សំឡេងថា ‘ជាបន្លា គឺជាសត្រូវ’*** ចំពោះបឋមជ្ឈាន, ក៏បើអ្នកចូលឈានមិនឮសំឡេងទេ, សំឡេងនោះ នឹងគប្បីជាបន្លា គឺជាសត្រូវបាន” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។

ពាក្យថា ***“អ្នកចូលសមាបត្តិឃើញរូបដោយចក្ខុ”*** ជាដើម សកវាទី ពោលដើម្បីចោទដោយពាក្យថា “ដរាបណា បុគ្គលកំពុងចូលឈាន អារម្មណ៍តាមបញ្ចទ្វារ រមែងមិនមាន, ក៏កាលបើអារម្មណ៍តាមបញ្ចទ្វារនោះ មិនមានប្រសិនបើ គេគប្បីបានឮសំឡេងមែន, សូម្បីគេក៏គប្បីឃើញនូវរូបបាន”។ ពាក្យថា ***“ព្រះមានព្រះភាគត្រាស់សំឡេងថា ជាសត្រូវ”*** លោកពោលហើយ ព្រោះភាវៈនៃសំឡេងនោះ ធ្វើការរុកកួន ។ ពិតមែន[៥] ពេលសំឡេងដ៏គ្រោតគ្រាតប៉ះខ្ទប់សោតៈហើយ ការចេញចាកឈាន រមែងមាន, ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ព្រះតម្រាស់នេះ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនខពិសោធន៍ (អះអាង) ថា អ្នកចូលសមាបត្តិស្តាប់សំឡេងបានឡើយ ។

ពាក្យថា ***“ព្រះមានព្រះភាគទ្រង់ត្រាស់វិតក្កៈ និងវិចារៈថា ជាសត្រូវចំពោះទុតិយជ្ឈាន”*** ជាដើម សកវាទីពោលដើម្បីឲ្យដឹងថា “បន្ទា គឺសត្រូវសូម្បីដទៃៗ មិនមានក្នុងសមាបត្តិយ៉ាងណា, សូម្បីការស្តាប់នូវសំឡេងជាដើម ក៏រមែងមិនមានក្នុងសមាបត្តិដូច្នោះ” ។ ពាក្យទាំងពួង មានអត្ថងាយស្រួលមែនពិត ៕

## ចប់សមាបន្នោ សទ្ទំ សុណាតីតិកថា

---

[៥] ពាក្យបាលីថា ឱឡារិកេន ហិ សទ្ទេន សោតេ ឃដ្ដិតេ បឋមជ្ឈានតោ វុដ្ឋានំ ហោតិ តេនេតំ វុត្តំ ។

## ៩.ចក្ខុនា រូបំ បស្សតីតិកថា

## សម្តែងអំពីការមើលឃើញរូបដោយចក្ខុ

*ឥឡូវនេះ ឈ្មោះថា រឿងឃើញរូបដោយចក្ខុ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយមហាសង្ឃិកៈថា "ចក្ខុបសាទប៉ុណ្ណោះ រមែងឃើញរូប" ព្រោះអាស្រ័យព្រះពុទ្ធវចនៈថា* ***"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ឃើញរូបដោយចក្ខុ"*** *ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ឃើញរូបដោយរូបឬ ?"*** *ជាដើម ដើម្បីចោទដោយពាក្យថា "បើបុគ្គលគប្បីឃើញរូបដោយចក្ខុមែន, បុគ្គលក៏គប្បីឃើញរូបដោយរូបដែរ" ។ បរវាទីឆ្លើយបដិសេធសំដៅយករូបាយតនៈ គឺមានរូបជាអារម្មណ៍ ត្រូវសកវាទីសួរម្តងទៀត ក៏ឆ្លើយតបសំដៅយកចក្ខុនោះឯង ។*

*ពាក្យថា* ***"ឃើញ"*** *ក្នុងពាក្យថា* ***"ទទួលដឹងរូប"*** *នេះ អធិប្បាយថា ពួកយើងរមែងសួរដោយសំដៅដល់ការដឹងចំពោះ, មិនមែនសួរត្រឹមតែការចូលទៅអាស្រ័យចក្ខុហើយឃើញ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសួរថា អ្នកមានចក្ខុ រមែងឃើញរូបដោយរូបតាមលទ្ធិរបស់លោកឬ ?*

*បរវាទីឆ្លើយបដិសេធផង ឆ្លើយតបផង ដោយន័យមុននុ៎ះឯង ។ លំដាប់នោះ ទើបសកវាទីពោលថា* ***"រូបជាមនោវិញ្ញាណឬ ?"*** *ដូច្នេះ ដើម្បីចោទដោយពាក្យថា "បើដូច្នោះមែន រូបក៏ជាមនោវិញ្ញាណ, ព្រោះថា មនោ-វិញ្ញាណនុ៎ះ ឈ្មោះថា រមែងទទួលដឹង" ដូច្នេះ; បរវាទី កាលបើមិនបានលេសន័យ គឺខអាងបន្តិចបន្តួច ទើបឆ្លើយបដិសេធមែនពិត ។ ពាក្យថា* ***"ការនឹក... របស់ចក្ខុ គប្បីមានឬ ?"*** *ជាដើម សេចក្តីថា សកវាទីរមែងសួរដើម្បីចោទដោយពាក្យថា "បើចក្ខុរមែងឃើញ ព្រោះអត្ថថា ការដឹងមែន, ការនឹក គឺអាវជ្ជនៈរបស់ចក្ខុនោះ ក៏គប្បីមាន ដូចអាវជ្ជនៈរបស់ចក្ខុវិញ្ញាណដែរ" ។ បរវាទីឆ្លើយបដិសេធថា " មិនគប្បីពោលដូច្នេះទេ ព្រោះថាចក្ខុាយតនៈមិនរាប់បញ្ចូលដោយការនឹក តែថា រមែងកើតឡើងក្នុងរវាងនៃការនឹកគិត" ។ សូម្បីក្នុងពាក្យថា "បុគ្គលស្តាប់សំឡេងដោយសោតៈ" ជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ព្រះសូត្រថា* ***"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ឃើញរូបដោយចក្ខុ"*** *ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយន័យរបស់សម្ភារ-កថា គឺដោយន័យរបស់ពាក្យជាគ្រឿងកំណត់ ។ អធិប្បាយថា ដូចយ៉ាងថា សូម្បីបុគ្គល* ***យឹតកូនធ្នូ*** *គេនាំគ្នាហៅថា* ***"យឹតដោយធ្នូ"*** *យ៉ាងណា, សូម្បីបុគ្គលកាលឃើញដោយចក្ខុវិញ្ញាណ គេក៏ហៅថា* ***"ឃើញដោយចក្ខុ"*** *ដូច្នេះ,*

*ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនខពិសោធន៍ថា ឃើញរូបដោយភ្នែក ។ សូម្បីក្នុងពាក្យទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ៕*

ចប់ចក្ខុនា រូបំ បស្សតីតិកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

*១.មនុស្សលោកកថា, ២.ធម្មទេសនាកថា, ៣.ករុណាកថា, ៤.គន្ធជាតិកថា, ៥.ឯកមគ្គកថា, ៦.ឈានសង្កន្តិកថា, ៧.ឈានន្តរិកកថា, ៨.សមាបន្នោ សទ្ទំ សុណាតីតិកថា, ៩.ចក្ខុនា រូបំ បស្សតីតិកថា ។*

**ចប់វគ្គទី ១៨**

## វគ្គទី ១៩

## ១.កិលេសប្បជហានកថា សម្តែងអំពីការលះកិលេស

*ឥឡូវនេះ ឈ្មោះថា រឿងលះកិលេស ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះថា "ឈ្មោះថា ការលះកិលេសរបស់អ្នកមានកិលេសដែលលះបានហើយ, ព្រោះថា កិលេសទាំងឡាយ ដែលជាអតីតក្តី អនាគតក្តី និងបច្ចុប្បន្នក្តី ជាសភាវៈដែលត្រូវលះមែនពិត ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបុគ្គលត្រូវលះកិលេស ដែលជាអតីតផង អនាគតផង និងបច្ចុប្បន្នផង" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"បុគ្គលលះកិលេសសូម្បីដែលជាអតីត"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។*

*ម្យ៉ាងទៀត ក្នុងបញ្ហារបស់បរវាទីថា* ***"បុគ្គលដែលលះកិលេសបានមិនមានឬ ?"*** *នេះ អធិប្បាយថា កាលបើបុគ្គលលះកិលេសទាំងឡាយមិនបានព្យាយាមលះកិលេសដែលផ្សេងដោយអតីតជាដើម ដូចការព្យាយាមរបស់អ្នកចោលសំរាមទេ, គ្រាអរិយមគ្គដែលមានព្រះនិព្វានជាអារម្មណ៍ប្រព្រឹត្តទៅហើយ កិលេសទាំងឡាយដែលនៅមិនទាន់កើតនោះឯង (សំដៅដល់កិលេសដែលជាអនុស័យ) រមែងមិនកើតឡើង ព្រោះហេតុដូច្នោះ ទើប*

ឈ្មោះថា ការលះកិលេសរមែងមាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធថា **“មិនគប្បីពោលយ៉ាងនេះទេ”** ។ បទថា **“បើដូច្នេះ បុគ្គលក៏លះកិលេសដែលជាអតីត”** ជាដើម បរវាទីពោលដោយការឆបោក គឺកន្ទួនតាមឧបាយនៃពាក្យនិយាយ ដោយពាក្យថា “ក៏បើដូច្នោះ មិនគប្បីពោលថា ការលះកិលេសមិនមាន” ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលរមែងលះកិលេសទាំងឡាយ ដែលផ្សេងដោយកិលេសជាអតីតជាដើម ៗ

ចប់កិលេសប្បជហានកថា

## ២.សុញ្ញតាកថា សម្តែងអំពីសុញ្ញតា

ឥឡូវនេះ ឈ្មោះថា រឿងសុញ្ញតា គឺភាពទទេ ៖

ក្នុងរឿងនោះ ពាក្យថា ***សុញ្ញតា*** បានដល់ សុញ្ញតា ២ គឺអនត្តលក្ខណៈរបស់ខន្ធទាំងឡាយ និងព្រះនិព្វាន ។ ក្នុងសុញ្ញតាទាំងនោះ អនត្តលក្ខណៈណាមួយខាងលើ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ដោយបរិយាយមួយ, ព្រះនិព្វានជាបរិយាបន្ន គឺជាធម៌ដែលរាប់បញ្ចូលក្នុងសុញ្ញតា ដោយបរិយាយមួយ; ក៏ជនទាំងឡាយណា មិនកាន់យកវិភាគនេះទេ មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា “សុញ្ញតា ជាធម៌រាប់បញ្ចូលក្នុងសង្ខារ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យ

ឆ្លើយតបជារបស់បរវាទី ។

ពាក្យថា ***“ធម៌មិនមាននិមិត្ត”*** បានដល់ ព្រះនិព្វានដែលវៀរចាក និមិត្តទាំងពួង; សូម្បីពាក្យថា ***“ធម៌ដែលមិនមានទីតាំង គឺអប្បណិហិតៈ”*** ក៏ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។ ***សួរថា*** ក៏ព្រោះហេតុអ្វី ទើបលោកនាំព្រះនិព្វាននេះមកពោល ? ឆ្លើយថា ដើម្បីលើកទោសរបស់លទ្ធិ ដែលមិនពោលចែកធម៌ (ឲ្យប្រាកដ) ; ព្រោះលទ្ធិរបស់អ្នកណាថា “សុញ្ញតាជាធម៌រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ដោយចំណែកតែមួយ” ដូច្នេះ ព្រោះមិនចែកចេញ(ឲ្យច្បាស់), លទ្ធិនៃជនទាំងនោះ ក៏រមែងប្រាកដថា “សូម្បីតែព្រះនិព្វាន ក៏ជាធម៌ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរ” ។ ដើម្បីលើកឡើងនូវទោសរបស់លទ្ធិនេះ ទើបសកវាទីនាំពាក្យថា អនិមិត្តៈ និងអប្បណិហិតៈ មកពោល ។ បរវាទីកាលមិនប្រាថ្នានូវសភាពនៃព្រះនិព្វាន ជាធម៌រាប់បញ្ចូលក្នុងសង្ខារនោះ ទើបឆ្លើយបដិសេធ ។ ពាក្យថា ***“សង្ខារក្ខន្ធមិនមែនជាធម៌ទៀង”*** ជាដើម សកវាទីពោលដើម្បីសម្តែង ការខុសដែលដល់នូវភាពជារបស់មិនទៀងនៃសុញ្ញតា ដែលបណ្ឌិតយល់ព្រមហើយថាព្រះនិព្វាន ។ ពាក្យថា ***“ភាពសូន្យទទេនៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងវិញ្ញាណក្ខន្ធឬ ?”*** សកវាទីពោលដើម្បីចោទ ដោយពាក្យថា “បើសុញ្ញតារបស់ខន្ធដទៃ រាប់បញ្ចូលដោយខន្ធដទៃមែន, សូម្បីសុញ្ញតារបស់សង្ខារក្ខន្ធ ក៏គប្បីរាប់បញ្ចូលដោយខន្ធដ៏សេសបានដែរ” ។ បទថា ***“ភាពសូន្យទទេនៃ

***សង្ខារក្ខន្ធ មិនគប្បីពោលថា រាប់បញ្ចូលក្នុងរូបក្ខន្ធឬ?"*** *ជាដើម សកវាទីពោលដើម្បីសម្តែងដោយបដិលោមថា "បើសុញ្ញតារបស់សង្ខារក្ខន្ធមិនរាប់បញ្ចូលដោយខន្ធដ៏សេសទេ, សូម្បីសុញ្ញតារបស់ខន្ធដ៏សេស ក៏ឈ្មោះថា រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ?" ។ ព្រះសូត្រថា* ***"ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងនេះ សូន្យចាកតួខ្លួន ឬសូន្យចាកភាវៈជារបស់ខ្លួន"*** *បរវាទីនាំមកអំពីលទ្ធិដទៃ ។ ក្នុងពាក្យទាំងនោះ ពាក្យថា* ***"សង្ខារទាំងនេះ"*** *អធិប្បាយថា ការឈានចុះ ក្នុងព្រះសាសនាថា "មែនពិត បញ្ចក្ខន្ធទាំងនោះ ឈ្មោះថា ជាសភាវៈសូន្យ ព្រោះសូន្យចាកខ្លួន និងរបស់ដែលជាប់ជាមួយខ្លួន" ដូច្នេះ រមែងមិនខុស, ដូចអាគតស្ថានថា* **"សព្វេ សង្ខារា អនិច្ចា"** *, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតទុក ។ តែព្រះសូត្រនេះ រមែងសម្តែងនូវភាវៈនៃសុញ្ញតា ជាធម៌ដែលរាប់បញ្ចូលដោយសង្ខារក្ខន្ធ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះសូត្រនោះ ទើបមិនមែនខពិសោធន៍ថា "ព្រះនិព្វានមិនមែនសុញ្ញតា គឺភាពសូន្យទទេឡើយ" ៕*

ចប់សុញ្ញតាកថា

## ៣.សាមញ្ញផលកថា សម្តែងអំពីសាមញ្ញផល

*ឥឡូវនេះ ឈ្មោះថា រឿងសាមញ្ញផល គឺផលរបស់សមណៈ ៖*

*ក្នុងរឿងនោះ ការសន្និដ្ឋាន គឺការចុះកាន់ ការយល់ឃើញក្នុងលទ្ធិរបស់សកវាទីថា* ***“វិបាកចិត្តរបស់អរិយមគ្គក្នុងមគ្គវីថិក្តី ក្នុងផលសមាបត្តិក្តី ឈ្មោះថា សាមញ្ញផល”*** *។ ម្យ៉ាងទៀត ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយបុព្វសេលិយៈថា* ***“ការលះកិលេសផង ការកើតឡើងនៃផលផង ជាសាមញ្ញផល ព្រោះហេតុណា, ព្រោះហេតុនោះ សាមញ្ញផលនោះ ទើបជាអសង្ខតៈ គឺព្រះនិព្វាន”*** *ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលី ព្រោះមានន័យតាមដែលពោលហើយ ក្នុងពេលមុននុ៎ះឯង ។*

ចប់សាមញ្ញផលកថា

## ៤.បត្តិកថា សម្តែងអំពីបត្តិ គឺការបាន

*ឥឡូវនេះ ឈ្មោះថា រឿងការបាន ៖*

*ក្នុងរឿងនោះ បុគ្គលរមែងបាននូវវត្ថុណាៗ ការបាននូវវត្ថុនោះៗ ឈ្មោះថា* ***បត្តិ*** *។ ក៏ជនទាំងឡាយណា មានការយល់ឃើញខុសថា “ការបានជាអសង្ខតៈ” ដូច្នេះ ដូចលទ្ធិនិកាយបុព្វសេលិយៈនោះឯង, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលី ព្រោះមានន័យដូចដែល*

ខ្ញុំពោលហើយ ក្នុងពេលមុននុ៎ះឯង ។

ពាក្យថា **"មិនគប្បីពោល"** ជាដើម បរវាទីពោលពាក្យបញ្ញត្តិថា "បត្តិ គឺការបាន ចាត់ជាអសង្ខតៈ" របស់លទ្ធិណា ដើម្បីប្រកាសលទ្ធិនោះ, ក្នុងបញ្ហានោះ សកវាទីបដិសេធថា "មិនគប្បីពោលយ៉ាងនេះទេ" គឺមិនយល់ព្រមនូវការបានទាំងអស់ថា ជាសភាវធម៌ មានរូបជាដើម; មែនពិត ធម៌អ្វីៗ ឈ្មោះថា បត្តិ គឺការបាន មិនមាន, ទាំងព្រះមានព្រះភាគ ក៏ទ្រង់បញ្ញត្តនូវការបាននោះថា ជាអសង្ខតៈ, តែថា បរវាទីបានឲ្យលទ្ធិរបស់ខ្លួនតាំងនៅថា **បត្តិ** គឺការបាននោះ ជាអសង្ខតៈ ដោយត្រឹមតែការបដិសេធសភាវធម៌ ដូចពោលមកនុ៎ះឯង ។ លទ្ធិនោះ រមែងតាំងនៅមិនបានឡើយ ព្រោះជាលទ្ធិដែលតាំងនៅហើយ ដោយមិនពិចារណា ៕

ចប់បត្តិកថា

## ៥.តថតាកថា សម្តែងអំពីតថតា គឺភាពនៃធម៌ពិត

ឥឡូវនេះ ឈ្មោះថា រឿងតថតា គឺភាពជាយ៉ាងនោះនៃធម៌ពិត ឬភាពនៃធម៌ពិត ប្រការមួយទៀត ហៅថា សច្ចធម៌ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះថា "ឈ្មោះថា តថតា គឺភាពជាយ៉ាងនេះ ដែលបណ្ឌិតយល់ព្រមហើយថា ជាសភាវរូបជាដើម នៃធម៌ទាំងពួង មានរូប

*ជាដើមឯណា, គឺតថតានោះ ជាអសង្ខតៈ ព្រោះភាពជាធម៌មិនរាប់បញ្ចូលក្នុងរូបជាដើម ដែលជាអសង្ខតៈ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ សូម្បីពាក្យដ៏សេស ក្នុងទីនេះក៏ជាក់ច្បាស់ហើយដែរ ព្រោះមានលក្ខណៈតាមដែលខ្ញុំពោលទុកហើយក្នុងពេលមុនន៉ុះឯង ៕*

ចប់តថតាកថា

## ៦.កុសលកថា សម្តែងអំពីកុសល

*ឥឡូវនេះ ឈ្មោះថា រឿងកុសល ៖*

*ក្នុងរឿងនោះ កុសលធម៌ មិនមានទោសផង, ជាធម៌មានផលដែលគួរប្រាថ្នាផង; ទាំងជាធម៌មិនប្រកបដោយកិលេស ទើបឈ្មោះថា ជាធម៌រកទោសគ្មាន; ដោយន័យនេះ បុគ្គលវៀរអកុសលចេញហើយ ឈ្មោះថា រមែងសេពធម៌ទាំងពួងដែលមិនមានទោស ។* ***កុសល*** *ឈ្មោះថា ផលដែលគួរប្រាថ្នា គឺជាបុណ្យដែលឲ្យសម្រេចនូវឥដ្ឋផល ក្នុងការប្រព្រឹត្តទៅនៃការកើតឡើងក្នុងភពតទៅ; ដោយន័យនេះ បុគ្គលរមែងសេពធម៌ដែលជាបទដើមន៉ុះឯង ក្នុងកុសលត្តិកៈ* * *។ ក៏ជនទាំងឡាយណា មិនកាន់យកវិភាគនេះ មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា* ***“ព្រះនិព្វាន***

---

* បទដើមនៃកុសលត្តិកៈ បានដល់ **កុសលា ធម្មា** = សភាវធម៌ទាំងឡាយ ដែលជាកុសលក៏មាន ។

*ជាកុសល ដោយហេតុត្រឹមតែជាធម៌មិនមានទោសប៉ុណ្ណោះ"* ដូច្នេះ, ពាក្យសួររបស់សកវាទីដើម្បីសម្ដែងនូវភាពនៃព្រះនិព្វាន មិនជាកុសល ព្រោះអត្ថថា ជាឥដ្ឋវិបាក ។ ពាក្យឆ្លើយតប ជារបស់បរវាទី ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ព្រោះសេចក្ដីមានន័យដូចដែលខ្ញុំពោលទុកហើយ ក្នុងពេលមុនទុះឯង៕

ចប់កុសលកថា

## ៧.អច្ចន្តនិយាមកថា

## សម្ដែងអំពីការទៀងទាត់ដោយចំណែកមួយ

ឥឡូវនេះ ឈ្មោះថា រឿងទៀងទាត់ដោយចំណែកមួយ គឺនិយាមដែលជាទីបំផុត មានតែម្យ៉ាង ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះថា "បុថុជ្ជនមានការទៀងទាត់ដោយចំណែកមួយ" ព្រោះអាស្រ័យព្រះសូត្រថា **"បុគ្គលនោះ គឺអ្នកប្រកបដោយអកុសលធម៌ ជាធម៌ខ្មៅដោយចំណែកតែមួយ ជាអ្នកលិចចុះហើយមួយគ្រាក៏លិចជាប់ទុះឯង"** [៦] ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជន

---

[៦] អំ. សត្តក. ។

ទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា ***“បុគ្គលដែលធ្វើមាតុឃាត”*** ជាដើម សកវាទីពោលដើម្បីចោទថា “កាលមិច្ឆត្តនិយាមនៃនិយតមិច្ឆាទិដ្ឋិបុគ្គលផង, បុគ្គលដែលធ្វើកម្មទាំងឡាយ មានការសម្លាប់មាតាជាដើមផង មាន; សូម្បីបុគ្គលដែលសម្លាប់មាតាជាដើមទាំងនោះ ក៏គប្បីជាអ្នកទៀងទាត់ជាទីបំផុត មិនមែនឬ?” ។ បរវាទីឆ្លើយបដិសេធថា “មិនគប្បីពោលយ៉ាងនេះទេ” ព្រោះលទ្ធិថា “បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិនេះ ជាអ្នកតាំងនៅជានិច្ច ក្នុងសង្សារវដ្ត, ជាអ្នកទៀងពិត សូម្បីក្នុងភពទីពីរ; តែថាបុគ្គលទាំងនេះ ជាអ្នកទៀងពិត ក្នុងអត្តភាពតែមួយប៉ុណ្ណោះ” ។

ពាក្យថា ***“វិចិកិច្ឆាតែងកើតឡើងហើយ ដល់អ្នកទៀងដោយចំណែកមួយ”*** សេចក្ដីថា សកវាទីរមែងពោលថា “បុគ្គលនេះ ជាអ្នកទៀងក៏ដោយ មិនទៀងក៏ដោយ, វិចិកិច្ឆា ក៏គប្បីកើតយ៉ាងនេះ” ។ បរវាទីកាលមិនឃើញហេតុដែលមិនជាទីកើតឡើងរបស់វិចិកិច្ឆា ទើបឆ្លើយតប ។ ត្រូវសកវាទីសួរថា “វិចិកិច្ឆាមិនគប្បីកើតឡើងដល់អ្នកទៀងដោយចំណែកមួយឬ?” បរវាទីឆ្លើយតប ដោយសំដៅយកការមិនកើតឡើង របស់វិចិកិច្ឆាដែលបុគ្គលសេពទិដ្ឋិណាហើយ រមែងចុះកាន់និយាមនោះ ។ តែសេចក្ដីនោះ ត្រូវសកវាទីសួរថា ***“អ្នកនោះ លះវិចិកិច្ឆាបានឬ ?”*** ក៏ឆ្លើយបដិសេធ ព្រោះភាវៈនៃវិចិកិច្ឆានោះ លះមិនបានដោយមគ្គ គឺ

មិច្ឆាមគ្គ, តែក៏ឆ្លើយតបថា “លះបាន” ព្រោះបុគ្គលប្រារព្ធទិដ្ឋិនោះហើយ សំដៅយកទិដ្ឋិជាប្រធាន, មិនបានសំដៅយកមោហៈដែលសម្បយុត្តដោយវិចិកិច្ឆាទេ, វិចិកិច្ឆា ក៏មិនកើតឡើង ។ លំដាប់នោះ សកវាទីពោលពាក្យថា “លះបានដោយសោតាបត្តិមគ្គ” ជាដើម ដើម្បីចោទដោយអំណាចនៃសោតាបត្តិមគ្គនោះ ព្រោះឈ្មោះថា ការលះវិចិកិច្ឆានេះ បើវៀរចាកអរិយមគ្គហើយ រមែងលះមិនបានឡើយ ។ បរវាទីឆ្លើយបដិសេធ ព្រោះវិចិកិច្ឆានោះ មិនអាចលះបាន ដោយមគ្គតែម្យ៉ាងទេ; និងត្រូវសកវាទីសួរទៀតថា **“លះបានដោយមគ្គណា ?”** បរវាទីសំដៅយកមិច្ឆាមគ្គ ទើបពោលពាក្យជាដើមថា **“ដោយមគ្គខាងអកុសល”** ។

ពាក្យថា **“ឧច្ឆេទទិដ្ឋិកើតឡើងដល់បុគ្គលដែលទៀងដោយសស្សតទិដ្ឋិឬ ?”** សេចក្ដីថា សកវាទីរមែងសួរនូវការកើតឡើងនៃនិយាមទី ២ ។ បរវាទីឆ្លើយតប ព្រោះព្រះបាលីថា “នត្ថិកវាទ អកិរិយវាទ អហេតុកវាទទាំងនេះ រមែងមានដល់បុគ្គលដែលមានត្រចៀកបះ គឺសំដៅដល់ការទទួលដឹងហេតុផលអ្វីៗ ទាំងអស់ សូម្បីពួកណាក៏ដោយ” ដូច្នេះ, សូម្បីនិយតមិច្ឆាទិដ្ឋិទាំង ៣ ក៏អាចកើតឡើងដល់បុគ្គលតែម្នាក់បាន ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **“ប្រសិនបើ”** ជាដើម ដើម្បីចោទដោយពាក្យថា “ក៏ឈ្មោះថា បុគ្គលម្នាក់ដែលមានការយល់ឃើញខុសនោះ រមែងមិន

*ជាអ្នកទៀងជាទីបំផុតឬ ?” ។ មែនពិត និយាមទី ២ មិនមែនជាគោល បំណងរបស់អ្នកមានការយល់ឃើញថាទៀងទេ ។ ក្នុងបញ្ហាថា* ***“ឧច្ឆេទទិដ្ឋិ មិនគប្បីកើត”*** *ជាដើម បរវាទីឆ្លើយតប ដោយសំដៅយកការមិនកើតឡើង នៃឧច្ឆេទទិដ្ឋិ ព្រោះកាន់យកការយល់ឃើញថា ការទៀងរបស់សស្សតទិដ្ឋិណា មាន, (ឧច្ឆេទ) ទិដ្ឋិបែបនោះ គឺគេកម្ចាត់ចេញហើយ ។ ត្រូវសកវាទីសួរ ថា* ***“លះឧច្ឆេទទិដ្ឋិបានឬ ?”*** *បរវាទីឆ្លើយបដិសេធ ព្រោះឧច្ឆេទទិដ្ឋិនោះ នៅមិនទាន់បានលះដោយមគ្គ, និងឆ្លើយតបថា “លះបាន” ព្រោះការ មិនទាន់កើតឡើង ដោយន័យដែលពោលមកហើយ ។ សូម្បីក្នុងពាក្យទាំង ឡាយ មានពាក្យថា* ***“សស្សតទិដ្ឋិគប្បីកើត”*** *ជាដើម ក៏មានន័យដូចគ្នា នេះដែរ ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ក្នុងវារៈដែល ពោលអំពីវិចិកិច្ឆានុ៎ះឯង ។*

*ពាក្យសួរថា* ***“មិនគប្បីពោល”*** *ជាដើម ជារបស់បរវាទី ។ ពាក្យឆ្លើយតបថា “មែន” ដូច្នេះ ព្រោះភាវៈនៃព្រះសូត្រនោះ គប្បី ជារបស់សកវាទី ។ ក្នុងអធិការនេះ មានអធិប្បាយថា “សូម្បីបុគ្គល ដែលលិចចុះក្នុងភពបន្ទាប់ទៅនុ៎ះឯង មាន; ព្រោះថា គេជាអភព្វបុគ្គល មិនអាចដើម្បីលះទិដ្ឋិនោះបាន ក្នុងភពនេះប៉ុណ្ណោះទេ” ។ ព្រោះហេតុ ដូច្នោះ ព្រះសូត្រនេះ មិនសម្រេចថា ការពិតមានតែម្យ៉ាងឡើយ; ប្រការ*

*មួយទៀតនោះ សំដៅដល់អរិយមគ្គ ។ ពាក្យថា “ការកំណត់ទីបំផុតមានតែម្យ៉ាង” នេះ លោកពោលដើម្បីសម្តែងថា “បរវាទីគប្បីស្វែងរកអត្ត ធ្វើនូវពាក្យត្រឹមតែថា ‘បុគ្គលនោះ ងើបឡើងហើយត្រឡប់លិចចុះអស់កាល” ដូច្នេះ ឲ្យជាទីអាស្រ័យហើយតាំងលទ្ធិ ដោយប្រការដូច្នេះ ៕*

ចប់អច្ចន្តនិយាមកថា

................................

## ៨.ឥន្ទ្រិយកថា សម្តែងអំពីឥន្ទ្រិយ

*ឥឡូវនេះ ឈ្មោះថា រឿងឥន្ទ្រិយ គឺធម៌ដែលជាធំ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយហេតុវាទ និងមហិសាសកៈថា “សទ្ធាដែលជាលោកិយ ឈ្មោះថាជាសទ្ធាប៉ុណ្ណោះ, មិនឈ្មោះថា ជាសទ្ធិន្ទ្រិយទេ, វិរិយៈដែលជា លោកិយ ។ល ។ សតិដែលជាលោកិយ ។ល ។ សមាធិដែលជាលោកិយ ។ល ។ បញ្ញាដែលជាលោកិយ ឈ្មោះថា ជាបញ្ញាប៉ុណ្ណោះ, មិនឈ្មោះថា ជាបញ្ញិន្ទ្រិយទេ” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

ពាក្យថា ***“សទ្ធាដែលជាលោកិយមិនមានឬ ?”*** ជាដើម លោកពោលដើម្បីសម្ដែងនូវភាវៈនៃធម៌ទាំងឡាយ មានសទ្ធាជាដើម សូម្បីជាលោកិយ ក៏ឈ្មោះថា ជាឥន្ទ្រិយដែរ ព្រោះអត្ថថា ជាធំក្រៃលែង, មិនមែនធម៌ដទៃក្រៅពីសទ្ធាជាដើម ឈ្មោះថា សទ្ធិន្ទ្រិយជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយ មានសទ្ធាជាដើមទាំង៦ង សូម្បីជាលោកិយក៏ឈ្មោះថា ជាសទ្ធិន្ទ្រិយជាដើមដែរ ។ ពាក្យថា ***“មនោដែលជាលោកិយមាន”*** ជាដើម សកវាទីពោលដើម្បីអធិប្បាយអត្ថនោះ ឲ្យជាក់ច្បាស់ដោយឧបមាថា “ធម៌ទាំងឡាយនោះ មានមនោជាដើម ជាលោកិយក៏ឈ្មោះថា មនិន្ទ្រិយជាដើម យ៉ាងណា, សូម្បីធម៌ទាំងឡាយ មានសទ្ធាជាដើម ដែលជាលោកិយ ក៏ឈ្មោះថា ជាសទ្ធិន្ទ្រិយជាដើម ក៏យ៉ាងនេះដែរ” ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីទាំងចុះ ៕

ចប់ឥន្ទ្រិយកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

១.កិលេសប្បជហនកថា, ២.សុញ្ញតាកថា, ៣.សាមញ្ញផលកថា, ៤.បត្តិកថា, ៥.តថតាកថា, ៦.កុសលកថា, ៧.អច្ចន្តនិយាមកថា, ៨.ឥន្ទ្រិយកថា ។

**ចប់វគ្គទី ១៩**

# វគ្គទី ២០

## ១.អសញ្ចិច្ចកថា សម្តែងអំពីការមិនក្លែង

*ឥឡូវនេះ ឈ្មោះថា រឿងអសញ្ចិច្ចៈ ការមិនក្លែង គឺគ្មានចេតនា ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈថា "ក៏ឈ្មោះថា អនន្តរិយវត្ថុជារបស់ធ្ងន់ ជារបស់ធំ, ព្រោះហេតុដូច្នោះ សូម្បីក្នុងវត្ថុទាំងឡាយនោះ ដែលអ្នកណាបានធ្វើឲ្យកើតហើយ ទោះបីមិនតាំងចិត្ត ក៏ជាអនន្តរិយកម្មដែរ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"បុគ្គលផ្តាច់ជីវិតមាតាដោយមិនបានក្លែង"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបដោយអំណាចនៃលទ្ធិ ជារបស់បរវាទី; លំដាប់នោះ ទើបសកវាទីពោលពាក្យថា "បុគ្គលសម្លាប់សត្វដោយមិនក្លែង" ជាដើម ដើម្បីចោទថា "ក៏ឈ្មោះថា អនន្តរិយកម្មជាកម្មបថ, បើបុគ្គលមិនចូលចិត្ត (ក្លែង) សម្លាប់សត្វ ក៏ជាប្រភេទនៃកម្មបថដែរ, កម្មទាំងឡាយដ៏សេស សូម្បីមានបាណាតិបាតជាដើម ក៏គប្បីជាកម្មមិនពេញចិត្ត" ដូច្នេះ, បរវាទីឆ្លើយបដិសេធ ព្រោះមិនមានក្នុងលទ្ធិដូច្នោះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីចុះ ។*

*ពាក្យសួរថា* ***"មិនគប្បីពោលថា បុគ្គលសម្លាប់មាតា ឈ្មោះថា ធ្វើអនន្តរិយកម្មឬ ?"*** *ជារបស់បរវាទី ។ ពាក្យឆ្លើយតបជារបស់សកវាទី*

*សំដៅយកការសម្លាប់ដោយមិនមានចេតនា ក្នុងការព្យាបាលរោគជាដើម ។ សូម្បីក្នុងបញ្ហាថា* ***“គេបានផ្តាច់ជីវិតមាតាហើយ មិនមែនឬ ?”*** *ពាក្យឆ្លើយតបជារបស់សកវាទីនោះឯង ព្រោះសំដៅយកការផ្តាច់ជីវិតឲ្យធ្លាក់ចុះដោយមិនមានចេតនា ។ ក៏បរវាទីមិនកាន់យកពាក្យអធិប្បាយយ៉ាងនេះ ទើបឲ្យលទ្ធិរបស់ខ្លួនតាំងនៅដោយពាក្យថា* ***“បើគេបានផ្តាច់ជីវិតមាតាហើយ”*** *ដូច្នេះ, តែការតាំងលទ្ធិនោះ រមែងតាំងនៅមិនបាន ព្រោះមិនតាំងទុកដោយឧបាយដែលត្រូវទំនង ។ សូម្បីបិតុឃាតជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ពាក្យសួររបស់សកវាទីថា* ***“បុគ្គលដែលធ្វើសង្ឃភេទ*** * ***ឈ្មោះថាជាអ្នកធ្វើអនន្តរិយកម្មឬ ?”*** *ដោយសំដៅយកអ្នកមានការសម្គាល់ក្នុងធម៌ គឺការបំបែកសង្ឃ ។ ពាក្យឆ្លើយតបជារបស់បរវាទី ព្រោះកាន់យកព្រះបាលីថា “បុគ្គលរមែងឆេះនៅក្នុងនរកអស់កប្ប ព្រោះបំបែកសង្ឃ*

---

* ពាក្យថា **“សង្ឃភេទ** = ការបំបែកសង្ឃ” ព្រោះមានពាក្យថា អ្នកមានការសម្គាល់ក្នុងធម៌ ចាត់ជាប្រភេទដែលល្អក៏បាន ដូចព្រះមោគ្គលីបុត្តតិស្សត្ថេរផ្ចាញ់ពួកអន្យតិរ្ថិយ ដែលមកបន្លំបួសក្នុងព្រះសាសនា ឬនឹងហៅថា ធម្មវាទីនេះ ជាអ្នកឈ្មោះថា ធ្វើអនន្តរិយកម្មដែរ តែមិនធ្លាក់អបាយឡើយ; ឯសង្ឃភេទរបស់ទេវទត្តនោះ ជាអធម្មវាទី ចាត់ជាសង្ឃភេទផង ជាអនន្តរិយ-កម្មផង និងធ្លាក់នរកផង ។

*ដែលព្រមព្រៀងគ្នា"* ដូច្នេះ ដោយមិនពិចារណា ។ ត្រូវសកវាទី សួរទៀតថា ***"បុគ្គលដែលធ្វើសង្ឃភេទ ឈ្មោះថា ជាអ្នកធ្វើអនន្តរិយកម្ម ទាំងអស់ពិតមែនឬ ?"*** បរវាទីឆ្លើយបដិសេធ ដោយសំដៅយកបុគ្គល ដែលមានការសម្គាល់ក្នុងធម៌ជាចំណែករបស់ខ្លួន ។ រមែងឆ្លើយតប ដោយសំដៅយកបុគ្គលដែលមានការសម្គាល់ក្នុងធម៌ជាចំណែកដទៃ ។ សូម្បី ក្នុង ២ បញ្ហាថា ***ធម្មសញ្ញី គឺបុគ្គលជាអ្នកមានការសម្គាល់ថា ត្រូវតាមធម៌*** ក៏មានន័យដូចគ្នានេះដែរ ។

ព្រះសូត្រថា ***"ព្រះមានព្រះភាគបានត្រាស់ទុកថា 'ម្នាលឧបាលិ បុគ្គលធ្វើសង្ឃភេទ... មិនមែនឬ ?"*** ដូច្នេះ សកវាទីពោលដើម្បីសម្តែង នូវភាវៈនៃបុគ្គលដែលជាធម្មវាទី ឈ្មោះថា ជាអ្នកធ្វើអនន្តរិយកម្មដោយ ចំណែកតែមួយប៉ុណ្ណោះ មិនធ្លាក់ទៅក្នុងអបាយ ។ម្យ៉ាងទៀត អធម្មវាទី នោះឯង ព្រះមានព្រះភាគទ្រង់ព្រះបំណងយកក្នុងគាថាដូច្នេះថា ***"នឹង ត្រូវទៅអបាយ នឹងត្រូវទៅនរក តាំងនៅរហូតកប្ប"*** ។ តែបរវាទីមិន កាន់យកពាក្យអធិប្បាយនេះទេ ទើបឡូលទ្ធិតាំងទុក ។ លទ្ធិនោះ ឈ្មោះថា តាំងនៅមិនបាន (ព្រោះមិនតាំងទុក) ដោយឧបាយដែលត្រូវទំនង ៕

ចប់អសញ្ចិច្ចកថា

## ២.ញាណកថា សម្តែងអំពីញាណ

*ឥឡូវនេះ ឈ្មោះថា រឿងញាណ* * ៖

*ក្នុងរឿងនោះ ញាណ ២ គឺលោកិយញ្ញាណ និងលោកុត្តរញ្ញាណ; ញាណក្នុងសមាបត្តិក្តី កម្មស្សកតាញ្ញាណ ដែលប្រព្រឹត្តទៅដោយអំណាចនៃការឲ្យទានជាដើមក្តី ហៅថា លោកិយញ្ញាណ, មគ្គញ្ញាណដែលកំណត់សច្ចៈក្តី ផលញ្ញាណក្តី ហៅថា លោកុត្តរញ្ញាណ ។ ក៏ជនទាំងឡាយណា មិនធ្វើវិភាគនេះទេ មានការយល់ឃើញខុសដូចលទ្ធិនិកាយហេតុវាទថា "ញាណដែលកំណត់សច្ចៈប៉ុណ្ណោះមាន, ញាណក្រៅអំពីនេះ មិនមានទេ; ព្រោះហេតុដូច្នោះ ញាណរបស់បុថុជ្ជន ទើបមិនមាន" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា* ***"បញ្ញា"*** *ជាដើម សកវាទីពោលដើម្បីសម្តែងវេវចនៈរបស់ញាណ ។ អធិប្បាយថា សកវាទីរមែងសម្តែងនូវញាណនោះ ដោយបញ្ញានោះថា "បើញាណរបស់បុគ្គលនោះ មិនមាន, សូម្បីបញ្ញាជាដើមក៏មិនមានដែរ; ឬបញ្ញាជាដើមមាន, សូម្បីញាណ ក៏មាន" ; ព្រោះហេតុ*

---

* វេវចនៈរបស់ញាណ គឺបញ្ញា ការចូលចិត្ត ការវិច័យ ការសាកសួរ និងការគិតជញ្ជឹង, ធម្មវិចយៈ គឺការពិចារណាធម៌ ការកំណត់ ការចូលទៅកំណត់ចំពោះ ។

*អ្វី ? ព្រោះភាវៈនៃបញ្ញាជាដើម មិនមែនជាធម៌ក្រៅអំពីញាណទេ ។ ពាក្យថា "បុថុជ្ជនគប្បីចូលបឋមជ្ឈាន" ជាដើម សកវាទីពោលដើម្បីសម្តែងញាណក្នុងសមាបត្តិ ។ ពាក្យថា* ***"បុថុជ្ជនគប្បីឱ្យទាន"*** *ជាដើម សកវាទីពោលដើម្បីសម្តែងដល់កម្មស្សកតាញាណ គឺញាណក្នុងភាពជាអ្នកមានកម្មជារបស់ខ្លួន ។ បទថា* ***"បុថុជ្ជនកំណត់ដឹងទូទៅនូវទុក្ខ"*** *សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងលោកុត្តរមគ្គញ្ញាណនោះឯង, តែមិនបានសម្តែងលោកុត្តរញ្ញាណតែប៉ុណ្ណោះទេ សំដៅសេចក្តីថា ទ្រង់សម្តែងលោកិយ-ញ្ញាណដែរ ៕*

## ចប់ញាណកថា

## ៣.និរយបាលកថា សម្តែងអំពីនាយនិរយបាល

*ឥឡូវនេះ ឈ្មោះថា រឿងនាយនិរយបាល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "ក្នុងនរក កម្មរបស់សត្វនរកនោះឯង រមែងសម្លាប់សត្វនរកទាំងឡាយ ដោយ (និម្មិត) ជារូបនាយនិរយបាល, សត្វទាំងឡាយឈ្មោះថា ជានាយនិរយបាលមិនមានទេ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ*

*ទើបសកវាទីពោលពាក្យថា **"ការធ្វើអាជ្ញា គឺការដាក់ទោស (កម្មករណ៍) មិនមានក្នុងនរកទាំងឡាយឬ ?"** ជាដើម ដើម្បីចោទដោយពាក្យថា "បើនាយនិរយបាលទាំងឡាយ មិនគប្បីមានក្នុងនរកមែន, សូម្បីអាជ្ញាទាំងឡាយក៏មិនគប្បីមានដែរ; តែកាលអាជ្ញាទាំងឡាយមាន, ការធ្វើអាជ្ញា ក៏គប្បីមានមិនមែនឬ ?" ។*

*ពាក្យថា **"ការធ្វើអាជ្ញា គប្បីមានក្នុងពួកមនុស្ស"** សកវាទីពោលហើយ ដើម្បីឲ្យជ្រាបច្បាស់ ។ ក្នុងសេចក្ដីនេះ មានអធិប្បាយថា ដូចជាគ្រឿងឧបករណ៍សម្រាប់ដាក់ទោសចំពោះមនុស្សទាំងឡាយ ការធ្វើក៏រមែងមាន យ៉ាងណា, សូម្បីក្នុងនរក ក៏យ៉ាងនេះដែរ ។*

*ពាក្យសួរថា **"នាយនិរយបាលមាននៅក្នុងនរកទាំងឡាយឬ ?"** ជារបស់បរវាទី ។ ពាក្យឆ្លើយតបជារបស់សកវាទី ។ បរវាទីនាំព្រះសូត្រមកដោយលទ្ធិរបស់ខ្លួនថា **"ស្ដេចវេស្សភូ ក៏មិនបានសម្លាប់, សូម្បីស្ដេចបេត្តិរាជ គឺពញាប្រេត (ស្ដេចប្រេត) ក៏មិនបានសម្លាប់ ។ ល ។ កម្មរបស់សត្វនោះឯង រមែងសម្លាប់គេ, អ្នកអស់បុណ្យអំពីលោកនេះ នឹងចូលដល់លោកខាងមុខ ក្នុងនរកនោះៗ"** ដូច្នេះ ព្រះសូត្រនោះ សកវាទីព្រមទទួលហើយថា **"នោះជាពាក្យដែលចុះកាន់ក្នុងព្រះសាសនា"** ។*

*ក្នុងពាក្យទាំងនោះ ពាក្យថា **"វេស្សភូ"** បានដល់ ទេពអង្គមួយ ។*

*ពាក្យថា **"ស្ដេចបេត្តិរាជ"** បានដល់ ប្រេតដែលមានឫទ្ធិច្រើនក្នុងបិត្តិ-វិស័យ ។ **ស្ដេចសោម** ជាដើម ប្រាកដជាក់ច្បាស់ហើយមែនពិត ។ សេចក្ដីនេះ លោកអធិប្បាយទុកថា **ស្ដេចវេស្សភូ** ជាដើម រមែងមិនសម្លាប់សត្វដែលលះលោកនេះហើយ ទៅកាន់លោកខាងមុខតាមកម្មទាំងឡាយរបស់ខ្លួនទេ; មួយវិញទៀត សត្វនោះ លះទីនោះទៅដោយកម្មណា, កម្មទាំងឡាយដែលជារបស់ខ្លួននោះឯង រមែងសម្លាប់សត្វក្នុងទីនោះ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងនូវភាវៈនៃសត្វទាំងឡាយមានកម្មជារបស់ខ្លួន, មិនមែនទ្រង់សម្ដែងនូវការមិនមាននាយនិរយបាលទាំងឡាយទេ ។ មួយវិញទៀត បទនៃព្រះសូត្រទាំងឡាយ ដែលសកវាទីនាំមកពោលហើយថា **"ម្នាលភិក្ខុទាំងឡាយ ពួកនាយនិរយបាលរមែងញ៉ាំងសត្វនរកនោះ ឱ្យទទួលអាជ្ញា ៥ ប្រការ"** ជាដើម មានអត្ថដូចដែលលោកណែនាំទុកហើយមែនពិត ៕*

ចប់និរយបាលកថា

## ៤.តិរច្ឆានកថា សម្ដែងអំពីសត្វតិរច្ឆាន

*ឥឡូវនេះ ឈ្មោះថា រឿងសត្វតិរច្ឆាន ៖*

*ក្នុងទេពទាំងនោះ ទេវបុត្រទាំងឡាយ ឈ្មោះថា ឯរាវ័ណជាដើម រមែងក្លែងភេទជាដំរី ជាសេះ, សត្វតិរច្ឆានទាំងឡាយរមែងមិនមានក្នុងទីនោះទេ; ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈថា "សត្វតិរច្ឆានទាំងឡាយ គប្បីមានក្នុងពួកទេព" ដូច្នេះ ព្រោះឃើញទេវបុត្រទាំងឡាយ ដែលនិម្មិតភេទជាសត្វតិរច្ឆាន, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ទេវតាមាននៅក្នុងពួកសត្វតិរច្ឆានឬ ?"*** *ជាដើម ដើម្បីចោទដោយពាក្យថា "បើសត្វតិរច្ឆានទាំងឡាយ គប្បីមានក្នុងទេវកំណើតបានមែន, ទេពទាំងឡាយ ក៏គប្បីមានក្នុងកំណើតរបស់សត្វតិរច្ឆានបានដែរ" ។*

*ពាក្យថា* ***"សត្វកន្ទាត"*** *ជាដើម សកវាទីពោលហើយដើម្បីសម្ដែងដល់សត្វទាំងឡាយ ដែលបរវាទីមិនប្រាថ្នាយកចំពោះសត្វណាមួយនោះទេ ។*

*ក្នុងបញ្ហាថា* ***"ដំរីដ៏ប្រសើរឈ្មោះឯរាវ័ណ"*** *សកវាទីពោលឆ្លើយតបព្រោះដំរីឈ្មោះឯរាវ័ណនោះមាន, តែមិនមែនជាសត្វតិរច្ឆានទេ ។ ពាក្យថា* ***"ពួកចងដំរី"*** *ជាដើម សកវាទីពោលដើម្បីចោទដោយពាក្យថា "បើដំរី*

*ជាដើម គប្បីមានក្នុងទីនោះមែន, សូម្បីពួកចង់រីជាដើម ក៏គប្បីមានក្នុងទីនោះដែរ" ។ ក្នុងពាក្យទាំងនោះ ពាក្យថា* ***"ពួកច្រូតស្មៅ"*** *បានដល់អ្នកឲ្យស្មៅសត្វ ។ ពាក្យថា* ***"ពួកប្រធានការងារ"*** *បានដល់ នាយហត្ថាចារ្យជាដើម, អធិប្បាយថា នាយហត្ថាចារ្យទាំងនោះ គប្បីធ្វើការហ្វឹកហាត់ដោយវិធីផ្សេងៗ ។ ពាក្យថា* ***"ពួកធ្វើអាហារឱ្យសត្វ"*** *បានដល់ អ្នកចំអិនអាហារឲ្យសត្វទាំងឡាយ មានដំរីជាដើម ។ ពាក្យថា* ***"មិនគប្បីពោលយ៉ាងនេះទេ"*** *សេចក្តីថា បរវាទីកាលមិនប្រាថ្នាដូច្នោះ ទើបឆ្លើយបដិសេធ ដោយប្រការដូច្នេះ ៕*

ចប់តិរច្ឆានកថា

.........................

## ៥.មគ្គកថា សម្តែងអំពីមគ្គ

*ឥឡូវនេះ ឈ្មោះថា រឿងមគ្គ ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយមហិសាសកៈថា "ពោលតាមពិត មគ្គមានអង្គ ៥ ប៉ុណ្ណោះ" ព្រោះអាស្រ័យព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា " ក៏កាយកម្មវចីកម្ម និងអាជីវៈរបស់អ្នកនោះ ជាអាការហ្មត់ចត់ (បរិសុទ្ធិ) ល្អហើយក្នុង*

*កាលមុនមែនពិត ។ល។”*[៧] *នុ៎ះឯង ទើបពោលថា “សម្មាវាចា សម្មា-កម្មន្ត និងសម្មាអាជីវៈ ជាធម៌មិនប្រកបជាមួយចិត្ត” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“មគ្គមានអង្គ ៥ ឬ ?”*** *ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*បទថា* ***“សម្មាវាចាជាអង្គនៃមគ្គ, តែសម្មាវាចានោះ មិនមែនជាតួមគ្គឬ ?”*** *ជាដើម សកវាទីពោលដោយអំណាចនៃលទ្ធិជនពួកដទៃ ។ មែនពិត ក្នុងលទ្ធិនោះថា “សម្មាវាចាជាដើម ជាអង្គនៃមគ្គ, តែមិនមែនជាតួមគ្គទេ ព្រោះភាវៈជារូប” ។ ពាក្យថា* ***“សម្មាទិដ្ឋិជាអង្គនៃមគ្គ”*** *ជាដើម សកវាទីពោលដើម្បីសម្ដែងថា “ភាវៈនៃអង្គរបស់មគ្គ មិនមែនជាមគ្គ រមែងមិនមាន” ។ ក្នុងព្រះសូត្រថា* ***“កាយកម្ម ។ល។ របស់បុគ្គលនោះ បរិសុទ្ធហើយក្នុងកាលមុនមែនពិតនោះឯង*** *ពាក្យនេះ ព្រះមានព្រះភាគត្រាស់ទុកថា ‘កាយកម្ម វចីកម្ម និងអាជីវៈ ជាអាការបរិសុទ្ធិហើយ” ដូច្នេះ ក៏ដើម្បីសម្ដែងនូវបដិបទាដែលកុលបុត្រគប្បីសម្រេច ជាការបរិសុទ្ធិហើយថា “ឈ្មោះថា មគ្គភាវនារមែងមានដល់អ្នកមានសីលបរិសុទ្ធហើយ, មិនមែនមានដល់បុគ្គលក្រៅអំពីនេះឡើយ” ដូច្នេះ, មិនមែន*

---

[៧] ម. ឧ. ។

ត្រាស់ទុកដើម្បីសម្តែងដល់មគ្គដែលប្រកបដោយអង្គ ៥ ដោយវៀរ សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈទាំងនោះទេ ។ ព្រោះសូត្រនោះឯង ព្រះមានព្រះភាគត្រាស់ថា "អរិយមគ្គមានអង្គ ៨ នេះ រមែងដល់នូវភាពបរិបូណ៌ ដោយភាវនារបស់បុគ្គលនោះ មានប្រការដូច្នេះ" ; ចំណែកព្រះសូត្រដែលសកវាទីនាំមក មានអត្ថតាមដែលលោកណែនាំទុកហើយនុ៎ះឯង ៕

## ចប់មគ្គកថា

...................

# ៦.ញាណកថា សម្តែងអំពីញាណ

ឥឡូវនេះ ឈ្មោះថា រឿងញាណ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយបុព្វសេលិយៈ និងអបរសេលិយៈថា "ញាណមានវត្ថុ ១២ ដោយសំដៅយកញាណមានអាការ ១២ ក្នុងធម្មចក្កប្បវត្តនសូត្រថា 'ជាលោកុត្តរញ្ញាណ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា ***"ញាណលោកុត្តរ មានវត្ថុ ១២ ឬ ?"*** ដើម្បីចោទបរវាទីដោយពាក្យថា "បើលោកុត្តរញ្ញាណនោះ មានវត្ថុ ១២ មែន, មគ្គញ្ញាណទាំងឡាយ

ក៏គប្បីមាន ១២ ដែរ” ដូច្នេះ; បរវាទីឆ្លើយបដិសេធ សំដៅយក លោកុត្តរញ្ញាណនោះ ជាសភាវៈដូចគ្នានឹងមគ្គញ្ញាណ និងឆ្លើយបដិសេធ សំដៅយកសេចក្ដីផ្សេងគ្នានៃញាណគ្រប់ៗ សច្ចៈ ដោយអំណាចនៃសច្ចញ្ញាណ កិច្ចញ្ញាណ និងកតញ្ញាណទាំងឡាយ ។ ក្នុងពាក្យថា **“សោតាបត្តិមគ្គ មាន ១២ ឬ ?”** ក៏មានន័យដូចគ្នានេះដែរ ។ ព្រះសូត្រថា “ព្រះមានព្រះភាគត្រាស់ទុកថា **‘ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ ។ល។ មិនមែនឬ ?”** ដូច្នេះ រមែងសម្ដែងដល់ភាពផ្សេងគ្នានៃញាណដែលជាចំណែកខាងដើម និងខាងចុងដែលបានសម្រេច, មិនមែនសម្ដែងនូវអរិយមគ្គថា មាន ១២ ទេ; ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនជាខអាងថា “ញាណលោកុត្តរ មានវត្ថុ ១២” ដូច្នេះឡើយ ៕

ចប់ញាណកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

១.អសញ្ចិច្ចកថា, ២.ញាណកថា, ៣.និរយបាលកថា, ៤.តិរច្ឆានកថា, ៥.មគ្គកថា, ៦.ញាណកថា ។

**ចប់វគ្គទី ២០**

**ចប់បណ្ណាសកៈទី ៤**

## វគ្គទី ២១

## ១.សាសនកថា សម្តែងអំពីសាសនា

*ឥឡូវនេះ ឈ្មោះថា រឿងសាសនា គឺពាក្យប្រៀនប្រដៅ ឬព្រះធម្មវិន័យ ៖*

*ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះថា “សាសនាគាត់តែងឡើងថ្មី” ដូច្នេះផងថា “បុគ្គលខ្លះ រមែងបំប្លែងឡើងជាថ្មីនូវសាសនារបស់ព្រះតថាគត” ដូច្នេះផង ទាំងនេះ ដោយសំដៅយកការសន្តាយនាទាំង ៣ លើក, សូម្បីពាក្យសួររបស់សកវាទីក្នុងកថាទាំង ៣ ក៏សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា **“សតិបដ្ឋានបានបំប្លែងឡើងថ្មីឬ ?”** ជាដើម សកវាទីពោលដើម្បីតិះដៀលបញ្ហាសូម្បីទាំង ៣ ដោយពាក្យថា “អរិយធម៌ទាំងឡាយ មានសតិបដ្ឋានជាដើមក្តី ទេសនានៃកុសលធម៌ជាដើមក្តី ឈ្មោះថា **សាសនា;** ក្នុងសាសនានោះ វៀរធម៌ទាំងឡាយ មានសតិបដ្ឋានជាដើមដែលព្រះមានព្រះភាគទ្រង់សម្តែងដល់ជនណាហើយ, សាសនា ឈ្មោះថា គឺបុគ្គលនោះ ធ្វើឡើងថ្មី ដោយការធ្វើធម៌ពួកដទៃ ឲ្យជាសតិបដ្ឋានជាដើម ឬធ្វើអកុសលធម៌ជាដើម ឲ្យជាកុសលធម៌ជាដើម, ឬថា សាសនា គឺនរណា*

*មួយ គប្បីធ្វើហើយយ៉ាងនេះ, ឬក៏អាចដើម្បីធ្វើយ៉ាងនេះបានឬ ?” ។ ពាក្យដ៏សេសក្នុងទីទាំងពួង គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕*

ចប់សាសនកថា

-·-·-·-·-

## ២.អវិវិត្តកថា សម្ដែងអំពីបុថុជ្ជនដែលមិនស្ងប់ស្ងាត់

*ឥឡូវនេះ ឈ្មោះថា រឿងបុថុជ្ជនដែលមិនស្ងប់ស្ងាត់ ៖*

*ក្នុងរឿងនោះ ការសន្និដ្ឋានក្នុងលទ្ធិរបស់សកវាទីនេះថា **“ធម៌ណាកើតឡើងចំពោះមុខ គឺជាបច្ចុប្បន្នដល់បុគ្គល, បុគ្គលនោះ ឈ្មោះថាមិនស្ងប់ស្ងាត់ចាកធម៌នោះទេ”** ។ ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះនោះឯងថា “បុថុជ្ជនមិនកំណត់ដឹងធម៌ដែលប្រកបដោយធាតុ ៣ * ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងខណៈតែមួយនុ៎ះឯង គេរមែងស្ងាត់ ស្ងប់ចាកធម៌ដែលប្រកបដោយធាតុ ៣ ទាំងអស់” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា **“ មិនស្ងាត់ចាកផស្សៈ ៣ ”** ជាដើម សកវាទីពោលដើម្បី*

---

* ធាតុ ៣ គឺកាមធាតុ រូបធាតុ និងអរូបធាតុ ។

សម្តែងទោស ដែលប្រព្រឹត្តទៅក្នុងខណៈមួយនៃធម៌ទាំងពួង មានផស្សៈជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕

**ចប់អវិវិត្តកថា**

.................................

## ៣.សញ្ញោជនកថា សម្តែងអំពីសញ្ញោជនៈ

ឥឡូវនេះ ឈ្មោះថា រឿងសញ្ញោជនៈ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយមហាសង្ឃិកៈថា "ការសម្រេចជាព្រះអរហន្ត មិនលះសញ្ញោជនៈខ្លះមាន" ដោយសម្គាល់ថា "ព្រះអរហន្តរមែងមិនដឹងពុទ្ធវិស័យទាំងពួង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបពោលថា 'ព្រះអរហន្តលះអវិជ្ជា និងវិចិកិច្ឆាមិនបាន" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។

ពាក្យថា ***"កាលដែលព្រះយោគី នៅមិនទាន់លះសក្កាយទិដ្ឋិ"*** ជាដើម សកវាទីពោលដើម្បីសម្តែងថា "ព្រះអរហន្តលះសញ្ញោជនៈទាំងអស់បាន" ។

ក្នុងបញ្ហាទីពីរថា "ព្រះអរហន្តដឹងពុទ្ធវិស័យទាំងពួងឬ ?" សកវាទីធ្វើការបដិសេធ ព្រោះព្រះអរហន្តមិនមានសព្វញ្ញុតញ្ញាណ, តែមិនបដិសេធថា

*“ព្រះអរហន្តមិនលះអវិជ្ជា និងវិចិកិច្ឆា” ដូច្នេះទេ ។ តែបរវាទីសំដៅយកព្រះអរហន្តមិនដឹងពុទ្ធវិស័យថា “មិនទាន់លះអវិជ្ជា និងវិចិកិច្ឆាទាំងឡាយ” ទើបបានឲ្យលទ្ធិតាំងទុកដោយពាក្យថា* ***“បើដូច្នោះ ការដែលព្រះយោគីនៅមិនទាន់លះសញ្ញោជនៈខ្លះ ហើយសម្រេចអរហត្តផល ក៏មានដែរ”*** *ដូច្នេះ; តែថា លទ្ធិនោះ រមែងតាំងនៅមិនបានឡើយ ព្រោះតាំងនៅដោយមិនត្រូវទំនង ៕*

ចប់សញ្ញោជនកថា

..............................

## ៤.ឫទ្ធិកថា សម្តែងអំពីឫទ្ធិ

*ឥឡូវនេះ ឈ្មោះថា រឿងឫទ្ធិ ៖*

*ក្នុងរឿងនោះ ឈ្មោះថា ឫទ្ធិនេះ ឲ្យសម្រេចក្នុងគ្រាខ្លះ, មិនឲ្យសម្រេចក្នុងគ្រាខ្លះ ។ ការសន្និដ្ឋានក្នុងលទ្ធិរបស់សកវាទីថា “ឫទ្ធិរមែងមិនសម្រេចក្នុងការធ្វើនូវធម៌ទាំងឡាយ ដែលមិនទៀងជាដើម ឲ្យជារបស់ទៀងជាដើមតែម្យ៉ាងបានឡើយ; ក៏ប៉ុន្តែ ឫទ្ធិនោះ បុគ្គលរមែងធ្វើដើម្បីប្រយោជន៍ដល់ជនណា ដោយផ្លាស់ប្តូរការបន្ត គឺអាយុដែលស្មើគ្នា ធ្វើមិនឲ្យស្មើគ្នា ឬធ្វើឲ្យប្រព្រឹត្តទៅបានយូរជាងគ្នា ដោយអំណាចនៃការបន្តអាយុដែលមានចំណែកស្មើគ្នាបាន, និងរមែងឲ្យសម្រេចបានគ្រាខ្លះ ព្រោះ*

*អាស្រ័យហេតុទាំងឡាយ មានបុណ្យជាដើម របស់បុគ្គលទាំងនោះ ដូចការធ្វើទឹកដែលគួរផឹក ឲ្យជាទឹកដោះថ្លា និងទឹកដោះជូរជាដើម ដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ, និងដូចក្នុងការបន្តតាំងនៅអស់កាលយូរ របស់ប្រទីបជាដើម ក្នុងកន្លែងជាទីកប់ទុកនូវ* ***មហាធាតុ*** *ដែរ"* ។

*ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "ឫទ្ធិឲ្យសម្រេចតាមការប្រាថ្នា" សំដៅសេចក្តីថា សម្រេចគ្រប់យ៉ាង ព្រោះអាស្រ័យព្រះសូត្រដែលពោលទុកថា "ព្រះបិលិន្ទវច្ឆៈមានអាយុបានអធិដ្ឋានប្រាសាទរបស់ព្រះបាទដែនមគធៈ... ចូរជាប្រាសាទមាស" ដូច្នេះ, ពាក្យសួររបស់សកវាទីថា "ឫទ្ធិជាហេតុសម្រេចតាមសេចក្តីប្រាថ្នា... គប្បីមានឬ ?" សំដៅដល់ជនទាំងនោះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា "ឫទ្ធិជាហេតុសម្រេចតាមសេចក្តីប្រាថ្នា" បានដល់ ឫទ្ធិដែលធ្វើឲ្យសមតាមសេចក្តីប្រាថ្នា សំដៅសេចក្តីថា ឲ្យសម្រេចតាមសេចក្តីត្រូវការ ។ ពាក្យថា* **"អាមន្តា"** *ជាពាក្យប្ដេជ្ញារបស់បរវាទី ដើម្បីតាំងលទ្ធិទុក ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ដើមឈើចូរមានស្លឹកជានិច្ចចុះ"*** *ដូច្នេះ ដើម្បីប្រកបធម៌ទាំងឡាយ មានការមិនទៀងជាដើម ថាជារបស់ទៀងជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ។*

*សូម្បីក្នុងការឡូលទិដ្ឋិតាំងទុកដោយព្រះសូត្រថា* ***“ប្រាសាទនោះ ក៏បានជាមាសហើយ”*** *ដូច្នេះ អធិប្បាយថា ប្រាសាទនោះ បានជាមាស ដោយឧបនិស្ស័យនៃបុណ្យរបស់ព្រះរាជា, មិនមែនដោយការប្រាថ្នា (ឫទ្ធិ) របស់ព្រះថេរៈតែម្យ៉ាងប៉ុណ្ណោះទេ; ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែននាំមកពិសោធន៍ថា “ឫទ្ធិឲ្យសម្រេចបានទាំងអស់” ដូច្នេះទេ ។*

ចប់ឫទ្ធិកថា

-----

## ៥.ពុទ្ធកថា សម្ដែងអំពីព្រះពុទ្ធជាម្ចាស់

*ឥឡូវនេះ ឈ្មោះថា រឿងព្រះពុទ្ធជាម្ចាស់ ៖*

*ក្នុងរឿងនោះ លើកលែងការផ្សេងគ្នានៃសរីរៈ អាយុ និងរស្មី ដែលមានក្នុងកាលនោះៗ ហើយ ឈ្មោះថា ការទន់ថយ និងក្រៃលែងនៃព្រះពុទ្ធទាំងឡាយ ដោយការត្រាស់ដឹងធម៌ទាំងឡាយដ៏សេស រមែងមិនមាន ។ តែជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈថា “ព្រះពុទ្ធទាំងឡាយ មិនប្លែកគ្នាឡើយ” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“ព្រះពុទ្ធដូចគ្នា មានភាពក្រៃលែង និងឱនថយជាងគ្នាឬ ?”*** *សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***“ដោយសតិបដ្ឋាន”*** *ជាដើម ដើម្បីសាកសួរដល់ធម៌*

*ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងហើយ ។ បរវាទីកាលមិនឃើញភាវៈនៃព្រះពុទ្ធទាំងនោះ មិនអាក្រក់ និងប្រណីតជាងគ្នា ដោយអំណាចនៃធម៌ដែលលោកត្រាស់ដឹងហើយ ទើបឆ្លើយបដិសេធទាំងអស់ ៕*

ចប់ពុទ្ធកថា

---

## ៦.សព្វទិសាកថា

## សម្តែងអំពីព្រះពុទ្ធស្ថិតនៅក្នុងទិសទាំងពួង

*ឥឡូវនេះ ឈ្មោះថា រឿងព្រះពុទ្ធស្ថិតនៅក្នុងទិសទាំងពួង ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយមហាសង្ឃិកៈថា "លោកធាតុសន្និវាសដោយជុំវិញ គឺក្នុងទិសទាំង ៤ ក្នុងទិសខាងក្រោម និងខាងលើ, ព្រះពុទ្ធទាំងឡាយ មាននៅក្នុងលោកធាតុទាំងអស់ ព្រះពុទ្ធទាំងនោះ សម្រេចការសិក្សាដ៏សមគួរ ដល់ព្រះអគ្គហើយ" , សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ត្រូវសកវាទីសួរថា* ***"ព្រះពុទ្ធស្ថិតនៅក្នុងបុរត្ថិមទិសឬ ?"*** *បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកព្រះសក្យមុនី ។ ត្រូវសកវាទីសួរម្តងទៀត ក៏ឆ្លើយតប ព្រោះសំដៅយកព្រះពុទ្ធដែលតាំងនៅក្នុងលោកធាតុដទៃ ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យថា* ***"ព្រះមានព្រះភាគអង្គនោះ***

***ទ្រង់ព្រះនាមអ្វី ?"*** *ជាដើម សកវាទីពោលហើយ ដើម្បីចោទថា "បើលោកមិនជ្រាប, លោកក៏មិនគួរពោលដល់ព្រះពុទ្ធអង្គនោះ ដោយអំណាចនៃព្រះនាមជាដើមឡើយ" ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងទីទាំងពួង ដោយឧបាយនេះចុះ ៕*

ចប់សព្វទិសាកថា

## ៧.ធម្មកថា សម្ដែងអំពីធម៌

*ឥឡូវនេះ ឈ្មោះថា រឿងធម៌ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈ និងឧត្តរាបថកៈពួកខ្លះថា "ធម៌ទាំងឡាយ មានរូបជាដើមជានិយតៈ គឺទៀង ព្រោះភាវៈនៃរូបជាដើម រមែងលះនូវសភាពនោះ, ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយ ទើបជានិយតៈ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"ធម៌ទាំងពួង"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ជាមិច្ឆត្តនិយតៈ"*** *ជាដើម ដើម្បីចោទថា "បើធម៌ទាំងឡាយ មានរូបជាដើមនោះ គប្បីជាសភាវៈទៀង, គឺគប្បីជាមិច្ឆត្តនិយតៈ ឬគប្បីជាសម្មត្តនិយតៈមែន, ឈ្មោះថា និយាមដទៃអំពីនេះ មិនមានទេ" ។ ក្នុងបញ្ហានោះ ពាក្យបដិសេធ និងពាក្យយល់ព្រមជារបស់បរវាទី ។*

ពាក្យថា ***“រូបជានិយតៈ ដោយអត្ថថា ជារូប”*** ជាដើម សកវាទី ពោលដើម្បីចោទដោយអំណាចនៃរូបដែលបុគ្គលពោលថា ជានិយតៈ ដោយអត្ថយ៉ាងនោះ; ក្នុងសេចក្ដីនេះ លោកអធិប្បាយទុកថា បុគ្គលគប្បី ពោលដោយប្រាថ្នាថា “ក៏រូប ឈ្មោះថា ជារបស់ទៀង ដោយអត្ថថា ជារូប ព្រោះហេតុដូច្នោះ ***រូប*** ទើបជារូបប៉ុណ្ណោះ, មិនមែនជាសភាវធម៌ មានវេទនាជាដើមទេ, នរណាមួយ មិនគប្បីពោលដោយប្រការដទៃអំពីនេះ ទេ” ; ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនមានរូបដទៃក្រៅអំពី អត្ថថា ជារូបទេ; មែនពិត ភាវៈនៃរូប មានរូបជាអត្ថផង ជារូបនោះឯង ផង មិនមែនជាធម៌ដទៃក្រៅអំពីរូបឡើយ; តែថា វោហារនេះ រមែង មាន ដើម្បីឲ្យដឹងដល់ភាពផ្សេងគ្នារបស់រូប និងធម៌ទាំងឡាយ មានវេទនា ជាដើម ។ ព្រោះហេតុដូច្នោះ ពាក្យថា ***“រូបជានិយតៈ ដោយអត្ថថា ជារូប”*** ដូច្នេះ រមែងជាពាក្យដែលសកវាទីពោលថា ***“រូបជានិយតៈឬ ?”*** ; ក៏ឈ្មោះថា និយតៈ គប្បីជាមិច្ឆត្តនិយតៈ ឬជាសម្មត្តនិយតៈ, ព្រោះ ក្រៅអំពីនិយតៈហើយ និយាម គឺកំណត់ការទៀងយ៉ាងដទៃ មិនមានទេ ។

***សួរថា*** កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកឆ្លើយតបថា ព្រោះមានអំណាចនៃការផ្សេងគ្នារបស់អត្ថទៅវិញ ?

មែនពិត ក្នុងពាក្យថា ***“រូបជានិយតៈ ដោយអត្ថថា ជារូប”*** នេះ

*លោកអត្ថាធិប្បាយថា រូប ក៏ជារូបប៉ុណ្ណោះ, មិនមែនជាសភាវធម៌ មានវេទនាជាដើមទេ ។ ព្រោះហេតុដូច្នោះ ទើបលោកពោលឆ្លើយតប ។*

*ម្យ៉ាងទៀត ភាវៈនៃរូបនោះ ជានិយតៈ គឺទៀងពិតដោយប្រការដទៃ អំពីប្រការដែលពោលមកនេះ រមែងមិនមាន ព្រោះហេតុដូច្នោះ ទើបសកវាទីពោលពាក្យថា* ***"ជាមិច្ឆត្តនិយតៈ"*** *ជាដើម ដើម្បីពោលចោទដោយន័យនុ៎ះឯង ។ ពាក្យទាំងអស់នោះ មានអត្ថងាយស្រួលមែនពិត ។ សូម្បីលទ្ធិថា* ***"បើយ៉ាងនេះ រូប ក៏ជានិយតៈ"*** *ដូច្នេះ លទ្ធិនេះ រមែងតាំងទុកមិនបានឡើយ ព្រោះតាំងទុកដោយមិនត្រូវទំនង ៕*

ចប់ធម្មកថា

## ៨.កម្មកថា សម្តែងអំពីកម្ម

*ឥឡូវនេះ ឈ្មោះថា រឿងកម្ម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈ និងឧត្តរាបថកៈពួកខ្លះទាំងនោះថា "ទីតាំងនៃទិដ្ឋធម្មវេទនីយៈជាដើម ជានិយតៈ គឺទៀងពិតប្រាកដ ដោយអត្ថថា ជាទិដ្ឋធម្មវេទនីយៈ, ព្រោះហេតុដូច្នោះ កម្មទាំងពួង ទើបជានិយតៈ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

ក្នុងពាក្យថា ***“ទិដ្ឋធម្មវេទនីយកម្ម ជានិយតៈ ព្រោះអត្ថថា ឱ្យផល ក្នុងបច្ចុប្បន្ន”*** នេះ ជាពាក្យឆ្លើយតបរបស់សកវាទី សំដៅយកសេចក្ដីនេះថា “ទិដ្ឋធម្មវេទនីយកម្ម ក៏ជាទិដ្ឋធម្មវេទនីយៈ គឺជាកម្មដែលឲ្យផលក្នុងភពបច្ចុប្បន្ននេះប៉ុណ្ណោះ; បើទិដ្ឋធម្មវេទនីយកម្មនេះ អាចឲ្យផលក្នុងភពបច្ចុប្បន្នបាន ក៏រមែងឲ្យផល, បើមិនអាចទេ ឈ្មោះថា ជាអហោសិកម្ម” ។ ម្យ៉ាងទៀត ទិដ្ឋធម្មវេទនីយកម្មនេះ មិនជានិយតៈដោយអំណាចនៃនិយាមមិច្ឆត្តៈឡើយ ។ គប្បីជ្រាបពាក្យដ៏សេស ដោយន័យដូចដែលពោលហើយក្នុងពេលមុននុ៎ះចុះ ៕

ចប់កម្មកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

១.សាសនកថា, ២.អវិវិត្តកថា, ៣.សញ្ញោជនកថា, ៤.ឫទ្ធិកថា, ៥.ពុទ្ធកថា, ៦.សព្វទិសាកថា, ៧.ធម្មកថា, ៨.កម្មកថា ។

**ចប់វគ្គទី ២១**

## វគ្គទី ២២

## ១.បរិនិព្វានកថា សម្ដែងអំពីការបរិនិព្វាន

*ឥឡូវនេះ ឈ្មោះថា រឿងបរិនិព្វាន ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "ព្រះអរហន្តមានសញ្ញោជនៈដែលនៅមិនទាន់ បានលះក្នុងវិស័យរបស់ព្រះសព្វញ្ញុពុទ្ធ រមែងបរិនិព្វាន, ព្រោះហេតុដូច្នោះ ការបរិនិព្វានដោយមិនលះនូវសញ្ញោជនៈណាមួយ ទើបមាន" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យដូចដែលពោលហើយក្នុងពេលមុនទុំះឯង៕*

ចប់បរិនិព្វានកថា

.........................

## ២.កុសលចិត្តកថា សម្ដែងអំពីចិត្តជាកុសល

*ឥឡូវនេះ ឈ្មោះថា រឿងចិត្តជាកុសល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "ព្រះអរហន្តជាអ្នកមានសតិបរិបូណ៌ សូម្បីតែការបរិនិព្វានក៏មានសតិសម្បជញ្ញៈមាំទាំ ទើបបរិនិព្វាន, ព្រោះហេតុនោះ ព្រះអរហន្តមានចិត្តជាកុសល ទើបបរិនិព្វាន" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់*

ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទី ពោលពាក្យថា ***“ព្រះអរហន្តកសាងសន្សំហើយ នូវបុញ្ញាភិសង្ខារ”*** ជាដើម ដើម្បីចោទដោយពាក្យថា “ឈ្មោះថា កុសលចិត្តរមែងមានដោយអំណាច នៃការកសាងសន្សំបុញ្ញាភិសង្ខារជាដើមនោះ” ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត, គប្បីជ្រាបអត្ថតាមព្រះបាលីនុ៎ះចុះ ។

ពាក្យថា ***“ព្រះអរហន្ត... មានសតិសម្បជញ្ញៈ”*** នេះ បរវាទីពោល ដើម្បីសម្តែងនូវមរណៈរបស់អ្នកមិនវង្វេងភ្លេចស្មារតី ដោយអំណាច នៃសតិសម្បជញ្ញៈដែលជាកិរិយា ក្នុងខណៈនៃជវន, មិនមែនសម្តែងថា “ព្រះអរហន្តមានចិត្តជាកុសលក្នុងខណៈដែលបរិនិព្វាន” ដូច្នេះទេ; ព្រោះ ហេតុដូច្នោះ ពាក្យនេះ ទើបមិនមែនជាការពិសោធន៍ថា “ព្រះអរហន្ត មានចិត្តជាកុសល បរិនិព្វាន” ដូច្នេះទេ ៕

ចប់កុសលចិត្តកថា

## ៣.អានេញ្ជកថា សម្តែងអំពីអានេញ្ជៈ

ឥឡូវនេះ ឈ្មោះថា រឿងអានេញ្ជៈ គឺភាពជាអ្នកមិនញាប់ញ័រ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិ និកាយឧត្តរាបថកៈពួកខ្លះថា “ព្រះអរហន្តតាំងនៅក្នុងអានេញ្ជៈហើយ ទើប

*បរិនិព្វាន” , ព្រោះកំណត់យកព្រះសូត្រថា “ព្រះមានព្រះភាគតាំងនៅក្នុងចតុត្ថជ្ឈានហើយ ទើបបរិនិព្វាន” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា* ***“ក្នុងភាពជាអ្នកមានចិត្តជាប្រក្រតី គឺបកតិចិត្ត”*** *បានដល់ភវង្គ ។ អធិប្បាយថា សត្វទាំងឡាយអ្នកមានសញ្ញាតាំងនៅក្នុងភវង្គចិត្តហើយ រមែងធ្វើកាលកិរិយាដោយចុតិចិត្តដែលមានភវង្គជាទីបំផុត ។ ទើបសកវាទីពោលនឹងបរវាទីនោះយ៉ាងនេះ ដើម្បីចោទដោយអត្ថនេះដោយប្រការ ។ ក្នុងបញ្ហានោះ សូម្បីប្រក្រតីចិត្តដែលមិនញាប់ញ័ររបស់ព្រះអរហន្តក្នុងចតុវោការភព ក៏ពិតមែន, ប៉ុន្តែបញ្ហានេះ ក៏លោកលើកឡើងសម្តែងហើយដោយបញ្ចវោការភព; ព្រោះហេតុដូច្នោះ ទើបសកវាទីពោលពាក្យថា* ***“... ក៏មិនត្រូវពោលថា”*** *ជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

## ចប់អានេញ្ជកថា

## ៤.ធម្មាភិសមយកថា សម្ដែងអំពីធម្មាភិសម័យ

*ឥឡូវនេះ ឈ្មោះថា រឿងធម្មាភិសម័យ គឺការត្រាស់ដឹងធម៌ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយឧត្តរាបថកៈពួកខ្លះថា "ការត្រាស់ដឹងធម៌របស់សត្វអ្នកដេកនៅក្នុងគភ៌មាន" ដូច្នេះ ព្រោះកាន់យកព្រះសោតាបន្នក្នុងភពអតីត អ្នកនៅក្នុងផ្ទៃមាតា ហើយចេញចាកគភ៌, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"ការសម្ដែងធម៌ជាដើម មានដល់សត្វអ្នកនៅក្នុងគភ៌ឬ ?"*** *ដើម្បីចោទថា "បើការត្រាស់ដឹងធម៌មាននៅក្នុងទីនោះមែន, ហេតុនៃការត្រាស់ដឹងធម៌ទាំងឡាយ មានការសម្ដែងធម៌ជាដើម ក៏គប្បីមានក្នុងទីនោះបាន" ។*

*ពាក្យថា "ការត្រាស់ដឹងធម៌មានដល់បុគ្គលអ្នកដេកលក់ហើយ" ជាដើម សកវាទីពោលសំដៅយកភវង្គវារៈ ។ មែនពិត ភវង្គរបស់សត្វដែលនៅក្នុងគភ៌ រមែងប្រព្រឹត្តទៅច្រើនយ៉ាង ។ ដោយហេតុនោះឯង សត្វដែលនៅក្នុងគភ៌នោះ ឈ្មោះថា ដេកលក់ហើយ ព្រោះមិនមានការប្រព្រឹត្តទៅនៃវេលាដែលនឹងគប្បីធ្វើកិច្ច, ឈ្មោះថា ប្រមាទហើយ ព្រោះមិនមានភាវនានុយោគ, ឈ្មោះថា អ្នកវង្វេងភ្លេចសតិ គ្មានសម្បជញ្ញៈ*

ព្រោះមិនមានសតិសម្បជញ្ញៈរបស់អ្នកកំណត់កម្មដ្ឋាន, កាលបើដូច្នេះ ការត្រាស់ដឹងធម៌របស់សត្វដែលមានសភាពបែបនោះ នឹងមានមកអំពីណា ៕

ចប់ធម្មាភិសមយកថា

..................................

## ៥-៧.តិស្សន្នម្បិ កថានំ សម្ដែងអំពីកថាទាំង ៣

ឥឡូវនេះ ឈ្មោះថា រឿងកថាទាំង ៣ ៖

កថាទាំង ៣ គឺធម្មាភិសម័យដែលមិនមានដល់បុគ្គល ៣ ប្រភេទ គឺដល់សត្វដែលនៅក្នុងគភ៌, ដល់បុគ្គលដែលដេកលក់ហើយជាដើម និងដល់បុគ្គលដែលយល់សប្តិ ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះ សូម្បីក្នុងទីនេះថា "ការសម្រេចព្រះអរហត្ត មានដល់សត្វដែលនៅក្នុងគភ៌" ដូច្នេះផង ព្រោះកាន់យកការសម្រេចព្រះអរហត្ត របស់ព្រះសោតាបន្នដែលកើតហើយមិនយូរ និងឃើញគភ៌តាំងនៅ ៧ ឆ្នាំ របស់នាងសុប្បវាសាឧបាសិកាថា "ធម្មាភិសម័យ រមែងមាន" ដូច្នេះផង ព្រោះកាន់យកការយល់សប្តិដែលជាទីទៅកាន់ភាពសូន្យទទេ (អាកាស) ជាដើមថា "ការសម្រេចព្រះអរហត្ត រមែងមានក្នុងទីនោះ" ដូច្នេះផង; ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ ដូចនឹងរឿងមុនៗនុ៎ះដែរ ៕

ចប់តិស្សន្នម្បិ កថានំ

..................................

## ៨.អព្យាកតកថា សម្តែងអំពីអព្យាក្រឹត

*ឥឡូវនេះ ឈ្មោះថា រឿងអព្យាក្រឹត ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា " ចិត្តរបស់បុគ្គលអ្នកយល់សប្តិទាំងឡាយ ជាអព្យាក្រឹត" ព្រោះព្រះបាលីថា* ***"ម្នាលភិក្ខុទាំងឡាយ ចេតនារបស់អ្នកយល់សប្តិនោះ រមែងមាន, តែចេតនានុ៎ះឯង ជាអព្វោហារិក (អព្វោហារិក*** *= មិនមានវោហារ គឺសំដៅសេចក្តីថា មិនមានពាក្យបញ្ញត្តិដែលព្រះអង្គទ្រង់បញ្ញត្តទុក ក្នុងព្រះវិន័យថា នឹងត្រូវអាបត្តិដូចម្តេច ?)"*[៨]*, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។*

*ពាក្យថា* ***" ចិត្តរបស់បុគ្គលដែលយល់សប្តិថា ជាអព្វោហារិក"*** *នេះ សកវាទីពោលសំដៅដល់អាបត្តិ គឺការត្រូវទោសតាមផ្លូវវិន័យ ។ មែនពិត អកុសលចិត្តរបស់អ្នកយល់សប្តិ រមែងប្រព្រឹត្តទៅដោយអំណាចនៃបាណាតិបាតជាដើម ក៏ពិតមែន, ប៉ុន្តែថា នោះជាការធ្វើអាក្រក់ដោយវត្ថុ ក៏ទេ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគមិនអាចដើម្បីនឹងបញ្ញត្តអាបត្តិ*

---

[៨] វិនយ. ៣/(សង្ឃាទិសេសកណ្ឌ) ។

*ក្នុងទីនោះបានទេ ។ ដោយហេតុនេះ ចិត្តដែលជាអព្យោហារិកនោះ ទើបមិនមែនជាអព្យាក្រឹតឡើយ ៕*

ចប់អព្យាកតកថា

............................

## ៩.អាសេវនបច្ចយតាកថា

## សម្តែងអំពីភាពជាអាសេវនប្បច្ច័យ

*ឥឡូវនេះ ឈ្មោះថា រឿងភាពជាអាសេវនប្បច្ច័យ គឺជាបច្ច័យព្រោះបង្កើតការស្រឡាញ់ ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា “ធម៌ទាំងពួង ជាដួរខណៈ, ធម៌អ្វីៗ សូម្បីតាំងនៅមួយគ្រាហើយ ឈ្មោះថា ការសេព (បង្កើតក្តីស្រឡាញ់) នូវអាសេវនប្បច្ច័យ ក៏ទេ; ព្រោះហេតុដូច្នោះ ភាពជាអាសេវនប្បច្ច័យ មិនមានដោយពិត, ម្យ៉ាងទៀត ធម៌អ្វីៗ ដែលកើតឡើងហើយ មិនជាអាសេវនប្បច្ច័យទេ” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីឲ្យបរវាទីនោះ ដឹងដោយព្រះសូត្រនោះឯង ទើបនាំព្រះសូត្រមកថា “ព្រះមានព្រះភាគត្រាស់ទុកថា ‘* ***ម្នាលភិក្ខុទាំងឡាយ បាណាតិបាត***

*ដែលបុគ្គលប្រព្រឹត្តហើយ'* ជាដើម មិនមែនឬ ?" ព្រះសូត្រទាំងពួងនោះ មានអត្ថងាយស្រួលមែនពិត ៕

ចប់អាសេវនប្បច្ចយតាកថា

## ១០.ខណិកកថា

## សម្តែងអំពីធម៌ទាំងពួងប្រព្រឹត្តទៅមួយជួរខណៈ

ឥឡូវនេះ ឈ្មោះថា ធម៌ទាំងពួងប្រព្រឹត្តទៅមួយជួរខណៈ គឺសំដៅដល់ខណៈចិត្ត ៖

ក្នុងបញ្ហានោះ សន្តតធម៌ទាំងពួង មិនទៀង, ព្រោះហេតុដូច្នោះ សន្តតធម៌ទាំងនោះ ទើបប្រព្រឹត្តទៅក្នុងជួរខណៈចិត្តមួយប៉ុណ្ណោះ ។ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិរបស់និកាយបុព្វសេលិយៈនិងអបរសេលិយៈថា "ក៏កាលបើមានសេចក្តីមិនទៀង ធម៌ម្យ៉ាង រលត់ទៅរហ័ស, ធម៌ម្យ៉ាងរលត់ទៅយឺត" , កាលបើដូច្នេះ ក៏អ្វីទៅ ជាការផ្សេងគ្នាក្នុងទីនេះ, ដូច្នេះ ពាក្យសួររបស់សកវាទីថា **"*ធម៌ទាំងពួង ប្រព្រឹត្តទៅក្នុងខណៈនៃចិត្តតែមួយឬ ?*"** សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។

*ក្នុងពាក្យទាំងឡាយ មានពាក្យថា "មហាបថវី... **សុទ្ធតែតាំងនៅក្នុងចិត្តឬ ?"** ជាដើម បរវាទីកាលមិនឃើញការតាំងនៅនៃមហាបថវីជាដើមនោះ ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យថា **"ចក្ខាយតនៈ"** ជាដើម សកវាទីពោលដើម្បីចោទថា "បើធម៌ទាំងពួងគប្បីមានមួយជួរខណៈចិត្តមែន, អាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម កើតឡើងហើយ ក៏គប្បីរលត់ទៅព្រមជាមួយនឹងវិញ្ញាណទាំងឡាយមានចក្ខុវិញ្ញាណជាដើមបានដែរ" ។ តែបរវាទីឆ្លើយបដិសេធ សំដៅយកការកើតឡើងនៃវិញ្ញាណរបស់សត្វដែលកើតក្នុងផ្ទៃមាតា ។ រមែងឆ្លើយតបសំដៅយកការប្រព្រឹត្តទៅ គឺបវត្តិកាល ដោយអំណាចនៃលទ្ធិនុ៎ះឯង ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ។ ពាក្យថា **"បើយ៉ាងនោះធម៌ទាំងពួង ក៏ប្រព្រឹត្តទៅមួយជួរខណៈចិត្ត"** ដូច្នេះ អធិប្បាយថា បរវាទីរមែងពោលតាមការពេញចិត្តរបស់ខ្លួនថា **"ធម៌ទាំងឡាយ ឈ្មោះថាជារបស់មិនទៀង មិនមាន,** ព្រោះហេតុដូច្នោះ **ធម៌ទាំងនោះ ទើបប្រព្រឹត្តទៅក្នុងខណៈចិត្តតែមួយ"** ។ ពាក្យនោះ មិនដូចនឹងពាក្យ ដែលបរវាទីនោះពោលហើយ ដោយប្រការដូច្នេះ ៕*

ចប់ខណិកកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១.បរិនិព្វានកថា, ២.កុសលចិត្តកថា, ៣.អានេញ្ជកថា, ៤.ធម្មាភិសមយកថា, ៥-៧.តិស្សុន្នម្បិ កថានំ, ៨.អព្យាកតកថា, ៩.អាសេវនប្បច្ចយតាកថា, ១០.ខណិកកថា ។*

**ចប់វគ្គទី ២២**

## វគ្គទី ២៣

## ១.ឯកាធិប្បាយកថា សម្ដែងអំពីបំណងតែម្យ៉ាង

*ឥឡូវនេះ ឈ្មោះថា បំណងតែម្យ៉ាង ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈ និងវេតុល្លៈថា "បំណងម្យ៉ាងរបស់បុគ្គល ២ មែនមាន ព្រោះធ្វើកិច្ចទាំងឡាយ មានការបូជាព្រះពុទ្ធជាម្ចាស់ជាដើម ព្រមជាមួយនឹងស្ត្រីដោយអំណាចនៃការប្រាថ្នាថា 'សូមបំណងតែម្យ៉ាងដូចគ្នា ចូរមានដោយសេចក្ដីករុណា ឬដោយការប្រាថ្នាតែម្យ៉ាងដូចគ្នា, ឬក៏ពួកយើង នឹងរួមគ្នាក្នុងសង្សារវដ្ដ' ដូច្នេះ ឈ្មោះថា មានបំណងតែម្យ៉ាងដូចគ្នា, មេថុនធម្មដែលមានបំណងតែម្យ៉ាងដូចគ្នាយ៉ាងនេះ ជនទាំង ២ នោះ គប្បីសេព" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស គប្បីពិចារណាមើលក្នុងព្រះបាលីចុះ ៕*

ចប់ឯកាធិប្បាយកថា

## ២.អរហន្តវណ្ណកថា សម្ដែងអំពីភេទរបស់ព្រះអរហន្ត

ឥឡូវនេះ ឈ្មោះថា រឿងភេទរបស់ព្រះអរហន្ត គឺការសេពមេថុនធម្ម ដោយភេទនៃព្រះអរហន្ត ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយឧត្តរាបថកៈថា "អមនុស្សទាំងឡាយ សេពមេថុនធម្ម ដោយភេទរបស់ព្រះអរហន្ត" ដូច្នេះ ព្រោះឃើញភិក្ខុលាមក អ្នកបរិបូណ៌ ដោយឥរិយាបថ អ្នកបរិបូណ៌ដោយកិរិយា, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕

ចប់អរហន្តវណ្ណកថា

................................

## ៣-៧.ឥស្សរិយកាមការិកាកថា

## សម្ដែងអំពីការប្រាថ្នាក្នុងភាពជាធំ

ឥឡូវនេះ ឈ្មោះថា រឿងការប្រាថ្នាក្នុងភាពជាធំ ៖

ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "ព្រះពោធិសត្វរមែងទៅកាន់វិនិបាត, ព្រះពោធិសត្វយាងចុះកាន់គភ៌, ព្រះពោធិសត្វបានធ្វើទុក្ករកិរិយា, ព្រះពោធិសត្វ បានធ្វើសេចក្ដីព្យាយាម

យ៉ាងដទៃ, ព្រះពោធិសត្វខទិ្ទសសាស្តាដទៃ ព្រោះហេតុតែមានប្រាថ្នាក្នុងភាពជាធំ” ដូច្នេះ ដោយសំដៅយកឆទ្ទន្តជាតកជាដើម, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងកថាដំបូង មានអត្ថងាយស្រួលមែនពិត ។

ក្នុងកថាទី ២ ថា “ព្រះពោធិសត្វមានឫទ្ធិឬ ?” សកវាទីសួរដើម្បីចោទថា “បើព្រះពោធិសត្វគប្បីសម្រេចសេចក្ដីប្រាថ្នាក្នុងភាពជាធំមែន ក៏គប្បីសម្រេចដោយឫទ្ធិ, មិនមែនដោយអំណាចនៃកម្មទេ” ដូច្នេះ; ក៏ក្នុងបញ្ហាដំបូង បរវាទីសំដៅយកឫទ្ធិដែលសម្រេចដោយភាវនា គឺឥទ្ធិបាទទើបឆ្លើយបដិសេធ, ក្នុងបញ្ហាទី ២ សំដៅយកបុញ្ញឫទ្ធិ ទើបឆ្លើយតប ។

ក្នុងកថាទី ៣ សកវាទីពោលពាក្យថា “លោកទៀង” ជាដើម ដើម្បីចោទថា “បើឈ្មោះថា ការធ្វើសេចក្ដីប្រាថ្នាក្នុងភាពជាធំ គឺការធ្វើទុក្ករកិរិយា ព្រះមានព្រះភាគទ្រង់ធ្វើដោយមិច្ឆាទិដ្ឋិមែន, ព្រះអង្គក៏គប្បីធ្វើទុក្ករកិរិយានោះតែម្យ៉ាង, គប្បីកាន់យកនូវទិដ្ឋិទាំងឡាយ មានសស្សតទិដ្ឋិ” ជាដើម ។ សូម្បីក្នុងកថាទី ៤ ក៏មានន័យដូចគ្នានេះដែរ ៕

ចប់ឥស្សរិយកាមការិកាកថា

# ៨.រាគប្បដិរូបកាទិកថា

## សម្តែងអំពីធម៌ជាគ្រឿងប្រៀបធៀបដោយរាគៈជាដើម

*ឥឡូវនេះ ឈ្មោះថា រឿងរាគប្បដិរូបកៈ គឺធម៌ដែលប្រៀបធៀបដោយរាគៈជាដើម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា " មានធម៌ដែលមិនមែនរាគៈ ប្រៀបដូចជារាគៈ " ដូច្នេះ ព្រោះសំដៅយកមេត្តា ករុណា និងមុទិតាធម៌ ព្រោះថា មានធម៌ដែលមិនមែនទោសៈ ប្រៀបដូចជាទោសៈ ព្រោះសំដៅយកឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ ព្រោះថា មានធម៌ដែលមិនមែនមោហៈ ប្រៀបដូចជាមោហៈដូច្នេះ ព្រោះសំដៅយកហសិតុប្បាទ ព្រោះថា មានធម៌ដែលមិនមែនកិលេស ប្រៀបដូចជាកិលេស ព្រោះសំដៅយកវាទៈដ៏រឹងប៉ឹង ដែលត្មះតិះដៀល បុគ្គលអ្នកទ្រុស្តសីលទាំងឡាយ និងអនុគ្រោះភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយ ដែលជាពាក្យតិះដៀល បានសរសើរសេចក្តីល្អរបស់ព្រះបិលិន្ទវច្ឆៈ និងព្រះតម្រាស់របស់ព្រះមានព្រះភាគថា* ***" មោឃបុរស "*** *ដែលជាសម្តីដូចទឹកមាត់ដូច្នោះ, ដោយពាក្យសួរក្នុងកថាទាំងពួង របស់សកវាទីសំដៅដល់ជនអ្នកឃើញខុសទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***" មានធម៌ដែលមិនមែនផស្សៈ តែប្រៀបដូច***

***ផស្សៈឬ ?"*** *ជាដើម ទៅនឹងបរវាទីនោះ ដើម្បីចោទថា "ឈ្មោះថា ធម៌ទាំងឡាយ មានផស្សៈជាដើម របស់ធម៌ប្រៀបដូចផស្សៈជាដើម រមែងមិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីរាគធម៌ជាដើម របស់ធម៌ ប្រៀបដូចរាគៈជាដើម ក៏រមែងមិនមាន" ។ បរវាទីឆ្លើយ បដិសេធ ព្រោះការមិនមាននៃធម៌ទាំងនោះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយស្រួលមែនពិត ៕*

ចប់រាគប្បដិរូបកាទិកថា

---

## ៩.អបរិនិប្ផន្នកថា សម្តែងអំពីធម៌ដែលមិនសម្រេចហើយ

*ឥឡូវនេះ ឈ្មោះថា រឿងអបរិនិប្ផន្នៈ គឺធម៌ដែលមិនសម្រេចហើយ សំដៅដល់ធម៌ដែលមិនកើតឡើង ព្រោះបច្ច័យប្រជុំគាក់តែង ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិ និកាយឧត្តរាបថកៈខ្លះ និងហេតុវាទខ្លះថា "ទុក្ខប៉ុណ្ណោះ ជាបរិនិប្ផន្នៈ គឺជាធម៌ដែលសម្រេចហើយ ឬកើតឡើងហើយ, ចំណែកធម៌ដ៏សេស គឺខន្ធ អាយតនៈ ធាតុ និងឥន្ទ្រិយ ជាអបរិនិប្ផន្នៈ គឺមិនសម្រេចហើយ មិន កើតឡើងហើយ" ដោយអាស្រ័យព្រះពុទ្ធវចនៈថា* ***"ក៏ទុក្ខប៉ុណ្ណោះ***

***រមែងកើតឡើង ទុក្ខប៉ុណ្ណោះ រមែងតាំងនៅផង រមែងរលត់ទៅផង ក្រៅអំពីទុក្ខ មិនមានអ្វីកើត ក្រៅអំពីទុក្ខ មិនមានអ្វីរលត់”***[៩] ដូច្នេះ, *ពាក្យសួររបស់សកវាទីថា “រូបជាអបរិនិប្ផន្នៈឬ ?” សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***“រូបមិនមែនជារបស់មិនទៀង”*** *ជាដើម ដើម្បីចោទថា “បើរូបជាអបរិ-និប្ផន្នៈមែន, រូបនោះ ក៏មិនមែនជារបស់មិនទៀងជាដើម” ។ បរវាទីកាលមិនឃើញរូបដូច្នោះ ទើបឆ្លើយបដិសេធ ។ សកវាទីបដិសេធលទ្ធិមួយរបស់បរវាទីនោះ ដោយពាក្យថា* ***“រូបជារបស់មិនទៀង... មិនមែនឬ ?”*** *ជាដើម កាលនឹងសួរបញ្ហាទី ២ ទើបពោលពាក្យថា* ***“ទុក្ខប៉ុណ្ណោះជាអបរិនិប្ផន្នៈឬ ?”*** *។ លំដាប់នោះ សកវាទីដើម្បីនឹងបដិសេធលទ្ធិរបស់បរវាទីនោះឯង ទើបពោលពាក្យជាដើមថា* ***“វត្ថុណាមិនទៀង វត្ថុនោះ ព្រះមានព្រះភាគត្រាស់ថា ‘ ជាទុក្ខ’ ... មិនមែនឬ ?”*** *។*

*ក្នុងសេចក្ដីនោះ មានអធិប្បាយថា សច្ចៈតែម្យ៉ាងប៉ុណ្ណោះ ជាទុក្ខតែម្យ៉ាង ក៏ទេ, ក៏ធម៌យ៉ាងណាមួយ ដែលមិនទៀង, ធម៌នោះ ក៏ជាទុក្ខមែនពិត; ទាំងរូប ក៏ជារបស់មិនទៀង, ព្រោះហេតុដូច្នោះ សូម្បីរូបនោះ*

---

[៩] សំ. ស. ។

ក៏ជាបរិនិប្ផន្នៈ; ដោយហេតុនោះ ទើបមិនគួរពោលថា "រូបជាអបរិនិប្ផន្នៈ, ទុក្ខប៉ុណ្ណោះ ជាបរិនិប្ផន្នៈ" ។ សូម្បីការប្រកបក្នុងធម៌ទាំងឡាយ មានវេទនាជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ម្យ៉ាងទៀត ក្នុងធម្មាយតនៈ និងធម្មធាតុទាំងឡាយ វៀរព្រះនិព្វានចេញហើយ បណ្ឌិតគប្បីជ្រាបថា "ធម៌ដ៏សេសទាំងអស់ ជាអនិច្ចំ" ។ ឥន្ទ្រិយទាំងឡាយ ក៏ជាអនិច្ចំដែរ ៕

ចប់អបរិនិប្ផន្នកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

១.ឯកាធិប្បាយកថា, ២.អរហន្តវណ្ណកថា, ៣-៧.ឥស្សរិយកាម-

ការិកាកថា, ៨.រាគប្បដិរូបកាទិកថា, ៩.អបរិនិប្ផន្នកថា ។

## ចប់វគ្គទី ២៣

## ចប់ខុទ្ទកបណ្ណាសកៈ

## និគមគាថា

**កំដោយពាក្យមានប្រមាណប៉ុណ្ណេះ ៖**

*ព្រះពុទ្ធឃោសាចារ្យបានរួបរួមកថាទាំងពួង អំពីបណ្ណាសកៈទាំង ៤ និងវគ្គទាំង ៣ ប៉ុណ្ណេះ ហើយចែកជាប្រភេទចេញទៅបានចំនួន ៣០០* ។*

*ព្រះជិនស្រី ទ្រង់ឈ្លាសក្នុងកថាមគ្គទាំងឡាយ ទ្រង់សម្ដែងហើយនូវកថាវត្ថុប្បករណ៍ណា ការពណ៌នាអត្ថនៃកថាវត្ថុប្បករណ៍នោះ សម្រេចរួចរាល់ហើយ ។*

*ខ្ញុំចងក្រងគម្ពីរនេះទុក មានប្រមាណ ១៣ ភាណវារៈ អំពីចំនួន ៣៥ ភាណវារៈ ដើម្បីការតាំងមាំនៃព្រះសទ្ធម្ម (ផង) ដើម្បីជាបែបផែន (ផង) ។*

*កុសលឯណា ដែលខ្ញុំសម្រេចហើយ ដល់ព្រមហើយ រមែងមានដោយអំណាចនៃកុសលនោះ សូមសត្វលោក គឺទេវតា និងមនុស្សទាំងឡាយ ចូរទទួលនូវរសនៃព្រះសទ្ធម្មរបស់ព្រះធម្មរាជានុ៎ះចុះ ។*

**ចប់កថាវត្ថុប្បករណ៍ដោយបរិបូណ៌**

---

* ក្នុងយោជនាថា បានចំនួន ២៣០ ប្រភេទ គឺក្នុងបណ្ណាសកៈទាំង ៤ បណ្ណាសកៈមួយៗ ៥០ ជា ២០០ និងក្នុងវគ្គទាំង ៣ ជាកថា ៣០ ទៀត រួមត្រូវជា ២៣០ ប្រភេទ ។

# អដ្ឋកថាយមកៈ

## ពណ៌នាអំពីគម្ពីរយមកៈ

### អារម្ភកថា

សទ្ធេបនេវ ទេវានំ ទេវទេវោ សុរាលយេ
កថាវត្ថុប្បករណំ ទេសយិត្វា រណញ្ជហោ ។
យមស្ស វិសយាតីតោ នានាយមកមណ្ឌិតំ
អភិធម្មប្បករណំ ឆដ្ឋំ ឆដ្ឋានទេសកោ។
យមកំ អយមាវដ្ដ- នីលាមលតនូរុហោ
យំ ទេសយិ អនុប្បត្តោ តស្ស សំវណ្ណនាក្កមោ
ឥទានិ យស្មា តស្មាស្ស ហោតិ សំវណ្ណនា អយំ។

*ព្រះសម្មាសម្ពុទ្ធ ជាវិសុទ្ធិទេព ទ្រង់ប្រហារកិលេស ដែលជាហេតុញុាំងសត្វឱ្យខ្សឹកខ្សួល ក្នុងភពតូច-ធំ គ្រាទ្រង់សម្ដែងកថាវត្ថុប្បករណ៍ដោយសង្ខេបដល់ពួកទេវតាទាំងឡាយ ក្នុងសុរាល័យទេវលោកហើយ ព្រះអង្គទ្រង់ឈានកន្លងផុតខេត្តដែន (វិស័យ) របស់យមរាជ ជាអ្នកមិនមានមន្ទិលកើតចំពោះព្រះអង្គ ដែលនឹងនាំមកកាន់វដ្តៈទៀត ទ្រង់សម្ដែងធម៌ជាគ្រឿងប្រហារកិលេស ទ្រង់បានសម្ដែងអភិធម្មប្បករណ៍ ឈ្មោះថា* **យមកៈ**

*ដែលជាបករណ៍ទី ៦ ប្រដាប់ដោយនានាយមកៈទុកហើយ ដល់ព្រមហើយ ព្រោះហេតុដូច្នោះ ការសំវណ្ណនានឹងមានដូចតទៅ ៖*

## ១.មូលយមកវណ្ណនា

### ពណ៌នាអំពីឧទ្ទេសវារៈ

*ក៏បករណ៍នេះ ព្រះមានព្រះភាគទ្រង់ចែកទុក ១០ យ៉ាង ដោយអំណាចនៃយមកៈ ១០ យ៉ាង គឺមូលយមកៈ ១, ខន្ធយមកៈ ១, អាយតនយមកៈ ១, ធាតុយមកៈ ១, សច្ចយមកៈ ១, សង្ខារយមកៈ ១, អនុសយយមកៈ ១, ចិត្តយមកៈ ១, ធម្មយមកៈ ១ និងឥន្ទ្រិយ-យមកៈ ១; គប្បីជ្រាបអត្ថនៃយមកៈទាំង ១០ យ៉ាង របស់បករណ៍នេះ ដូចតទៅ ៖*

***សួរថា*** *ឈ្មោះថា* ***យមកៈ*** *ព្រោះអត្ថថា ដូចម្ដេច ?*

*ឆ្លើយថា ព្រោះអត្ថថា* **យុគលវេដ្ឋន** *= ជាគូគ្នា ។*

*ពិតមែនហើយ (ពាក្យគូគ្នា) លោកហៅថា* ***យមកៈ*** *។ ដូចជាកាលដែលលោកសម្ដែងទុកថា* **“យមកបាដិហារិយ** *= បាដិហារ្យជាគូ,* **យមកសាលា** *= ឈើសាលៈជាគូ”* *ជាដើម ។*

*ក្នុងយមកៈទាំង ១០ យ៉ាងនេះ យមកៈមួយគូៗ ឈ្មោះថា* ***គូ*** *ព្រោះសម្ដែងទុកដោយអំណាចនៃយមកៈទាំងឡាយ គឺគូ ដោយប្រការដូច្នេះ,*

ក៏បករណ៍ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា **យមកៈ** ព្រោះរួមនូវគូទាំងឡាយនេះទុក ។

យមកៈដំបូងនៃយមកៈទាំង ១០ យ៉ាង ហៅថា **មូលយមកៈ** ព្រោះក្នុងមូលយមកៈនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើការសួរ និងឆ្លើយដោយអំណាចនៃមូលយមកៈនោះ មាន ២ វារៈ គឺឧទ្ទេសវារៈ និងនិទ្ទេសវារៈ ។ ក្នុង ២ វារៈនោះ ឧទ្ទេសវារៈជាវារៈដំបូង ទ្រង់លើកឡើងហើយនាំចេញសម្តែងទៅតាមលំដាប់ ។

យមកៈនេះថា **"យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលា, យេ វា បន កុសលមូលា, សព្វេ តេ ធម្មា កុសលា"** ជាយមកៈដើម (គូដំបូង) របស់មូលយមកៈនោះ ។

គប្បីជ្រាបសេចក្តីជាគូគ្នា (យមកៈ) នៃឧទ្ទេសវារៈនោះ ដោយវិធី ៣ យ៉ាង គឺ **អត្ថយមកៈ** លោកសម្តែងដោយអំណាចនៃធម៌ពីរយ៉ាង គឺកុសលធម៌ និងអកុសលធម៌ម្យ៉ាង, **ធម្មយមកៈ** លោកសម្តែងដោយអំណាចនៃធម៌ជាបែបផែន ដែលប្រព្រឹត្តទៅដោយអនុលោម (តាមលំដាប់) និងបដិលោម (សារមកវិញតាមលំដាប់) របស់ធម៌ទាំងនោះម្យ៉ាង; ម្យ៉ាងទៀត លោកសម្តែង **បុច្ឆាយមកៈ** ដោយអំណាចនៃពាក្យសួរដែលប្រព្រឹត្តទៅដោយអនុលោម និងបដិលោម ។ សូម្បីយមកៈទាំងឡាយ

ដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។

ឥឡូវនេះ គប្បីជ្រាបការកំណត់ព្រះបាលីដោយអំណាចនៃប្រភេទរបស់វារៈមាន **នយៈ យមកៈ បុច្ឆា** និង **អត្ថ** នៃខន្ធវារៈក្នុងមូលយមកៈនេះ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយយមកៈទាំងឡាយយ៉ាងនេះ ៖

ន័យទាំង ៤ យ៉ាងនេះ គឺ **មូលន័យ, មូលមូលន័យ, មូលកន័យ** និង **មូលមូលកន័យ** មានហើយ ព្រោះអាស្រ័យបទដែលជាខាងដើមនេះថា **“កុសលា ធម្មា”** នៃកុសលត្តិកមាតិកា ។

ក្នុងន័យទាំង ៤ យ៉ាងនេះ ន័យនីមួយៗ មានយមកៈ ៣ យ៉ាង គឺ **មូលយមកៈ, ឯកមូលយមកៈ** និង **អញ្ញមញ្ញមូលយមកៈ** ទើបជាយមកៈ ១២ យ៉ាង ។

ក្នុងយមកៈនីមួយៗ មានបុច្ឆា ២ យ៉ាង ដោយអំណាចនៃ **អនុលោម** និង **បដិលោម** ទើបជាបុច្ឆា ២៤ ។

ក្នុងបុច្ឆានីមួយៗ មានអត្ថ ២ យ៉ាង ដោយអំណាចនៃ **ការសន្និដ្ឋាន** (បទតាំង) និង **ការសង្ស័យ** (បទសួរ ឬបទសង្ស័យ) ទើបជាអត្ថ ៤៨ ។

គប្បីជ្រាបអត្ថនៃការសន្និដ្ឋានក្នុងបទថា **“យេ កេចិ កុសលា ធម្មា** = ធម៌ឯណានីមួយដែលជាកុសល**”** នេះ ព្រោះការមិនសង្ស័យ ក្នុងកុសល

ទាំងឡាយថា ជាកុសល ឬមិនមែនជាកុសល ។

គប្បីជ្រាបអត្ថនៃការសង្ស័យក្នុងបទថា **“សព្វេ តេ កុសលមូលា** = កុសលទាំងអស់នោះ ជាកុសលមូលឬ” នេះ ព្រោះការសួរដោយអំណាចនៃសេចក្ដីសង្ស័យយ៉ាងនេះថា “កុសលទាំងអស់នោះ ជាកុសលមូល ឬមិនជាកុសលមូល” ; ក៏សេចក្ដីនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដើម្បីសម្ដែងសេចក្ដីសង្ស័យ ក្នុងឋានជាទីសង្ស័យរបស់វេនេយ្យសត្វទាំងឡាយ, តែឈ្មោះថា សេចក្ដីសង្ស័យរមែងមិនមានដល់ព្រះតថាគត; សូម្បីក្នុងបទបុច្ឆាដទៃអំពីបទនេះ ក៏មានន័យដូចគ្នានេះដែរ ។

បណ្ឌិតគប្បីជ្រាបថា ក៏សូម្បីបទទាំងឡាយ ៤ ដែលពោលហើយ ដោយន័យ ១៦, យមកៈ ៤៨, បុច្ឆា ៩៦, អត្ថ ១៩២ ដោយអំណាចនៃខទ្វេសក្នុងកុសលត្តិកមាតិកាថា “ក៏ន័យទាំង ៤ នេះ រមែងមាន ព្រោះអាស្រ័យកុសលបទ, យមកៈ ១២ រមែងមានដោយអំណាចនៃយមកៈ ៣ យ៉ាង ក្នុងន័យមួយៗ, អត្ថ ៤៨ រមែងមានដោយអំណាចនៃអត្ថ ២ យ៉ាង ក្នុងបុច្ឆាមួយដូច្នេះ យ៉ាងណា, ន័យទាំង ៤ យ៉ាងនេះ ក៏រមែងមាន ព្រោះអាស្រ័យកុសលបទខ្លះ ព្រោះអាស្រ័យអព្យាកតបទខ្លះ យ៉ាងនោះ” ដូច្នេះ ព្រោះអាស្រ័យនូវបទ ទើបឈ្មោះថា នាំមកសម្ដែងហើយ ព្រោះនឹងធ្វើបទទាំង ៣ ឲ្យប្រមូលគ្នាខ្លះ ។

*ខាងមុខអំពីនេះ វារៈ ៩ យ៉ាង មានវារៈថា* **“យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលហេតុ** *= ធម៌ពួកណាមួយ ជាកុសល, ធម៌ទាំងអស់នោះ ជាកុសលហេតុឬ ?” ជាដើម ព្រះមានព្រះភាគទ្រង់លើកឡើងសម្តែងហើយ ដោយអំណាចនៃវេវចនៈរបស់មូលវារៈនោះឯង; សូម្បីវារៈទាំងអស់ មាន ១០ វារៈ* ***គឺមូលវារៈ ១ ហេតុវារៈ ១ និទានវារៈ ១ សម្ភវារៈ ១ បភវវារៈ ១ សមុដ្ឋានវារៈ ១ អាហារវារៈ ១ អាលម្ពណវារៈ ១ បច្ចយវារៈ ១*** និង ***សមុទយវារៈ ១*** *រមែងមានដោយប្រការដូច្នេះ ។*

*នយៈ ១៦០, យមកៈ ៤៨០, បុច្ឆា ៩៦០, អត្ថ ១៩២០ គប្បីជ្រាបថា លោកលើកឡើងសម្តែងទុកហើយក្នុងវារៈទាំង ១០ សូម្បីទាំងអស់ថា “គប្បីជ្រាបវារៈទាំងឡាយ មាននយៈជាដើម សូម្បីក្នុងបទដ៏សេស ដោយការកំណត់បទដែលមានមកហើយក្នុងមូលកវារៈនុ៎ះឯង” ; បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលី ដោយអំណាចនៃប្រភេទរបស់វារៈមាន* ***នយៈ យមកៈ បុច្ឆា*** និង ***អត្ថ*** *ក្នុងខន្ធេសវារៈ យ៉ាងនេះសិន ។*

*ព្រះគាថាដែលថា* **“មូលំ ហេតុ និទានំ ច”** *ជាដើម ឈ្មោះថា* ***ឧទានគាថា*** *របស់វារៈទាំងឡាយ សូម្បីទាំង ១០; ពាក្យទាំងឡាយ មានពាក្យថា* ***“មូល”*** *ជាដើម សូម្បីទាំងអស់ក្នុងគាថានោះ ជាវេវចនៈរបស់ហេតុ (ការណៈ) នុ៎ះឯង ។*

*ក៏ហេតុ ឈ្មោះថា **មូល** ព្រោះអត្ថថា តាំងទុកចំពោះ ។*

*ធម្មជាតិណារមែងទៅ គឺរមែងប្រព្រឹត្តទៅ ដើម្បីញុំាងផលរបស់ខ្លួនឲ្យសម្រេច ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **ហេតុ** ។*

*ធម្មជាតិណារមែងឲ្យនូវផលរបស់ខ្លួន ហាក់ដូចសម្តែងឡើងថា "អញ្ជើញលោកកាន់យកនូវផលនោះចុះ" ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **និទាន** ។*

*ផលរមែងកើតព្រមពីធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **សម្ភវៈ** ។*

*ផលរមែងកើតទូទៅពីធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **បភវៈ** ។*

*ផលរមែងតាំងឡើងក្នុងធម៌នេះ ឬថា រមែងតាំងឡើងដោយធម៌នេះ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា **សមុដ្ឋាន** ។*

*ធម៌ណារមែងនាំមកនូវផលរបស់ខ្លួន ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **អាហារ** ។*

*ធម៌ណាដែលផលរបស់ខ្លួនរមែងទាញទុក ព្រោះអត្ថថា មិនគប្បីត្រូវបដិសេធ (ដោយផលរបស់ខ្លួន) ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **អាលម្ពណៈ** (ឬអារម្មណ៍) ។*

*ផលអាស្រ័យធម៌នោះ គឺមិនបដិសេធ (ធម៌នោះ) រមែងកើត គឺរមែងប្រព្រឹត្តទៅ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា* ***បច្ច័យ*** *=* **ឯតំ បដិច្ច អបដិក្ខិបិត្វា ផលំ ឯតំ បវត្តីតិ បច្ចយោ** *។*

*ផលរមែងកើតអំពីធម៌នេះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា* ***សមុទយះ*** *។*

*បណ្ឌិតគប្បីជ្រាបអត្ថនៃពាក្យរបស់បទទាំងឡាយនោះ យ៉ាងនេះដោយប្រការដូច្នេះ ៕*

ចប់ឧទ្ទេសវារៈ

.................................

# ១.មូលយមកវណ្ណនា

## ពណ៌នាអំពីនិទ្ទេសវារៈ

*ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្តើមនិទ្ទេសវារៈដោយន័យជាដើមថា* **“យេ កេចិ កុសលា ធម្មា** *= ធម៌ពួកណាមួយជាកុសល”* *។*

*ក្នុងពាក្យទាំងនោះ ពាក្យថា* **“យេ កេចិ** *= ពួកណាមួយ” ជាពាក្យសម្តែងដល់កុសលទាំងអស់ ដោយមិនមានចំណែកសល់ ។*

*ពីរបទថា* **“កុសលា ធម្មា”** *បានដល់ សភាវធម៌ដែលជាកុសល មិនមានទោស មានផលជាសុខ ជាលក្ខណៈដែលព្រះមានព្រះភាគត្រាស់*

*ទុកហើយ ក្នុងបទភាជនៈនៃកុសលត្តិកៈ ។*

*ប្រើនបទថា* **“សព្វេ តេ កុសលមូលា** *= ធម៌ទាំងពួងនោះ ជាកុសលមូលឬ ? ” បានដល់ រមែងសួរថា ធម៌ទាំងពួងនោះ នឹងជាកុសល-មូល មិនមែនឬ ?*

*ពីរបទថា* **“ តីណេវ កុសលមូលានិ** *= បីប៉ុណ្ណោះ ឈ្មោះថា កុសលមូល” បានដល់ ធម៌ទាំងអស់នោះ មិនឈ្មោះថា* ***កុសលមូលទេ*** *អធិប្បាយថា មូល ៣ មានអលោភមូលជាដើមប៉ុណ្ណោះ ឈ្មោះថា កុសលមូល ។*

*ប្រើនបទថា* **“អវសេសា កុសលា ធម្មា ន កុសលមូលា** *= ធម៌ទាំងឡាយដ៏សេស ឈ្មោះថា* ***កុសល,*** *តែមិនឈ្មោះថា កុសលមូលទេ” បានដល់ កុសលធម៌ទាំងឡាយដ៏សេស មានផស្សៈជាដើម មិនឈ្មោះថា កុសលមូលឡើយ; ម្យ៉ាងទៀត អធិប្បាយថា កុសលទាំងឡាយដ៏សេស មានផស្សៈជាដើម ឈ្មោះថា កុសលធម៌ប៉ុណ្ណោះ មិនឈ្មោះថា កុសល-មូលទេ ។*

*ប្រើនបទថា* **“យេ វា បន កុសលមូលា** *= ឬក៏កុសលមូលណា” បានដល់ មូល ៣ មានអលោភមូលជាដើម លោកកាន់យកហើយថា “ឬក៏ធម៌ណាជាកុសលមូល ដោយបទទីពីរនៃបុច្ឆាដំបូង ” ។*

ប្រើនបទថា **“សព្វេ តេ ធម្មា កុសលា** = ធម៌ទាំងពួងនោះ ជាកុសលឬ ?” បានដល់ រមែងសួរថា សូម្បីធម៌ទាំង ៣ នោះ ជាកុសលឬ ?; ពាក្យថា **“អាមន្តា** = មែន” បានដល់ ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីទ្រង់ឆ្លើយតបសភាវៈនៃកុសលមូល សូម្បីទាំងអស់ថាជាកុសល; នេះជាសេចក្តីរបស់មូលយមកៈក្នុងមូលន័យសិន; គប្បីជ្រាបន័យរបស់ការវិសជ្ជនាក្នុងបុច្ឆាទាំងពួង ដោយឧបាយនេះចុះ ។

សេចក្តីប្លែកគ្នាយ៉ាងណា មាននៅក្នុងទីណា, ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) នឹងពណ៌នាសេចក្តីប្លែកគ្នានោះ ក្នុងទីនោះតទៅ ពោលគឺក្នុងឯកមូលយមកៈ កុសលទាំងឡាយ បណ្ឌិតមិនគួរកាន់យកកុសល ដែលមានមូលតែម្យ៉ាង ដោយអត្ថនៃការរាប់ទេ, តែគួរកាន់យកដោយអត្ថនៃការរាប់, តែគួរកាន់យកដោយអត្ថដែលស្មើគ្នាថា “ធម៌ទាំងអស់នោះ មានមូលតែមួយ ជាមួយនឹងកុសលមូល” អធិប្បាយថា ក្នុងឯកមូលយមកៈនេះ កុសលទាំងអស់នោះ មានមូលស្មើគ្នាជាមួយនឹងកុសលមូល, មូលណា ជាមូលរបស់ផស្សៈ, មូលនោះ ក៏ជាមូលរបស់ធម៌ទាំងឡាយ មានវេទនាជាដើមនោះឯង; កាលបើដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់យល់ព្រមសភាវៈនៃកុសលទាំងនោះ ថាជាយ៉ាងនោះ ទើបត្រាស់ពាក្យថា **“អាមន្តា** = មែន” ។

*ពាក្យថា* **“ កុសលសមុដ្ឋានំ ”** *លោកសម្ដែងរូបដែលមានកុសលចិត្តជាសមុដ្ឋាន ។*

*ពាក្យថា* **“ ឯកមូលំ ”** *បានដល់ មានមូលស្មើគ្នា ជាកុសលមូលមានអលោភមូលជាដើម; មូលទាំងឡាយ មានអលោភមូលជាដើម ឈ្មោះថា* ***មូល*** *ព្រោះជាហេតុ ជាបច្ច័យដល់ធម៌ទាំងឡាយ មានផស្សៈជាដើម យ៉ាងណា, មូលនោះ ក៏ជាមូលសូម្បីដល់សមុដ្ឋានរូបដូច្នោះដែរ; តែសមុដ្ឋានរូបនោះ មិនមែនជាកុសលទេ ព្រោះមិនមានលក្ខណៈនៃកុសល ។*

*ព្រះមានព្រះភាគជាម្ចាស់ មិនត្រាស់សួរក្នុងយមកៈដទៃៗ ទៀតថា* **“យេ កេចិ កុសលា** *= ធម៌ពួកណាមួយ ជាកុសល, តែត្រាស់សួរថា* **“យេ កេចិ កុសលមូលេន ឯកមូលា** *= ធម៌ពួកណាមួយ មានមូលជាមួយគ្នានឹងកុសលមូល” ។*

***សួរថា*** *ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះធម៌នោះឯង សូម្បីមានព្រមដោយព្យញ្ជនៈនោះ; ពាក្យថា* **“ កុសលមូលានិ ”** *នេះ ជាវិសេសនៈរបស់ពាក្យមុន; ពិតណាស់ ព្រះអដ្ឋគ្រាស់ថា* ***“ មូលពួកណា រមែងកើតឡើងជាមួយគ្នា ”*** *, មូលពួកនោះ ក៏ជាកុសលមូលខ្លះ ជាអកុសលមូលខ្លះ និងជាអព្យាក្រឹតខ្លះ, ពាក្យនេះ លោកពោលទុកដើម្បីសម្ដែងវិសេសនៈរបស់ពាក្យថា* ***កុសលមូលានិ*** *។*

ពាក្យថា **“ អញ្ញមញ្ញមូលានិ ច** = ជាមូលដល់គ្នានឹងគ្នា” អធិប្បាយថា មូលទាំងឡាយ រមែងជាហេតុ ជាបច្ច័យដល់គ្នានឹងគ្នា; ព្រោះជាហេតុ ជាបច្ច័យ ក្នុងបដិលោមបុច្ឆាទុំះឯង មិនត្រាស់ថា **“ សព្វេ តេ ធម្មា កុសលមូលេន ឯកមូលា** = ធម៌ទាំងអស់នោះ មានមូលជាមួយគ្នា ជាកុសលមូល” , តែត្រាស់ថា **“សព្វេ តេ ធម្មា កុសលា** = ធម៌ទាំងអស់នោះ ជាកុសល” , ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនមានសេចក្តីប្លែកគ្នា; ក៏កាលនឹងធ្វើការបុច្ឆាថា **“ កុសលមូលេន ឯកមូលា** = មានមូលដូចគ្នានឹងកុសលមូលឬ ? ” ដូច្នេះ គប្បីធ្វើការវិសជ្ជនា តាមន័យដែលពោលហើយ ក្នុងពេលមុនថា **“មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ** = មូលទាំងឡាយណា កើតឡើងក្នុងពេលជាមួយគ្នា” , ក៏កាលបើសេចក្តីប្លែកគ្នាមិនមានហើយ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់មិនត្រាស់សួរយ៉ាងនោះទេ; តែទ្រង់នឹងត្រាស់សួរយ៉ាងនេះ សូម្បីក្នុងមូលន័យជាដើម ។ ក្នុងអញ្ញមញ្ញមូលយមកៈ ក៏គប្បីជ្រាបពាក្យសួរដែលប្លែកគ្នា ដោយឧបាយនេះចុះ ។

ក្នុង ***មូលមូលន័យ*** ពាក្យថា **“សព្វេ តេ កុសលមូលា** = ធម៌ទាំងឡាយនោះ មានមូលជាកុសលមូល” បានដល់ រមែងសួរថា “ធម៌

ទាំងឡាយនោះ ឈ្មោះថា ***មូល*** ពោលគឺកុសលមូលឬ ?" ; ពាក្យថា "**ឯកមូលមូលា** = មានមូល ដែលហៅថា មូល គឺជាមួយគ្នា" ដូច្នេះ អធិប្បាយថា មូលដែលជាមូលជាមួយគ្នា ជាកុសលមានហើយ ព្រោះហេតុនោះ មូលនោះ ទើបឈ្មោះថា ***ជាមូល ដែលហៅថា មូល គឺជាមួយគ្នា*** ព្រោះអត្ថថា ស្មើគ្នា = **សមានដ្ឋេន** ។

បទថា "**អញ្ញមញ្ញមូលមូលា** = មានមូលដែលជាមូលដល់គ្នានឹងគ្នា" ដូច្នេះ បានដល់ មូលដល់គ្នានឹងគ្នា ឈ្មោះថា អញ្ញមញ្ញមូល គឺថា អញ្ញ-មញ្ញមូល ឈ្មោះថា មូលរបស់ធម៌ទាំងនោះ ព្រោះអត្ថថា ជាហេតុ ជាបច្ច័យ ព្រោះហេតុនោះ មូលនោះ ទើបឈ្មោះថា ***អញ្ញមញ្ញមូល*** ។

ក្នុង ***មូលកន័យ*** បទថា "**កុសលមូលកា**" អធិប្បាយថា មានមូលដែលជាកុសលរបស់ធម៌ទាំងនោះ ព្រោះអត្ថថា ជាហេតុ ជាបច្ច័យ ព្រោះហេតុនោះ កុសលទាំងនោះ ទើបឈ្មោះថា មានមូលដែលហៅថា កុសលមូល, នេះជាសេចក្ដីពិសេសក្នុងន័យយមកបុច្ឆាជាដើម ព្រោះអាស្រ័យកុសលបទត្រឹមតែប៉ុណ្ណេះ, សូម្បីក្នុងបទទាំងឡាយ មានអកុសលបទជាដើម ក៏មានន័យដូចគ្នានេះដែរ; ចំណែកសេចក្ដីពិសេស មានដូចតទៅនេះ ៖

ពីរបទថា "**អហេតុកំ អកុសលំ**" ត្រាស់អត្ថសំដៅយកមោហៈដែល

សម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ។ ពីរបទថា **“អហេតុកំ អព្យាកតំ”** បានដល់ ធម៌ដ៏សេសលះបង់ចោលសហេតុកៈ និងអព្យាកតសមុដ្ឋានរូប រមែងបានក្នុងទីនេះថា ចិត្តុប្បាទ ១៨, រូប និងនិព្វាន ឈ្មោះថា មិនមានមូលជាមួយគ្នា និងអព្យាកតមូល លោកធ្វើអព្យាក្រឹតនោះ ឲ្យជាអព្វោហារិក គឺវត្ថុដែលពោលអាងមិនបាន ឬមិនមានវោហារ ហើយទើបធ្វើការវិសជ្ជនា ដោយអំណាចនៃអព្យាកតមូលដែលមានសេចក្ដីដូចគ្នា ។

ធម៌ទាំងឡាយ ពោលគឺ ***នាម*** ឈ្មោះថា ***នាមធម៌*** នាមទាំងនោះ ពោលដោយអត្ថ បានដល់ ***អរូបក្ខន្ធ ៤*** និង ***និព្វាន***; ពីរបទថា **“នវេវ នាមមូលានិ** = ៩ ប៉ុណ្ណោះ ឈ្មោះថា នាមមូល” បានដល់ មូល ៩ យ៉ាង ដោយអំណាចនៃកុសល អកុសល និងអព្យាក្រឹត ។ មូលនាមដែលជាអហេតុកៈ មិនមានមូលជាមួយគ្នានឹងនាមមូល ព្រោះហេតុដូច្នោះ នាមនោះ ទើបឈ្មោះថា មិនមានហេតុ, សូម្បីនាមទាំងអស់ គឺចិត្តុប្បាទ ១៨ មោហៈ ដែលសម្បយុត្តដោយវិចិកិច្ឆា ឧទ្ធច្ចៈ និងនិព្វាន មិនមានមូលជាមួយគ្នានឹងនាមមូលទេ; ក៏អហេតុកនាមនោះ រមែងមិនកើតព្រមជាមួយនឹងនាមមូល, អធិប្បាយថា ***សហេតុកនាមរមែងកើតឡើងព្រមគ្នាជាមួយនឹងនាមមូល*** សូម្បីក្នុងបទទាំងឡាយថា **“សហេតុកំ នាមំ នាមមូលេន”** ដូច្នេះ; ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយស្រួល

*ទាំងអស់ ដោយប្រការដូច្នេះ ។*

*សូម្បីក្នុងវារៈទាំងឡាយ មានហេតុវារៈជាដើម គប្បីជ្រាបសេចក្ដីដោយឧបាយនេះចុះ; គាថាជាដើមថា* **“មូលំ ហេតុ និទានំ ច”** *ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃឧទានរបស់វារៈទាំង ១០ តាមដែលខ្ញុំពន្យល់មកហើយ ។*

ចប់មូលយមកៈ

-------

## ២.ខន្ធយមកៈ

## ពណ៌នាអំពីឧទ្ទេសវារៈ

*ឥឡូវនេះ ជាការពណ៌នា* ***ខន្ធយមកៈ*** *ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកក្នុងលំដាប់តអំពី* ***មូលយមកៈ*** *ព្រោះទ្រង់រួបរួមនូវធម៌ទាំងឡាយមានកុសលធម៌ជាដើម ដែលព្រះអង្គទ្រង់សម្ដែងហើយក្នុងមូលយមកៈ ដោយអំណាចនៃខន្ធ; គប្បីជ្រាបការកំណត់បាលីក្នុងខន្ធយមកៈ យ៉ាងនេះសិន ៖*

*ក្នុង* ***ខន្ធយមកៈ*** *នេះ មានមហាវារៈ ៣ គឺ* ***បណ្ណត្តិវារៈ បវត្តិវារៈ*** *និង* ***បរិញ្ញាវារៈ*** *។*

*ក្នុងមហាវារៈទាំង ៣ នោះ* ***បណ្ណត្តិវារៈ*** *ត្រាស់ហៅថា បណ្ណត្តិវារៈ ព្រោះទ្រង់ធ្វើដោយអំណាចនៃការជម្រះឈ្មោះរបស់ខន្ធទាំងឡាយ ។*

***បវត្តិវារ:*** *ត្រាស់ហៅថា បវត្តិវារៈ ព្រោះទ្រង់ជម្រះការប្រព្រឹត្តទៅដោយអំណាចនៃការកើតឡើង និងការរលត់ទៅរបស់ខន្ធទាំងឡាយ ដែលព្រះអង្គទ្រង់ជម្រះឈ្មោះហើយ ។*

***បរិញ្ញាវារ:*** *ត្រាស់ហៅថា បរិញ្ញាវារៈ ព្រោះទ្រង់សម្ដែងបរិញ្ញា ៣ នៃខន្ធទាំងឡាយដែលប្រព្រឹត្តទៅហើយតាមលំដាប់ដោយសង្ខេប ។*

*ក្នុងមហាវារៈទាំងនោះ* ***បណ្ណត្តិវារ:*** *ព្រះអង្គទ្រង់កំណត់ដោយអាការ ២ យ៉ាង ដោយអំណាចនៃឧទ្ទេស និងនិទ្ទេស; សូម្បីក្នុងឧទ្ទេសនិងនិទ្ទេសទាំងនេះ ឧទ្ទេសវារៈ មិនមានតែមួយផ្នែកទេ, ចាប់ផ្ដើមអំពីដើមព្រះអង្គទ្រង់កំណត់និទ្ទេសដោយចែកតែមួយ ដោយអំណាចនៃបុច្ឆា និងវិសជ្ជនា; បណ្ឌិតគប្បីជ្រាបឧទ្ទេសវារៈនៃបណ្ណត្តិវារៈតាំងពីបទថា* **“ បញ្ច-ក្ខន្ធា”** *ជាដើម រហូតដល់* **ន ខន្ធា ន សង្ខារា**; *សូម្បីពាក្យថា “បុច្ឆាវារៈ” នេះ ក៏ជាឈ្មោះ របស់ឧទ្ទេសនោះ; ក្នុងបណ្ណត្តិវារៈនោះ បទថា* **“ បញ្ច-ក្ខន្ធា”** *ដូច្នេះ សេចក្ដីថា នេះជាឧទ្ទេសរបស់ខន្ធទាំងឡាយ ដែលគប្បីសួរដោយអំណាចនៃយមកៈ ។*

*គប្បីជ្រាបការកំណត់ឈ្មោះរបស់ខន្ធទាំងឡាយនោះ ដោយប្រភេទថា* ***“រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ*** *និង* ***វិញ្ញាណក្ខន្ធ”*** *។*

*ឥឡូវនេះ នយវារៈ ៤ គឺ* ***បទសោធនវារ:, បទសោធនមូលចក្កវារ:,***

***សុទ្ធក្ខន្ធវារៈ*** និង ***សុទ្ធក្ខន្ធមូលចក្កវារៈ*** រមែងមានដោយអំណាចនៃខន្ធទាំងឡាយនោះ ។

ក្នុងនយវារៈទាំងនោះ វារៈដែលធ្វើការជម្រះបទមានន័យជាដើមថា **"រូបំ រូបក្ខន្ធោ រូបំ"** នោះឯង ឈ្មោះថា ***បទសោធនវារៈ***, បទសោធនវារៈនេះ មាន ២ យ៉ាង ដោយអំណាចនៃអនុលោម និងបដិលោម; ក្នុងបទសោធនវារៈនោះ ត្រង់អនុលោមវារៈមាន ៥ យមកៈ គឺ **"រូបំ រូបក្ខន្ធោ, រូបក្ខន្ធោ រូបំ"** ជាដើម, សូម្បីក្នុងបដិលោម ក៏មាន ៥ យ៉ាង គឺ **"ន រូបំ ន រូបក្ខន្ធោ, ន រូបក្ខន្ធោ រូបំ"** ជាដើម ។

ខាងមុខអំពីនេះ ជាវារៈដែលទ្រង់ចង (ព័ន្ធ) មូលមួយខន្ធៗ នៃខន្ធទាំងឡាយ ដែលព្រះអង្គទ្រង់ជម្រះហើយ ក្នុងបទសោធនវារៈនោះឯង ឲ្យជាចក្រ ៤ ដោយន័យជាដើមថា **"រូបំ រូបក្ខន្ធោ, ខន្ធា វេទនាក្ខន្ធោ"** ឈ្មោះថា ***បទសោធនមូលចក្កវារៈ*** ព្រោះភាវៈនៃចក្រទាំងឡាយ ដែលជាមូលនៃការជម្រះបទ មាន ។ សូម្បីបទសោធនមូលចក្កវារៈនោះ ក៏មាន ២ យ៉ាង ដោយអំណាចនៃអនុលោម និងបដិលោម; ក្នុងអនុលោម និងបដិលោមទាំងនោះ ក្នុងអនុលោមវារៈ មានយមកៈ ២០ ព្រោះធ្វើមូលនៃខន្ធមួយៗ ឲ្យជា ៤ មាន **ន រូបំ ន រូបក្ខន្ធោ, ន ខន្ធា ន វេទនាក្ខន្ធោ** ជាដើម ។

ខាងមុខអំពីនេះ វារៈដែលដំណើរទៅហើយ ដោយអំណាចនៃខន្ធសុទ្ធៗ មានន័យជាដើមថា **“រូបំ ខន្ធោ, ខន្ធា រូបំ”** ដូច្នេះ ឈ្មោះថា ***សុទ្ធក្ខន្ធវារៈ***; ក្នុងសុទ្ធក្ខន្ធវារៈនោះ ក្នុងបុច្ឆាថា **“ខន្ធា រូបំ”** ជាដើម គប្បីកាន់យកសេចក្តីថា ខន្ធទាំងឡាយ ឈ្មោះថា ***រូបក្ខន្ធ*** មិនមែនឬ ?, ខន្ធទាំងឡាយ ឈ្មោះថា វេទនាខន្ធឬ ?; ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះលោកចែកទុកក្នុងនិទ្ទេសវារៈយ៉ាងនេះ ។

ក្នុងនិទ្ទេសវារៈនោះ ***សួរថា*** រូប ឈ្មោះថា ខន្ធឬ ? ឆ្លើយថា មែន ។

***សួរថា*** ខន្ធទាំងឡាយ ឈ្មោះថា រូបក្ខន្ធឬ ?

ឆ្លើយថា រូបក្ខន្ធ ឈ្មោះថា រូបជង ឈ្មោះថា រូបក្ខន្ធជង, ខន្ធទាំងឡាយដ៏សេស មិនឈ្មោះថា ***រូបក្ខន្ធ*** ទេ ។ លោកលើកបទឡើង ចែកអត្ថដោយន័យជាដើមថា “ខន្ធទាំងឡាយ ឈ្មោះថា រូបក្ខន្ធឬ ?” នៃបទទាំងឡាយថា “ខន្ធទាំងឡាយ ឈ្មោះថា រូបឬ ?” ដោយប្រការដូច្នេះ; ក៏ដោយហេតុនោះ វារៈនោះ ទើបលោកហៅថា ***សុទ្ធក្ខន្ធវារៈ*** ។ ក្នុងសុទ្ធក្ខន្ធវារៈនេះ ពាក្យថា **“ន ខន្ធា”** ជាពាក្យដែលមានប្រមាណ ដូចក្នុងការជម្រះពាក្យ; ក៏សុទ្ធក្ខន្ធវារៈរមែងមានដោយប្រការណាៗ, ការប្រព្រឹត្តទៅជាប្រមាណ រមែងមានដោយប្រការនោះៗ; សូម្បីក្នុងអាយតនយមកៈជាដើមខាងមុខ ក៏មានន័យដូចគ្នានេះដែរ; ក៏ឯសុទ្ធក្ខន្ធវារៈ មាន ២ យ៉ាង

*ដោយអំណាចនៃអនុលោម និងបដិលោម; ក្នុងអនុលោម និងបដិលោមទាំងនោះ អនុលោមវារៈ មានយមកៈ ៥ យ៉ាង គឺ* **"រូបំ ខន្ធោ, ខន្ធា រូបំ"** *ជាដើម, សូម្បីក្នុងបដិលោមវារៈ ក៏មានយមកៈ ៥ យ៉ាង គឺ* **"ន រូបំ ន ខន្ធោ, ន ខន្ធា ន រូបំ"** *ជាដើម ។*

*ខាងមុខអំពីនោះ លោកធ្វើការសម្ដែងមូលនៃខន្ធមួយៗ ក្នុងសុទ្ធក្ខន្ធទាំងឡាយនោះ ដោយន័យជាដើមថា* **"រូបំ ខន្ធោ, ខន្ធា វេទនា"** *ឲ្យជា ៤ ឈ្មោះថា សុទ្ធក្ខន្ធមូលចក្កវារៈ ព្រោះចក្រមានសុទ្ធក្ខន្ធជាមូល; ក្នុងសុទ្ធក្ខន្ធ-មូលចក្កវារៈនោះ គប្បីជ្រាបអត្ថដោយន័យជាដើមថា "ខន្ធទាំងឡាយឈ្មោះថា វេទនាខន្ធឬ ?" ក្នុងពាក្យសួរថា* **"ខន្ធា វេទនា"** *ជាដើម ។*

*ដោយប្រការក្រៅនេះ ទើបមានសេចក្ដីខុសគ្នាពីនិទ្ទេសវារៈ; សូម្បីសុទ្ធក្ខន្ធមូលចក្កវារៈនោះ ក៏មាន ២ យ៉ាង ដោយអំណាចនៃអនុលោម និងបដិលោម; ក្នុងអនុលោម និងបដិលោមទាំងនោះ, អនុលោមវារៈ មានយមកៈ ២០ ព្រោះធ្វើមូលនៃខន្ធមួយៗ ឲ្យជាចក្រ ៤ មានបទជាដើមថា* **"រូបំ ខន្ធោ, ខន្ធា វេទនា"** *, សូម្បីក្នុងបដិលោមវារៈ ក៏មាន ២០ ដូចគ្នា ព្រោះធ្វើមូលនៃខន្ធមួយៗ ឲ្យជា ៤ មានបទជាដើមថា* **"ន រូបំ ន ខន្ធោ, ន ខន្ធា ន វេទនា"** *ដូច្នេះ; គប្បីជ្រាបនិទ្ទេសវារៈនៃបណ្ណត្តិវារៈ ដែលប្រដាប់ហើយដោយយមកៈ ១០០, ដោយពាក្យសួរ ២០០ និង*

*ដោយអត្ថ ៤០០ ព្រោះធ្វើអត្ថទាំងឡាយឲ្យជាពីរ ដោយអំណាចនៃការសន្និដ្ឋាន និងការសង្ស័យ ដើម្បីសួរក្នុងន័យមួយៗ យ៉ាងនេះសិន ដោយប្រការដូច្នេះ ៕*

ចប់ឧទ្ទេសវារៈ

.....................

## ១.បណ្ណត្តិវារវណ្ណនា

## ពណ៌នាអំពីនិទ្ទេសវារៈ បទសោធនវារៈ

*ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្តើមនិទ្ទេសវារៈដោយន័យជាដើមថា* **“ រូបំ រូបក្ខន្ធោ ”** *; ព្រះមានព្រះភាគត្រាស់ហៅថា* ***រូប*** *យ៉ាងណាមួយក្នុងបញ្ហានេះថា* **“ រូបំ រូបក្ខន្ធោ** *= ធម៌ដែលឈ្មោះថា* ***រូប*** *ឈ្មោះថារូបក្ខន្ធឬ ? ”* *ដូច្នេះ រូបទាំងអស់នោះ ព្រះអង្គត្រាស់ទុកដើម្បីទ្រង់ជម្រះពាក្យថា* ***រូបក្ខន្ធ*** *។*

*ពាក្យវិសជ្ជនាដែលថា* **“ បិយរូបំ សាតរូបំ រូបំ ន រូបក្ខន្ធោ** *= បិយរូប និងសាតរូប ឈ្មោះថា* ***រូប****, មិនឈ្មោះថា រូបក្ខន្ធទេ” អធិប្បាយថា ពាក្យថា* ***“រូបណា”*** *ដែលព្រះអង្គត្រាស់ថា “រូប” ក្នុងពាក្យថា* **“បិយរូបំ សាតរូបំ”** *នេះ, រូបនោះ ឈ្មោះថា រូបប៉ុណ្ណោះ, មិនឈ្មោះថា* ***រូបក្ខន្ធ*** *ឡើយ ។*

*ពាក្យវិសជ្ជនាដែលថា* **“រូបក្ខន្ធោ រូបញ្ចេវ រូបក្ខន្ធោ ច** *= រូបក្ខន្ធ ឈ្មោះថា រូបផង ឈ្មោះថា រូបក្ខន្ធផង” អធិប្បាយថា ក៏រូបណា ជារូបក្ខន្ធ, រូបនោះ រមែងគួរដើម្បីពោលថា “ជារូប” ផង “ ជារូបក្ខន្ធ” ផង ។*

*ក្នុងបញ្ហាដែលថា* **“រូបក្ខន្ធោ រូបំ** *= រូបក្ខន្ធ ឈ្មោះថា* ***រូប*** មិន *មែនឬ ?” ដូច្នេះ ព្រោះរូបក្ខន្ធ គប្បីពោលថា ជារូបដោយពិតប្រាកដ, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់ថា* **“អាមន្តា** *= មែន” ; គប្បីជ្រាបវិសជ្ជនាទាំងអស់ ដោយឧបាយនេះ; ចំណែកសេចក្ដីប្លែកគ្នាមានហើយ ក្នុងទីណា, នឹងពណ៌នាសេចក្ដីប្លែកគ្នានុ៎ះ ក្នុងទីនុ៎ះឯង ។*

*ក្នុង* ***សញ្ញាយមកៈ*** *ពាក្យថា* ***“ទិដ្ឋិសញ្ញា”*** *បានដល់ ទិដ្ឋិសញ្ញា ដែលមានមកហើយក្នុងពាក្យជាដើមថា* ***“បបញ្ចសញ្ញា”*** *។*

*ក្នុង* ***សង្ខារយមកៈ*** *ពាក្យថា* **“អវសេសា សង្ខារា** *= សង្ខារទាំងឡាយដ៏សេស” បានដល់ សង្ខតធម៌ដ៏សេសអំពីសង្ខារក្ខន្ធ ដែលមានមកហើយ ក្នុងពាក្យជាដើមថា* **“អនិច្ចា វត សង្ខារា”** *ដូច្នេះ; សូម្បីក្នុងបដិលោមវារៈ ក៏មានន័យដូចគ្នានេះដែរ ៕*

ចប់បទសោធនវារៈ

## បទសោធនមូលចក្កវារៈ

ក្នុង ***បទសោធនមូលចក្កវារៈ*** ពាក្យបុច្ឆាថា **“ខន្ធា វេទនាខន្ធោ”** ដូច្នេះ រមែងត្រាស់សួរថា “ខន្ធទាំងឡាយណាមាន, ខន្ធទាំងឡាយនោះ ឈ្មោះថា ***វេទនាខន្ធ*** មិនមែនឬ ?” ត្រាស់តបថា “វេទនាខន្ធ ឈ្មោះថា ***ខន្ធផង*** ឈ្មោះថា ***វេទនាខន្ធផង***, តែខន្ធទាំងឡាយដ៏សេស ឈ្មោះថា ***ខន្ធប៉ុណ្ណោះ មិនឈ្មោះថា វេទនាខន្ធ*** ទេ” ដល់ពាក្យសួរនោះ; សូម្បីពាក្យសួរដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។

ក្នុង ***បដិលោម*** ត្រង់ពាក្យសួរថា **“ន ខន្ធា ន វេទនាខន្ធោ** = ធម៌ដែលមិនឈ្មោះថា ខន្ធ មិនឈ្មោះថា វេទនាខន្ធ តើដូចម្ដេច ?” នេះ បានដល់ ធម៌ទាំងឡាយណា ពោលគឺបញ្ញត្តិ និងនិព្វាននោះ មិនឈ្មោះថា ខន្ធទេ, ព្រោះបញ្ញត្តិ និងនិព្វាន មិនឈ្មោះថា ***វេទនាខន្ធ***, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់ថា **“អាមន្តា** = មែន” ; សូម្បីក្នុងពាក្យវិសជ្ជនាដ៏សេស ក៏មានន័យដោយប្រការដូច្នេះដែរ ៕

ចប់បទសោធនមូលចក្កវារៈ

## សុទ្ធក្ខន្ធវារៈ

ក្នុង ***សុទ្ធក្ខន្ធវារៈ*** ពាក្យសួរថា **“រូបំ ខន្ធោ** = ធម៌ដែលឈ្មោះថា រូប ឈ្មោះថា ខន្ធ តើដូចម្ដេច ?” រមែងត្រាស់សួរថា “រូបយ៉ាងណានីមួយ ដែលពោលថា ‘***រូប***’ រូបទាំងអស់នោះ ជាខន្ធឬ ?” ; ក្នុងពាក្យសួរនោះ ព្រោះរូប ពោលគឺ ***បិយរូប និងសាតរូបក្ដី ភូតរូប និងឧបាទាយរូបទាំងអស់ក្ដី*** ដល់ការសង្គ្រោះចូលក្នុងខន្ធ ៥ មែនពិត, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់តបថា **“អាមន្តា** = មែន” ។

ក្នុងទុតិយបទ គួរសួរថា ***“ខន្ធទាំងឡាយ ឈ្មោះថា រូប តើដូចម្ដេច ?”*** ព្រោះព្រះអង្គទ្រង់អធិប្បាយរូបក្ខន្ធទុកដោយពាក្យថា “រូប” ដូច្នេះហើយ, ព្រោះហេតុដូច្នោះ ទើបទ្រង់មិននឹកដល់ពាក្យ (នោះ) កាលបើត្រាស់សួរដោយអំណាចនៃអត្ថ ទើបត្រាស់ថា ***“ខន្ធទាំងឡាយ ឈ្មោះថា រូបក្ខន្ធ តើដូចម្ដេច ?”*** ។ គប្បីជ្រាបសេចក្ដីក្នុងបទទាំងពួង ដោយឧបាយនេះ; សូម្បីក្នុងនិទ្ទេសវារៈ នៃអាយតនយមកៈជាដើមខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។

សូម្បីក្នុងពាក្យសួរថា **“សញ្ញា សញ្ញាខន្ធោ** = ធម៌ដែលឈ្មោះថា សញ្ញា ឈ្មោះថា សញ្ញាខន្ធ តើដូចម្ដេច ?” នេះ, ***ទិដ្ឋិសញ្ញាក្ដី សញ្ញាក្ដី*** ព្រះអង្គត្រាស់ថា **“អាមន្តា** = មែន” ព្រោះសេចក្ដីនៃទិដ្ឋិសញ្ញា

និងសូម្បីសញ្ញាទាំងអស់ ក៏ជាខន្ធ ។

សូម្បីក្នុងបទថា “ **សង្ខារា សង្ខារក្ខន្ធោ** = សង្ខារ ឈ្មោះថា សង្ខារក្ខន្ធឬ ?” ក៏មានន័យដូចគ្នានេះដែរ; ឈ្មោះថា ***សង្ខារដែលផុតចាកភាពជាខន្ធ រមែងមិនមាន*** ។

ក្នុងបដិលោម ពាក្យសួរថា “**ន រូបំ ន ខន្ធោ** = ធម៌ដែលមិនឈ្មោះថា រូប មិនឈ្មោះថា ខន្ធ តើដូចម្តេច ?” ដូច្នេះ ព្រះមានព្រះភាគត្រាស់សួរថា “ធម្មជាតិណា មិនមែនរូប, ធម្មជាតិនោះ ក៏មិនមែនខន្ធ តើដូចម្តេច ?” ក៏ក្នុងវិសជ្ជនាបញ្ហានោះថា “**រូបំ ឋបេត្វា អវសេសា ខន្ធា ន រូបំ ខន្ធា** = វៀររូបចេញហើយ ខន្ធទាំងឡាយដ៏សេស មិនឈ្មោះថា រូប ឈ្មោះថា ខន្ធ” អធិប្បាយថា ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម ក្រៅអំពីរូប មិនឈ្មោះថា រូបឡើយ, តែឈ្មោះថា ***ខន្ធ*** ។

បទថា “**រូបញ្ច ខន្ធេ ច ឋបេត្វា អវសេសា** = វៀររូប និងខន្ធទាំងឡាយ ធម៌ដ៏សេស” បានដល់ ***បញ្ញត្តិ និងនិព្វានដែលផុតចាក ខន្ធ ៥;*** ក្នុងបទថា “**អវសេសា**” សូម្បីពួកដទៃអំពីបទនេះ ក៏មានន័យដូចគ្នាដោយប្រការដូច្នេះដែរ ។

ចប់សុទ្ធក្ខន្ធវារៈ

## សុទ្ធក្ខន្ធមូលចក្កវារៈ

សូម្បីក្នុង ***សុទ្ធក្ខន្ធមូលចក្កវារៈ*** ពាក្យសួរទាំងឡាយ មានពាក្យសួរថា **“រូបំ ខន្ធោ** = ធម៌ដែលឈ្មោះថា រូប ឈ្មោះថា ខន្ធ តើដូចម្ដេច ?” គប្បីជ្រាបសេចក្ដីដោយន័យដែលពោលហើយ ក្នុងកាលមុន ៕

**ចប់សុទ្ធក្ខន្ធមូលចក្កវារៈ**

**នៃបណ្ណត្តិវារៈ**

---

## ២.បវត្តិវារវណ្ណនា

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមបវត្តិវារៈ ដោយន័យជាដើមថា **“យស្ស រូបក្ខន្ធោ”** ; ***សួរថា*** ព្រោះហេតុអ្វី ទើបព្រះអង្គមិនទ្រង់ត្រាស់ខន្ធេសវារៈ ទុកក្នុងបវត្តិវារៈនេះ ? ឆ្លើយថា ព្រោះមានន័យតាមដែលទ្រង់សម្ដែងទុកហើយ ក្នុងកាលមុន; ក៏ន័យក្នុងខន្ធេសវារៈ ព្រះមានព្រះភាគទ្រង់សម្ដែងទុកហើយក្នុងបណ្ណត្តិវារៈ, ក៏ដោយន័យនោះ ទើបព្រះមានព្រះភាគ មិនត្រាស់ខន្ធេសវារៈនោះទេ ទ្រង់ផ្ដើមនិទ្ទេសវារៈតែម្យ៉ាង ព្រោះសូម្បីមិនត្រាស់ខន្ធេសវារៈទុកក្នុងបណ្ណត្តិវារៈនេះ ក៏ដោយ នរណាមួយក៏អាចជ្រាបបានដែរ ។

***ក៏អន្តរវារៈ ៣ គឺឧប្បាទវារៈ និរោធវារៈ និងឧប្បាទនិរោធវារៈ រមែងមានក្នុងមហាវារៈ ពោលគឺបវត្តិវារៈនេះ ។***

*ក្នុងវារៈទាំង ៣ នោះ វារៈទី ១ ហៅថា* ***ឧប្បាទវារៈ*** *ព្រោះសម្ដែងលក្ខណៈនៃការកើតឡើងរបស់ធម៌ទាំងឡាយ ។*

*វារៈទី ២ ហៅថា* ***និរោធវារៈ*** *ព្រោះសម្ដែងលក្ខណៈនៃការរលត់របស់ធម៌ទាំងឡាយនោះឯង ។*

*វារៈទី ៣ ហៅថា* ***ឧប្បាទនិរោធវារៈ*** *ព្រោះសម្ដែងលក្ខណៈនៃវារៈទាំង ២ ឡើងវិញ ។*

*ព្រះមានព្រះភាគទ្រង់សម្ដែងអាការនៃការកើតឡើង របស់ធម៌ទាំងឡាយ ក្នុងបវត្តិវារៈនេះ ដោយឧប្បាទវារៈ, ទ្រង់សម្ដែងសេចក្ដីមិនទៀងរបស់ធម៌ទាំងឡាយនោះឯង ដោយនិរោធវារៈថា* **“***ឈ្មោះថា ការកើតឡើង ឈ្មោះថា ទៀង រមែងមិនមាន***”** *, ទ្រង់សម្ដែងការកើតឡើង និងការមិនទៀងទាំងពីរនោះ ដោយឧប្បាទនិរោធវារៈ ។*

*ក្នុងឧប្បាទវារៈនោះ មានប្រភេទនៃកាល ៦ យ៉ាង ដោយអំណាចនៃអទ្ធា ៣ គឺបច្ចុប្បន្ន អតីត និងអនាគត, បច្ចុប្បន្ន និងអតីត, បច្ចុប្បន្ន និងអនាគត, ហើយអតីត និងអនាគត ។*

*ក្នុងកាលទាំងនោះ ពាក្យថា* **“យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** *= រូបក្ខន្ធ*

*កំពុងកើតដល់បុគ្គលណា”* គប្បីជ្រាបថា ***ជាបច្ចុប្បន្ន*** *ដោយអំណាចនៃការតាំងឈ្មោះដែលជាបច្ចុប្បន្ន, ក៏បច្ចុប្បន្ននោះ ព្រះអង្គត្រាស់ទុកមុនថា “បច្ចុប្បន្ននោះ ជាធម្មជាតិដែលបុគ្គលគប្បីដឹងដោយល្អ ហួសវិស័យនឹងប្រៀបធៀប” ព្រោះភាវៈនៃធម៌ទាំងឡាយ ដែលជាបច្ចុប្បន្ន បុគ្គលគប្បីកាន់យកបានដោយប្រចក្សច្បាស់ ។*

***អតីតកាល*** *គប្បីជ្រាបដោយអំណាចនៃការតាំងឈ្មោះ ដែលជាអតីតថា* **“យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ** *= រូបក្ខន្ធធ្លាប់កើត (កើតហើយ) ដល់បុគ្គលណា, ក៏អតីតនោះ លោកពោលទុកក្នុងលំដាប់ទីពីរ ព្រោះអតីតធម៌ធ្លាប់កើតឡើងហើយ ក្នុងកាលមុន ជាធម៌ដែលបុគ្គលគប្បីដឹងច្បាស់ដោយប្រចក្ស ល្អជាងអនាគត ដែលបុគ្គលគប្បីដឹងច្បាស់ដោយអនុមាន ។*

*គប្បីជ្រាប* ***អនាគតកាល*** *ដោយអំណាចនៃការតាំងឈ្មោះដែលជាអនាគតថា* **“យស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** *= រូបក្ខន្ធនឹងកើតឡើងដល់បុគ្គលណា” អនាគតកាលនោះ ពោលទុកក្នុងលំដាប់ទី ៣ ព្រោះកាន់យកថា ធម៌ទាំងឡាយយ៉ាងនេះ ជារូប នឹងកើតឡើងសូម្បីក្នុងអនាគត ដោយអំណាចនៃធម៌ដែលធ្លាប់កើតឡើងហើយ ដោយប្រចក្ស និងដោយធម៌ដែលកាន់យកហើយ ដោយអនុមាន (ទាញហេតុផលដោយវិចារណកិច្ច) ។*

*ពាក្យសួរថា* **“យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ**

**ឧប្បជ្ជិត្ថ"** គប្បីជ្រាបថា ជាបច្ចុប្បន្នជាមួយនឹងអតីត ដោយអំណាចនៃការតាំងឈ្មោះ ដែលជាបច្ចុប្បន្នជាមួយឈ្មោះដែលជាអតីត, បច្ចុប្បន្នជាមួយអតីត (បច្ចុប្បន្នាតីតវារៈ) នោះ ពោលទុកក្នុងលំដាប់ទី ៤ ព្រោះបច្ចុប្បន្ន និងអតីត បុគ្គលគប្បីដឹងច្បាស់បានងាយជាងកាលទាំង ៣ ដែលបញ្ចូលគ្នា ។

គប្បីជ្រាបបច្ចុប្បន្នជាមួយអនាគត ដោយអំណាចនៃឈ្មោះដែលជាបច្ចុប្បន្ន និងឈ្មោះដែលជាអនាគតថា **"យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាខន្ធោ ឧប្បជ្ជិស្សតិ"** ; បច្ចុប្បន្នជាមួយអនាគតនោះ ពោលទុកក្នុងលំដាប់ទី ៥ ព្រោះថា បច្ចុប្បន្នជាមួយអនាគតនោះ ជាកាលដែលបុគ្គលគប្បីដឹងបានងាយជាង ដោយសេចក្ដី ព្រោះធម៌ទាំងឡាយ ដែលគប្បីកាន់យកដោយប្រចក្សរមែងមាន ។

គប្បីជ្រាបអតីតជាមួយអនាគត ដោយអំណាចនៃការតាំងឈ្មោះដែលជាអនាគតជាមួយអតីតថា **"យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ, តស្ស វេទនាខន្ធោ ឧប្បជ្ជិស្សតិ"** ; អតីតជាមួយអនាគតនោះ គប្បីដឹងបានលំបាកជាងកាលទាំងឡាយមុនៗ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុងលំដាប់ទី ៦ ។

ក្នុងកាលទាំង ៦ នោះ បច្ចុប្បន្នកាលដែលជាកាលទី ១ មាន ៣

វារៈ គឺបុគ្គលវារៈ, ឱកាសវារៈ និងបុគ្គលោកាសវារៈ ។

ក្នុងវារៈទាំង ៣ នោះ ការសម្ដែងការកើតឡើងនៃខន្ធទាំងឡាយដោយអំណាចនៃបុគ្គល ដោយពាក្យថា **"យស្ស"** ឈ្មោះថា ***បុគ្គលវារៈ*** ។

ការសម្ដែងអំពីការកើតឡើងនៃខន្ធទាំងឡាយ ដោយអំណាចនៃឱកាសដោយពាក្យថា **"យត្ថ"** ឈ្មោះថា ***ឱកាសវារៈ*** ។

ការសម្ដែងអំពីការកើតឡើងនៃខន្ធទាំងឡាយ ដោយអំណាចនៃបុគ្គលនិងឱកាស ដោយពាក្យថា **"យស្ស យត្ថ"** ឈ្មោះថា ***បុគ្គលោកាសវារៈ*** ។

វារៈទាំង ៣ នោះ ព្រះអង្គទ្រង់សម្ដែងអនុលោមន័យមុនហើយទើបសម្ដែងបដិលោមន័យខាងក្រោយ; ក្នុងអនុលោមន័យ និងបដិលោម-ន័យ ការសម្ដែងអំពីការកើតឡើងដោយពាក្យថា " **ឧប្បជ្ជតិ** = រមែងកើត (កំពុងកើត) **ឧប្បជ្ជិត្ថ** = កើតហើយ (ធ្លាប់កើត) **ឧប្បជ្ជិស្សតិ** = នឹងកើត" ឈ្មោះថា អនុលោមន័យ, ការសម្ដែងនូវការមិនកើតឡើងដោយពាក្យថា **"នុប្បជ្ជតិ** = រមែងមិនកើត (ឬមិនកំពុងកើត) **នុប្បជ្ជិត្ថ** = មិនកើតហើយ (មិនធ្លាប់កើត) **នុប្បជ្ជិស្សតិ** = នឹងមិនកើត" ឈ្មោះថា ***បដិលោមន័យ*** ។

ក្នុងអនុលោមន័យនៃបុគ្គលវារៈ ក្នុងបច្ចុប្បន្នកាលនោះ មានយមកៈ ១០ យ៉ាង ព្រោះរាប់ហើយ មិនរាប់ទៀត (គឺរាប់ចំពោះតែមិន

*ដូចគ្នា) គឺយមកៈ ៤ ដែលមានរូបក្ខន្ធជាមូលយ៉ាងនេះថា ៖*

**“យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ; យស្ស វា បន វេទនាក្ខន្ធោ ឧប្បជ្ជតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** = *រូបក្ខន្ធរមែងកើតដល់បុគ្គលណា វេទនាខន្ធក៏កើតដល់បុគ្គលនោះឬ ?, ឬថាវេទនាខន្ធរមែងកើតដល់បុគ្គលណា រូបក្ខន្ធក៏កើតដល់បុគ្គលនោះឬ ?*

**យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាក្ខន្ធោ ឧប្បជ្ជតិ; យស្ស វា បន សញ្ញាក្ខន្ធោ ឧប្បជ្ជតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** = *រូបក្ខន្ធរមែងកើតដល់បុគ្គលណា, សញ្ញាខន្ធ ក៏កើតដល់បុគ្គលនោះឬ ?; ឬក៏សញ្ញាខន្ធ រមែងកើតដល់បុគ្គលណា, រូបក្ខន្ធ ក៏កើតដល់បុគ្គលនោះឬ ?*

**យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស សង្ខារក្ខន្ធោ ឧប្បជ្ជតិ; យស្ស វា បន សង្ខារក្ខន្ធោ ឧប្បជ្ជតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** = *រូបក្ខន្ធរមែងកើតដល់បុគ្គលណា, សង្ខារក្ខន្ធ ក៏កើតដល់បុគ្គលនោះឬ ? ឬក៏សង្ខារក្ខន្ធរមែងកើតដល់បុគ្គលណា រូបក្ខន្ធក៏កើតដល់បុគ្គលនោះឬ ?*

**យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វិញ្ញាណក្ខន្ធោ ឧប្បជ្ជតិ; យស្ស វា បន វិញ្ញាណក្ខន្ធោ ឧប្បជ្ជតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** = *រូបក្ខន្ធរមែងកើតដល់បុគ្គលណា, វិញ្ញាណក្ខន្ធ ក៏កើតដល់បុគ្គលនោះឬ ? ឬក៏វិញ្ញាណក្ខន្ធរមែងកើតដល់បុគ្គលណា, រូបក្ខន្ធ ក៏កើតដល់បុគ្គលនោះឬ?* ” ។

*យមកៈ ៣ យ៉ាង ដែលមានវេទនាខន្ធជាមូល ដោយន័យជាដើមថា* **“យស្ស វេទនាខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាខន្ធោ ឧប្បជ្ជតិ”** *យមកៈ ២ យ៉ាង មានសញ្ញាខន្ធជាមូលយមកៈម្យ៉ាង ដែលមានសង្ខារក្ខន្ធជាមូល ។*

*ក្នុងយមកៈទាំង ១០ យ៉ាងនោះ យមកៈ ៤ យ៉ាងដែលមានរូបក្ខន្ធជាមូល ព្រះអង្គទ្រង់វិសជ្ជនាយមកៈខាងដើមតែម្យ៉ាងប៉ុណ្ណោះ, យមកៈដ៏សេស (៣ ទៀត) មានការវិសជ្ជនាដូចគ្នានឹងយមកៈដើមនោះដែរ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគអង្គនោះ ទ្រង់សង្ខេបទុកដើម្បីងាយស្រួលដល់ភាសាដែលមានបែបដែន; សូម្បីក្នុងមូលទាំងឡាយមានវេទនាខន្ធជាមូលជាដើម ការវិសជ្ជនាមានតែមួយដូចគ្នា ដោយពាក្យថា* **“អាមន្តា** *= មែន”, ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់វិសជ្ជនា យមកៈ ១០ យ៉ាងហើយ ដោយការវិសជ្ជនាយមកៈមួយៗ ក្នុងអនុលោមន័យ ត្រង់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាលទាំងនេះ យ៉ាងនេះថា “យមកៈទាំងនោះ ទ្រង់សង្ខេបទុកដើម្បីងាយស្រួលដល់ភាសា ដែលមានបែបដែន” ។*

*ក្នុងអនុលោមន័យ ត្រង់វារៈទាំង ៣ ក្នុងបច្ចុប្បន្នកាលមានយមកៈ ៣០ យ៉ាង គឺក្នុងបុគ្គលវារៈ មាន ១០ យ៉ាង ក្នុងឱកាសវារៈ មាន ១០ យ៉ាង និងក្នុងបុគ្គលោកាសវារៈ មាន ១០ យ៉ាងណា, សូម្បីក្នុងបដិលោម-*

ន័យ ក៏មាន ៣០ យ៉ាងនោះដែរ ទើបរួមជាយមកៈ ៦០ យ៉ាង ក្នុងបច្ចុប្បន្នកាលទាំងអស់មែនពិត ។

ក្នុងយមកៈ ៦០ យ៉ាងនោះ គប្បីជ្រាបថា មានបុច្ឆា ១២០ មានអត្ថ ២៤០ ។

វារៈទាំង ៦ គប្បីជ្រាបថា "មានយមកៈ ៦០ ព្រោះធ្វើឲ្យជា ១០ ក្នុងវារៈមួយៗ រួមចូលគ្នានឹងយមកៈ ៣០០ ក្នុងពេលមុន ទើបត្រូវជាយមកៈ ៣៦០ បុច្ឆា ៧២០ អត្ថ ១៤៤០" ; នេះជាការកំណត់ព្រះបាលីក្នុងឧប្បាទវារៈមុន; ក៏ក្នុងឧប្បាទវារៈ យ៉ាងណា, គប្បីជ្រាបថា សូម្បីក្នុងនិរោធវារៈ សូម្បីក្នុងឧប្បាទនិរោធវារៈ ក៏យ៉ាងនោះដែរ; សូម្បីក្នុងបវត្តិមហាវារៈទាំងអស់ ទើបមានយមកៈ ១០៨០ បុច្ឆា ២១៦០ អត្ថ ៤៣២០ ។

តែព្រះបាលីក្នុងឧប្បាទវារៈ និងនិរោធវារៈ ព្រះមានព្រះភាគទ្រង់វិសជ្ជនាសង្ខេបទុកហើយ នូវយមកៈមួយៗ ប៉ុណ្ណោះ ក្នុងវារៈនោះៗ ត្រង់ប្រភេទនៃកាលដែលលាយចូលគ្នា ៣ យ៉ាង; ក្នុងប្រភេទនៃកាលដែលលាយបញ្ចូលគ្នា ៣ យ៉ាង ព្រះមានព្រះភាគទ្រង់វិសជ្ជនាយមកៈម្យ៉ាង សូម្បីក្នុងមូលដែលមានវេទនាខន្ធជាមូលជាដើម ដោយន័យជាដើមថា " **យស្ស វេទនាខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាខន្ធោ ឧប្បជ្ជិត្ថ** = វេទនាខន្ធ រមែង

កើតដល់បុគ្គលណា, សញ្ញាខន្ធធ្លាប់កើតដល់បុគ្គលនោះ មែនទេ ?” ។ សូម្បីក្នុងឧប្បាទនិរោធវារៈ ព្រះមានព្រះភាគ ក៏ទ្រង់វិសជ្ជនាយមកៈនោះ ទុកក្នុងប្រភេទនៃកាលទាំង ៦; គប្បីជ្រាបថា យមកៈដ៏សេស ទ្រង់សង្ខេបទុក ព្រោះយមកៈនោះ ព្រះអង្គទ្រង់វិសជ្ជនាឲ្យស្មើគ្នា ជាមួយនឹងយមកៈនោះ; នេះជាការកំណត់ព្រះបាលី សូម្បីក្នុងបវត្តិមហាវារៈទាំងអស់ ។

ក៏ដើម្បីវិនិច្ឆ័យអត្ថនៃខន្ធយមកៈនេះ គប្បីជ្រាបលក្ខណៈដូចតទៅនេះ

បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យអត្ថនៃបញ្ហា ៤ យ៉ាង ក្នុងបវត្តិមហាវារៈនេះ ដែលលោកដាក់ទុកក្នុងពាក្យវិសជ្ជនា ៥ យ៉ាង ក្នុងឋាន ២៧; ក្នុងអត្ថវិនិច្ឆ័យនោះ ឈ្មោះថា បញ្ហា ៤ យ៉ាង គឺ **បុរេបញ្ហា បច្ឆាបញ្ហា បរិបុណ្ណបញ្ហា** និង **មោឃបញ្ហា**; ក៏យមកៈមួយៗ មានបុច្ឆា ២ យ៉ាង (គឺអនុលោម និងបដិលោម), សូម្បីបុច្ឆាមួយៗ ក៏មានបទ ២ យ៉ាង (គឺសន្និដ្ឋាន និងសំសយៈ) ។

ក្នុងបញ្ហា ៤ យ៉ាងនោះ ការវិសជ្ជនានូវបញ្ហាណា រមែងមានការកើតឡើង ឬការរលត់ទៅនៃខន្ធដែលកាន់យកដោយបទតែមួយ, បញ្ហានេះ ឈ្មោះថា **បុរេបញ្ហា** ។

ក៏ក្នុងការវិសជ្ជនានូវបញ្ហាណា រមែងមានការកើតឡើង ឬការរលត់ទៅនៃខន្ធដែលកាន់យកដោយបទសូម្បីទាំង ២, បញ្ហានេះ ឈ្មោះថា

*បច្ឆាបញ្ហា* ។

កំក្នុងការវិសជ្ជនានូវបញ្ហាណា រមែងមានការកើតឡើង ឬការរលត់ទៅនៃខន្ធដែលកាន់យកហើយ ដោយបទត្រឹមតែមួយខ្វះ, ដោយបទសូម្បីទាំង ២ ខ្វះ, បញ្ហានេះ ឈ្មោះថា ***បរិបុណ្ណបញ្ហា***; តែការហាម ឬការបដិសេធន៍ រមែងមានវិសជ្ជនានូវបញ្ហាណា, បញ្ហានេះ ឈ្មោះថា ***មោឃ-បញ្ហា***; ក៏ព្រោះមោឃបញ្ហានេះ បើព្រះអង្គទ្រង់មិនសម្តែងទុក នរណាមួយក៏មិនអាចដឹងបាន, ព្រោះហេតុដូច្នោះ ទើបនឹងសម្តែងបញ្ហានោះទុក ។

ការកើតឡើងនៃវេទនាខន្ធ គឺលោកកាន់យកដោយបទត្រឹមតែម្យ៉ាងក្នុងការវិសជ្ជនានេះថា “**ឧប្បជ្ជតិ** = កំពុងកើត” ក្នុងពាក្យសួរថា “**យត្ថ រូបក្ខន្ធោ នុប្បជ្ជតិ, តត្ថ វេទនាខន្ធោ នុប្បជ្ជតិ** = រូបក្ខន្ធ មិនមែនកំពុងកើតក្នុងភូមិណា, វេទនាខន្ធមិនមែនកំពុងកើតក្នុងភូមិនោះឬ ?”, ព្រោះហេតុនោះ បញ្ហានេះផង បញ្ហាដទៃដែលមានសភាពយ៉ាងនេះផង គប្បីជ្រាបថា ***ជាបុរេបញ្ហា*** ។

ការកើតឡើងនៃរូប និងវេទនាខន្ធក្នុងអតីតរបស់សត្វណានីមួយ ដែលកាន់យកដោយបទទាំង ២ រមែងមានក្នុងការវិសជ្ជនានេះថា “**អាមន្តា** = មែន” ក្នុងបញ្ហាថា “**យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ, តស្ស វេទនាខន្ធោ ឧប្បជ្ជិត្ថ** = រូបក្ខន្ធធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធ ក៏ធ្លាប់កើតហើយ

*ដល់បុគ្គលនោះឬ ?", ព្រោះហេតុនោះ បញ្ហានេះ និងបញ្ហាដទៃ ដែលមានសភាពយ៉ាងនេះ ឈ្មោះថា* ***បច្ឆាបញ្ហា*** *។*

*ក៏សូម្បីការកើតឡើងនៃរូបក្ខន្ធ ដែលកាន់យកហើយដោយបទត្រឹមតែម្យ៉ាង រមែងមានក្នុងបុរិមកោដ្ឋាសៈនេះថា* **"អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ, នោ ច តេសំ វេទនាក្ខន្ធោ ឧប្បជ្ជតិ** *= កាលបើបុគ្គលទាំងនោះ កំពុងកើតក្នុងអសញ្ញសត្តភូមិ រូបក្ខន្ធ ក៏កំពុងកើត, តែវេទនាខន្ធ មិនមែនកំពុងកើតដល់បុគ្គលទាំងនោះទេ" ; ក្នុងការវិសជ្ជនានេះ មានជាដើមថា* **"អសញ្ញសត្តំ ឧបបជ្ជន្តានំ"** *ក្នុងបញ្ហាដំបូងនេះថា* **"យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ** *= រូបក្ខន្ធកំពុងកើតដល់បុគ្គលណា វេទនាខន្ធ ក៏កំពុងកើតដល់បុគ្គលនោះឬ?" ។*

*សូម្បីការកើតឡើងនៃរូប និងវេទនាខន្ធដែលកាន់យកហើយ សូម្បីដោយបទទាំង ២ រមែងមានក្នុងបច្ឆិមកោដ្ឋាសៈនេះថា* **"បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ រូបក្ខន្ធោ ច ឧប្បជ្ជតិ, វេទនាក្ខន្ធោ ច ឧប្បជ្ជតិ** *= កាលបុគ្គលទាំងឡាយនោះ កំពុងកើតក្នុងបញ្ចវោការភូមិ រូបក្ខន្ធ ក៏កំពុងកើត, វេទនាខន្ធ ក៏កំពុងកើត" , ព្រោះហេតុដូច្នោះ បញ្ហានេះ និងបញ្ហាដទៃ ដែលមាន សភាពយ៉ាងនេះ គប្បីជ្រាបថាជា* ***បរិបុណ្ណបញ្ហា****; សូម្បីពាក្យថា* ***"បុរេបច្ឆា បញ្ហា"*** *ក៏ជាឈ្មោះរបស់បរិបុណ្ណបញ្ហានេះដែរ ។*

ក៏ក្នុងការវិសជ្ជនាបរិបុណ្ណបញ្ហានេះ ព្រះមានព្រះភាគទ្រង់សម្តែងការកើតឡើងនៃរូបក្ខន្ធនោះឯង ដែលសង្គ្រោះទុកដោយបទតែមួយ ក្នុងបុរិម-កោដ្ឋាសៈ; ក្នុងទុតិយកោដ្ឋាសៈ ការកើតឡើង និងការរលត់ទៅនៃខន្ធដែលកាន់យកហើយដោយបទតែមួយ រមែងមានក្នុងបញ្ហាណា ដោយន័យ និងលក្ខណៈនេះ នៃរូប និងវេទនាខន្ធដែលកាន់យកដោយបទទាំង ២ បញ្ហានោះ ហៅថា ***បុរេបញ្ហា*** ។

ការកើតឡើង ឬការរលត់ទៅរបស់ខន្ធទាំងឡាយ ដែលកាន់យកដោយបទទាំង ២ រមែងមានក្នុងបញ្ហាណា, បញ្ហានោះ ហៅថា ***បច្ឆាបញ្ហា*** ។

***បដិក្ខេបវិសជ្ជនា*** រមែងមានក្នុងការវិសជ្ជនានេះ ដោយពាក្យថា **“នត្ថិ** = មិនមាន” ក្នុងបញ្ហានេះថា **“យស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស វេទនាខន្ធោ នុប្បជ្ជិត្ថ** = រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ ?” ។

***បដិសេធវិសជ្ជនា*** រមែងមានក្នុងការវិសជ្ជនានេះ ដោយពាក្យថា **“នោ** = មិនមែន” ក្នុងពាក្យសួរថា **“យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាខន្ធោ និរុជ្ឈតិ** = រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធ ក៏កំពុងរលត់ដល់បុគ្គលនោះឬ ?”; ព្រោះហេតុនោះ បញ្ហានេះ និងបញ្ហាដទៃ ដែលមានសភាពយ៉ាងនេះ រួមជា ២ យ៉ាង គប្បីជ្រាបថាជា

***មោឃបញ្ហា***; សូម្បីមោឃបញ្ហានេះ ហៅថា ឆេទតុច្ចបញ្ហា ក៏បាន; គប្បីជ្រាបបញ្ហាទាំង ៤ យ៉ាងនេះជាមុនសិន ។

ក៏វិសជ្ជនាទាំងនេះ ***គឺបាលិគតិវិសជ្ជនា បដិវចនវិសជ្ជនា សរូបទស្សនវិសជ្ជនា បដិក្ខេបវិសជ្ជនា*** និង ***បដិសេធវិសជ្ជនា*** ឈ្មោះថា វិសជ្ជនា ៥ យ៉ាង; ក្នុងវិសជ្ជនា ៥ យ៉ាងនោះ វិសជ្ជនាណា ជាបាលីបទ (របៀបបាលី) ប៉ុណ្ណោះ គឺលោកវិសជ្ជនានូវអត្ថទុក, វិសជ្ជនានេះ ឈ្មោះថា ***បាលិគតិវិសជ្ជនា***, បាលិគតិវិសជ្ជនានេះ រមែងមានក្នុងបុរេបញ្ហា; វិសជ្ជនានេះថា **ឧប្បជ្ជតិ** = កំពុងកើត ក្នុងបញ្ហាថា “ **យត្ថ រូបក្ខន្ធោ នុប្បជ្ជតិ, តត្ថ វេទនាខន្ធោ នុប្បជ្ជតិ** = រូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិណា, វេទនាខន្ធ ក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ ?” ជាបទត្រឹមតែព្រះបាលីដែលព្រះអង្គទ្រង់វិសជ្ជនាអត្ថទុកល្អហើយ, ព្រោះហេតុដូច្នោះ គប្បីជ្រាបការវិសជ្ជនា ដោយបាលិគតិវិសជ្ជនាក្នុងឋានយ៉ាងនេះចុះ ។

ក៏វិសជ្ជនាណាដែលលោកដោះស្រាយអត្ថ ដោយសេចក្ដីជាពាក្យឆ្លើយ, វិសជ្ជនានេះ ឈ្មោះថា បដិវចនវិសជ្ជនា, បដិវចនវិសជ្ជនានេះ រមែងមានក្នុងបច្ឆាបញ្ហា; ក៏វិសជ្ជនានេះ ដោយពាក្យថា “ **អាមន្តា** = មែន” ក្នុងបញ្ហាថា “ **យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ, តស្ស វេទនាខន្ធោ ឧប្បជ្ជិត្ថ** = រូបក្ខន្ធធ្លាប់កើតដល់បុគ្គលណា វេទនាខន្ធ ក៏ធ្លាប់កើតដល់

បុគ្គលនោះឬ ?" ដែលព្រះអង្គទ្រង់វិសជ្ជនាអត្ថទុកល្អហើយ ដោយអំណាចនៃការឆ្លើយនោះឯង, ព្រោះហេតុដូច្នោះ គប្បីជ្រាបបដិវចនវិសជ្ជនាក្នុងឋានដូច្នេះ ។

ពាក្យវិសជ្ជនាណា ដែលលោកសម្តែងអត្ថទុកដោយសរុប, វិសជ្ជនានេះ ឈ្មោះថា ***សរូបទស្សនវិសជ្ជនា***, សរូបទស្សនវិសជ្ជនានេះ រមែងមានក្នុង ***បរិបុណ្ណបញ្ហា*** ។

ក៏វិសជ្ជនាថា **" អសញ្ញសត្តំ ឧបបជ្ជន្តានំ "** ក្នុងបញ្ហាថា **" យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាខន្ធោ ឧប្បជ្ជតិ "** នេះ គឺព្រះអង្គទ្រង់វិសជ្ជនាអត្ថទុកល្អហើយ ដោយការសម្តែងជាសរុបថា "រូបក្ខន្ធរមែងកើតដល់បុគ្គលទាំងនេះ, តែវេទនាខន្ធមិនកើតទេ, រូបក្ខន្ធ និងវេទនាខន្ធ ក៏រមែងកើតដល់បុគ្គលទាំងនេះ" , ព្រោះហេតុនោះ គប្បីជ្រាប ***សរូបទស្សន-វិសជ្ជនា*** ក្នុងទីទាំងឡាយដូច្នេះ ។

ក៏ពាក្យវិសជ្ជនាណាដែលលោកវិសជ្ជនាបញ្ហា ដោយការហាមអត្ថព្រោះការមិនមានអត្ថដូច្នោះ, ពាក្យវិសជ្ជនានោះ ឈ្មោះថា ***បដិក្ខេប-វិសជ្ជនា*** ។

វិសជ្ជនាណាដែលលោកវិសជ្ជនាបញ្ហា ដោយបដិសេធអត្ថ ព្រោះការមិនមាននូវអត្ថដូច្នោះ ក្នុងខណៈមួយៗ, វិសជ្ជនានេះ ឈ្មោះថា

បដិសេធវិសជ្ជនា, បដិសេធវិសជ្ជនានោះ រមែងមានក្នុងមោឃបញ្ហា ។

មែនពិត ពាក្យវិសជ្ជនានេះថា “**នត្ថិ** = មិនមាន” ក្នុងបញ្ហាថា “**យស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថ** = រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធ ក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ ?” ជាពាក្យវិសជ្ជនាដែលលោកដោះស្រាយទុកល្អហើយ ដោយការហាមអត្ថថា ឈ្មោះថា សត្វដូច្នេះ រមែងមិនមាន, ព្រោះហេតុដូច្នោះ គប្បីជ្រាបការវិសជ្ជនាក្នុងទីទាំងពួង ***ដោយបដិក្ខេបវិសជ្ជនា*** ។

ក៏ពាក្យវិសជ្ជនានេះថា “**នោ** = មិនមែន” ក្នុងបញ្ហាថា “**យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈតិ** = រូបក្ខន្ធរមែងកើតដល់បុគ្គលណា, វេទនាខន្ធរមែងរលត់ដល់បុគ្គលនោះឬ ?” គឺលោកវិសជ្ជនាទុកល្អហើយ ដោយការបដិសេធអត្ថថា ឈ្មោះថា ការរលត់ទៅព្រមជាមួយនឹងការកើតឡើង រមែងមិនមានក្នុងបដិសន្ធិខណៈមួយៗ, ព្រោះហេតុដូច្នោះ គប្បីជ្រាបវិសជ្ជនាដោយការបដិសេធក្នុងឋានមានសភាពបែបនេះ ។

ឥឡូវនេះ គប្បីជ្រាបបញ្ហា ៤ យ៉ាង និងវិសជ្ជនា ៥ យ៉ាង ដែលគួរដាក់ទុកក្នុងឋាន ២៧ ពួកណា, គប្បីជ្រាបឋានទាំងនោះ យ៉ាងនេះ គឺ ៖

-អសញ្ញសត្តំ ឧប្បជ្ជន្តានំ ១ ឋាន -អសញ្ញសត្តេ ឥត្ថ ១ ឋាន

-អសញ្ញសត្តានំ ១ ឋាន -អសញ្ញសត្តា ច ឥន្តានំ ១ ឋាន

-អរូបំ ឧប្បជ្ជន្តានំ ១ ឋាន -អរូបេ ឥត្ថ ១ ឋាន

-អរូបានំ ១ ឋាន -អរូបា ច ឥន្តានំ ១ ឋាន

-អរូបេ បច្ឆិមភវិកានំ ១ ឋាន

-អរូបេ បរិនិព្វាយន្តានំ *(បាលី* * *ប្រើជា បរិនិព្វុត្តានំ)* ១ ឋាន

-យេ ច អរូបំ ឧប្បជ្ជិត្វា បរិនិព្វាយិស្សន្តិ ១ ឋាន

-បញ្ចវោការំ ឧប្បជ្ជន្តានំ ១ ឋាន -បញ្ចវោការេ ឥត្ថ ១ ឋាន

-បញ្ចវោការានំ ១ ឋាន -បញ្ចវោការា ច ឥន្តានំ ១ ឋាន

-បញ្ចវោការេ បច្ឆិមភវិកានំ ១ ឋាន -បញ្ចវោការេ បរិនិព្វាយន្តានំ ១ ឋាន

-សុទ្ធាវាសំ ឧប្បជ្ជន្តានំ ១ ឋាន -សុទ្ធាវាសេ ឥត្ថ ១ ឋាន

-សុទ្ធាវាសានំ ១ ឋាន -សុទ្ធាវាសេ បរិនិព្វាយន្តានំ ១ ឋាន

-សព្វេសំ ឧប្បជ្ជន្តានំ ១ ឋាន -សព្វេសំ ច ឥន្តានំ ១ ឋាន

-បច្ឆិមភវិកានំ *ដោយសាធារណៈដល់សត្វទាំងពួង* ១ ឋានទៀត

-បរិនិព្វាយន្តានំ *(បាលីប្រើជាបរិនិព្វុត្តានំ)* ១ ឋាន

-ចតុវោការំ បញ្ចវោការំ ឧប្បជ្ជន្តានំ ១ ឋាន

---

* ពាក្យថា បាលីនេះ សំដៅដល់ព្រះអភិធម្មបិដក ។

**-ចក្ខុទ្វារភាវ បញ្ចទ្វារភាវ ច ទន្ធានំ** ១ ឋាន ។

បណ្ឌិតគប្បីដាក់ពាក្យវិសជ្ជនា ៥ យ៉ាង ទុកក្នុងឋានទាំង ២៧ នេះហើយ គប្បីជ្រាបការវិនិច្ឆ័យអត្ថនៃបញ្ហា ៤ យ៉ាង ក្នុងបវត្តិ-មហាវារៈ ដោយប្រការដូច្នេះ; ក៏អត្ថវិនិច្ឆ័យនោះ ដែលបណ្ឌិតជ្រាបហើយយ៉ាងនេះ កាលបើវិសជ្ជនាបញ្ហា រមែងជាការវិសជ្ជនាហើយដោយស្រួល, និងកាលបើវិនិច្ឆ័យនូវអត្ថ រមែងជាការវិនិច្ឆ័យហើយដោយងាយ ។

ន័យថា **"យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** = រូបក្ខន្ធរមែងកើតដល់បុគ្គលណា" នេះ បានដល់ រមែងសួរថា រូបក្ខន្ធកំពុងកើតក្នុងឧប្បាទក្ខណ-សមង្គីដល់បុគ្គលណា វេទនាក៏កំពុងកើតដល់បុគ្គលនោះឬ ?; ព្រោះហេតុនោះ សូម្បីវេទនាខន្ធ ក៏កំពុងកើតដល់បុគ្គលនោះ ក្នុងខណៈនោះឯង; ពីរបទថា **"អសញ្ញសត្តំ ឧប្បជ្ជន្តានំ"** បានដល់ កាលបុគ្គលទាំងនោះ កើតក្នុងអសញ្ញសត្តភពដោយអំណាចនៃបដិសន្ធិដែលមិនមែនចិត្ត; បទថា **"តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ"** បានដល់ រូបក្ខន្ធតែមួយប៉ុណ្ណោះ កំពុងកើតដល់អសញ្ញសត្តនោះ; ក៏រូបក្ខន្ធរបស់អសញ្ញសត្តដែលកើតហើយក្នុងបវត្តិកាល រមែងកើតខ្លះ រលត់ខ្លះ, ព្រោះហេតុនោះ ទើបមិនត្រាស់ថា **"អសញ្ញ-**

**សត្តានំ** = *កំពុងកើត*[*] *ក្នុងអសញ្ញសត្តភូមិ” តែត្រាស់ថា* “**អសញ្ញ-សត្តំ ឧប្បជ្ជន្តានំ** = *រមែងកើត គឺកំពុងកើតក្នុងអសញ្ញសត្តភូមិ” ; ច្រើនបទថា* “**នោ ច តេសំ វេទនាខន្ធោ ឧប្បជ្ជតិ** = *តែវេទនាខន្ធ រមែងមិនកើតដល់បុគ្គលទាំងនោះ” បានដល់ វេទនាខន្ធរបស់អសញ្ញសត្វទាំងនោះ មិនមែនកំពុងកើតឡើយ ព្រោះភាវៈនៃអសញ្ញសត្វនោះ មិនមានចិត្ត នេះជាការវិសជ្ជនាដោយការសម្តែងសរុបក្នុងបុរិមកោដ្ឋាសៈ នៃបរិបុណ្ណបញ្ហា ត្រង់ឋានទី ១ ក្នុងឋានទាំង ២៧ យ៉ាង ។*

*ពីរបទថា* “**បញ្ចវោការំ ឧប្បជ្ជន្តានំ** = *កំពុងកើតក្នុងបញ្ចវោ-ការភូមិ” បានដល់ ចូលដល់បញ្ចវោការភពដោយអំណាចនៃការបដិសន្ធិ ដែលរួមដោយរូប និងអរូប; ច្រើនបទថា* “**តេសំ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាខន្ធោ ច ឧប្បជ្ជតិ** = *រូបក្ខន្ធផង វេទនាខន្ធផង រមែងកើតដល់បុគ្គលទាំងនោះ” បានដល់ សូម្បីខន្ធ ២ ពោលគឺរូប និងវេទនា រមែងកើតឡើងដល់សត្វទាំងឡាយ ដែលចូលដល់បញ្ចវោការភពទាំងនោះ ដោយពិត, តែថា ក្នុងបវត្តិកាល ខន្ធទាំង ២ នោះ រមែងកើតឡើងខ្លះ រលត់ខ្លះ*

---

[*] ពាក្យថា កំពុងកើត សំដៅការកំពុងកើត និងកំពុងស្លាប់, ពាក្យថា **អសញ្ញសត្តានំ** ក្នុងយមកៈនេះ ទើបមានសេចក្តីសម្គាល់ថា កំពុងកើត និងកំពុងស្លាប់ ។

ដល់សត្វដែលកើតឡើងហើយ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា **"បញ្ចវោការានំ** = កើតក្នុងបញ្ចវោការភូមិ" តែត្រាស់ថា **"បញ្ចវោការំ ឧប្បជ្ជន្តានំ** = កំពុងកើតក្នុងបញ្ចវោការភូមិ" ; នេះជាការវិសជ្ជនា ដោយសម្ដែងសរុបក្នុងបច្ឆិមកោដ្ឋាសៈនៃបរិបុណ្ណបញ្ហា ក្នុងឋានថា **"បញ្ចវោការំ ឧប្បជ្ជន្តានំ"** គប្បីជ្រាបការវិសជ្ជនាទាំងអស់ ដោយឧបាយនេះ; ក៏នេះជានិយមលក្ខណៈក្នុងការកើត និងរលត់នេះ ៖

ក៏ក្នុងខន្ធយមកៈនេះ សូម្បីទាំងអស់ ព្រះមានព្រះភាគទ្រង់សម្ដែងឧប្បាទវារៈទុក ដោយអំណាចនៃការកើតឡើងក្នុងបដិសន្ធិកាលនោះឯងថា "ការមិនស្ទាបអង្អែល (គឺទ្រង់មិនសម្ដែង) នូវការកើត និងរលត់ក្នុងបវត្តិកាលថា 'ក៏ក្នុងខន្ធយមកៈនេះ សូម្បីទាំងអស់ កាលសត្វទាំងឡាយកើតឡើងហើយ ក្នុងបញ្ចវោការភពនោះៗ ការកើតឡើង និងរលត់ដែលមិនមានទីបំផុតនៃខន្ធ ៥ សូម្បីមានក្នុងបវត្តិកាលរហូតទៅទល់គ្នានឹងស្លាប់ ការវែកញែកធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅយ៉ាងរហ័ស ដើម្បីសម្ដែងការកើត និងរលត់ មិនមែនធ្វើបានដោយងាយទេ" ដូច្នេះ ហើយទើបទ្រង់សម្ដែងការកើតឡើងនៃខន្ធទាំងឡាយ ក្នុងបដិសន្ធិរបស់សត្វ ដែលកើតហើយផ្សេងៗ ដែលញុំាងវិបាកវដ្តៈថ្មីៗ ឲ្យសម្រេចបានដោយស្រួល ព្រះមានព្រះភាគត្រាស់និរោធវារៈ ដោយអំណាចនៃការរលត់ក្នុងមរណកាល

ថា “ក៏ការសម្តែងការរលត់ ក្នុងកាលជាទីបំផុតនៃវិបាកវដ្តៈដែលកើតឡើង ហើយ ជាការធ្វើបានងាយ” ; ក៏ការមិនស្អាបអង្អែលការកើត និងរលត់ក្នុងបវត្តិកាលនេះ ជាប្រមាណដូចម្តេចទៅ ? នុ៎ះឯង គឺព្រះបាលី ។

ម្យ៉ាងទៀត ព្រះបាលីថា “**បច្ឆិមភវិកានំ តេសំ រូបក្ខន្ធោ ច នុប្បជ្ជតិ វេទនាក្ខន្ធោ ច នុប្បជ្ជិស្សតិ** = រូបក្ខន្ធ ក៏រមែងមិនកើត វេទនាខន្ធ ក៏នឹងមិនកើតដល់បច្ឆិមភវិកបុគ្គលទាំងនោះ” នេះជាប្រមាណក្រៃលែង ក្នុងវារៈនៃអនាគតកាលរបស់ឧប្បាទវារៈដោយពិសេស ក្នុងព្រះបាលី; កាលវារៈដែលសមគួរដល់ការកើតឡើងនៃរូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងបវត្តិកាលរបស់បច្ឆិមភវិកបុគ្គល សូម្បីមានការកើតឡើងក្នុងបវត្តិកាល គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនកាន់យកដោយភាវៈដែលពោលហើយ ទើបទ្រង់ធ្វើការសន្និដ្ឋានថា “**រូបក្ខន្ធោ ច នុប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច នុប្បជ្ជិស្សតិ** = រូបក្ខន្ធ ក៏នឹងមិនកើត វេទនា ក៏នឹងមិនកើត” ; ក៏ព្រះបាលីនេះថា “**សុទ្ធាវាសេ បរិនិព្វន្តានំ** = កំពុងបរិនិព្វានក្នុងសុទ្ធាវាស” ដូច្នេះ ជាប្រមាណក្រៃលែង ក្នុងការមិនពាល់ត្រូវនូវការរលត់ក្នុងបវត្តិកាល ក៏គន្លងនៃការរាប់នូវសញ្ញាខន្ធទាំងឡាយ ដែលរលត់ទៅហើយ ព្រោះកើតឡើងហើយក្នុងបវត្តិកាល ចាប់តាំងអំពីបដិសន្ធិកាល ដែលតាំងនៅក្នុងភវង្គខណៈ នៃចុតិចិត្តរបស់បរិនិព្វុតបុគ្គល

*ក្នុងសុទ្ធាវាស រមែងមិនមានទេ កាលបើដូច្នេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនកាន់យកការរលត់ក្នុងបវត្តិកាល ដោយភាវៈដែលពោលហើយ ទើបទ្រង់ធ្វើការសន្និដ្ឋានថា* **“តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** *= សញ្ញាខន្ធមិនរលត់ហើយ (គឺមិនធ្លាប់រលត់) ដល់បុគ្គលទាំងនោះ ក្នុងភូមិនោះ”* ។

*បណ្ឌិតនៅពេលជ្រាបលក្ខណៈពិតប្រាកដ ក្នុងការកើតឡើង និងការរលត់ទៅនេះហើយ គួរកាន់យកការកើតឡើងដោយបដិសន្ធិកាល និងការរលត់ដោយចុតិកាលប៉ុណ្ណោះ ហើយគប្បីជ្រាបវិនិច្ឆ័យអត្ថនៃការវិសជ្ជនាទាំងឡាយ ដែលមានមកហើយក្នុងឋានទាំងឡាយនោះៗ ដោយប្រការដូច្នេះ; ប៉ុន្តែ ការវិនិច្ឆ័យអត្ថនោះ លោកមិនធ្វើឲ្យពិស្តារឡើយ ដោយលំដាប់នៃការវិសជ្ជនាថា ការវិនិច្ឆ័យអត្ថនោះ នរណាមួយ ក៏អាចជ្រាបបាន ដោយន័យដែលពោលទុកហើយក្នុងការវិសជ្ជនាដំបូង; បើបុគ្គលណាមិនអាចនឹងជ្រាបការវិនិច្ឆ័យអត្ថទាំងនោះ, បុគ្គលនោះ គប្បីចូលទៅអង្គុយជិតអាចារ្យ ស្តាប់ដោយល្អហើយ គប្បីជ្រាបតាមន័យដែលអាចារ្យឲ្យហើយយ៉ាងនេះចុះ* ។

***យមកៈទាំងឡាយណា ក្នុងខន្ធ ៥ រមែងមានដោយអំណាចនៃឧប្បាទវារៈ, និរោធវារៈ, ឧប្បាទវារៈ និងនិរោធវារៈទាំងពីររួមគ្នា ដោយ***

*អំណាចនៃអនុលោមន័យ និងបដិលោមន័យ, ព្រះជិនស្រីជាម្ចាស់ ត្រាស់ហើយនូវយមកៈទាំងនោះ ក្នុងវារៈទាំងឡាយ ក្នុងបវត្តិកាល ព្រោះទ្រង់សម្តែងហើយនូវបុគ្គលវារៈ, ឱកាសវារៈ និងបុគ្គលោកាសវារៈ ការកំណត់ព្រះបាលីទាំងនោះ ព្រះមានព្រះភាគទ្រង់សម្តែងហើយដោយលំដាប់ សូម្បីការប្រកបអត្ថដើម្បីវិសជ្ជនាបញ្ហា ព្រមទាំងវិសជ្ជនានូវឋានទាំងឡាយ នៃការវិសជ្ជនាយ៉ាងណាមួយ ដោយប្រការទាំងពួង; ព្រះមានព្រះភាគទ្រង់សម្តែងហើយ ទ្រង់ប្រកាសហើយក្នុងបញ្ហាមួយៗ ក្នុងលំដាប់នៃការវិសជ្ជនាបញ្ហាក្នុងបវត្តិមហាវារៈនេះ ប្រព្រឹត្តទៅហើយដោយពិស្តារ; ព្រោះហេតុដូច្នោះបណ្ឌិតទាំងឡាយ គប្បីជ្រាបអត្ថដោយន័យនេះថា ខាងមុខ អំពីនេះទៅនរណាហ្ន៎ អាចនឹងពណ៌នានូវអត្ថនេះបាន ៕*

ចប់បវត្តិមហាវារៈ

## ៣.បរិញ្ញាវារវណ្ណនា

*សូម្បីក្នុងបរិញ្ញាវារៈ ដែលមានក្នុងលំដាប់តអំពីបវត្តិមហាវារៈនោះ មានប្រភេទនៃកាល ៦ យ៉ាងប៉ុណ្ណោះ, មានន័យ ២ យ៉ាង ដោយអនុលោមនិងបដិលោម, តែក្នុងវារៈទាំង ៣ គឺបុគ្គលវារៈ ឱកាសវារៈ និងបុគ្គលោកាសវារៈ រមែងបានតែបុគ្គលវារៈប៉ុណ្ណោះ, មិនមានវារៈក្រៅពីនេះទេ ។*

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះមានពាក្យវិសជ្ជនាតែមួយដូចគ្នា ។*

*បើបុគ្គលណាមួយ ដឹងរូបក្ខន្ធក្នុងទីណាមួយមែន, ក៏រមែងដឹងសូម្បីនូវវេទនាខន្ធ; បើដឹងនូវវេទនាខន្ធមែន, ក៏រមែងដឹងនូវរូបក្ខន្ធដែរ; បើបុគ្គលណាមិនដឹងរូបក្ខន្ធទេ, ក៏រមែងមិនដឹងសូម្បីនូវវេទនាខន្ធដែរ; បើមិនដឹងនូវវេទនាខន្ធ, ក៏រមែងមិនដឹងសូម្បីនូវរូបក្ខន្ធដែរ; ព្រោះហេតុដូច្នោះ សូម្បីក្នុងវារៈទាំងនោះ គប្បីជ្រាបថា រមែងមិនមានវារៈទាំង ២ នោះ ក្នុងបរិញ្ញាវារៈនេះទេ ព្រោះមានពាក្យវិសជ្ជនាដូចគ្នាថា “បុគ្គលគប្បីសួរដោយអំណាចនៃពាក្យជាបុច្ឆាជាដើមថា* **យត្ថ រូបក្ខន្ធំ បរិជានាតិ តត្ថ វេទនាខន្ធំ បរិជានាតិ’** *ដូច្នេះហើយ គប្បីវិសជ្ជនាថា* **‘អាមន្តា** *= មែន” នុ៎ះឯង ។*

*ម្យ៉ាងទៀត* ***បុគ្គលវារៈ*** *ព្រះមានព្រះភាគទ្រង់សម្តែងហើយ ក្នុងបរិញ្ញាវារៈនេះថា ឈ្មោះថា បរិញ្ញាកិច្ច រមែងមានដល់បុគ្គលប៉ុណ្ណោះ, មិនមានដល់* ***ឱកាស,*** *បុគ្គលប៉ុណ្ណោះ អាចដើម្បីដឹង, មិនមែន* ***ឱកាស*** *ទេ ព្រោះហេតុនោះ ទើបទ្រង់មិនកាន់យក* ***ឱកាសវារៈ;*** *ក៏ព្រោះព្រះមានព្រះភាគទ្រង់មិនកាន់យកឱកាសវារៈនោះទេ,* ***បុគ្គលោកាសវារៈ*** *ដែលមានក្នុងលំដាប់នៃ* ***ឱកាសវារៈ*** *នោះ សូម្បីបាន ក៏ទ្រង់មិនកាន់យក;*

ក៏ ***បុគ្គលវារៈ*** នេះ ទ្រង់បានកាន់យកហើយក្នុងបច្ចុប្បន្នកាល យមកៈ ១០ យ៉ាង ដោយការកាន់យកទៀត ក្នុងអនុលោមន័យ ដោយន័យដែលពោលហើយក្នុងពេលមុនថា យមកៈដែលមានរូបក្ខន្ធជាមូល ៤, វេទនាខន្ធជាមូល ៣, សញ្ញាខន្ធ ជា មូល ២, សង្ខារក្ខន្ធជាមូល ១ ក្នុងបដិលោមន័យ ១០ ទៀត ទើបរួមត្រូវជាយមកៈ ២០, សូម្បីក្នុងកាលដ៏សេស ក៏ដូចគ្នាដែរ ព្រោះហេតុដូច្នោះ គប្បីជ្រាបការកំណត់ព្រះបាលីក្នុងបរិញ្ញាវារៈនេះថា យមកៈ ១២០ បុច្ឆា ២៤០ អត្ថ ៤៨០ រមែងមានក្នុងកាលទាំង ៦ ព្រោះធ្វើកាលមួយៗ ឲ្យជា ២០ ។

ក៏ការវិនិច្ឆ័យអត្ថក្នុងបរិញ្ញាវារៈនេះ អទ្ធា ៣ គឺអតីត អនាគត និងបច្ចុប្បន្ន រមែងមិនមានដោយអំណាចនៃចុតិ និងបដិសន្ធិ ដូចគ្នានឹងបវត្តិវារៈ, តែរមែងមានដោយអំណាចនៃខណៈចិត្តក្នុងបវត្តិប៉ុណ្ណោះ; ព្រោះហេតុនោះ ក្នុងបរិញ្ញាវារៈនេះ ទើបលោកធ្វើការវិសជ្ជនាថា " មែន" ក្នុងពាក្យសួរ ទាំងឡាយជាដើមថា "បុគ្គលណាកំពុងដឹងនូវរូបក្ខន្ធ បុគ្គលនោះ ក៏កំពុងដឹងនូវវេទនាខន្ធឬ ?" បុគ្គលដឹងនូវខន្ធណាមួយ ក្នុងខន្ធ ៥ ព្រោះញុំាំងបរិញ្ញាកិច្ចឲ្យសម្រេច ដោយកិច្ចដែលមាននិព្វានជាអារម្មណ៍ ក្នុងលោកុត្តរមគ្គ ទើបពោលបានថា រមែងដឹងសូម្បីនូវខន្ធក្រៅពីនេះ ។

ពាក្យថា **"បរិជានាតិ** = រមែងដឹងដោយជុំវិញ" ក្នុងបរិញ្ញាវារៈ

*នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា* ***“ មែន ”*** *ព្រោះទ្រង់សំដៅយកការព្រមព្រៀងនៃមគ្គដ៏កំពូល (អរហត្តមគ្គ) គឺដល់នូវទីបំផុតនៃបរិញ្ញា-កិច្ច ក្នុងបញ្ហាទាំងឡាយ ត្រង់អនុលោមន័យ; ប៉ុន្តែ ក្នុងបដិលោមន័យ ពាក្យថា* **“ ន បរិជានាតិ** *= មិនមែនកំពុងដឹងដោយជុំវិញទេ” ក្នុងបញ្ហាទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា* ***“ មែន ”*** *ព្រោះទ្រង់សំដៅយកបុគ្គលទាំងឡាយ មានបុថុជ្ជនជាដើម, ចំណែកក្នុងពាក្យថា* **“បរិជានិត្ថ** *= ធ្លាប់ដឹងដោយជុំវិញ ក្នុងអតីតកាល” នេះ បានដល់ សូម្បីបុគ្គលតាំងនៅក្នុងផលដ៏កំពូល ក្នុងលំដាប់នៃមគ្គ ឈ្មោះថា ដឹងដោយជុំវិញមែនពិត ព្រោះសម្រេចបរិញ្ញាកិច្ចហើយ; ព្រះមានព្រះភាគត្រាស់សួរនូវការព្រមព្រៀងនៃមគ្គដ៏កំពូល ដោយបញ្ហាថា* ***“ បុគ្គលណាកំពុងដឹងច្បាស់នូវរូបក្ខន្ធ បុគ្គលនោះ ធ្លាប់ដឹងច្បាស់នូវវេទនាខន្ធឬ ? ”*** *; ក៏ព្រោះបុគ្គលនេះ ឈ្មោះថារមែងដឹង (គឺកំពុងដឹង) នូវខន្ធ ៥ ប៉ុណ្ណោះ, (នៅមិនធ្លាប់ដឹងច្បាស់) ព្រោះបរិញ្ញាកិច្ច គឺខ្លួនមិនទាន់បានសម្រេចនៅឡើយ, ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់ធ្វើការបដិសេធថា* **“នោ** *= មិនមែនទេ” ។*

*ចំណែកក្នុងបញ្ហាទី ២ ព្រះមានព្រះភាគត្រាស់សួរនូវព្រះអរហត្តថា* **បរិជានិត្ថ** *= ដឹងច្បាស់ហើយឬ ?; ក៏ព្រោះបរិញ្ញាកិច្ចដែលលោកធ្វើ*

សម្រេចហើយ មិនមាន ព្រោះហេតុនោះ ឈ្មោះថា កិច្ចដែលគួរកំណត់ដឹង ទើបមិនមានដល់ព្រះអរហន្តនោះ, ដូច្នេះ ទើបព្រះមានព្រះភាគទ្រង់បដិសេធថា **"នោ = មិនមែន"** ; ក្នុងការវិសជ្ជនានៃបដិលោមន័យក្នុងទុតិយបញ្ហានេះថា **អរហា រូបក្ខន្ធំ ន បរិជានាតិ** = ព្រះអរហន្តមិនមែនកំពុងដឹងនូវរូបក្ខន្ធទេ, ព្រះមានព្រះភាគត្រាស់ហើយ ព្រោះមិនមានការដឹងច្បាស់របស់ព្រះអរហន្ត; ច្រើនបទថា ***បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏កំពូល (អរហត្តមគ្គ) មិនដឹងហើយនូវវេទនាខន្ធ*** ព្រះមានព្រះភាគត្រាស់ហើយ ព្រោះបុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ មិនទាន់បានសម្រេចបរិញ្ញាកិច្ច ។ អរហត្តមគ្គបុគ្គលនោះ មិនធ្លាប់ដឹងនូវវេទនាខន្ធតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ, សូម្បីធម៌តែមួយ ក៏មិនធ្លាប់បានដឹងដែរ; ព្រះមានព្រះភាគត្រាស់ពាក្យនេះទុក ដោយអំណាចនៃពាក្យសួរ; សូម្បីពាក្យនេះថា **នោ ច រូបក្ខន្ធំ** ក៏ព្រះអង្គត្រាស់ហើយ ដោយអំណាចនៃពាក្យសួរទុំនះឯង, ក៏អរហត្តមគ្គបុគ្គលនោះ រមែងដឹងនូវខន្ធដទៃៗ ទៀត ។

បញ្ហាថា បុគ្គលណាកំពុងដឹងនូវរូបក្ខន្ធ បុគ្គលនោះ ក៏នឹងដឹងនូវវេទនាខន្ធឬ ? អធិប្បាយថា ព្រោះបុគ្គលដែលតាំងនៅក្នុងមគ្គ ជាអ្នកមានខណៈចិត្តតែមួយ (គឺមគ្គចិត្តកើតមួយខណៈ), ព្រោះហេតុដូច្នោះ បុគ្គលនោះ រមែងមិនដល់នូវការរាប់ថា ***នឹងដឹង;*** ដោយហេតុនោះ

*ទើបព្រះអង្គត្រាស់ថា* **“នោ = មិនមែន”** ; *ប្រើនបទថា* **តេ រូបក្ខន្ធញ្ច ន បរិជានិត្ថ** = *បុគ្គលទាំងនោះ មិនធ្លាប់ដឹងនូវរូបក្ខន្ធផង, ព្រះមានព្រះភាគត្រាស់ហើយ ដោយពាក្យសួរស្មើគ្នា, អធិប្បាយក្នុងបញ្ហានេះថា បុគ្គលទាំងឡាយ មិនដឹងហើយ (គឺមិនទាន់បានដឹង) ។ បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យអត្ថក្នុងទីទាំងពួង ដោយឧបាយនេះចុះ ៕*

**ចប់បរិញ្ញាវារៈ នៃខន្ធយមកៈ**

## ៣.អាយតនយមកៈ

### ១.ពណ៌នាអំពីបញ្ញត្តិឧទ្ទេសវារៈ

*ឥឡូវនេះ ជាការពណ៌នា* ***អាយតនយមកៈ*** *ដែលរួបរួមទុក សូម្បីដោយអំណាចនៃអាយតនៈ ក្នុងធម៌ មានកុសលជាដើម ដែលសម្ដែងទុកក្នុងមូលយមកៈនោះឯង ហើយសម្ដែងទុកក្នុងលំដាប់នៃខន្ធយមកៈ; បណ្ឌិតគប្បីជ្រាបការកំណត់បាលីតាមន័យដែលលោកពោលទុកហើយ ក្នុងខន្ធយមកៈនុ៎ះចុះ ។ ក៏ក្នុងខន្ធយមកៈនុ៎ះ មហាវារៈ ៣ យ៉ាង គឺបណ្ណត្តិវារៈ បវត្តិវារៈ និងបរិញ្ញាវារៈ រមែងមាន យ៉ាងណា, សូម្បីអាយតនយមកៈនេះ ក៏មានដូច្នោះដែរ ។ សូម្បីអត្ថនៃមហាវារៈទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលលោកពោលទុកហើយ ក្នុងខន្ធយមកៈនុ៎ះចុះ ។*

ក៏ក្នុងអាយតនយមកៈនេះ ***បណ្ណត្តិវារៈ*** លោកកំណត់ទុក ២ យ៉ាង ដោយអំណាចនៃឧទ្ទេស និងនិទ្ទេស ។ វារៈទាំងឡាយក្រៅពីនេះ លោកកំណត់ទុកដោយអំណាចនៃនិទ្ទេសនុ៎ះឯង ។ ព្រោះហេតុដូច្នោះ ក្នុងវារៈទាំងនោះ បណ្ឌិតគប្បីធ្វើបទថា **"ទ្វាទសាយតនានិ** = អាយតនៈ ១២" ជាដើម ឲ្យហើយត្រឹមណា, គប្បីជ្រាបឧទ្ទេសវារៈនៃបណ្ណត្តិវារៈថា **"មនាយតនំ ន មនោ"** ត្រឹមនោះ ។ បណ្ដាបទទាំងនោះ បទថា **"ទ្វាទសាយតនានិ"** សេចក្ដីថា នេះជាឧទ្ទេសនៃអាយតនៈទាំងឡាយ ដែលគួរសួរដោយអំណាចនៃយមកៈ ។ បទថា **"ចក្ខាយតនំ ។ បេ ។ ធម្មាយតនំ"** សេចក្ដីថា ដោយប្រភេទនេះ ជាការកំណត់ឈ្មោះរបស់អាយតនៈទាំងនោះឯង ។ ក៏ក្នុងទីនេះ លោកពោលអជ្ឈត្តរូបាយតនៈ (អាយតនៈដែលជារូបខាងក្នុង) ទាំងឡាយ ទុកហើយតាមលំដាប់ជាមុនសិន ដើម្បីស្រួលដល់ការសួរ ដោយអំណាចនៃយមកៈ ។ ខាងក្រោយ ទើបពោលថា ពាហិររូបាយតនៈ (អាយតនៈដែលជារូបខាងក្រៅ) ទាំងឡាយ ។ ក្នុងទីបំផុត ទើបពោលមនាយតនៈ និងធម្មាយតនៈទាំងឡាយ ។

ក្នុងវារៈទាំងឡាយ ៤ គឺបទសោធនវារៈ បទសោធនមូលចក្កវារៈ សុទ្ធាយតនវារៈ និងសុទ្ធាយតនមូលចក្កវារៈ រមែងមានដោយអំណាចនៃអាយតនៈទាំងឡាយនេះ ក្នុងទីនេះ ដោយអំណាចនៃខន្ធនោះឯង ក្នុងខាង

ក្រោយ ៗ ក៏ក្នុងអាយតនយមកៈនេះ វារៈមួយៗ មាន ២ យ៉ាងនោះឯង ដោយអំណាចនៃអនុលោម និងបដិលោម ។ អត្ថនៃវារៈទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងខន្ធយមកៈនុ៎ះចុះ ។

បណ្ឌិតគប្បីជ្រាបក្នុងខន្ធេសវារៈនៃបណ្ណត្តិវារៈ ដែលប្រកបដោយយមកៈ ៥៧៦ យ៉ាង បុច្ឆា ១១៥២ យ៉ាង និងអត្ថ ២៣០៤ យ៉ាង ក្នុងអាយតនយមកៈនេះ យ៉ាងនេះ គឺក្នុងអនុលោមវារៈនៃបទសោធនវារៈ ក្នុងខន្ធយមកៈ យមកៈ ៥ យ៉ាង មានជាអាទិ៍ថា **“រូបំ រូបក្ខន្ធោ, រូបក្ខន្ធោ រូបំ”** ដូច្នេះ យ៉ាងណា, ក្នុងអាយតនយមកៈនេះ យមកៈ ១២ យ៉ាង មានជាអាទិ៍ថា **“ចក្ខុ ចក្ខាយតនំ, ចក្ខាយតនំ ចក្ខុ”** ក៏ដូច្នោះដែរ ។ សូម្បីបដិលោមវារៈ ក៏មានយមកៈ ១២ យ៉ាង មានពាក្យថា **“ន ចក្ខុ ន ចក្ខាយតនំ, ន ចក្ខាយតនំ ន ចក្ខុ”** ជាដើម ។ តែក្នុងអនុលោមវារៈនេះ បទសោធនមូលចក្កវារៈ មានយមកៈ ១៣២ យ៉ាង ព្រោះធ្វើមូលនៃអាយតនៈ មួយៗ ឲ្យជា ១១ យ៉ាង, សូម្បីក្នុងបដិលោមវារៈ ក៏មាន ១៣២ យ៉ាងនោះឯង ។ ក្នុងអនុលោមវារៈ សូម្បីសុទ្ធាយតនវារៈ មានយមកៈ ១២ យ៉ាង, ក្នុងបដិលោមវារៈ ក៏មាន ១២ យ៉ាង ។ ក្នុងអនុលោមនៃសុទ្ធាយតនមូលចក្កវារៈ មានយមកៈ ១៣២ យ៉ាង ព្រោះធ្វើមូលនៃអាយតនៈ មួយៗ ឲ្យជា ១១ យ៉ាង ។ សូម្បីក្នុងបដិលោម-

វារៈ ក៏មាន ១៣២ យ៉ាងដូចគ្នា ។ ក៏ក្នុងនិទ្ទេសវារៈនៃអាយតនយមកៈ នោះ បណ្ឌិតគប្បីជ្រាប អត្ថតាមន័យដែលលោកពោលទុកហើយ ក្នុងបណ្ណត្តិវារនិទ្ទេសនៃខន្ធយមកៈ ខាងក្រោយនុ៎ះឯង ។ ក្នុងវារៈដទៃ រមែងមានសេចក្តីផ្សេងគ្នា ៕

## ២.ពណ៌នាអំពីបញ្ញត្តិនិទ្ទេសវារៈ

ក្នុងអាយតនយមកៈនោះ គប្បីជ្រាបសេចក្តីប្លែកគ្នា ដូចតទៅនេះ ៖

បទថា **ទិព្វចក្ខុ** បានដល់ ទុតិយវិជ្ជាញាណ ។ បទថា **បញ្ញាចក្ខុ** បានដល់ តតិយវិជ្ជាញាណ ។ បទថា **ទិព្វសោត** បានដល់ ទុតិយ-អភិញ្ញាញាណ ។ តណ្ហានោះឯង ឈ្មោះថា ***តណ្ហាសោត*** ។ ពាក្យជាដើមថា នាមកាយ រូបកាយ ហត្ថិកាយ អស្សកាយ ឈ្មោះថា **អវសេសោ កាយោ** = កាយដ៏សេស ។ ពីរបទថា **អវសេសំ រូបំ** បានដល់ ភូតរូប ឧបាទាយរូបនុ៎ះឯង និងបិយរូប សាតរូបដ៏សេស អំពីរូបាយតនៈ ។ ពាក្យថា **សីលគន្ធោ** ជាដើម ជាឈ្មោះនៃធម៌ទាំងឡាយ មានសីលជាដើមនោះឯង ព្រោះអត្ថថា **ទាយនដ្ឋេន** = ផ្សាយទៅ; សូម្បីពាក្យថា **អត្ថរសោ**ជាដើម ក៏ជាឈ្មោះរបស់ធម៌ទាំងឡាយ មានអត្ថជាដើម ព្រោះអត្ថថា ពីរោះល្អ ។ ពីរបទថា **អវសេសោ ធម្មោ** បានដល់ ប្រភេទនៃធម៌មិន

មែនតែមួយ មានបរិយត្តិធម៌ជាដើម នេះជាសេចក្តីប្លែកគ្នា ក្នុងអាយតនយមកៈនេះ ។

## ៣.ពណ៌នាអំពីបវត្តិវារៈ

ក៏ក្នុងអាយតនយមកៈនេះ ក្នុងអន្តរវារៈ ៣ យ៉ាង មានឧប្បាទវារៈជាដើម នៃបវត្តិវារៈ មានប្រភេទរបស់កាល ៦ យ៉ាង ក្នុងប្រភេទនៃកាលមួយៗ នោះឯង ។ បណ្តាប្រភេទនៃកាលទាំងនោះ វារៈទាំងឡាយ មានបុគ្គលវារៈជាដើម រមែងមានក្នុងកាលមួយៗ ។ សូម្បីវារៈទាំងអស់នោះ មាន ២ យ៉ាង ដោយអំណាចនៃអនុលោមន័យ និងបដិលោមន័យ ។ ក្នុងវារៈទាំងនោះ ក្នុងបច្ចុប្បន្នកាល ត្រង់អនុលោមន័យនៃបុគ្គលវារៈ យមកៈ ១០ យ៉ាង មានដោយការកាន់យក ហើយមិនកាន់យកម្តងទៀត គឺមូលនៃរូបក្ខន្ធ ក្នុងខន្ធយមកៈ ៤, មូលនៃវេទនាខន្ធ ៣, មូលនៃសញ្ញាខន្ធ ២, មូលនៃសង្ខារក្ខន្ធ ១ យ៉ាងណា, មូលនៃចក្ខាយតនៈ ១១ យ៉ាង ក៏មានដូច្នោះដែរ គឺចក្ខាយតនៈ រមែងកើតឡើងដល់សត្វណា សោតាយតនៈរមែងកើតឡើងដល់សត្វនោះ, ឬសោតាយតនៈរមែងកើតឡើងដល់សត្វណា ចក្ខាយតនៈរមែងកើតឡើងដល់សត្វនោះ ។ ចក្ខាយតនៈ រមែង

កើតឡើងដល់សត្វណា ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈ ក៏រមែងកើតឡើងដល់សត្វនោះ, ឬថា ធម្មាយតនៈ រមែងកើតឡើងដល់សត្វណា ចក្ខាយតនៈ ក៏រមែងកើតឡើងដល់សត្វនោះដែរ" ។ ដោយន័យមានជាដើមថា **"យស្ស សោតាយតនំ ឧប្បជ្ជតិ តស្ស ឃានាយតនំ ឧប្បជ្ជតិ"** ទើបមានយមកៈ ៦៦ យ៉ាង ដោយការកាន់យកហើយមិនកាន់យកទៀត គឺមូលនៃសោតាយតនៈ ១០, មូលនៃឃានាយតនៈ ៩, មូល នៃជិវ្ហាយតនៈ ៨, មូលនៃកាយាយតនៈ ៧, មូលនៃរូបាយតនៈ ៦, មូល នៃសទ្ទាយតនៈ ៥, មូលនៃគន្ធាយតនៈ ៤, មូលនៃរសាយតនៈ ៣, មូល នៃផោដ្ឋព្វាយតនៈ ២ និងមូលនៃមនាយតនៈ ១ ។ ក្នុងអាយតនៈ ១១ យ៉ាង គឺជាមូលនៃចក្ខាយតនៈនោះ ចក្ខាយតនៈ រមែងកើតឡើងដល់សត្វណា អាយតនៈទាំង ៥ យ៉ាងនេះឯង គឺសោតាយតនៈ រូបាយតនៈ ឃានាយតនៈ មនាយតនៈ និងធម្មាយតនៈ ក៏រមែងកើតឡើងដល់សត្វនោះ លោកវិសជ្ជនាហើយ ។

ក្នុងអាយតនៈទាំងនោះ អាយតនៈដំបូង គួរវិសជ្ជនាមុន អាយតនៈដំបូងនោះ លោកវិសជ្ជនាហើយ; អាយតនៈ ២ ជាការវិសជ្ជនាដូចគ្នានឹងអាយតនៈដំបូង ក៏ពិតមែនហើយ, ប៉ុន្តែថា អាយតនៈទី ២ លោកក៏

វិសជ្ជនាហើយ ដើម្បីការពារសេចក្ដីសង្ស័យថា "ឃានាយតនៈ មិនប្រព្រឹត្តទៅ ដោយចំណែកតែម្យ៉ាង ក្នុងបវត្តិកាលរបស់ចក្ខុសោតាយតនៈ អាយតនៈតែម្យ៉ាង គប្បីវិសជ្ជនាដូចម្ដេចហ្ន៎" ។ យមកៈ ៣ យ៉ាង ជាមួយរូបាយតនៈ មនាយតនៈ និងធម្មាយតនៈ ឈ្មោះថា លោកវិសជ្ជនាហើយ ព្រោះវិសជ្ជនា មិនដូចគ្នា ។ ក្នុងអាយតនៈដ៏សេស យមកៈ ២ និងជិវ្ហាយតនៈ និងកាយាយតនៈ ជាការវិសជ្ជនាដូចគ្នានឹងអាយតនៈ ២ យ៉ាងខាងដើមដែរ ។

វិសជ្ជនាយមកៈ ជាមួយនឹងអាយតនៈនោះឯង រមែងមិនមាន ព្រោះមិនកើតឡើងក្នុងបដិសន្ធិខណៈនៃសទ្ទាយតនៈ ។ អាយតនៈទាំងឡាយ លោកសង្ខេបទុកហើយ ដើម្បីភាពស្រាលនៃបែបផែនថា យមកៈ ៣ យ៉ាង សូម្បីជាមួយនឹងគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ រមែងជាការវិសជ្ជនាដូចគ្នានឹងអាយតនៈ ២ ខាងដើមនុ៎ះឯង ។ ក្នុងមូលនៃសោតាយតនៈ សូម្បីអាយតនៈតែម្យ៉ាង មិនឡើងកាន់ព្រះបាលីឡើយថា អាយតនៈណា ដែលបណ្ឌិតបាន, អាយតនៈនោះ រមែងជាការវិសជ្ជនា ដូចគ្នានឹងអាយតនៈទាំងឡាយខាងដើម ។

ក្នុងមូលនៃឃានាយតនៈទាំងឡាយ យមកៈតែម្យ៉ាង ឡើងកាន់ព្រះបាលីជាមួយនឹងរូបាយតនៈ យមកៈពីរបីយ៉ាង ឡើងកាន់ព្រះបាលីជាមួយ

មនាយតនៈ និងធម្មាយតនៈ ។ យមកៈទាំងឡាយដ៏សេស មិនឡើងកាន់ (ព្រះបាលី) ទេ ព្រោះការវិសជ្ជនាដូចគ្នានឹងឃានាយតនយមកៈដែរ ។ មូលនៃជិវ្ហាយតនៈ និងកាយាយតនៈ ក៏យ៉ាងនោះដែរ ។

ក្នុងមូលនៃរូបាយតនៈទាំងឡាយ យមកៈ ២ យ៉ាងនោះឯង លោកវិសជ្ជនាហើយ ព្រមជាមួយមនាយតនៈ និងធម្មាយតនៈ ។ យមកៈ ៣ យ៉ាង ព្រមជាមួយគន្ធៈ រសៈ និងផោដ្ឋព្វៈ រមែងជាការវិសជ្ជនាដូចគ្នានឹងរូបាយតនៈ និងមនាយតនៈដែរ ។ ពាក្យថា “ **សរូបកានំ អចិត្តកានំ** ” ជាដើម លោកពោលហើយក្នុងខាងក្រោយនោះឯង យ៉ាងណា, សូម្បីក្នុងអាយតនយមកៈនេះ ក៏ដូច្នោះដែរ គប្បីជ្រាបការប្រកបថា “ **សរូបកានំ អគន្ធកានំ អរសកានំ អផោដ្ឋព្វកានំ** ” ។

ក៏ភាវៈនៃអាយតនៈទាំងឡាយ មានគន្ធាយតនៈជាដើមនោះឯង លោកមានបំណងយកហើយក្នុងអាយតនយមកៈនេះ, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងអាយតនយមកៈនេះ ដោយអំណាចនៃអាយតនៈថា “ **សរូបកានំ សគន្ធាយតនំ** ” ។ មូលនៃសទ្ទាយតនៈទាំងឡាយ មិនឡើងកាន់ព្រះបាលីឡើយ ព្រោះមិនមានអត្ថ ។ អាយតនៈដែលជាមូលនៃគន្ធៈ រសៈ និងផោដ្ឋព្វៈបួនបី និងពីរយ៉ាង មិនឡើងកាន់ព្រះបាលីឡើយ ព្រោះវិសជ្ជនា ដូចគ្នានឹងអាយតនៈទាំងឡាយដែលមានក្នុងពេលមុន ។

*យមកៈទាំង ៦៦ យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា លោកវិសជ្ជនាហើយ ដោយការវិសជ្ជនាយមកៈ ២-៣ យ៉ាងនោះឯង ក្នុងអនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាល យ៉ាងនេះថា* **មនាយតនមូលកំ ទិសជ្ជិត-មេវ** *ដូច្នេះ ។ យមកៈ ១៩៨ យ៉ាង រមែងមានក្នុងអនុលោមន័យត្រង់វារៈទាំងឡាយ ៣ ក្នុងបច្ចុប្បន្នកាលថា ក៏ក្នុងបុគ្គលវារៈ មាន ៦៦ យ៉ាងណា, សូម្បីក្នុងឱកាសវារៈ សូម្បីក្នុងបុគ្គលោកាសវារៈ ក៏យ៉ាងនោះដែរ ។ សូម្បីយមកៈទាំងអស់ ៣៩៦ យ៉ាង រមែងមានក្នុងបច្ចុប្បន្នកាលថា ក៏ក្នុងអនុលោមន័យ យ៉ាងណា, សូម្បីក្នុងបដិលោមន័យ ក៏ដូច្នោះដែរ ។ បុច្ឆា ៧៩២ យ៉ាង និងអត្ថ ១៥៨៤ យ៉ាង គប្បីជ្រាបថា រមែងមានក្នុងយមកៈទាំងឡាយនោះ ។ សូម្បីយមកៈទាំងអស់ ២៣៧៦ ថា "ក្នុងការចែកកាល ៥ យ៉ាង សូម្បីដ៏សេស" ដូច្នេះ រមែងមានយ៉ាងនោះ ។*

*នេះជាការកំណត់ព្រះបាលីក្នុងឧប្បាទវារៈនេះថា ពាក្យសួរដែលទ្រុឌុណអំពីយមកៈនោះ, អត្ថដែលទ្រុឌុណអំពីពាក្យសួរនោះ; សូម្បីយមកៈទាំងអស់ ២១២៨ រមែងមានក្នុងបវត្តិវារៈថា សូម្បីក្នុងនិរោធវារៈ និងឧប្បាទ-និរោធវារៈ ក៏មានន័យដូចគ្នានេះដែរ ។ គប្បីជ្រាបការសួរទ្រុឌុណអំពីយមកៈនោះ, គប្បីជ្រាបអត្ថទ្រុឌុណអំពីពាក្យសួរនោះ ។ ក៏ព្រះបាលីលោកពោលពាក្យជាដើមថា* ***មនាយតនៈ និងធម្មាយតនៈ រមែងមានសេចក្តី***

**ដូចគ្នា, រមែងមិនមាន សេចក្តីផ្សេងគ្នាជាមួយនឹងអាយតនៈមួយឡើយ;** តែសេចក្តីសង្ខេប រមែងមានក្នុងវារៈខាងលើដូច្នេះ ហើយទើបរួបរួមទុកក្នុងអាយតនៈនោះៗ ។ ព្រោះហេតុដូច្នោះ ពាក្យណា លោករួបរួមទុកហើយក្នុងទីនោះៗ, ពាក្យទាំងអស់នោះ បណ្ឌិតគប្បីកំណត់ទុកចុះ ។

ក៏ក្នុងការវិនិច្ឆ័យអត្ថ គប្បីជ្រាបន័យខាងមុខក្នុងអាយតនយមកៈនេះ ដូចតទៅនេះ ៖

ពាក្យថា **សចក្ខុកានំ អសោតកានំ** លោកពោលសំដៅយកឱបបាតិកៈដែលចូលពីកំណើតក្នុងអបាយ ។ ក៏អ្នកមានចក្ខុនោះ រមែងជាអ្នកមិនមានសោតៈកើតឡើង ។ ដូចព្រះធម្មសង្គាហកាចារ្យពោលហើយថា "អាយតនៈ ១០ យ៉ាងដទៃទៀត របស់សត្វណាមួយ រមែងប្រាកដ ក្នុងឧប្បត្តិក្ខណៈនៃកាមធាតុ, អាយតនៈ ១០ រមែងប្រាកដក្នុងឧប្បត្តិក្ខណៈ របស់ពួកប្រេតដែលជាឱបបាតិកៈ របស់ពួកអសុរដែលជាឱបបាតិកៈ របស់សត្វតិរច្ឆានដែលជាឱបបាតិកៈ របស់ពួកសត្វនរកដែលជាឱបបាតិកៈ របស់ពួកមនុស្សអ្នកចូលពីកំណើត ចក្ខាយតនៈ រូបាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈ រមែងប្រាកដដល់ពួកប្រេតដែលជា ឱបបាតិកៈ ។ល។ ដល់ពួកមនុស្សអ្នកចូលអំពីកំណើត ក្នុងខណៈកើតឡើង" ។ ពាក្យថា

**សចក្ខុកានំ សសោតកានំ** លោកពោលសំដៅយកអាយតនៈ ដែលបរិបូណ៌ក្នុងសុគតិ ទុគ្គតិ និងរូបព្រហ្មដែលជាឱបបាតិកៈ; ក៏អ្នកមានចក្ខុទាំងនោះរមែងជាអ្នកមានសោតៈកើតឡើង ។ ដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា “អាយតនៈ ១១ យ៉ាង របស់សត្វណាមួយ រមែងប្រាកដក្នុងឧប្បត្តិក្ខណៈនៃកាមធាតុ, អាយតនៈ ១១ យ៉ាង រមែងប្រាកដដល់ពួកទេវតាជាន់កាមាវចរ ពួកមនុស្សបឋមកប្ប ពួកប្រេតដែលជាឱបបាតិកៈ ពួកអសុរដែលជាឱបបាតិកៈ ពួកសត្វតិរច្ឆានដែលជាឱបបាតិកៈ ពួកសត្វនរក ដែលជាឱបបាតិកៈ និងពួកសត្វដែលមានអាយតនៈបរិបូណ៌ ។ អាយតនៈទាំង ៥ ណា រមែងប្រាកដក្នុងឧប្បត្តិក្ខណៈនៃកាមធាតុ អាយតនៈទាំង ៥ នេះ គឺចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ មនាយតនៈ និងធម្មាយតនៈ រមែងប្រាកដក្នុងឧប្បត្តិក្ខណៈនៃរូបធាតុ” ។

ពាក្យថា **អឃានកានំ** លោកពោលសំដៅយកព្រហ្ម មានព្រហ្មបរិសជ្ជាជាដើម ។ ក៏អ្នកមានចក្ខុទាំងនោះ រមែងជាអ្នកមិនមានឃានៈកើតឡើង ។ ក៏ឱបបាតិកៈដែលមិនមានឃានៈ រមែងមិនមានក្នុងកាមធាតុ; បើគប្បីមានដល់នរណាមួយមែន, ក៏គប្បីពោលបានថា “អាយតនៈ ៨ ក៏រមែងប្រាកដ” ; ក៏អ្នកដេកក្នុងគភ៌ណាៗ គប្បីជាអ្នកមិនមានឃានៈ, អ្នកដេកក្នុងគភ៌នោះៗ លោកមិនមានបំណងយកក្នុងអាយតនយមកៈនេះទេ

ព្រោះពាក្យថា **“សចក្ខុកានំ”** ។

ពាក្យថា **សចក្ខុកានំ សឃានកានំ** លោកពោលសំដៅយកឱបបាតិកសត្វដែលថ្លង់អំពីកំណើតខ្លះ មានអាយតនៈបរិបូណ៌ខ្លះ ។

ពាក្យថា **សឃានកានំ អចក្ខុកានំ** លោកពោលសំដៅយកឱបបាតិកសត្វដែលខ្វាក់អំពីកំណើតខ្លះ ថ្លង់អំពីកំណើតខ្លះ ។

ពាក្យថា **សឃានកានំ សចក្ខុកានំ** លោកពោលសំដៅយកឱបបាតិកសត្វ ដែលមានអាយតនៈបរិបូណ៌នោះឯង ។

អ្នកដទៃខ្លះ អ្នកដេកក្នុងគភ៌ខ្លះ ដែលបណ្ឌិតរមែងបាននោះឯង ក្នុងពួកឱបបាតិកសត្វដែលខ្វាក់ និងថ្លង់អំពីកំណើត ក្នុងពាក្យថា **សរូបកានំ អចក្ខុកានំ** នេះ ។ សូម្បីអ្នកមិនមានរូប និងបុគ្គល ៣ ជំពូក មានបុគ្គលខ្វាក់អំពីកំណើតជាដើម ដែលពោលទុកហើយក្នុងពេលមុន បណ្ឌិតរមែងបានក្នុងពាក្យថា **សចិត្តកានំ អចក្ខុកានំ** នេះ ។

សូម្បីពួកអសញ្ញសត្វ និងបុគ្គល ៤ ជំពូក ដែលពោលហើយក្នុងបទខាងដើម បណ្ឌិតរមែងមានក្នុងបទដំបូងថា **អចក្ខុកានំ** នេះ ។ ពួកគព្ភសេយ្យសត្វ ពួកអសញ្ញសត្វ និងពួករូបព្រហ្មដ៏សេស ដែលបណ្ឌិតរមែងបានក្នុងពាក្យថា **សរូបកានំ អឃានកានំ** នេះ ។ ពួកគព្ភសេយ្យសត្វ ពួករូបព្រហ្ម និងអរូបព្រហ្ម ដែលបណ្ឌិតរមែងមានក្នុងពាក្យថា **សចិត្តកានំ**

**អឈានកានំ** នេះ ។ គប្បីជ្រាបបុគ្គលវិភាគក្នុងបុគ្គលវារៈទាំងអស់ ដោយន័យនេះថា ក៏ពួកឯកវោការសត្វ និងចតុវោការសត្វនោះឯង ដែលបណ្ឌិតរមែងមានក្នុងបទទាំងឡាយថា **អចិត្តកានំ អរូបកានំ** ។

ក្នុងឱកាសវារៈ ពាក្យថា **យត្ថ ចក្ខាយតនំ** បានដល់ រមែងសួរនូវលោកនៃរូបព្រហ្ម, ព្រោះហេតុនោះឯង ទើបលោកពោលថា **"អាមន្តា** = **មែន"** ។ ក៏អាយតនៈទាំងនោះ ដោយនិយមក្នុងផ្ទៃនោះ រមែងកើតក្នុងបដិសន្ធិ ។ នេះជាន័យមុខ ក្នុងអាយតនយមកៈនេះ ។ គប្បីជ្រាបអត្ថសម្ពន្ធក្នុងបវត្តិវារៈទាំងអស់ ដោយន័យមុខនេះចុះ ។ បរិញ្ញាវារៈ គប្បីជ្រាបថា ជាន័យដែលលោកពោលទុកហើយ ក្នុងខន្ធយមកៈនុ៎ះឯង៕

ចប់អាយតនយមកៈ

................................

## ៤.ធាតុយមកៈ

ឥឡូវនេះ ***ជាការពណ៌នាអំពីធាតុយមកៈ*** ដែលលោករួបរួមសម្ដែងទុកហើយ ក្នុងលំដាប់នៃអាយតនយមកៈដោយអំណាចនៃធាតុក្នុងធម៌ មានកុសលជាដើម ដែលលោកសម្ដែងទុកហើយក្នុងមូលយមកៈទាំងនោះឯង ។ គប្បីជ្រាបការកំណត់ព្រះបាលី តាមន័យដែលលោកពោលទុកហើយ ក្នុងអាយតនយមកៈនោះចុះ ។ ក៏ក្នុងធាតុយមកៈនេះ

*មហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងអន្តរវារៈដ៏សេស ព្រមទាំងប្រភេទទាំងឡាយ មានប្រភេទនៃកាលជាដើម រមែងមានដូចដែលមកហើយក្នុងអាយតនយមកៈនោះឯង ។ ម្យ៉ាងទៀត ក្នុងធាតុយមកៈនេះ លោកពោលរូបធាតុខាងក្នុង និងខាងក្រៅនោះហើយ ទើបពោលវិញ្ញាណធាតុតាមលំដាប់ ដើម្បីងាយស្រួលដល់ការសួរយមកៈ ។ ក៏យមកៈច្រើនជាងអាយតនយមកៈ ការសួរដែលទទេគុណដោយយមកៈ និងអត្ថដែលទទេគុណដោយការសួរ មានក្នុងធាតុយមកៈនេះ ព្រោះធាតុទាំងឡាយមានច្រើន ។ ការវិនិច្ឆ័យអដ្ឋកថានៃយមកៈ ដែលមាននៅក្នុងយមកៈទាំងឡាយ មានចក្ខុធាតុមូលកៈជាដើមនោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងអាយតនយមកៈនោះឯង ។ ក៏គតិនៃអត្ថក្នុងធាតុយមកៈនេះ រមែងមានដូចគ្នានឹងយមកៈនោះដែរ ។ ម្យ៉ាងទៀត សូម្បីព្រះបាលីក៏លោកសង្ខេបទុកហើយ ដោយហេតុនោះឯង, បរិញ្ញាវារៈ គប្បីជ្រាបថា ជាវារៈតាមប្រក្រតីនុ៎ះចុះ ។*

ចប់ធាតុយមកៈ

---

# ៥.សច្ចយមកៈ

## ១.ពណ៌នាអំពីបណ្ណត្តិវារៈ

ការពណ៌នាអំពីសច្ចយមកៈ ដែលលោករួបរួមសម្ដែងទុកហើយ ក្នុងលំដាប់នៃធាតុយមកៈ ដោយអំណាចនៃសច្ចៈ ក្នុងធម៌មានកុសលជាដើម ដែលលោកបានសម្ដែងទុកក្នុងមូលយមកៈនោះឯង រមែងមានក្នុងកាលឥឡូវនេះ ។ គប្បីជ្រាបមហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងប្រភេទនៃវារៈដ៏សេស មានអន្តរវារៈជាដើម តាមន័យដែលពោលហើយ សូម្បីក្នុងធាតុនោះចុះ ។ តែបណ្ណត្តិវារៈ ក្នុងសច្ចយមកៈនេះ ដោយអំណាចនៃសច្ចៈ ៤ គប្បីជ្រាបការរាប់យមកៈក្នុងវារៈទាំង ៤ នេះ គឺបទសោធនវារៈ បទសោធនមូលចក្កវារៈ សុទ្ធសច្ចវារៈ សុទ្ធសច្ចមូលចក្កវារៈ ។ តែក្នុងបណ្ណត្តិវារនិទ្ទេស គប្បីជ្រាបតេភូមិកធម៌ដែលរួចផុតល្អហើយចាកទុក្ខវេទនា និងតណ្ហា ដោយពាក្យថា **អវសេសំ ទុក្ខសច្ចំ** ។ ប្រភេទនៃកាមាវចរ-កុសលជាដើម ដែលលោកសម្ដែងទុកហើយ ក្នុងសច្ចវិភង្គថា **អវសេសោ សមុទយោ** ដូច្នេះ រមែងជាបច្ច័យនៃទុក្ខសច្ច ។ ពីរបទថា **អវសេសោ និរោធោ** បានដល់ តទង្គនិរោធ វិក្ខម្ភននិរោធ សមុច្ឆេទនិរោធ បដិបស្សទ្ធិ-និរោធ និងខណភង្គនិរោធ ។ ពីរបទថា **អវសេសោ មគ្គោ** សេចក្ដីថា ក៏មគ្គមានអង្គ ៥ រមែងមានក្នុងសម័យនោះឯង ។ មគ្គជាដើមយ៉ាងនេះ គឺអដ្ឋង្គិកមគ្គ មិច្ឆាមគ្គ ជង្ឃមគ្គ និងសកដមគ្គ ៕

## ២.ពណ៌នាអំពីបវត្តិវារៈ

ក៏ក្នុងបវត្តិវារៈ ត្រង់អនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្ន-កាលនេះ ទុក្ខសច្ចមូល ៣, សមុទសច្ចមូល ២, និរោធសច្ចមូល ១ រួមត្រូវជាយមកៈ ៦ យ៉ាង ដោយអំណាចនៃព្រះបាលី ព្រោះកាន់យកសច្ចៈដែលបាន និងមិនបានហើយថា "ទុក្ខសច្ចរមែងកើតដល់សត្វណា សមុទយសច្ច ក៏កើតឡើងដល់សត្វនោះ, ឬក៏សមុទយសច្ចរមែងកើតឡើងដល់សត្វណា ទុក្ខសច្ចរក៏កើតឡើងដល់សត្វនោះ" ។ ក្នុងសច្ចៈទាំងឡាយនោះ ព្រោះការកើត និងរលត់ រមែងមិនសមគួរដល់និរោធ, ព្រោះហេតុដូច្នោះ យមកៈទាំងឡាយ ៣ គឺយមកៈដែលជាមូលនៃទុក្ខសច្ច ២ ជាមួយសមុទយសច្ច និងមគ្គសច្ច, យមកៈដែលជាមូលនៃសមុទយសច្ច ១ ជាមួយនឹងមគ្គសច្ច ទើបមាន ។ ក្នុងបដិលោមន័យរបស់បុគ្គលវារៈនោះខ្លះ ក្នុងឱកាសវារៈជាដើមខ្លះ ក៏មានន័យដូចគ្នានេះដែរ ។ គប្បីជ្រាបការរាប់យមកៈ ដោយអំណាចនៃយមកៈមួយៗ ៣ ក្នុងវារៈទាំងអស់នេះ ដោយប្រការដូច្នេះ ។

ក៏ក្នុងអត្ថវិនិច្ឆ័យ គប្បីជ្រាបលក្ខណៈក្នុងសច្ចយមកៈនេះ ដូចតទៅនេះ ៖

ក៏ក្នុងបវត្តិវារៈនៃសច្ចយមកៈនេះ នរណាមួយ រមែងមិនបាន និរោធសច្ចមុននោះឯង ។ តែក្នុងវារៈទាំងឡាយ ៣ ដ៏សេស សមុទយសច្ច និងមគ្គសច្ច បុគ្គលរមែងមានក្នុងបវត្តិកាលដោយចំណែកតែម្យ៉ាងនោះឯង ។ ទុក្ខសច្ច បុគ្គលរមែងមានក្នុងចុតិខ្លះ បដិសន្ធិខ្លះ និងក្នុងបវត្តិកាលខ្លះ ។ តែកាល ៣ មានបច្ចុប្បន្នកាលជាដើម បុគ្គលរមែងមានសូម្បីក្នុងចុតិខ្លះ បដិសន្ធិខ្លះ និងក្នុងបវត្តិកាលខ្លះ ។ បុគ្គលរមែងមានសច្ចៈណា ក្នុងសច្ចយមកៈនេះ, គប្បីជ្រាបអត្ថវិនិច្ឆ័យដោយអំណាចនៃសច្ចៈនោះៗ មានប្រការយ៉ាងនេះ ។

គប្បីជ្រាបន័យមុខ ក្នុងសច្ចយមកៈនោះ ដូចតទៅនេះ ៖

ពីរបទថា **សព្វេសំ ឧប្បជ្ជន្តានំ** សេចក្ដីថា ដោយហោចទៅ សូម្បីជាន់សុទ្ធាវាស ។ ក៏សូម្បីទេវតាជាន់សុទ្ធាវាសនោះ រមែងកើតដោយទុក្ខសច្ចនោះឯង ។ ពាក្យថា **តណ្ហាវិប្បយុត្តចិត្តស្ស** នេះ លោកពោលទុកហើយដើម្បីសម្ដែងការឧបបត្តិនៃចំណែកមួយ ក្នុងទុក្ខសច្ច និងសមុទយ-សច្ច ។ ព្រោះហេតុដូច្នោះ ពាក្យនោះ គប្បីកាន់យកដោយអំណាចនៃបញ្ចវោការភពទុំះចុះ ។ តែក្នុងចតុវោការភព ពាក្យថា សូម្បីសច្ចៈតែម្យ៉ាង រមែងមិនកើតឡើងក្នុងឧប្បាទក្ខណៈ របស់ផលសមាបត្តិ ចិត្តដែល

សម្បយុត្តដោយតណ្ហាដូច្នេះនេះ បណ្ឌិតមិនគួរកាន់យកក្នុងសច្ចយមកៈនេះទេ ។ ពីរបទថា **តេសំ ទុក្ខសច្ចស្ស** សេចក្ដីថា ឈ្មោះថា ទុក្ខសច្ចដ៏សេស វៀរតណ្ហាចេញ រមែងមានក្នុងខណៈនោះ ពាក្យនោះ លោកពោលសំដៅយកទុក្ខសច្ចនោះ ។ សូម្បីក្នុងឧប្បាទក្ខណៈនៃមគ្គ ក៏មានន័យដូចគ្នានេះដែរ ។ តែក្នុងសច្ចយមកៈនោះ រូបនោះឯង ឈ្មោះថា ទុក្ខសច្ច, ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គដ៏សេស ជាធម៌ដែលរួចផុតល្អហើយអំពីសច្ចៈ ។ ព្រោះហេតុនោះឯង ទើបលោកពោលថា "មគ្គសច្ចរមែងកើតឡើងដល់ជនទាំងនោះ ក្នុងឧប្បាទក្ខណៈនៃមគ្គក្នុងអរូប តែទុក្ខសច្ចរមែងមិនកើតឡើងដល់ជនទាំងនោះ" ។ គប្បីជ្រាបឱកាសដោយអំណាចនៃខណៈក្នុងសច្ចយមកៈយ៉ាងនេះថា ក្នុងខណៈនៃឧបបត្តិនោះ និងក្នុងខណៈនៃការកើតឡើងរបស់ចិត្ត ដែលវិប្បយុត្តដោយតណ្ហារបស់ជនទាំងនោះថា ក្នុងឧប្បាទក្ខណៈនៃចិត្តដែលវិប្បយុត្តដោយតណ្ហា ដែលប្រព្រឹត្តទៅរបស់អ្នកកើតទាំងអស់ ក្នុងឧប្បាទក្ខណៈរបស់អ្នក កើតទាំងអស់នោះ ។ ក្នុងសច្ចៈដែលមានសភាពយ៉ាងនោះ សូម្បីដទៃទៀត ក៏មានន័យដូចគ្នានេះដែរ ។ បទថា **អនភិសមេតាវីនំ** បានដល់ សត្វដែលមិនសម្រេចអភិសម័យ ពោលគឺចតុសច្ចបដិវេធ គឺការចាក់ធ្លុះសច្ចៈទាំង ៤ ។ បទថា **អភិសមេតាវីនំ**

បានដល់ អភិសមិតសច្ច គឺសច្ចៈដែលស្ងប់ក្រៃលែង ។ គប្បីជ្រាបអត្ថវិនិច្ឆ័យក្នុងបទទាំងពួង ដោយមុខន័យនេះចុះ ៕

## ៣.ពណ៌នាអំពីបរិញ្ញាវារៈ

ក៏ក្នុងបរិញ្ញាវារៈ បុគ្គលរមែងបានបរិញ្ញា ៣ គឺញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ។ ក៏ព្រោះឈ្មោះថា បរិញ្ញា រមែងមិនមានក្នុងលោកុត្តរធម៌ទាំងឡាយ, ព្រោះហេតុដូច្នោះ សច្ចៈ ២ ទើបលោកកាន់យកហើយក្នុងសច្ចយមកៈនេះ ។ ពាក្យថា **ទុក្ខសច្ចំ បរិជានាតិ** ក្នុងសច្ចយមកៈនោះ លោកពោលទុកហើយ ដោយអំណាចនៃញាតបរិញ្ញា និងតីរណបរិញ្ញា ។ ពាក្យថា **សមុទយសច្ចំ បជហាតិ** លោកពោលទុកហើយ ដោយអំណាចនៃញាតបរិញ្ញា និងបហានបរិញ្ញា ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយអំណាចនៃបរិញ្ញាទាំងឡាយនេះ មានប្រការដូច្នេះ ៕

ចប់សច្ចយមកៈ

# ៦.សង្ខារយមកៈ

## ១.ពណ៌នាអំពីបញ្ញត្តិវារៈ

*ឥឡូវនេះ ជាការពណ៌នាសង្ខារយមកៈ ដែលព្រះមានព្រះភាគទ្រង់សម្ដែងតអំពីសច្ចយមកៈ ព្រោះទ្រង់រួបរួមធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដែលព្រះអង្គទ្រង់សម្ដែងហើយក្នុងមូលយមកៈទាំងនោះ ទុកជាឯកទេស ដោយអំណាចនៃធម៌ដែលសង្គ្រោះបាន ។ សូម្បីក្នុងសង្ខារ-យមកៈនោះ គប្បីជ្រាបប្រភេទនៃវារៈដ៏សេស គឺមហាវារៈទាំងឡាយ មានបណ្ណត្តិវារៈ និងអន្តរវារៈជាដើម ដោយន័យដែលពោលហើយ ក្នុងពេលមុន ។*

*ចំណែកសេចក្ដីប្លែកគ្នាក្នុងសង្ខារយមកៈនេះ មានដូចតទៅនេះ ៖*

*ក្នុងបណ្ណត្តិវារៈជាមុន បទសោធនវារៈថា* **“រូបំ រូបក្ខន្ធោ, ចក្ខុំ ចក្ខាយតនំ, ចក្ខុំ ចក្ខុធាតុ, ទុក្ខំ ទុក្ខសច្ចំ”** *ដូច្នេះ ព្រះមានព្រះភាគទ្រង់លើកធម៌ទាំងឡាយ មានខន្ធជាដើម ដែលព្រះអង្គទ្រង់ប្រារព្ធហើយ សម្ដែងហើយ ក្នុងពេលមុន យ៉ាងណា, សូម្បីសង្ខារ ៣ ខាងដើម ព្រះអង្គទ្រង់មិនប្រារព្ធយ៉ាងនោះទេ, តែទ្រង់សម្ដែងបែកទុកថា* **“អស្សាសបស្សាសា កាយសង្ខារោ** *= ខ្យល់អស្សាសៈ និងបស្សាសៈ ឈ្មោះថា កាយសង្ខារ”* *ជាដើម ។*

*ក្នុងសង្ខារទាំង ៣ នេះ សង្ខារនៃកាយ ឈ្មោះថា* ***កាយសង្ខារ*** *។ សង្ខារជាផលរបស់ករជកាយ ដែលកើតហើយអំពីហេតុនោះឯង ឈ្មោះថា* ***កាយសង្ខារ*** *ព្រោះពាក្យថា “ធម៌ទាំងឡាយនោះ គឺខ្យល់អស្សាសៈ និង បស្សាសៈ មានក្នុងកាយ ជាប់ជាមួយនឹងកាយ”*[១០] *។*

*ន័យម្យ៉ាងទៀត សភាវៈណា ដែលបច្ច័យធ្វើព្រម គឺតាក់តែង, ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា* ***សង្ខារ*** *។*

***សួរថា*** *សង្ខារនោះ អ្វីរមែងធ្វើព្រម គឺតាក់តែង ?*

*ឆ្លើយថា សង្ខារនោះ គឺកាយរមែងតាក់តែង ក៏សង្ខារនេះ គឺករ-ជកាយរមែងតាក់តែង ដូចស្នប់បង្កើតខ្យល់ សូម្បីកាលបើយ៉ាងនេះ* ***កាយ-សង្ខារ*** *គឺសង្ខារនៃកាយ, អធិប្បាយថា ខ្យល់អស្សាសៈ និងបស្សាសៈ ដែលកាយធ្វើហើយ ។*

*ក៏សភាវៈណា រមែងតាក់តែង ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា* ***សង្ខារ*** *ព្រោះពាក្យថា* ***“ម្នាលវិសាខៈមានអាយុ បុគ្គលត្រិះរិះ ហើយ ពិចារណាហើយ ទើបនិយាយជាខាងក្រោយ, ព្រោះហេតុនោះ វិតក្កៈ និងវិចារៈ ទើបឈ្មោះថា វចីសង្ខារ”***[១១] *។*

---

[១០] ម. មូ., សំ. សឡា. ។

[១១] ម. មូ. ។

***សួរថា*** *អ្វីរមែងតាក់តែង ?*

*ឆ្លើយថា ចិត្តរមែងតាក់តែង ។ សង្ខារនៃចិត្ត ឈ្មោះថា* ***ចិត្ត-សង្ខារ*** *ព្រោះធ្វើឆដ្ឋីវិភត្តិឲ្យចុះក្នុងអត្ថនៃតតិយាវិភត្តិ; ពាក្យថា* ***ចិត្តសង្ខារ*** *នេះ ជាឈ្មោះរបស់ចេតសិកធម៌ទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានទាំងអស់; ព្រះមានព្រះភាគទ្រង់ត្រាស់វៀរវិតក្កៈ និងវិចារៈចេញ ព្រោះទ្រង់កាន់យកវិតក្កៈ និងវិចារៈ ជាចំណែកមួយ ដោយភាពជាវចីសង្ខារ ។*

*ឥឡូវនេះ ព្រះអង្គទ្រង់ផ្ដើមបទសោធនវារៈថា* **"កាយោ កាយ-សង្ខារោ"** *ជាដើម, យមកៈ ៦ យ៉ាង គឺយមកៈ ៣ យ៉ាង ក្នុងអនុ-លោមន័យ, ៣ យ៉ាងទៀត ក្នុងបដិលោមន័យរបស់បទសោធនវារៈនោះ; យមកៈ ១២ យ៉ាង គឺយមកៈ ៦ យ៉ាង ក្នុងអនុលោមន័យ, ៦ យ៉ាងទៀត ក្នុងបដិលោមន័យ ព្រោះធ្វើមូលនៃសង្ខារមួយៗ ក្នុងបទសោធន-មូលចក្កវារៈឲ្យជាពីរ ។*

*ចំណែកក្នុងសុទ្ធសង្ខារវារៈ ត្រាស់យមកៈទាំងឡាយទុកដោយន័យជាដើមថា* **"រូបំ ខន្ធោ, ខន្ធោ រូបំ; ចក្ខុំ អាយតនំ, អាយតនំ ចក្ខុំ"** *ដូច្នេះ ក្នុងវារៈទាំងឡាយ មានសុទ្ធក្ខន្ធវារៈជាដើម យ៉ាងណា, ក៏ត្រាស់យមកៈ ៦ យ៉ាង សូម្បីក្នុងសុទ្ធិកវារៈទាំងពួង ដូច្នោះដែរ គឺយមកៈ ៣ យ៉ាង ក្នុងអនុលោម ៣, ក្នុងបដិលោម គឺមានកាយសង្ខារជាមូល ២*

មានវចីសង្ខារជាមូល ១ ដោយន័យជាដើមថា **“កាយសង្ខារោ វចីសង្ខារោ, វចីសង្ខារោ កាយសង្ខារោ”** មិនត្រាស់ថា **“កាយោ សង្ខារោ, សង្ខារោ កាយោ”** ដូច្នេះទេ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះយមកៈទាំង ៦ យ៉ាងនោះ មិនមានដោយអំណាចនៃបទមួយៗ ក្នុងសុទ្ធិកវារៈ; អត្ថរមែងមានដោយអំណាចនៃការជម្រះបទមួយៗ ក្នុងសុទ្ធិកវារៈថា **“រូបំ ខន្ធោ, ខន្ធោ រូបំ; ចក្ខុ អាយតនំ, អាយតនំ ចក្ខុ”** ព្រោះក្នុងខន្ធយមកៈជាដើម ទ្រង់មានបំណងយកខន្ធដ៏ប្រសើរ មានរូបក្ខន្ធជាដើម និងអាយតនៈដ៏ប្រសើរ មានចក្ខាយតនៈជាដើម យ៉ាងណា, ក្នុងសង្ខារយមកៈនេះ មិនមានអត្ថថា **“កាយោ សង្ខារោ, សង្ខារោ កាយោ”** យ៉ាងនេះទេ; ចំណែកអត្ថតែមួយថា **កាយសង្ខារោ** រមែងមានដោយបទ ២ គឺកាយ និងសង្ខារ; ព្រះមានព្រះភាគ មិនត្រាស់ថា **“កាយោ សង្ខារោ, សង្ខារោ កាយោ”** ដូច្នេះទេ ព្រោះមិនមានអត្ថថា អស្សាសៈ ឬបស្សាសៈ ដោយអំណាចនៃការជម្រះបទមួយៗ ក្នុងសុទ្ធិកវារៈ, តែទ្រង់ត្រាស់ថា **“កាយោ កាយសង្ខារោ”** ជាបទដើម, សូម្បីពាក្យថា **កាយោ កាយសង្ខារោ** រមែងមិនសមគួរដោយបទរបស់កាយ វចី

និងចិត្ត ព្រោះភាវៈនៃសង្ខារទាំងឡាយដែលលោកមានបំណងយកហើយ លោកមិនកាន់យកក្នុងទីនេះទេ; នេះជាសុទ្ធសង្ខារវារៈ អធិប្បាយថា ក្នុងការជម្រះបទ សូម្បីវៀរចាកអត្ថហើយ ការពោលរមែងមិនសមគួរទេ ន័យនោះ លោកកាន់យកហើយក្នុងសុទ្ធសង្ខារវារៈ; តែក្នុងបទសោធនវារៈនេះ យមកៈ ៦ យ៉ាង រមែងសមគួរ ព្រោះធ្វើមូលនៃសង្ខារមួយៗ គឺ **កាយសង្ខារោ វចីសង្ខារោ, វចីសង្ខារោ កាយសង្ខារោ** ឲ្យមានពីរៗ ព្រោះភាវៈនៃកាយសង្ខារមានតែម្យ៉ាង មកអំពីវចីសង្ខារ គឺមួយៗ ដូចនឹងវចីសង្ខារជាដើម វចីសង្ខារមានតែម្យ៉ាង មកអំពីចិត្តសង្ខារជាដើម និងចិត្តសង្ខារមានតែម្យ៉ាង មកអំពីសង្ខារជាដើម; ក្នុងយមកៈ ៦ យ៉ាងនោះ រមែងមាន ៣ យ៉ាងប៉ុណ្ណោះ ***ព្រោះរាប់ហើយ និងមិនរាប់ទៀត*** (អគ្គហិតគ្គហណេន); ព្រោះហេតុនោះ ទើបត្រាស់យមកៈទុក ៦ យ៉ាង គឺ ៣ យ៉ាង ក្នុងអនុលោមន័យ, ៣ យ៉ាងទៀត ក្នុងបដិលោមន័យ ដើម្បីសម្ដែងយមកៈ ៣ យ៉ាងនោះឯង; អធិប្បាយថា ក៏ក្នុងសុទ្ធសង្ខារ-មូលចក្កវារៈ ទ្រង់មិនកាន់យកហើយ ក្នុងទីនេះ គប្បីជ្រាបខទ្ទេសវារៈនៃបណ្ណត្តិវារៈ ដោយប្រការដូច្នេះ ។

ក៏ក្នុងអនុលោមនៃនិទ្ទេសវារៈមុន ឈ្មោះនៃសង្ខារទាំងឡាយ មានកាយសង្ខារជាដើម មិនមែនកាយជាដើមទេ, ព្រោះហេតុនោះ ទើបលោក

បដិសេធថា **“នោ = មិនមែន”** ។

ក្នុងបដិលោម ពាក្យសួរថា **ន កាយោ ន កាយសង្ខារោ** ដូច្នេះ បានដល់ រមែងសួរថា ***ធម៌ណាមិនមានកាយ, សូម្បីធម៌នោះ ក៏មិនមានកាយសង្ខារឬ ?*** ពាក្យឆ្លើយដែលថា កាយសង្ខារមិនមែនកាយ តែជាកាយសង្ខារ អធិប្បាយថា កាយសង្ខារ មិនមែនជាកាយទេ, កាយនោះក៏មិនមែនជាកាយសង្ខារដែរ ។

ពាក្យថា **អវសេសា** អធិប្បាយថា ពួកពីរនៃសង្ខារដ៏សេសតែម្យ៉ាងក៏ទេ, សូម្បីធម្មជាតិទាំងអស់ ដែលផ្សេងគ្នាដោយសន្តតិបញ្ញត្តិដ៏សេស ដែលរួចផុតហើយចាកកាយសង្ខារ ក៏មិនឈ្មោះថា កាយ និងមិនឈ្មោះថា កាយសង្ខារទេ គប្បីជ្រាបអត្ថក្នុងពាក្យវិសជ្ជនាទាំងពួង ដោយឧបាយនេះ មានប្រការដូច្នេះចុះ ៕

ចប់បញ្ញត្តិវារៈ

## ២.ពណ៌នាអំពីបវត្តិវារៈ

ក៏ ***បវត្តិវារៈ*** ក្នុងសង្ខារយមកៈនេះ ត្រង់អនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាល យមកៈ ៣ យ៉ាងប៉ុណ្ណោះ គឺយមកៈដែលមានកាយសង្ខារជាមូល ២ យ៉ាង, ដែលមានវចីសង្ខារជាមូលម្យ៉ាង រមែងមាន ក្នុងពាក្យសួរថា ***“កាយសង្ខារកំពុងកើតឡើងដល់បុគ្គលណា វចីសង្ខារ ក៏កំពុងកើតឡើងដល់បុគ្គលនោះឬ ?”*** ដូច្នេះ, យមកៈ ៣ យ៉ាងនោះ លោកកាន់យកហើយមែនពិត; សូម្បីក្នុងបដិលោមន័យក្តី ក្នុងវារៈទាំងឡាយ មានឱកាសវារៈជាដើមក្តី នៃបវត្តិវារៈនោះ ក៏មានន័យដូចគ្នានេះដែរ; គប្បីជ្រាបការរាប់យមកៈដោយអំណាចនៃយមកៈ ៣ យ៉ាង ក្នុងវារៈទាំងពួង ត្រង់បវត្តិវារៈយ៉ាងនេះចុះ ។

ក៏ការវិនិច្ឆ័យអត្ថក្នុងបវត្តិវារៈនេះ គប្បីជ្រាបលក្ខណៈនេះ ដូចតទៅ ៖

ក៏ក្នុងសង្ខារយមកៈនេះ ប្រភេទនៃកាល មានបច្ចុប្បន្នកាលជាដើម គប្បីកាន់យកដោយអំណាចនៃបវត្តិកាល ដោយពាក្យជាដើមថា ***“ក្នុងឧប្បាទក្ខណៈនៃខ្យល់អស្សាសៈ និងបស្សាសៈ, ក្នុងឧប្បាទក្ខណៈនៃការកើតវិតក្កៈ និងវិចារៈ”*** ដូច្នេះ, មិនគប្បីកាន់យកដោយអំណាចនៃចុតិ និងបដិសន្ធិកាលឡើយ; គប្បីកាន់យកដោយអំណាចនៃបវត្តិកាល ដោយពាក្យ

ជាដើមថា ***“កាយសង្ខារកំពុងកើតឡើងក្នុងទីនោះ គឺក្នុងទុតិយជ្ឈាន និងតតិយជ្ឈាន”***; សូម្បីក្នុងចតុត្ថជ្ឈាន (ភូមិ) គប្បីជ្រាបថា លោកកាន់យកហើយដោយអំណាចនៃឱកាសវារៈ គប្បីជ្រាបវិនិច្ឆ័យអត្ថ ដោយអំណាចនៃលក្ខណៈដែលមាននោះ ក្នុងបវត្តិវារៈនេះ មានប្រការដូច្នេះ ។

គប្បីជ្រាបន័យខាងដើម ក្នុងបវត្តិវារៈនោះ ដូចតទៅ ៖

ពាក្យថា វៀរវិតក្កៈ និងវិចារៈ លោកពោលហើយដោយអំណាចនៃទុតិយជ្ឈាន និងតតិយជ្ឈាន; បទថា **តេសំ** បានដល់ ការព្រមព្រៀងនៃទុតិយជ្ឈាន និងតតិយជ្ឈានរបស់បុគ្គលទាំងនោះ; បទថា **កាមាវចរានំ** បានដល់ សត្វដែលកើតហើយក្នុងកាមាវចរភូមិ; តែថា ខ្យល់អស្សាសៈ និងបស្សាសៈ រមែងមិនមានដល់ទេវតាក្នុងរូបាវចរភូមិទេ, សូម្បីរូបនោះឯងក៏មិនមានដល់ទេវតាក្នុងអរូបាវចរភូមិដែរ ។

ពាក្យថា ***វៀរខ្យល់អស្សាសៈ និងបស្សាសៈ*** ដូច្នេះ លោកពោលសំដៅយកការកើតឡើងនៃវិតក្កៈ និងវិចារៈ របស់សត្វដែលកើតហើយក្នុងរូបភព និងអរូបភព ។

ពាក្យថា ***ក្នុងបឋមជ្ឈាន ក្នុងកាមាវចរ*** ដូច្នេះ បានដល់ បឋមជ្ឈានក្នុងកាមាវចរភូមិនេះ លោកកាន់យកដោយអំណាចនៃមគ្គដ៏លើស (អរហត្តមគ្គ), មិនកាន់យកដោយអំណាចនៃអប្បនាទេ; ព្រោះថា ពួកពីរនៃសង្ខារ

*នេះ រមែងកើតឡើងក្នុងចិត្តដែលប្រព្រឹត្តទៅជាមួយវិតក្កៈ និងវិចារៈ សូម្បីដែលមិនទាន់ដល់អប្បនា ។*

*ពាក្យថា* ***ក្នុងភង្គខណៈនៃចិត្ត*** *លោកពោលទុកហើយ ព្រោះភាវៈនៃកាយសង្ខារមានចិត្តជាសមុដ្ឋាន; ពិតមែន កាលចិត្តកើតឡើងនោះឯង រមែងញុំាងរូប ឬអរូបឲ្យកើតឡើង, គ្រារលត់ រមែងមិនញុំាងរូប ឬអរូប ឲ្យកើតឡើងទេ ។*

*ពាក្យថា* ***គ្រាចិត្តដួងទីពីរនៃសុទ្ធាវាសព្រហ្មប្រព្រឹត្តទៅ*** *បានដល់ភវង្គចិត្តដែលជាចិត្តទីពីរ រាប់អំពីបដិសន្ធិចិត្ត; ពាក្យនោះ លោកពោលហើយដើម្បីសម្តែងថា ភវង្គចិត្តនោះ សូម្បីកាលបដិសន្ធិចិត្តប្រព្រឹត្តទៅ មិនធ្លាប់កើតឡើងហើយដល់ព្រហ្មក្នុងសុទ្ធាវាសភូមិនោះ ក៏ពិតមែន, ប៉ុន្តែវិបាកចិត្តដែលមិនសម្បយុត្តគ្នា រមែងប្រព្រឹត្តទៅរហូតអស់កាលត្រឹមណា, ឈ្មោះថាមិនធ្លាប់កើតឡើងរហូតអស់កាលត្រឹមនោះឯង; ព្រហ្មទាំងនោះ កើតឡើងហើយដោយវិបាកចិត្តរបស់ឈានណា, វិបាកចិត្តរបស់ឈាននោះ កាលកើតសូម្បីមួយរយដងខ្លះ មួយពាន់ដងខ្លះ ឈ្មោះថា* ***បឋមចិត្ត*** *នោះឯង; សំដៅដល់ភវង្គដែលកើតបន្តអំពីបដិសន្ធិចិត្ត ។*

*ចំណែកអាវជ្ជនចិត្តក្នុងភវនិកន្តិ (ជវនៈ) មិនមានដូចវិបាកចិត្តទេ*

(ព្រោះអាវជ្ជនចិត្ត ជាកិរិយាចិត្ត) ឈ្មោះថា ***ទុតិយចិត្ត*** គប្បីជ្រាបថា ពាក្យថា ***ទុតិយចិត្ត*** នេះ លោកពោលសំដៅយក ***អាវជ្ជនចិត្ត*** នោះ ។

ពាក្យថា ***នៃបុគ្គលដែលព្រមព្រៀងដោយបច្ឆិមចិត្ត*** បានដល់ ព្រះខីណាស្រពព្រមព្រៀងដោយចិត្តដែលមិនជាបច្ច័យដល់បដិសន្ធិ ជាចិត្តដួងទីបំផុតនៃចិត្តទាំងពួង ។

ពាក្យថា ***នូវបច្ឆិមចិត្តដែលមិនមានវិតក្កៈ មិនមានវិចារៈ*** នេះ លោកពោលហើយដោយអំណាចនៃចុតិចិត្ត ដែលប្រកបដោយទុតិយជ្ឈាន របស់រូបាវចរបុគ្គល និងដោយអំណាចនៃចុតិចិត្តដែលប្រកបដោយចតុត្ថជ្ឈាន របស់រូបាវចរបុគ្គល; បទថា ***តេសំ*** បានដល់ ការព្រមព្រៀងនៃបច្ឆិមចិត្តជាដើម របស់បុគ្គលទាំងនោះ ។

លោកឲ្យពាក្យឆ្លើយតបថា ***ត្រូវហើយ*** (មែន) ព្រោះការរលត់ទៅក្នុងខណៈមួយៗ របស់កាយសង្ខារ (តែងរលត់ទៅ) ព្រមជាមួយនឹងចិត្តសង្ខារនោះឯង, មិនបានឆ្លើយតប ព្រោះការរលត់ទៅនៃចិត្តសង្ខារព្រមជាមួយនឹងកាយសង្ខារទេ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះចិត្តសង្ខារ សូម្បីវៀរចាកកាយសង្ខារ រមែងកើតឡើងផង រមែងរលត់ទៅផង, ចំណែកកាយសង្ខារមានចិត្តជាសមុដ្ឋាន ។ ***ខ្យល់***

***អស្សាសៈ បស្សាសៈ និងរូបដែលមានចិត្តជាសមុដ្ឋាន កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត តាំងនៅដរាបដល់ចិត្ត ១៦ ដួងដទៃទៀត កើតឡើង ។***

*ប្រើនបទថា* **តេសំ សោឡសន្នំ សព្វបច្ឆិមេន សទ្ធឹ និរុជ្ឈតិ** *បានដល់រូបដែលមានចិត្តជាសមុដ្ឋាន រមែងកើតឡើងព្រមជាមួយនឹងចិត្តដួងណា, រមែងរលត់ទៅព្រមជាមួយនឹងចិត្តដួងទី ១៧ ចាប់តាំងពីចិត្តនោះ; រមែងមិនរលត់ទៅក្នុងឧប្បាទៈ ឬឋិតិខណៈនៃចិត្តដួងណាៗ, និងរមែងមិនកើតឡើងសូម្បីក្នុងឋិតិខណៈ ឬភង្គខណៈឡើយ លោកពោលថា* **"អាមន្តា = មែន"** *ព្រោះការរលត់ទៅក្នុងខណៈមួយៗ ព្រមជាមួយនឹងចិត្តសង្ខារ តាមពិតនេះជាធម្មតារបស់រូបដែលមានចិត្តជាសមុដ្ឋាន ។*

*តែក្នុងអដ្ឋកថាសីហឡៈនៃវិភង្គប្បករណ៍ លោកពោលទុកថា "រូបដែលមានចិត្តជាសមុដ្ឋាន រមែងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្តដួងទី ១៧" ដូច្នេះ, ពាក្យពោលនោះ រមែងខុសចាកព្រះបាលីនេះ; លោកពោលហើយក្នុងព្រះបាលីថា* ***"ក៏បាលី (បិដក) នោះឯង មានកម្លាំងជាងអដ្ឋកថា"*** *គប្បីកាន់យកពាក្យពោលនោះ ជាប្រមាណ ។*

*ក្នុងពាក្យសួរថា* ***កាយសង្ខារកើតដល់បុគ្គលណា វចីសង្ខារ ក៏រលត់ដល់បុគ្គលនោះឬ ?*** *ដូច្នេះនេះ លោកបដិសេធថា* ***មិនមែន*** *ព្រោះកាយសង្ខាររមែងកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្ត, តែវិតក្កៈ និងវិចារៈ រមែង*

*រលត់ទៅក្នុងខណៈនោះ ក៏ទេ គប្បីជ្រាបវិនិច្ឆ័យក្នុងទីទាំងពួង ដោយមុខន័យនេះ; បរិញ្ញាវារៈប្រព្រឹត្តទៅតាមប្រក្រតីនុ៎ះឯង ។*

**ចប់សង្ខារយមកៈ**

---------

## ៧.អនុសយយមកវណ្ណនា ពណ៌នាអំពីបរិច្ឆេទបរិច្ឆន្នុទ្ទេសវារៈ

*ឥឡូវនេះ ជាការពណ៌នាសេចក្ដីនៃអនុសយយមកៈ ដូចដែលព្រះមានព្រះភាគទ្រង់រួបរួមឯកទេសនៃកុសលធម៌ជាដើម ដែលទ្រង់សម្ដែងទុកក្នុងមូលយមកៈនុ៎ះឯង ដោយអំណាចនៃការបានដឹងហើយ ទ្រង់សម្ដែងទុកក្នុងលំដាប់នៃសង្ខារយមកៈ ។ បណ្ឌិតគប្បីជ្រាបនូវការកំណត់បាលីក្នុងអនុសយយមកៈសិន ព្រោះថា អនុសយយមកៈនេះ ព្រះអង្គទ្រង់ទេសនាបាលីទុកម្ដងទៀត, មិនដូចទេសនាក្នុងខន្ធយមកៈជាដើមទេ ។*

***សួរថា*** *ទ្រង់ទេសនាទុកដូចម្ដេច ?*

*ឆ្លើយថា ខាងដើម ទ្រង់ទេសនាសម្ដែងទុក ៣ វារៈ គឺ*

**១-បរិច្ឆេទវារៈ** *វារៈពោលអំពីការកំណត់*

**២-បរិច្ឆិន្នុទ្ទេសវារៈ** *វារៈពោលអំពីឧទ្ទេសដែលកំណត់ទុកហើយ*

**៣-ឧប្បត្តិដ្ឋានវារៈ** *វារៈពោលអំពីកន្លែងជាទីកើតឡើងមុន ។*

*ដើម្បីឲ្យសិក្សាអនុស័យទាំងឡាយ ដោយអាការ ៣ យ៉ាង គឺដោយ*

*បរិច្ឆេទ ដោយខុទ្ទេស និងដោយខុប្បត្តិដ្ឋាន; តពីនោះ ក៏ទ្រង់ប្រកបអនុស័យទាំងឡាយ សម្ដែងយមកទេសនាដោយអំណាចនៃមហាវារៈ ៧ ។*

*ក្នុងអនុសយយមកៈនោះ ពាក្យថា* **"សត្ត អនុសយា"** *នេះ ឈ្មោះថា* ***បរិច្ឆេទវារៈ*** *ព្រោះភាវៈនៃអនុស័យទាំងឡាយ ព្រះអង្គកំណត់ចំនួនសម្ដែងទុកថា "អនុស័យនេះ មាន ៧ ប៉ុណ្ណោះ, មិនលើសជាងនេះ, មិនខ្វះជាងនេះទេ" ។*

*ពាក្យថា* **"កាមរាគានុសយោ ។ បេ ។ អវិជ្ជានុសយោ"** *នេះ ឈ្មោះថា* ***បរិច្ឆិន្នុទ្ទេសវារៈ*** *ព្រោះវារៈនេះ ទ្រង់លើកត្រឹមតែឈ្មោះនៃធម៌ដែលកំណត់ទុកហើយ ដោយបរិច្ឆេទវារៈនោះ ឡើងសម្ដែងថា "ឈ្មោះថាធម៌ទាំងនេះ ជាធម៌ប្រភេទនោះ" ។*

*ក្នុងសេចក្ដីនោះ ពាក្យថា* **"កាមរាគានុសយោ អនុសេតិ ឯត្ថ ។ បេ ។ អវិជ្ជានុសយោ អនុសេតិ"** *នេះ ឈ្មោះថា* ***ឧប្បត្តិដ្ឋានវារៈ*** *ព្រោះវារៈនេះ ទ្រង់សម្ដែងឋានជាទីកើតឡើងនៃធម៌ទាំងនោះ យ៉ាងនេះថា* ***"អនុស័យទាំងនេះ រមែងដេកត្រាំក្នុងវារៈទាំងឡាយឈ្មោះនេះ"*** *។*

*ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ប្រកបនូវអនុស័យទាំងឡាយហើយ សម្ដែងយមកទេសនាដោយអំណាចនៃមហាវារៈ ៧ ឯណា,*

*មហាវារៈទាំងនោះ មានឈ្មោះដូច្នេះ គឺ*

**១.អនុសយវារៈ** *វារៈពោលអំពីអនុស័យ*

**២.សានុសយវារៈ** *វារៈពោលអំពីអ្នកមានអនុស័យ*

**៣.បជហនវារៈ** *វារៈពោលអំពីការលះ*

**៤.បរិញ្ញាវារៈ** *វារៈពោលអំពីការកំណត់ដឹង*

**៥.បហីនវារៈ** *វារៈពោលអំពីការលះបានហើយ*

**៦.ឧប្បជ្ជនវារៈ** *វារៈពោលអំពីការកើត*

**៧.ធាតុវារៈ** *វារៈពោលអំពីធាតុ ៕*

---

## អធិប្បាយអនុសយវារៈ

*បណ្ដាមហាវារៈទាំងនោះ វារៈទី ១ ឈ្មោះថា* ***អនុសយវារៈ*** *នោះ មាន ២ ន័យ គឺដោយអំណាចនៃអនុលោមន័យ និងបដិលោមន័យ ។ ក្នុងន័យទាំង ២ នោះ អនុលោមន័យមានអន្តរវារៈ ៣ ដោយអំណាចនៃបុគ្គល និងភូមិ គឺ*

**-យស្ស អនុសេតិ** *...កំពុងដេកត្រាំដល់បុគ្គលណា (បុគ្គលវារៈ)*

**-យត្ថ អនុសេតិ** *...កំពុងដេកត្រាំក្នុងភូមិណា (ឱកាសវារៈ)*

**-យស្ស យត្ថានុសេតិ** *...កំពុងដេកត្រាំដល់បុគ្គលណា ក្នុងភូមិណា*

*(បុគ្គលោកាសវារៈ)* ។

*បណ្ដាអន្តរវារៈទាំង ៣ នោះ ក្នុងបុគ្គលវារៈដំបូង មាន ២១ យមកៈ គឺមានកាមរាគានុស័យជាមូល ៦ យមកៈ ដោយព្រះបាលីថា ៖*

**“យស្ស កាមរាគានុសយោ អនុសេតិ, តស្ស បដិឃានុសយោ អនុសេតិ, យស្ស វា បន បដិឃានុសយោ អនុសេតិ, តស្ស កាមរាគានុសយោ អនុសេតិ ។**

**យស្ស កាមរាគានុសយោ អនុសេតិ, តស្ស មានានុសយោ... ទិដ្ឋានុសយោ... វិចិកិច្ឆានុសយោ... ភវរាគានុសយោ... អវិជ្ជានុសយោ... អនុសេតិ, យស្ស វា បន អវិជ្ជានុសយោ អនុសេតិ, តស្ស កាមរាគានុសយោ អនុសេតិ”** ។

*ដែលមានបដិឃានុស័យជាមូល ៥ យមកៈ, មានមានានុស័យជាមូល ៤ យមកៈ, មានទិដ្ឋានុស័យជាមូល ៣ យមកៈ, មានវិចិកិច្ឆានុស័យជាមូល ២ យមកៈ, មានភវរាគានុស័យជាមូល ១ យមកៈ ដោយអំណាចនៃការរាប់ហើយ និងមិនរាប់ទៀត; សូម្បីវារៈទាំងអស់ដែលមានមូល ១ ទើបរួមត្រូវជា ២១ យមកៈ ដោយប្រការដូច្នេះ ។*

*បុគ្គលវារៈ ១៥ យមកៈដទៃទៀត គឺដែលមានមូល ២ (ទុកមូល) ដែលមានមកក្នុងព្រះបាលីយ៉ាងនេះថា* **“យស្ស កាមរាគានុសយោ ច**

**បដិឃានុសយោ ច អនុសេន្តិ”** ដូច្នេះ មាន ៥ យមកៈ, ដែលមានមូល ៣ (តិកមូល) មាន ៤ យមកៈ, ដែលមានមូល ៤ (ចតុក្កមូល) មាន ៣ យមកៈ, ដែលមានមូល ៥ (បញ្ចកមូល) មាន ២ យមកៈ, ដែលមានមូល ៦ (ឆក្កមូល) ១ យមកៈ ។ រួមក្នុងបុគ្គលវារៈត្រូវជា ៣៦ យមកៈ គឺយមកៈដែលមានមូល ១ មាន ២១ យមកៈ ដែលមានមូល ២ ជាដើម ១៥ យមកៈទៀត (២១ + ១៥ = ៣៦) ។

ក្នុងឱកាសវារៈ និងបុគ្គលោកាសវារៈ ក៏ដូចគ្នាដែរ គឺមាន ៣៦, ព្រោះហេតុនោះ សូម្បីអន្តរវារៈទាំងអស់ ក្នុងអនុលោមន័យ ទើបត្រូវជា ១០៨ យមកៈ, ក្នុងបដិលោមន័យ ក៏ដូចគ្នាដែរ (មាន ១០៨) ព្រោះហេតុដូច្នោះ ក្នុងមហាវារៈដំបូង គឺអនុសយវារៈ ទើបរួមត្រូវជា ២១៦ យមកៈ បណ្ឌិតគប្បីជ្រាបពាក្យបុច្ឆាគុណនឹង ២ តែគ្រប់យមកៈនោះ, សេចក្តី គឺពាក្យវិសជ្ជនាគុណនឹង ២ អំពីពាក្យបុច្ឆានោះ ។ ក៏ក្នុងអនុសយវារៈនេះ យ៉ាងណា, គប្បីជ្រាបន័យក្នុងយមកៈមួយៗ សូម្បីនៃមហាវារៈទាំង ៥ នេះ គឺ ***សានុសយវារៈ បជហនវារៈ បរិញ្ញាវារៈ បហីនវារៈ*** និង ***ឧប្បជ្ជនវារៈ*** ថា “ពាក្យបុច្ឆាត្រូវគុណនឹង ២ គ្រប់ៗ យមកៈ, អត្ថន័យ គឺពាក្យវិសជ្ជនាត្រូវគុណនឹង២ អំពីពាក្យបុច្ឆានោះ” ។ តែថា ក្នុងមហាវារៈ ៥ នេះ មានសេចក្តីផ្សេងអំពី ៣ វារៈ ដំបូង គឺក្នុង

ទិកាសវារៈព្រះមានព្រះភាគមិនត្រាស់ពាក្យថា **“យត្ថ យត្ថ”** ទេ, តែទ្រង់សម្ដែងទេសនា ដោយព្រះតម្រាស់ថា **“យតោ យតោ”** ។ ពាក្យដ៏សេសក៏មានន័យដូចគ្នានេះដែរ ។

ក៏ក្នុងមហាវារៈទាំងអស់ វារៈចុងក្រោយ ឈ្មោះថា ***ធាតុវារៈ***, ធាតុវារៈនោះ តាំងឡើង ២ យ៉ាង គឺ ***បុច្ឆាវារៈ*** និង ***វិសជ្ជនាវារៈ***; ***សួរថា*** ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ក្នុងពាក្យបុច្ឆាវារៈនៃធាតុវារៈនោះថា ***“កាលបើសត្វរលត់ក្នុងកាមធាតុ ហើយចូលដល់កាម-ធាតុ”*** ដូច្នេះ តែមិនត្រាស់ថា ***“កាលបើសត្វចូលដល់កាមធាតុ ចុតិហើយចាកកាមធាតុ”*** ដូច្នេះទេ ឆ្លើយថា កាលបើពោលដោយអត្ថហើយមិនប្លែកគ្នាឡើយ; ព្រោះសូម្បីពាក្យសួរទាំងពីរនេះ ក៏មានអត្ថដូចគ្នាដែរ, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់បុច្ឆាយមកៈមួយៗ នោះឯង ពីយមកៈមួយៗ ដោយលំដាប់ ក្នុងទីបំផុតនៃពាក្យសួរទាំងអស់ ហើយទើបធ្វើពាក្យវិសជ្ជនាទុក តាមន័យជាដើមថា ***“កាលបើសត្វចុតិចាកកាមធាតុ ហើយចូលដល់កាមធាតុ អនុស័យ ៧ រមែងដេកត្រាំដល់សត្វពួកណាខ្លះ”*** ដូច្នេះ; ក្នុងបណ្ដាពាក្យសួរទាំងអស់នោះ អនុលោមបុច្ឆាមានកាមធាតុជាមូល ៩ គឺសុទ្ធិកបុច្ឆា ៦ យមកៈ ដោយព្រះបាលីថា

*“កាលបើសត្វចុតិចាកកាមធាតុ ចូលដល់កាមធាតុ..., ចូលដល់រូបធាតុ..., ចូលដល់អរូបធាតុ..., ចូលដល់នកាមធាតុ... ចូលដល់នរូបធាតុ និងចូលដល់នអរូបធាតុ”* ដូច្នេះ, ព្រមទាំងមិស្សកបុច្ឆា ៣ ទៀត គឺ *“កាលបើសត្វចុតិចាកកាមធាតុហើយ ចូលដល់នកាមធាតុ នអរូបធាតុ, ចូលដល់នរូបធាតុ នអរូបធាតុ..., ចូលដល់នកាមធាតុ និងនរូបធាតុ”* ។

អនុលោមបុច្ឆាដែលមាននរូបធាតុជាមូល ក៏មាន ៩, ដែលមានអរូបធាតុជាមូល ក៏មាន ៩ ដូចគ្នាដែរ រួមត្រូវជាអនុលោមបុច្ឆា ២៧; បដិលោមបុច្ឆាដែលមាននកាមធាតុ នរូបធាតុ និងនអរូបធាតុជាមូល ក៏មាន ២៧ ដែរ ។ រួមពាក្យសួរទាំងអស់ គឺអនុលោមបុច្ឆា ២៧ បដិលោមបុច្ឆា ២៧ និងពាក្យសួរដែលជាទុកមូល ២៧ ទៀត ដូចព្រះបាលីថា **“ន កាមធាតុយា ន អរូបធាតុយា ន រូបធាតុយា ន អរូបធាតុយា ន កាមធាតុយា ន រូបធាតុយា”** ដូច្នេះ ទើបត្រូវជាពាក្យបុច្ឆា ១៨ ។ បណ្ឌិតគប្បីធ្វើការវិសជ្ជនាបញ្ហាក្នុងទីនេះ ដោយអំណាចនៃពាក្យសួរទាំងនោះចុះ ។ សេចក្ដីនេះ ជាការកំណត់បាលីក្នុងធាតុវារៈ និងគប្បីជ្រាបសូម្បីការកំណត់បាលីក្នុងអនុសយយមកៈទាំងអស់ ដោយប្រការដូច្នេះចុះ ។

ក៏ពាក្យណាៗ ក្នុងអនុសយយមកៈដែលមានអត្ថន័យដ៏លំបាក គប្បីជ្រាបវិនិច្ឆ័យកថាក្នុងទីនោះៗ តាំងពីដើមថា ៖

***សួរថា*** *ឈ្មោះថា* ***អនុស័យ*** *ព្រោះអត្ថថា ដូចម្ដេច ?*

*ឆ្លើយថា ឈ្មោះថា* ***អនុស័យ*** *ព្រោះអត្ថថា ដេកត្រាំ ។*

***សួរថា*** *អនុស័យនោះ ឈ្មោះថា មានអត្ថដេកត្រាំ តើដូចម្ដេច ?*

*ឆ្លើយថា ដែលមានឈ្មោះយ៉ាងនោះ ព្រោះអត្ថថា* ***លះមិនបាន*** *។*

***ពិតមែនហើយ កិលេសទាំងនេះ ឈ្មោះថា រមែងដេកសម្ងំក្នុងសន្តានរបស់សត្វ ព្រោះអត្ថថា លះមិនបាន, ព្រោះហេតុដូច្នោះ ទើបអាចារ្យទាំងឡាយ ហៅកិលេសទាំងនោះថា អនុស័យ*** *។*

*ពាក្យថា* **"អនុសេន្តិ** *= រមែងដេកសម្ងំ"* *អធិប្បាយថា មានហេតុដ៏សមគួរហើយទើបកើតឡើង; ម្យ៉ាងទៀត កិលេសដែលមានអាការលះមិនបាន ឈ្មោះថា* ***អនុសយដ្ឋៈ*** *ព្រោះអត្ថថា គប្បីមានការដេកសម្ងំ, ក៏មិនគួរពោលថា* ***"កិលេសមានអាការលះមិនបាននេះ រមែងកើតឡើង"*** *ដូច្នេះទេ, ព្រោះហេតុដូច្នោះ គួរពោលថា* ***"អនុស័យទាំងឡាយ រមែងកើតឡើង"*** *។ ពាក្យថា* **"អនុសយា ឧប្បជ្ជន្តិ"** *នេះ ក្នុងទីនេះ ជាពាក្យយល់ព្រមថា* ***អនុស័យ គឺកិលេសដែលមានអាការលះមិនបាន*** *។ ក៏ពាក្យថា* **"អនុសយោ"** *ព្រះមានព្រះភាគត្រាស់ហៅថា កិលេសដែលមានកម្លាំង ព្រោះអត្ថថា លះមិនបាន ។*

បណ្ឌិតគប្បីជ្រាបថា ***អនុស័យនេះ ជាចិត្តសម្បយុត្តប្រព្រឹត្តទៅមួយអន្លើដោយអារម្មណ៍ (ដឹងអារម្មណ៍បាន) ជាសហេតុកៈ ព្រោះអត្ថថា មានបច្ច័យប្រជុំតាក់តែង និងជាអកុសលតែម្យ៉ាង ជាអតីតខ្លះ ជាអនាគតខ្លះ និងជាបច្ចុប្បន្នខ្លះ,*** ព្រោះហេតុដូច្នោះ ទើបគួរពោលថា អនុស័យ រមែងកើតឡើង ។

ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យកថានេះ ជាប្រមាណ ៖

ក្នុងព្រះអភិធម្ម លោកបដិសេធវាទៈទាំងអស់ ទុកក្នុងកថាវត្ថុថា "អនុស័យទាំងឡាយជាអព្យាក្រឹត ជាអហេតុកៈ ជាចិត្តវិប្បយុត្ត" * ។

***ក្នុងបដិសម្ភិទាមគ្គ លោកបានពោលជាពាក្យសួរទុកថា "បុគ្គលរមែងលះកិលេសទាំងឡាយដែលជាបច្ចុប្បន្នប៉ុណ្ណោះឬ ?"*** គឺថា ***បុគ្គលរមែងលះអនុស័យ គឺកិលេសដែលមានកម្លាំងបាន ព្រោះអនុស័យទាំងនោះជាបច្ចុប្បន្នឬ ?*** ។

***ក្នុងធម្មសង្គហៈ*** លោកពោលទុកក្នុងបទភាជនិយនៃមោហៈថា "ការកើតឡើងនៃអវិជ្ជានុស័យ រួមជាមួយនឹងអកុសលចិត្តថា ***'អវិជ្ជានុស័យ អវិជ្ជាបរិយុដ្ឋាន អវិជ្ជាលង្គី មោហៈ និងអកុសលមូល' , នេះរមែងមាន***

---

* សូមអានក្នុងកថាវត្ថុ ។

***ក្នុងសម័យណា មោហៈក៏មានក្នុងសម័យនោះ"*** ។

ក្នុងអនុសយយមកៈនេះដែរ លោកពោលទុកក្នុង ***ឧប្បជ្ជនវារៈ*** នៃមហាវារៈ ៧ ណាមួយថា ***"កាមរាគានុស័យកំពុងកើតដល់បុគ្គលណា, បដិឃានុស័យ ក៏កំពុងកើតដល់បុគ្គលនោះមែនឬ ?"*** ជាដើម; ព្រោះហេតុដូច្នោះ ពាក្យណាដែលលោកអធិប្បាយថា "ពាក្យថា ***'ដេកសម្ងំ'*** គឺមានហេតុដ៏សមគួរហើយទើបកើតឡើង" , ពាក្យនោះ គប្បីជ្រាបថា លោកពោលទុកល្អហើយដោយអំណាចនៃបែបដែននេះ ជាប្រមាណ ។ សូម្បីពាក្យដែលពោលថា "អនុស័យជាចិត្តសម្បយុត្តប្រព្រឹត្តទៅមួយអន្លើដោយអារម្មណ៍ (គឺដឹងអារម្មណ៍បាន)" , សូម្បីពាក្យនោះ លោកក៏ពោលល្អហើយដែរ, ព្រោះហេតុដូច្នោះ គប្បីដល់ការយល់ព្រមក្នុងទីនេះថា "ឈ្មោះថា អនុស័យនោះ ជាធម៌សម្រេចហើយ ជាចិត្តសម្បយុត្ត និងជាអកុសល" ដោយប្រការដូច្នេះ ព្រមទាំងគប្បីជ្រាបពាក្យវិគ្រោះទាំងឡាយមានពាក្យថា **"កាមរាគានុសយោ"** ជាដើមថា កាមរាគៈនោះឯង ជាអនុស័យ ព្រោះអត្ថថា លះមិនទាន់បាន ព្រោះហេតុដូច្នោះ ទើបឈ្មោះថា កាមរាគានុស័យ; សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ៕

## ពណ៌នាអំពីឧប្បត្តិដ្ឋានវារៈ

*ឥឡូវនេះ ដើម្បីប្រកាស* ***ឧប្បត្តិដ្ឋានវារៈ*** *គឺវារៈពោលអំពីឋានជាទីកើតឡើងនៃអនុស័យទាំងនោះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា* **“តត្ថ កាមរាគានុសយោ អនុសេតិ”** *ជាដើម ។*

*ពាក្យថា* **“តត្ថ កាមធាតុយា ទ្វីសុ វេទនាសុ”** *បានដល់ កាម-រាគានុស័យកើតក្នុងវេទនាទាំងឡាយ ២ គឺសុខវេទនា និងឧបេក្ខាវេទនាក្នុងកាមាវចរភូមិ* * *។*

*ពាក្យថា* **“ឯត្ថ កាមរាគានុសយោ អនុសេតិ”** *បានដល់ កាម-រាគានុស័យរមែងដេកសម្ងំក្នុងវេទនាទាំង ២ នេះ ។ អធិប្បាយថា កាម-រាគានុស័យនេះ រមែងដេកសម្ងំដោយអាការ ២ យ៉ាង គឺដោយអំណាចនៃការកើតរួម និងដោយអំណាចនៃអារម្មណ៍ក្នុងសុខវេទនា និងឧបេក្ខា-វេទនានៃអកុសលទាំងឡាយ ។ ក៏អនុស័យនោះ ជាធម៌កើតព្រមជាមួយសុខវេទនា និងឧបេក្ខាវេទនាជាអកុសលខ្លះ, រមែងធ្វើវេទនាទាំង ២ នោះឲ្យជាអារម្មណ៍កើតឡើងខ្លះ និងធ្វើវេទនាក្នុងកាមាវចរកុសល វិបាក និងកិរិយាដ៏សេស ឲ្យជាអារម្មណ៍នោះឯង កើតឡើងខ្លះ; ម្យ៉ាងទៀត*

---

* ពាក្យថា កាមាវចរភូមិ និងកាមធាតុ មានអត្ថសេចក្ដីដូចគ្នា ។

*អនុស័យនោះ កាលបើដេកសម្ងំក្នុងវេទនាទាំង ២ ក្នុងកាមធាតុ រមែងដេកសម្ងំ សូម្បីក្នុងសញ្ញា សង្ខារ និងវិញ្ញាណដែលសម្បយុត្តដោយវេទនាទាំងពីរនោះដែរ ។ តែអនុស័យដែលដេកសម្ងំ តែងដេកសម្ងំក្នុងវេទនាទាំងពីរ មិនអាចដើម្បីនឹងកើតរួមជាមួយសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះ ឬថា មិនផ្ញើសញ្ញាដែលសម្បយុត្តដោយវេទនានោះ ហើយកើតឡើងទេ ។*

*ក៏កាលបើមានសេចក្ដីយ៉ាងនេះ វេទនាទាំងពីរ ទើបជាប្រធានក្នុងសម្បយុត្តធម៌ដ៏សេស ដោយការកើតឡើងនៃកាមរាគានុស័យ ព្រោះអត្ថថាពេញចិត្តសេចក្ដីសុខដែលមានការរីករាយ និងការស្ងប់, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* ***“កាមរាគានុស័យរមែងដេកសម្ងំក្នុងវេទនាទាំងពីរនេះ”*** *ជាដើម ។ ពិតណាស់ សុខវេទនាក្នុងវេនេយ្យសត្វ គឺសត្វដែលនឹងដឹងធម៌ ដើម្បីដឹងធម៌ដ៏ឱឡារ គឺយ៉ាងគ្រោតគ្រាត ។*

*មួយវិញទៀត កាមរាគានុស័យនេះ កាលបើដេកសម្ងំដោយអំណាចនៃអារម្មណ៍ រមែងដេកសម្ងំក្នុងវេទនាទាំងពីរ និងក្នុងធម៌ដែលសម្បយុត្តដោយវេទនាទាំងពីរត្រឹមតែប៉ុណ្ណោះ ក៏មិនមែន, គឺរមែងដេកសម្ងំ សូម្បីក្នុងរូបជាដើម ដែលជាទីប្រាថ្នាដងមែនពិត; សូម្បីពាក្យនេះ ព្រះមានព្រះភាគក៏ត្រាស់ទុកក្នុងវិភង្គប្បករណ៍ថា* ***“រូបឯណា ជាទីស្រឡាញ់*** **(បិយរូបំ)** ***ជាទី***

***ពេញចិត្ត (សាតរូបំ) តែងមានក្នុងលោក, កាមរាគានុស័យរបស់សត្វទាំងឡាយ រមែងដេកសម្ងំក្នុងបិយរូប និងសាតរូបនេះ"*** ដូច្នេះ មិនមែនឬ ? សូម្បីក្នុងគម្ពីរយមកៈនេះ ក៏ត្រាស់ទុកក្នុងបដិលោមន័យរបស់អនុសយវារៈថា ***"កាមរាគានុស័យ រមែងមិនដេកសម្ងំក្នុងភូមិណា, ទិដ្ឋានុស័យ ក៏រមែងមិនដេកសម្ងំក្នុងភូមិនោះ មែនឬ ?"*** ដូច្នេះ, ក៏កាមរាគានុស័យនោះរមែងមិនដេកសម្ងំក្នុងទុក្ខវេទនា ក្នុងរូបធាតុ និងអរូបធាតុទាំងនេះ, តែទិដ្ឋានុស័យ រមែងមិនដេកក្នុងទីនោះ ក៏មិនមែន, ក្នុងឋានដែលមិនទាក់ទងដោយកាមរាគានុស័យ ក៏មិនដេកសម្ងំ, ទិដ្ឋានុស័យ ក៏មិនដេកសម្ងំ" ។

ពិតណាស់ ក្នុងសេចក្ដីនេះ ***កាមរាគានុស័យ*** វៀរទុក្ខវេទនាព្រមទាំងសម្បយុត្តធម៌ វៀររូបារូបាវចរធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ និងវៀរលោកុត្តរធម៌ ៩ ចេញ ព្រោះបានត្រាស់ទុកថា ***"កាមរាគានុស័យ មិនដេកសម្ងំ ក្នុងទុក្ខវេទនា និងក្នុងរូបធាតុឡើយ"*** ជាដើម ប៉ុន្តែ រមែងដេកសម្ងំក្នុងរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈដ៏សេស ។

***សួរថា*** ព្រោះហេតុអ្វី ទើបត្រាស់ពាក្យនោះ ក្នុងបករណ៍នេះ ?

ឆ្លើយថា ព្រោះសភាវៈទាំងនោះ ជារបស់ល្អិត ។

ពិតមែនហើយ ព្រះអង្គមិនត្រាស់ថា ***"កាមរាគានុស័យរមែងដេក***

***សម្ងំក្នុងរូបទាំងនេះ"*** ជាដើមទេ ព្រោះវេទនាទាំងពីរប៉ុណ្ណោះ ជាប្រធាន គឺជាអារម្មណ៍ប្រាកដច្បាស់ និងព្រោះរូបទាំងនេះ ជាអារម្មណ៍ល្អិត គឺប្រាកដមិនមានច្រើន ដោយន័យដែលពោលទុកហើយ ក្នុងខាងក្រោយ, តែកាលបើពោលដោយអត្ថហើយ រមែងកើតមាន; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា សូម្បីកាមរាគានុស័យ ក៏ដេកសម្ងំក្នុងរូបទាំងឡាយនោះដែរ ។

***បញ្ជាក់ថា*** ព្រះសាស្តារមែងមិនត្រាស់ចំពោះធម៌ទាំងអស់ ក្នុងទីទាំងពួងទេ ។ វៀរតែធម៌ណា ដឹងបានដោយអំណាចនៃសត្វដែលព្រះអង្គទ្រង់ណែនាំដើម្បីឲ្យដឹងធម៌ ក៏រមែងត្រាស់ធម៌ទាំងអស់នោះ ដោយហេតុនេះទើបត្រាស់ទុកក្នុងទីខ្លះ ។ ពិតណាស់ ពាក្យណាដែលព្រះអង្គទ្រង់បុច្ឆាថា "ទិដ្ឋានុស័យរមែងដេកសម្ងំក្នុងទីណា" ដូច្នេះ រមែងបានពាក្យវិសជ្ជនាយ៉ាងនេះថា ***"ទិដ្ឋានុស័យរមែងដេកសម្ងំក្នុងធម៌ទាំងឡាយ ដែលរាប់បញ្ចូលដោយសក្កាយៈទាំងពួង"*** ដូច្នេះ, ធម៌ទាំងអស់នោះ ព្រះអង្គត្រាស់ទុកហើយ ។

ក្នុងទីដទៃទៀត ពាក្យណា ដែលមានពាក្យវិសជ្ជនាយ៉ាងនេះថា "វិចិកិច្ឆានុស័យ មានានុស័យ និងទិដ្ឋានុស័យ រមែងដេកសម្ងំក្នុងរូបធាតុនិងអរូបធាតុនេះ, ឯវិចិកិច្ឆានុស័យ កាមរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ រមែងដេកសម្ងំក្នុងវេទនាទាំងពីរក្នុងកាមធាតុ, ឯវិចិកិច្ឆានុស័យ

បដិឃានុស័យ ទិដ្ឋានុស័យ និងអវិជ្ជានុស័យ រមែងដេកសម្ងំក្នុងទុក្ខវេទនានេះ” ដូច្នេះ, ព្រះអង្គមិនបានត្រាស់ពាក្យទាំងអស់នោះទេ ត្រាស់ត្រឹមតែវេទនា ៣ ជាមួយរូបធាតុ និងអរូបធាតុប៉ុណ្ណោះ ។ ក៏អរូបធម៌ដែលសម្បយុត្តដោយវេទនា និងរូបទាំងអស់ មិនត្រាស់ទុកទេ ។ មិនបានត្រាស់ទុក ក៏ពិតមែនហើយ, ប៉ុន្តែ ទិដ្ឋានុស័យ ក៏រមែងដេកសម្ងំក្នុងទីនោះដែរ ។ សេចក្ដីនេះ យ៉ាងណា, ក្នុងទីនេះ មិនបានត្រាស់ឥដ្ឋារម្មណ៍មានរូបជាដើមទុក ក៏ពិតមែន, ប៉ុន្តែ កាមរាគានុស័យ ក៏រមែងដេកសម្ងំក្នុងរូបដែលជាឥដ្ឋារម្មណ៍យ៉ាងនោះដែរ ។ បណ្ឌិតគប្បីជ្រាបឋានជាទីកើតឡើងនៃកាមរាគានុស័យ ដូចដែលបានពណ៌នាមកដូច្នេះចុះ ។

បណ្ឌិតគប្បីជ្រាបឋានជាទីកើតឡើងនៃបដិឃានុស័យ ដោយព្រះបាលីថា **“ទុក្ខាយ វេទនាយ”** ជាដើម បានដល់ វេទនាទាំង ៣ គឺ ទោមនស្សវេទនា ២ និងទុក្ខវេទនាដែលសម្បយុត្តដោយកាយវិញ្ញាណ ១ នេះ ឈ្មោះថា អនុសយដ្ឋាន គឺកន្លែងជាទីកើតឡើងនៃបដិឃានុស័យ ។ ក៏បដិឃានុស័យនោះ រមែងដេកសម្ងំក្នុងទោមនស្សវេទនាដោយអាការ ២ យ៉ាង គឺដោយអំណាចនៃការកើតឡើងព្រមគ្នាផង ដោយអំណាចនៃអារម្មណ៍ផង, និងរមែងដេកសម្ងំក្នុងទុក្ខវេទនាដ៏សេស ដោយអំណាចនៃអារម្មណ៍ ។ ក៏បដិឃានុស័យនោះ កាលបើដេកសម្ងំក្នុងវេទនាទាំងនោះ រមែងដេកសម្ងំ

*សូម្បីក្នុងសញ្ញា សង្ខារ និងវិញ្ញាណជាដើម ដែលសម្បយុត្តដោយវេទនាទាំងនោះដែរ ។ ពិតមែនហើយ បដិឃានុស័យនេះ កើតរួមជាមួយនឹងវេទនាណា, ក៏សូម្បីសភាពនៃការកើតរួមជាមួយធម៌ទាំងឡាយ មានសញ្ញាជាដើម ដែលសម្បយុត្តជាមួយវេទនានុ៎ះឯង, ឬថា រមែងញុំាងវេទនាឲ្យជាអារម្មណ៍, ក៏រមែងញុំាងសូម្បីធម៌ទាំងឡាយ មានសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះ ក៏ដូចគ្នាដែរ ។ សូម្បីកាលបើមានសេចក្តីដូច្នោះ ទុក្ខវេទនានោះឯង ទើបជាធំក្នុងសម្បយុត្តធម៌ដ៏សេស ព្រោះការកើតឡើងនៃបដិឃានុស័យ ដោយអត្ថថា មិនពេញចិត្ត និងព្រោះភាវៈនៃខ្វនសោយទុក្ខក្នុងធម៌ដែលមិនពេញចិត្ត, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់ពាក្យនេះថា* ***“បដិឃានុស័យ រមែងដេកសម្ងំក្នុងទុក្ខវេទនានេះ”*** *; ពិតណាស់ សេចក្តីសុខ គឺសុខវេទនា ក្នុងដៅពង្សនៃសត្វ ដែលព្រះអង្គទ្រង់ណែនាំក្នុងការត្រាស់ដឹងធម៌ ដើម្បីមានការដឹងធម៌ ដោយអំណាចនៃភាពដ៏ឱឡារិក ។*

*ម្យ៉ាងទៀត បដិឃានុស័យ កាលបើដេកសម្ងំដោយអំណាចនៃអារម្មណ៍ រមែងមិនដេកសម្ងំតែក្នុងទុក្ខវេទនា និងក្នុងសម្បយុត្តធម៌ប៉ុណ្ណោះទេ, រមែងដេកសម្ងំសូម្បីក្នុងធម៌ទាំងឡាយ មានរូបជាដើមដែលមិនគួរប្រាថ្នាផងដែរ ។ ដូចពាក្យដែលទ្រង់ត្រាស់ទុកក្នុងគម្ពីរវិភង្គប្បករណ៍ថា* ***“រូបឯណា ដែលមិន***

***ជាទីស្រឡាញ់ មិនជាទីពេញចិត្តតែងមានក្នុងលោក, បដិឃានុស័យរបស់សត្វទាំងឡាយ រមែងដេកសម្ងំក្នុងរូបដែលមិនគួរស្រឡាញ់ មិនគួរពេញចិត្តនេះ"*** ដូច្នេះ ***មិនមែនឬ*** ? សូម្បីក្នុងបករណ៍យមកៈនេះ ក្នុងបដិលោមន័យរបស់អនុសយវារៈ ក៏ត្រាស់ទុកថា ***"បដិឃានុស័យ រមែងមិនដេកសម្ងំក្នុងវេទនាទាំងពីរ ក្នុងកាមធាតុនេះទេ, តែកាមរាគានុស័យរមែងមិនដេកសម្ងំក្នុងទីនោះ ក៏មិនមែន, ក្នុងរូបធាតុ និងអរូបធាតុ ដែលមិនទាក់ទងគ្នា បដិឃានុស័យ ក៏មិនដេកសម្ងំ, កាមរាគានុស័យ ក៏មិនដេកសម្ងំដែរ"*** ។ ព្រះមានព្រះភាគទ្រង់អធិប្បាយទុកថា បដិឃានុស័យរមែងដេកសម្ងំក្នុងធម៌ទាំងឡាយដ៏សេស មានរូបជាដើម ដោយវៀរវេទនាពីរ គឺសុខវេទនា និងឧបេក្ខាវេទនា ព្រមទាំងសម្បយុត្តធម៌ វៀររូបាវចរធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ និងវៀរលោកុត្តរធម៌ ៩ ព្រោះភាវៈនៃទេសនានោះ ព្រះអង្គត្រាស់ថា "បដិឃានុស័យរមែងមិនដេកសម្ងំ ក្នុងកាមាវចរ-វេទនាទាំងពីរ និងក្នុងរូបធាតុជាដើម" ។

***សួរថា*** ព្រោះហេតុអ្វី ទើបមិនត្រាស់ទុក ?

ឆ្លើយថា ព្រោះជាសភាវៈល្អិត ។

ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ទុកថា ***"បដិឃានុស័យ***

***រមែងដេកសម្ងំក្នុងធម៌ទាំងនេះ ព្រោះភាវៈនៃទុក្ខវេទនាជាធំ តាមន័យដែលពោលហើយនោះឯង និងក្នុងធម៌ទាំងឡាយ មានរូបជាដើម ព្រោះជាធម៌ល្អិត"*** ដូច្នេះ, តែកាលបើពោលដោយអត្ថហើយ រមែងមាន; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ***"បដិឃានុស័យ*** រមែងដេកសម្ងំ ស្ងប់ស្ងៀមក្នុងធម៌ទាំងឡាយ មានរូបជាដើមទាំងនោះឯង" ។

***សួរថា*** វេទនាទាំងពីរក្រៅនេះ ជាឥដ្ឋារម្មណ៍របស់បដិឃៈឬទេ ?

ឆ្លើយថា វេទនាទាំងពីរក្រៅនេះ មិនជាអារម្មណ៍របស់បដិឃៈ ក៏មិនមែនដែរ ។

តាមពិតទៅ ***ទោមនស្សរបស់អ្នកមានឈានវិនាសហើយ រមែងកើតព្រោះប្រារព្ធវេទនាទាំងនោះ ដែលប្រព្រឹត្តទៅជាមួយនឹងសម្បយុត្តធម៌ដោយអំណាចនៃការក្តៅក្រហាយ គឺទោមនស្សរមែងកើត ព្រោះតាមរឭកដល់សេចក្តីវិនាសរបស់អ្នកមានឥដ្ឋារម្មណ៍ខ្លះ, រមែងកើត ព្រោះតាមរឭកដល់វត្ថុដែលមិនមាន របស់អ្នកមិនមានឥដ្ឋារម្មណ៍ខ្លះ; ក៏សេចក្តីនេះ គ្រាន់តែជាទោមនស្សប៉ុណ្ណោះ, មិនមែនជាបដិឃានុស័យទេ;*** ព្រោះបដិឃានុស័យនោះ ជាកិលេសដ៏មានកម្លាំង កើតឡើងដោយអំណាចនៃការប៉ះខ្ទប់អនិដ្ឋារម្មណ៍, ព្រោះហេតុនោះ ស្ងប់បដិឃៈកើតរួមនឹងទោមនស្សក្នុងទីនេះ រមែងមិនជាបដិឃានុស័យទេ ព្រោះមិនធ្វើបដិឃកិច្ចរបស់ខ្លួន, រមែងដល់

*នូវភាពជាអព្យោហារិក គឺដល់ការពោលអាងមិនបាន ។*

*ព្យាបាទ សូម្បីកើតរួមជាមួយចេតនាក្នុងបាណាតិបាត ក៏មិនឈ្មោះថា ជាមនោកម្ម, គឺដល់នូវភាពជាអព្យោហារិក យ៉ាងណា, សេចក្តីនេះក៏យ៉ាងនោះដែរ មិនមែនជាបដិឃានុស័យទេ, គឺរមែងដល់ការពោលអាងមិនបាន; សមពិតដូចដែលលោកពោលទុកថា* ***“បុគ្គលរមែងលះបដិឃៈ គឺទោមនស្ស មានសភាពបែបនេះ ដោយសំដៅយកទោមនស្ស អាស្រ័យនេក្ខម្មៈ ដែលជាឥដ្ឋារម្មណ៍ម្យ៉ាង ដោយសភាវៈនោះ បដិឃានុស័យក៏រមែងមិនដេកសម្ងំ ក្នុងទីនោះ”*** *។*

*បណ្ឌិតគប្បីជ្រាបនូវឋានជាទីដេកសម្ងំនៃ* ***មានានុស័យ*** *ដោយព្រះបាលីថា* **“កាមធាតុយា ទ្វីសុ វេទនាសុ”** *ជាដើម មាន ៣ គឺកាមាវចរវេទនា ២ រូបធាតុ និងអរូបធាតុ ១ ។ បណ្ឌិតគប្បីជ្រាបការដេកសម្ងំរបស់មានានុស័យ ដែលជាសហជាត ដូចកាមរាគានុស័យក្នុងអកុសលវេទនាទាំងឡាយដែរ ។ ក៏មានានុស័យរមែងដេកសម្ងំក្នុងកាមាវចរ សូម្បីទាំងអស់ ព្រមទាំងសម្បយុត្តធម៌ក្នុងសុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនាទាំងឡាយ ព្រមទាំងក្នុងរូបធាតុទាំងឡាយ ដោយអំណាចនៃអារម្មណ៍ប៉ុណ្ណោះ ។ ក្នុងបដិលោមន័យរបស់អនុសយវារៈ មានានុស័យនេះ វៀរទុក្ខវេទនា និងលោកុត្តរធម៌ ៩ រមែងដេកសម្ងំក្នុងរូប និងអរូបធាតុ*

វិសេសប៉ុណ្ណោះ ព្រោះព្រះមានព្រះភាគត្រាស់ថា ***“កាមរាគានុស័យរមែងមិនដេកសម្ងំ, មានានុស័យ ក៏រមែងមិនដេកសម្ងំ ក្នុងធម៌ដែលទាក់ទងដោយទុក្ខវេទនានេះ”*** ។ គប្បីជ្រាបទីកន្លែងកើតនៃមានានុស័យ ដូចពណ៌នាមកដូច្នេះ ។

៦ ***ទិដ្ឋានុស័យ*** និង ***វិចិកិច្ឆានុស័យ*** រមែងមិនដេកសម្ងំក្នុងលោកុត្តរធម៌តែម្យ៉ាងប៉ុណ្ណោះទេ, ប៉ុន្តែ ភាពពិតនៅដេកសម្ងំសូម្បីក្នុងធម៌ទាំងពួង ដែលប្រព្រឹត្តទៅជាមួយភូមិ ៣ ទៀត ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា “ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យរមែងដេកសម្ងំក្នុងធម៌ទាំងឡាយដែលបដិសំយុត្តដោយសក្កាយៈទាំងពួង” ។ ក៏ក្នុងបទទាំងនោះ បទថា ***“សព្វសក្កាយបរិយាបន្នេសុ”*** បានដល់ ក្នុងធម៌ទាំងពួង ***ដែលរាប់បញ្ចូលដោយសក្កាយៈ ព្រោះអត្ថថា អាស្រ័យសង្សារវដ្ត*** ។ ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបថា ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យទាំងនេះ រមែងដេកសម្ងំក្នុងចិត្តុប្បាទ ៥ ដួង គឺលោភសម្បយុត្តចិត្ត ៤ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដោយអំណាចនៃការដេកសម្ងំដែលជាសហជាត ឬក៏ធម៌ទាំងពីរនោះរមែងដេកសម្ងំក្នុងអារម្មណ៍ ជាបវត្តិកាល ព្រោះប្រារព្ធចិត្តុប្បាទទាំង ៥ នេះ ឬធម៌ដទៃដែលប្រព្រឹត្តទៅជាមួយភូមិ ៣ ។ បណ្ឌិតគប្បីជ្រាបឋានជាទីកើតឡើងនៃទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដូចបានពណ៌នាមកនេះ ។

ចំណែក ***ភវរាគានុស័យ*** បណ្ឌិតគប្បីពោលថា រមែងដេកសម្ងំក្នុងវេទនា ២ ក្នុងកាមធាតុ ព្រោះកើតឡើងក្នុងទិដ្ឋិវិប្បយុត្តចិត្ត ៤ ដួងក៏ពិតមែនហើយ, ប៉ុន្តែថា ភវរាគានុស័យនោះ កាលបើកើតជាមួយវេទនាទាំងពួង ក្នុងកាមធាតុ រមែងមានចំពោះក្នុងរូបាវចរារូបាវចរប៉ុណ្ណោះ, និងមិនញ៉ាំងធម៌សូម្បីតែមួយ ដែលរាប់បញ្ចូលដោយកាមធាតុឲ្យជាអារម្មណ៍ទេ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ***“ភវរាគានុស័យរមែងដេកសម្ងំក្នុងរូបធាតុ និងអរូបធាតុនេះ ព្រោះកំណត់ទុកដោយអំណាចនៃការដេកសម្ងំក្នុងអារម្មណ៍”*** ។ ម្យ៉ាងទៀត ឈ្មោះថា រាគៈនេះ មាន ២ ដោយអំណាចនៃកាមរាគៈ និងភវរាគៈ ។

ក្នុង ២ យ៉ាងនោះ ***កាមរាគៈ*** លោកពោលថា ***“រមែងដេកសម្ងំក្នុងវេទនាទាំងពីរនៃកាមធាតុ”*** ។

បើថា សូម្បីភវរាគៈ ហាក់ដូចជាកាមរាគៈយ៉ាងនេះមែន, ការសម្ដែងភវរាគៈមួយអន្លើដោយកាមរាគៈ ក៏ហាក់ដូចជាទាក់ទង (ច្រឡូកច្រឡំ) គ្នា, ព្រោះហេតុដូច្នោះ ព្រះអង្គទ្រង់ចែកកិលេសមានរាគៈជាដើមទុក ដើម្បីត្រូវការសម្ដែងសេចក្ដីផ្សេងគ្នារបស់កាមរាគៈ ជាមួយភវរាគៈហើយ ទើបទ្រង់សម្ដែងទេសនាយ៉ាងនេះ ។ បណ្ឌិតគប្បីជ្រាបឋានជាទីកើតឡើងនៃភវរាគានុស័យ ដូចពណ៌នាមកនេះ ។

ចំណែក ***អវិជ្ជានុស័យ*** រមែងដេកសម្ងំក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "អវិជ្ជានុស័យ រមែងដេកសម្ងំក្នុងធម៌ទាំងឡាយ ដែលរាប់បញ្ចូលដោយសក្កាយៈទាំងពួងទុកក្នុងទីនេះ" ។ បណ្ឌិតគប្បីជ្រាបអវិជ្ជានុស័យ ជាធម៌ដេកសម្ងំ ដែលជាសហជាតក្នុងចិត្តុប្បាទ ១២ ដួង ។ កាលបើពោលដោយអំណាចនៃការធ្វើអារម្មណ៍ហើយ អវិជ្ជានុស័យមិនប្រារព្ធធម៌អ្វីៗ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ហើយប្រព្រឹត្តទៅមិនបាន ។ បណ្ឌិតគប្បីជ្រាបឋានជាទីកើតឡើងនៃអវិជ្ជានុស័យ ដូចពណ៌នាមកនេះ ។ នេះជាវិនិច្ឆ័យកថា ក្នុងបរិច្ឆេទវារៈ បរិច្ឆិន្នុទ្ទេសវារៈ និងឧប្បត្តិដ្ឋានវារៈសិនចុះ ៕

ចប់ឧប្បត្តិដ្ឋានវារៈ

..............................

## មហាវារៈ ៧

### ១.ពណ៌នាអំពីអនុសយវារៈ

ក៏ក្នុងអនុសយវារៈទីមួយនៃមហាវារៈ ៧ ពាក្យណាដែលពោលទុកថា ***"កាមរាគានុស័យកំពុងដេកសម្ងំដល់បុគ្គលណា បដិឃានុស័យ ក៏កំពុងដេកសម្ងំដល់បុគ្គលនោះ មិនមែនឬ ?"*** ដូច្នេះ ឆ្លើយថា **"អាមន្តា** = មែន",

ពាក្យនោះ រមែងប្រាកដហាក់បីដូចជាឲ្យពាក្យឆ្លើយតបដែលមិនល្អ ។

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះកាមរាគៈ និងបដិឃៈ មិនកើតក្នុងខណៈជាមួយគ្នាទេ; ដូចយ៉ាងថា "មនាយតនៈ ធម្មាយតនៈ កាយសង្ខារ និងវចីសង្ខារ រមែងកើតឡើងក្នុងខណៈជាមួយគ្នាក្នុងពាក្យថា* ***" មនាយតនៈកំពុងកើតដល់បុគ្គលណា, ធម្មាយតនៈ ក៏កំពុងកើតដល់បុគ្គលនោះពិតឬ ?"*** *។*

*លោកឆ្លើយតបថា* **"អាមន្តា** *= ពិត" ; ក្នុងខណៈកើតឡើង នៃអស្សាសៈ និងបស្សាសៈ កាយសង្ខាររបស់បុគ្គលទាំងនោះ កំពុងកើតឡើង វចីសង្ខាររបស់បុគ្គលទាំងនោះ ក៏កំពុងកើតឡើងជាដើម យ៉ាងណា, កាមរាគៈ និងបដិឃៈ រមែងកើតឡើងយ៉ាងនោះមិនបានទេ ។ ព្រោះកាមរាគៈ រមែងកើតក្នុងលោភសហគតចិត្តុប្បាទ ៨ ដួង, ចំណែកបដិឃៈរមែងកើតក្នុងទោមនស្សសហគតចិត្តុប្បាទ ២ ដួង ដោយប្រការដូច្នេះ ការកើតឡើងក្នុងខណៈជាមួយគ្នារបស់ធម៌ទាំងនោះ (កាមរាគៈ និងបដិឃៈ) ទើបមិនមាន; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីធ្វើពាក្យបដិសេធក្នុងទីនេះថា* **"នោ"** *។ ក៏ក្នុងទីនេះ លោកមិនកាន់យកវោហារដែលកំពុងប្រព្រឹត្តទៅ ដោយអំណាចនៃបច្ចុប្បន្នខណៈ ដូចក្នុងយមកៈទាំងឡាយខាងក្រោយ ព្រោះសេចក្តីនោះមិនបដិសេធ ក៏ត្រូវឆ្លើយតបថា* **"អាមន្តា"** *ដូច្នេះ ទើបគួរកាន់យកដោយ*

ប្រការដទៃៗ ។

***សួរថា*** គួរកាន់យកដោយអាការដូចម្ដេច ?

ឆ្លើយថា ដោយអំណាចនៃកិលេសដែលលះមិនទាន់បាន ។

ពិតមែនហើយ វោហារដែលកំពុងប្រព្រឹត្តទៅថា **"អនុសេតិ"** នេះ លោកពោលសំដៅយកកិលេសដែលលះមិនទាន់បាន ។ មិនបានសំដៅយកបច្ចុប្បន្នក្ខណៈទេ ។ ព្រោះលោកពោលសំដៅយកកិលេសជាសភាវៈដែលលះមិនទាន់បាន, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ***"កាមរាគានុស័យដែលបុគ្គលណាលះមិនទាន់បាន សូម្បីបដិឃានុស័យរបស់បុគ្គលនោះ ក៏លះមិនទាន់បានដែរ ទើបជាសភាវៈ (គួរ) ឱ្យដល់ភាពជាធម៌ដេកសម្ងំក្នុងពាក្យបុច្ឆាថា 'កាមរាគានុស័យកំពុងដេកសម្ងំដល់បុគ្គលណា, បដិឃានុស័យ ក៏កំពុងដេកសម្ងំដល់បុគ្គលនោះមែនឬ ?"*** ។

ម្យ៉ាងទៀត ក្នុងអនុស័យទាំងនោះ អនុស័យមួយដែលបុគ្គលណាមិនទាន់បានលះ, អនុស័យក្រៅនេះ របស់បុគ្គលនោះ ក៏មិនអាចលះបានឡើយ, ព្រោះហេតុដូច្នោះ ទើបពោលថា **"អាមន្តា"** ; ប្រសិនបើពាក្យលោកធានាថា **"អាមន្តា"** ដូច្នេះ ក្នុងខប្បដ្ឋនវារៈខាងមុខ ព្រោះមាន

ពាក្យសួរយ៉ាងនេះថា ***"កាមរាគានុស័យកំពុងកើតដល់បុគ្គលណា, បដិឃានុ-ស័យ ក៏កំពុងកើតដល់បុគ្គលនោះមែនឬ ?"*** ។ ក្នុងសេចក្តីនេះ គប្បីកាន់យកន័យដូចម្តេច ? សូម្បីក្នុងសេចក្តីនោះ ក៏លោកកាន់យកដោយអំណាចនៃកិលេសនោះ ដែលលះមិនទាន់បានមែនពិត, ឬថា កាលបើបច្ច័យ គឺការកើតឡើងតែងមាន ក៏គប្បីកាន់យកដោយអំណាចនៃការមិនបដិសេធនូវការកើតចុះ ។

ដូចយ៉ាងជាងគំនូរជាដើម ផ្តើមធ្វើចិត្តកម្មមានការគូសវាសជាដើម កាលបើការងារនៅមិនទាន់សម្រេច ត្រូវមិត្តសហាយជាដើមសួរថា "លោកធ្វើអ្វីក្នុងថ្ងៃទាំងនេះ" ក្នុងទីដែលយើងឃើញហើយៗ សូម្បីក្នុងខណៈដែលមិនទាន់បានធ្វើការងារទាំងនោះ ក៏រមែងពោលថា "យើងកំពុងធ្វើចិត្តកម្ម, កំពុងធ្វើកដ្ឋកម្ម" ដូច្នេះ; សូម្បីក្នុងខណៈនោះ មិនបានធ្វើចិត្តកម្មជាដើម ក៏ពិតមែនហើយ, ប៉ុន្តែ ក៏ឈ្មោះថា កំពុងតែធ្វើដែរ ព្រោះអាស្រ័យខណៈដែលធ្វើហើយ និងខណៈដែលគួរនឹងធ្វើតទៅ យ៉ាងណា ។ អនុស័យទាំងឡាយ ក្នុងសន្តានណា ដែលលះមិនទាន់បាន ក៏យ៉ាងនោះដែរ, ឬថា កាលបើបច្ច័យញ៉ាំងអនុស័យទាំងនោះ ឲ្យកើតមានក្នុងសន្តានណា, ការកើតឡើងនៃអនុស័យទាំងនោះ ដែលធម្មតាមិនបានហាមទុកទេ ក្នុងសេចក្តីនោះ បណ្ឌិតគប្បីជ្រាបនូវន័យរបស់អនុស័យ សូម្បីក្នុងខណៈដែលមិនទាន់កើតឡើង

យ៉ាងនេះថា ***"កាមរាគានុស័យកំពុងកើតឡើងដល់បុគ្គលណា ព្រោះអាស្រ័យការធ្លាប់កើតហើយផង និងបម្រុងនឹងកើតឡើងក្នុងកាលដទៃផង, បដិឃា-នុស័យរបស់បុគ្គលនោះ ក៏ឈ្មោះថា កំពុងកើតឡើងដែរ"*** ដូច្នេះ; ក្នុងការវិសជ្ជនា សូម្បីដទៃអំពីនេះ ដែលមានសភាពយ៉ាងនេះ ក៏មានន័យដូចគ្នានេះដែរ ។

ពាក្យថា **"នោ ច តស្ស"** នេះ ព្រះមានព្រះភាគត្រាស់ទុក ព្រោះភាវៈនៃកាមរាគៈ និងព្យាបាទៈ ជាសភាវៈដែលព្រះអនាគាមីលះបានហើយដោយមិនមានសេសសល់ឡើយ ។

ពាក្យថា **"តិណ្ណំ បុគ្គលានំ"** បានដល់ បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។

ពាក្យថា **"ទ្វិន្នំ បុគ្គលានំ"** បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ក្នុងឋានទាំងឡាយដែលមានសភាពយ៉ាងនេះ សូម្បីខាងមុខក៏មានន័យដូចគ្នានេះដែរ ។

***ក្នុងពាក្យសួរទីមួយ និងទីពីរនៃឱកាសវារៈ*** លោកធ្វើការបដិសេធថា **"នោ"** ដូច្នេះ; ព្រោះកាមរាគានុស័យរមែងដេកសម្ងំក្នុងវេទនា ២ នៃកាមធាតុ, បដិឃានុស័យរមែងដេកសម្ងំក្នុងទុក្ខវេទនា ព្រោះហេតុដូច្នោះទើបបដិសេធថា **"នោ"** ។

***ក្នុងពាក្យសួរទី ៣*** លោកពោលធានាថា **"អាចន្នា"** ព្រោះការដេកសម្ងំនៃធម៌ទាំងពីរ ក្នុងវេទនាទាំងពីរនៃកាមធាតុ ឋាន គឺកន្លែងកើតឡើងនៃមានានុស័យក្នុងរូបធាតុ អរូបធាតុ មួយអន្លើដោយកាមរាគានុស័យនោះ ជាទីដែលមិនទូទៅ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា ***"ក៏កាមរាគានុស័យរមែងមិនដេកសម្ងំក្នុងរូបធាតុនោះទេ"*** ដូច្នេះ; តាមន័យនេះ បណ្ឌិតគប្បីពិចារណាមើលវារៈ ពោលដោយឋានជាទីកើតឡើងនៃអនុស័យទាំងពួងហើយ គប្បីជ្រាបនូវឋានជាទីកើតឡើងនៃអនុស័យទាំងពួង និងគប្បីជ្រាបនូវឋានជាទីកើតឡើងដែលជាសាធារណៈ និងអសាធារណៈ ។

ក្នុងពាក្យសួរដែលមានមូល ២ ព្រោះកាមរាគានុស័យរមែងមិនកើតក្នុងទីជាមួយគ្នា និងមិនធ្វើធម៌មួយឲ្យជាអារម្មណ៍ឡើយ, ព្រោះហេតុដូច្នោះ ទើបធ្វើការបដិសេធថា **"នត្ថិ"** ។ ក៏ក្នុងទីនេះ គប្បីជ្រាបសេចក្ដីអធិប្បាយថា អនុស័យទាំងពីរនេះ គប្បីដេកសម្ងំក្នុងទីណា, ទីនោះមិនជាកន្លែងជាមួយគ្នាទេ; ព្រោះហេតុដូច្នោះ ពាក្យសួរថា ***"មានានុស័យ រមែងដេកសម្ងំក្នុងទីណា ?"*** ដូច្នេះនេះ ឈ្មោះថា មិនជាពាក្យបុច្ឆាឡើយ ។ សូម្បីក្នុងអនុស័យដទៃៗ ដែលមានសភាពយ៉ាងនេះ ក៏មានន័យដូចគ្នានេះដែរ ។

ពាក្យថា **"ចតុន្នំ"** ក្នុងបុគ្គលោកាសវារៈ បានដល់ បុគ្គល ៤ ជំពូក គឺបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ។

*ក្នុងបដិលោមន័យ ព្រះមានព្រះភាគទ្រង់កាន់យកសេចក្ដីនេះហើយ ទើបត្រាស់សួរថា* ***“កាមរាគានុស័យ រមែងមិនដេកសម្ងំក្នុងបុគ្គលណា”*** *ជាដើម ។ ទ្រង់កាន់យកព្រះអនាគាមី និងព្រះអរហន្ត ទើបត្រាស់សួរថា* ***“កាមរាគានុស័យ រមែងមិនដេកសម្ងំដល់បុគ្គលទាំងពីរក្នុងភូមិទាំងពួង”*** *។ បណ្ឌិតគប្បីកាន់យកកាមាវចរធម៌សូម្បីទាំងអស់ ដែលសម្បយុត្តដោយវេទនា ក្នុងព្រះបាលីថា* **“កាមធាតុយា ទ្វីសុ វេទនាសុ”** *ដូច្នេះខ្លះ និងកាន់យកវត្ថុអារម្មណ៍នៃធម៌ទាំងនុ៎ះខ្លះ ៕*

ចប់អនុសយវារៈ

## ២.ពណ៌នាអំពីសានុសយវារៈ

*ក៏ក្នុង* ***សានុសយវារៈ*** *ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា* **“យោ កាមរាគានុសយេន សានុសយោ”** *នេះ អធិប្បាយថា ប្រៀបដូចបុគ្គលអ្នកមានអាពាធដោយរោគយ៉ាងណាមួយ មានរោគជរាដែលពិតប្រាកដជាដើម ជរាបណា រោគទាំងឡាយមិនរួចទៅចាកបុគ្គលនោះទេ; អ្នកនោះ ឈ្មោះថាជាអ្នកមានរោគ សូម្បីក្នុងខណៈនៃរោគនោះ នៅមិនទាន់កើត យ៉ាងណា, សេចក្ដីនេះ ក៏យ៉ាងនោះដែរ អនុស័យទាំងឡាយនៃសត្វអ្នកមានប្រក្រតីទៅ*

*តាមវដ្តៈ អ្នកមានកិលេសមិនដល់នូវការដកឡើងដោយអរិយមគ្គត្រឹមណា, សូម្បីក្នុងខណៈដែលអនុស័យទាំងឡាយមិនទាន់កើតឡើង គេក៏ឈ្មោះថា ជាអ្នកប្រព្រឹត្តទៅមួយអន្លើដោយអនុស័យ គឺមានអនុស័យនោះឯង; ព្រោះសំដៅយកភាវៈនៃសត្វជាអ្នកមានអនុស័យបែបនេះ ទើបធានាដោយពាក្យថា* **“អាមន្តា”** *។ ពាក្យដ៏សេសក្នុងទីនេះ ដូចនឹងអនុសយវារៈនោះដែរ ។*

*ក៏ក្នុង* ***ឱកាសវារៈ*** *ព្រះមានព្រះភាគត្រាស់ថា* **“រូបធាតុយា អរូបធាតុយា ឯត្ថ មានានុសយេន សានុសយោ”** *អធិប្បាយថា ក្នុងធាតុទាំងឡាយនោះ ភាវៈនៃបុគ្គលដែលប្រព្រឹត្តទៅមួយអន្លើដោយអនុស័យ គឺមានអនុស័យប្រាកដ, តែឋានជាទីកើតឡើងនៃអនុស័យមិនប្រាកដឡើយ, ក៏ដើម្បីសម្តែងឋានជាទីកើតឡើងនៃអនុស័យនោះ ទើបព្រះអង្គផ្តើមវារៈនេះ, ព្រោះហេតុដូច្នោះ ទើបទ្រង់ត្រាស់ថា* **“តតោ មានានុសយេន សានុសយោ”** *ជាដើម អំពីវារៈនោះ ។ ក៏កាលបើដូច្នោះ ទើបទ្រង់ត្រាស់នូវឋានដែលកើតឡើងនៃអនុស័យថា “បុគ្គលអ្នកប្រព្រឹត្តទៅ មួយអន្លើដោយមានានុស័យ គឺមានមានានុស័យកើតឡើងអំពីធាតុទាំងពីរនោះ” ដូច្នេះ, បើព្រះអង្គមិនត្រាស់នូវអត្ថនៃបញ្ហានេះទេ ក៏ព្រះអង្គមិនត្រាស់នូវអត្ថនៃបញ្ហាជាបឋមថា* **“អាទិបញ្ហស្ស អត្ថោ បាកដោ ន ហោតិ** *= អត្ថនៃបញ្ហាដំបូងជាសេចក្តីមិនប្រាកដ” ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្តីនៃបញ្ហា*

នេះ យ៉ាងនេះចុះ ។

ពាក្យថា **“យតោ កាមរាគានុសយេន”** បានដល់ កាមរាគានុស័យ កើតឡើងហើយអំពីទីណា ។

ពាក្យថា **“សានុសយោ”** ជាឈ្មោះនៃបុគ្គលដែលប្រព្រឹត្តទៅ មួយអន្លើដោយអនុស័យ គឺមានអនុស័យ; សូម្បីដោយបដិឃានុស័យ ក៏កើតឡើងពីទីនោះដូច្នេះដែរ ។ តែព្រោះអនុស័យទាំងពីរ គឺកាមរាគៈ និងបដិឃៈនោះ មិនកើតឡើងជាមួយគ្នាទេ, ព្រោះហេតុដូច្នោះ ទើប បដិសេធថា **“នោ”** ។

ពាក្យថា **“អរហា សព្វត្ថ”** នេះ លោកធ្វើសត្តមីវិភត្តិ ក្នុងទីសម្ដែង អត្ថទាំងអស់ ដោយអំណាចនៃអត្ថថា “ព្រះអរហន្តជាអ្នកមិនមានអនុស័យ យ៉ាងណាមួយ ដែលកើតឡើងក្នុងធម៌ទាំងពួង” ដូច្នេះនេះ ។ បណ្ឌិតគប្បី ជ្រាបនូវការវិនិច្ឆ័យអត្ថ ក្នុងពាក្យទាំងពួងដោយឧបាយនេះចុះ ៕

**ចប់សានុសយវារៈ**

.............................

## ៣.ពណ៌នាអំពីបជហនវារៈ

ក្នុងបជហនវារៈ បទថា **“បជហតិ”** បានដល់ រមែងលះអនុស័យ ដោយមគ្គនោះ, គឺថា រមែងធ្វើឲ្យដល់ភាពជាធម្មជាតិមិនកើតឡើងតទៅ

ទៀត ដោយអំណាចនៃបហានបរិញ្ញា ។

ពាក្យថា **"អាមន្តា"** ជាពាក្យធានាដោយសំដៅយកព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអនាគាមិមគ្គ ។

ពាក្យថា **"តេនេកដ្ឋំ បជហតិ"** នេះ ត្រាស់សំដៅយកភាវៈនៃបុគ្គល នោះ ជាអ្នកតាំងនៅក្នុងបរិញ្ញាដ៏លើស គឺបហានៈ ។

ពាក្យថា **"នោ"** នេះ លោកបដិសេធសំដៅយកព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអរហត្តមគ្គ ។

ពាក្យថា **"យតោ កាមរាគានុសយំ បជហតិ"** គឺរមែងលះ កាមរាគានុស័យដែលកើតឡើងអំពីទីណា ។

ពាក្យថា **"អដ្ឋមកោ"** បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុង សោតាបត្តិមគ្គ ដោយការរាប់តាំងពីព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្ត-ផលជាទីមួយ, ព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនោះ ទើប ឈ្មោះថា ជាព្រះអរិយបុគ្គលទី ៨ ។ ពិតណាស់ ព្រះអរហន្តជាព្រះ អរិយបុគ្គលទីមួយ ព្រោះលោកជាព្រះទក្ខិណេយ្យបុគ្គលដ៏លើស ដោយ ការរាប់តាមលំដាប់ទក្ខិណេយ្យបុគ្គល ។ ព្រះអរិយបុគ្គលដែលតាំងនៅក្នុង អរហត្តមគ្គជាទីពីរ, ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអនាគាមិផល ជាទី ៣, ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអនាគាមិមគ្គជាទី ៤ ។ល។ ព្រះអរិយ-

*បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គជាទី ៨, ព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនោះ ត្រាស់ថា ជាបុគ្គលទី ៨ ។ ម្យ៉ាងទៀតពាក្យថា* **“អដ្ឋមកោ”** *នេះ ជានាមសញ្ញារបស់លោក ។*

*ពាក្យថា* **“អនាគាមិមគ្គសមង្គិញ្ច អដ្ឋមកញ្ច ឋបេត្វា អវសេសា”** *បានដល់ ព្រះសេក្ខៈ និងព្រះអសេក្ខៈទាំងឡាយមួយអន្លើដោយបុថុជ្ជន ។ ពិតមែនហើយ ក្នុងបុគ្គលទាំងនោះ បុថុជ្ជនរមែងលះកាមរាគានុស័យមិនបាន ព្រោះភាវៈនៃបុថុជ្ជននោះ មិនមានបហានបរិញ្ញា ។ អធិប្បាយថា វៀរចាកបុគ្គលដ៏សេស គឺអ្នកដល់ព្រមដោយមគ្គទាំងពីរ បានដល់ សោតាបត្តិមគ្គ អនាគាមិមគ្គ ព្រោះអនុស័យទាំងនោះ លោកលះបានហើយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងពួង ដោយន័យនេះចុះ ៕*

ចប់បជហានវារៈ

## ៤.ពណ៌នាអំពីបរិញ្ញាវារៈ

*ក្នុង* ***បរិញ្ញាវារៈ*** *ពាក្យថា* **“បរិជានាតិ”** *គឺរមែងដឹងច្បាស់ ដោយបរិញ្ញាទាំង ៣; ពាក្យដ៏សេសក្នុងទីនេះ មានន័យដូចពោលហើយខាងក្រោយ ។ ពិតណាស់ សូម្បីវារៈនេះ ក៏ព្រះអង្គទ្រង់វិសជ្ជនា ដោយអំណាចនៃព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គប៉ុណ្ណោះ ដូចបជហានវារៈដែរ ៕*

ចប់បរិញ្ញាវារៈ

## ៥.ពណ៌នាអំពីបហីនវារៈ

*ព្រះអង្គទ្រង់ផ្ដើមទេសនាទុកក្នុង **បហីនវារៈ** ដោយអំណាចនៃព្រះអរិយបុគ្គលដែលតាំងនៅក្នុងផល ។ ព្រោះថា សូម្បីអនុស័យទាំងពីរនេះដែលព្រះអនាគាមីលះបានហើយ, ព្រោះហេតុដូច្នោះ ទើបធានាថា* **"អាមន្តា"** *។*

*ក្នុងឱកាសវារៈ លោកពោលទុក ព្រោះមានពាក្យសួរថា **"កាម-រាគានុស័យដែលលះបានហើយ ក្នុងភូមិណា, បដិឃានុស័យ ក៏លះបានហើយក្នុងភូមិនោះ មែនឬ ?"** មិនសមគួរនឹងពោលថា "ពាក្យថា '**លះបានហើយ**' ឬថា '**លះមិនទាន់បាន**" ដូច្នេះទេ ។*

***សួរថា** ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះភាវៈនៃភូមិនោះ ជាទីកើតឡើងមិនទូទៅ ។*

*ពិតណាស់ ឋានជាទីកើតឡើងនៃកាមរាគានុស័យ ក៏ម្យ៉ាង, នៃបដិឃានុស័យ ក៏ម្យ៉ាង ។ គឺថា អនុស័យរបស់មគ្គបុគ្គលដែលមិនចម្រើនហើយ រមែងកើតឡើងក្នុងភូមិណា, គ្រាលោកចម្រើនមគ្គឲ្យកើតឡើងហើយ ក៏ឈ្មោះថា លះបានហើយក្នុងទីនុ៎ះឯង ។ ក៏ក្នុងបណ្ដាអនុស័យទាំងពីរនោះ បដិឃានុស័យ រមែងមិនកើតក្នុងឋានជាទីកើតឡើងនៃកាមរាគានុស័យ,*

*សូម្បីកាមរាគានុស័យ ក៏មិនកើតក្នុងឋានជាទីកើតឡើង នៃបដិឃានុស័យដែរ, ព្រោះហេតុដូច្នោះ ទើបមិនគួរពោលថា "អនុស័យនោះ លោកលះបានហើយ ឬថា* ***លះមិនបាន*** *ក្នុងទី (ភូមិ) នោះ; ព្រោះថា កាមរាគានុស័យនោះ លោកលះបានហើយ ក្នុងឋានជាទីកើតរបស់ខ្លួន, ទើបមិនគួរពោលថា "អនុស័យនោះ លោកលះបានហើយ" ក្នុងទីនោះ ព្រោះលោកលះមិនទាន់បាន ។ ទីណា ជាទីកើតឡើងនៃកាមរាគានុស័យ មិនគួរពោលថា លោកលះមិនទាន់បាន ក្នុងទីនោះ, ព្រោះភាវៈនៃកាមរាគានុស័យនោះមិនមាននៅក្នុងទីនោះទេ ។*

*ក៏ក្នុងពាក្យថា* **"យត្ថ កាមរាគានុសយោ បហីនោ, តត្ថ មានានុសយោ បហីនោ"** *នេះ ព្រះមានព្រះភាគសំដៅយកឋានជាសាធារណៈ ទើបត្រាស់ថា* **"អាមន្តា"** *។ ព្រោះថា កាមរាគានុស័យរមែងដេកសម្ងំក្នុងវេទនាទាំង ២ ក្នុងកាមធាតុ, មានានុស័យរមែងដេកសម្ងំក្នុងវេទនាទាំង ២ នោះផង ក្នុងរូបធាតុ និងអរូបធាតុទាំងឡាយផង; តែមានានុស័យនោះ វៀរឋានជាអសាធារណៈ ក្នុងឋានសាធារណៈ រមែងឈ្មោះថា លោកលះបានហើយព្រមទាំងកាមរាគានុស័យ, ព្រោះហេតុដូច្នោះ ទើបធានាថា* **"អាមន្តា"** *។ បណ្ឌិតគប្បីជ្រាបភាពជាអ្នកលះបានហើយ និងពាក្យដែលមិនគប្បីពោលក្នុងឱកាសវារៈសូម្បីទាំងអស់ ដោយន័យនេះចុះ ។*

*ក៏ពាក្យថា* **“នត្ថិ”** *ក្នុងអាគតស្ថានទាំងឡាយ បណ្ឌិតគប្បីជ្រាបនូវវិនិច្ឆ័យ ដូចនឹងពាក្យដែលលោកពោលហើយខាងក្រោយចុះ ។ បុគ្គលោកាសវារៈ មានគតិដូចឱកាសវារៈនោះដែរ ។ ក្នុងបដិលោមន័យ ពាក្យថា* **“យស្ស កាមរាគានុសយោ អប្បហីនោ”** *នេះ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដោយអំណាចនៃភាពជាបុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតមែនហើយ អនុស័យទាំង ២ នេះ បុគ្គល ៦ ជំពូក តាំងពីបុថុជ្ជនរហូតដល់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអនាគាមិមគ្គ លះមិនទាន់បាន ក៏ពិតមែន, ប៉ុន្តែថា ក្នុងទីនេះ លោកមានបំណងយកព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គ ព្រោះព្រះបាលីថា* **“បរតោ តិណ្ណំ បុគ្គលានំ ទ្វិន្នំ បុគ្គលានំ”** *ជាដើម, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា* **“អាមន្តា”** *ដោយសំដៅយកបុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមីប៉ុណ្ណោះ ។*

*ពាក្យថា* **“ទ្វិន្នំ បុគ្គលានំ”** *បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមី ។ គប្បីជ្រាបនូវវិនិច្ឆ័យក្នុងបុគ្គលវារៈ ដោយន័យនេះឯង ។ ក៏ឱកាសវារៈ និងបុគ្គលោកាសវារៈ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខាងក្រោយចុះ ។*

**ចប់បហីនវារៈ**

*៦. ក្នុង* ***ឧប្បជ្ជនវារៈ*** *ដូចគ្នានឹងអនុសយវារៈនុ៎ះដែរ ។*

## ៧.ពណ៌នាអំពីធាតុវារៈ និងធាតុវិសជ្ជនាវារៈ

*បណ្ឌិតគប្បីជ្រាប* ***ធាតុវារៈ*** *សិនថា ៖* **“កតិ អនុសយា អនុសេន្តិ”** *បានដល់ អនុស័យប៉ុន្មាន ដែលប្រព្រឹត្តទៅតាមសន្តានហើយដេកនៅ ។*

*ពាក្យថា* **“កតិ អនុសយា នានុសេន្តិ** *= អនុស័យប៉ុន្មាន មិនទៅតាមសន្តានហើយដេកនៅ” ។*

*ពាក្យថា* **“កតិ អនុសយា ភង្គា”** *សេចក្ដីថា បណ្ឌិតគប្បីចែកយ៉ាងនេះថា “អនុស័យប៉ុន្មាន រមែងដេកសម្ងំ អនុស័យប៉ុន្មាន រមែងមិនដេកសម្ងំ” ។ ពាក្យដ៏សេសក្នុងទីនេះ ពាក្យណាដែលគួរពោល, ពាក្យនោះ លោកក៏ពោលហើយ ក្នុងឋានដែលកំណត់ព្រះបាលីខាងក្រោយនុ៎ះឯង ។ តែក្នុងនិទ្ទេសវារៈ លោកពោលទុកដោយអំណាចនៃបុថុជ្ជនថា “អនុស័យ ៧ រមែងដេកសម្ងំក្នុងនរណា ?” ។*

*ពាក្យថា* **“កស្សចិ បញ្ច”** *នេះ លោកពោលទុកដោយអំណាចនៃព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតមែនហើយ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ គឺលោកទាំងនោះ លះបានហើយ ព្រោះហេតុនោះ អនុស័យទាំង ៥ ប៉ុណ្ណោះ ទើបដេកសម្ងំ ។*

*បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យនេះថា ព្រះមានព្រះភាគទ្រង់កាន់យកសេចក្ដី*

ក្នុងបទថា **“ឧប្បជ្ជន្តិ”** នៃបទថា **“អនុសេន្តិ”** ក្នុងអនុសយវារៈ យ៉ាងណា, ក្នុងធាតុវារៈនេះ គប្បីជ្រាបថា មិនគប្បីកាន់យកយ៉ាងនោះដែរ ។

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះអនុស័យមិនកើតឡើងក្នុងខណៈនោះទេ ។*

*ពិតណាស់ កាលបើបុគ្គលកំពុងចូលកាមធាតុ វិបាកចិត្ត និងរូបដែលមានកម្មជាសមុដ្ឋាន រមែងកើត, តែអកុសលចិត្តរមែងមិនកើត ក្នុងខណៈនោះឡើយ ។ ក៏អនុស័យទាំងឡាយ រមែងកើតឡើងក្នុងខណៈនៃអកុសលចិត្ត, តែមិនកើតឡើងក្នុងខណៈនៃវិបាកចិត្ត ព្រោះហេតុដូច្នោះ ការមិនកើតក្នុងខណៈដូចពោលហើយនោះ ទើបមិនគួរកាន់យកឡើយ ។*

***សួរថា*** *គប្បីកាន់យកដូចម្ដេច ?*

*ឆ្លើយថា រមែងដឹងបានដោយប្រការណា ក៏គប្បីកាន់យកដោយប្រការនោះចុះ ។*

***សួរថា*** *រមែងដឹងបានដូចម្ដេច ?*

*ឆ្លើយថា រមែងដឹងបាន ព្រោះអត្ថថា ជាកិលេសដែលលះមិនទាន់បាន ។ ដូចយ៉ាងបុគ្គលដែលព្រមព្រៀងដោយកុសល និងអព្យាកតចិត្ត ព្រោះរាគៈ ទោសៈ និងមោហៈ ដែលខ្លួនលះមិនទាន់បាន លោកក៏ហៅថា “អ្នកមានរាគៈ ទោសៈ និងមោហៈ” យ៉ាងណា, សេចក្ដីនេះ ក៏យ៉ាងនោះ*

ដែរ; ព្រះមានព្រះភាគត្រាស់ថា "អនុស័យទាំងនោះ រមែងដេកសម្ងំក្នុងបុគ្គលនោះៗ សូម្បីក្នុងខណៈនៃបដិសន្ធិ ព្រោះភាវៈនៃមគ្គភាវនាមិនទាន់បានលះ" ។ ព្រះមានព្រះភាគមិនបានត្រាស់ថា "អនុស័យទាំងនោះ រមែងដេកសម្ងំតែម្យ៉ាងទេ, តែគប្បីជ្រាបថា អនុស័យទាំងនោះ ឈ្មោះថា ***ដេកសម្ងំ*** ព្រោះជាកិលេសជាតិដែលលះមិនទាន់បាននោះឯង" ។

ពាក្យថា **"អនុសយា ភគ្គា នត្ថិ"** អធិប្បាយថា ក៏ឈ្មោះថាអនុស័យ ដែលបណ្ឌិតគប្បីចែកយ៉ាងនេះថា "អនុស័យណា កំពុងដេកសម្ងំក្នុងបុគ្គលណា, អនុស័យនោះប៉ុណ្ណោះ រមែងដេកសម្ងំមែនពិត; អនុស័យនេះ រមែងដេកសម្ងំ និងមិនដេកសម្ងំ; អនុស័យនេះ គប្បីដេកសម្ងំផងមិនគប្បីដេកសម្ងំផង" ដូច្នេះ រមែងមិនមាន ។

ពាក្យថា **"រូបធាតុំ ឧប្បជ្ជន្តស្ស កស្សចិ តយោ"** នេះ ត្រាស់ទុកដោយអំណាចនៃព្រះអនាគាមី ។ ពិតណាស់ សូម្បីកាមរាគៈ បដិឃៈ ទិដ្ឋិ និងវិចិកិច្ឆាទាំង ៤ លោកលះបានហើយដោយមិនឲ្យមានសល់, អនុស័យ ៣ ក្រៅនេះ លោកលះមិនទាន់បាន; ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"កស្សចិ តយោ អនុសយា អនុសេន្តិ** = អនុស័យ ៣ រមែងដេកសម្ងំក្នុងនរណា" ។

*ពាក្យថា* **“ន កាមធាតុំ”** *អធិប្បាយថា កាលបើចូលដល់ធាតុទាំងពីរដ៏សេស ព្រោះតែលោកបដិសេធកាមធាតុចេញ ។*

*ពាក្យថា* **“សគ្គេច”** *នេះ ព្រះមានព្រះភាគទ្រង់កំណត់ ហើយត្រាស់ថា “ឈ្មោះថា ការកើតក្នុងកាមធាតុរបស់ព្រះអរិយសាវកអ្នកចុតិចាករូបធាតុ រមែងមិនមាន, មានចំពោះតែបុថុជ្ជនប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា* **‘សគ្គេច”** *។ សូម្បីក្នុងពាក្យថា* **“សគ្គេច”** *នៃបុគ្គលដែលចុតិចាកអរូបធាតុហើយ ចូលដល់កាមធាតុនេះ ក៏មានន័យដូចគ្នានេះដែរ ។*

***សួរថា*** *ព្រោះហេតុអ្វី ពាក្យថា “ការកើតឡើងក្នុងរូបធាតុ រមែងមិនមាន” ដូច្នេះ ? ។*

*ឆ្លើយថា ព្រោះមិនមានរូបាវចរជ្ឈានដែលជាធម៌ឲ្យសម្រេចក្នុងការកើតនោះ ។*

*ពិតណាស់ បុគ្គលនោះ ចូលដល់ធាតុនោះ ព្រោះឈានកន្លងរូបសញ្ញា ដោយប្រការទាំងពួង ព្រោះហេតុដូច្នោះ រូបាវចរជ្ឈានរបស់លោកទើបមិនមាននៅក្នុងទីនេះ ព្រោះមិនមានរូបាវចរជ្ឈាននោះ បណ្ឌិតគប្បីជ្រាបថា ការកើតឡើងក្នុងរូបធាតុ ទើបមិនមាន ។*

*ក្នុងបទថា* **“អរូបធាតុយា ចុតស្ស ន កាមធាតុំ”** *នេះ ទ្រង់ប្រាថ្នា*

យកអរូបធាតុប៉ុណ្ណោះ ។ គប្បីជ្រាបសេចក្ដីក្នុងវិសជ្ជនាទាំងពួង ដោយន័យដូចគ្នានេះចុះ ៕

**ចប់ធាតុវារៈ និងធាតុវិសជ្ជនាវារៈ**

**ចប់អនុសយយមកៈ**

---

## ៨.ចិត្តយមកៈ

## ពណ៌នាអំពីមាតិកាឋបនវារៈ

ឥឡូវនេះ នឹងពណ៌នាអត្ថនៃចិត្តយមកៈដែលព្រះមានព្រះភាគទ្រង់រួបរួមទុកជាឯកទេសមួយផ្សេង ដោយអំណាចនៃធម៌ទាំងឡាយនោះឯងមានកុសលធម៌ជាដើម ដែលបានសម្ដែងទុកក្នុងមូលយមកៈ ទើបសម្ដែងតពីអនុសយយមកៈ ។

ក្នុងចិត្តយមកៈនោះ មុនដំបូងគប្បីជ្រាបបាលីវវត្ថាន * សិន ៖ ក្នុងចិត្តយមកៈនេះ មាន ៧ វារៈ គឺ

**-មាតិកាឋបនវារៈ** វារៈដែលពោលអំពីការតាំងមាតិកា (ឧទ្ទេស) ។

---

* ការកំណត់មាតិកា ។

**-ឋបិតមាតិកាវិសជ្ជនាវារៈ** *វារៈដែលពោលអំពីការវិសជ្ជនា មាតិកា (និទ្ទេស) ដែលតាំងទុកហើយ ។*

*ក្នុងមាតិកាឋបនវារៈនោះ ខាងដើមមានសុទ្ធិកមហាវារៈ ៣ គឺ*

**-បុគ្គលវារៈ** *វារៈដែលពោលអំពីបុគ្គល*

**-ធម្មវារៈ** *វារៈដែលពោលអំពីធម៌*

**-បុគ្គលធម្មវារៈ** *វារៈដែលពោលអំពីបុគ្គល និងធម៌ ។*

*ក្នុងវារៈទាំង ៣ នោះ វារៈណាសម្ដែងប្រភេទនៃធម៌មានការកើត និងការរលត់ជាដើមទៅ ដោយលើកបុគ្គលឡើងសម្ដែងយ៉ាងនេះថា* **“យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** *= ចិត្តរបស់បុគ្គលណាកំពុងកើត មិនមែនកំពុងរលត់”* *ជាដើម, វារៈនោះ ឈ្មោះថា* ***បុគ្គលវារៈ*** *។*

*វារៈណាសម្ដែងប្រភេទនៃធម៌ មានការកើត និងការរលត់ជាដើម ដោយលើកធម៌ប៉ុណ្ណោះឡើងសម្ដែងយ៉ាងនេះថា* **“យំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** *= ចិត្តណាកំពុងកើត មិនមែនកំពុងរលត់”* *ជាដើម វារៈនោះ ឈ្មោះថា* ***ធម្មវារៈ*** *។*

*វារៈណាសម្ដែងប្រភេទនៃធម៌ មានការកើត និងការរលត់ជាដើម របស់ចិត្ត ប្រព្រឹត្តទៅដោយលើកបុគ្គល និងធម៌ឡើងសម្ដែងយ៉ាងនេះថា* **“យស្ស យំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** *= ចិត្តរបស់បុគ្គលណាកំពុងកើត*

*មិនមែនកំពុងរលត់"* *ជាដើម, វារៈនោះ ឈ្មោះថា* ***បុគ្គលធម្មវារៈ*** *ฯ*

*តពីនោះ អាស្រ័យបទ ១៦ មានពាក្យថា* **"យស្ស សរាគំ ចិត្តំ** *= ចិត្តរបស់បុគ្គលណាមានរាគៈ" ជាដើម ទើបបាននូវមិស្សកវារៈ ៤៨ វារៈ គឺ*

***-បុគ្គលវារៈ ១៦ វារៈ***

***-ធម្មវារៈ ១៦ វារៈ***

***-បុគ្គលធម្មវារៈ ១៦ វារៈ*** *ฯ*

*ពួកមិស្សកវារៈដែលចែកចេញទៅ* ***ដោយសរាគបទ*** *ជាដើម ฯ មិស្សកវារៈ ៤៨ វារៈនោះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកត្រឹមតែបទដើម គឺសរាគបទហើយទ្រង់បំប្រួញទុក ฯ*

*តពីនោះ អាស្រ័យបទនៃអភិធម្មមាតិកា ២៦៦ បទ ដោយន័យថា* **"យស្ស កុសលចិត្តំ"** *ជាដើម ទើបបាននូវមិស្សកវារៈ ៧៩៨ វារៈទៀត គឺ*

***-បុគ្គលវារៈ ២៦៦ វារៈ***

***-ធម្មវារៈ ២៦៦ វារៈ***

***-បុគ្គលធម្មវារៈ ២៦៦ វារៈ*** *ฯ*

*វារៈទាំងនេះ ចែកចេញទៅដោយកុសលជាដើម ฯ សូម្បីវារៈទាំងនោះ ក៏ព្រះអង្គទ្រង់សម្ដែងត្រឹមតែបទដើម គឺកុសលបទហើយទ្រង់បំប្រួញ*

ទុកដូចគ្នា ។ ក្នុងចិត្តយមកៈនេះ មានបទបុច្ឆា និងវិសជ្ជនាទំនងដូចគ្នា បទពួកណា មិនប្រកបដោយចិត្ត បទទាំងនោះ ព្រះមានព្រះភាគទ្រង់កាន់យកជាមោឃបុច្ឆា ។

ក៏បណ្តាវារៈទាំង ៣ នោះ សុទ្ធិកបុគ្គលមហាវារៈ ដែលជាវារៈដំបូង មានអន្តរវារៈ ១៨ វារៈ គឺ

***១.ឧប្បាទនិរោធកាលសម្ភេទវារៈ*** វារៈពោលអំពីការលាយគ្នានៃកាលរបស់ឧប្បាទៈ និងនិរោធ ។

***២.ឧប្បាទុប្បន្នវារៈ*** វារៈពោលអំពីឧប្បាទៈ និងឧប្បន្នៈ

***៣.និរោធុប្បន្នវារៈ*** វារៈពោលអំពីនិរោធ និងឧប្បន្នៈ

***៤.ឧប្បាទវារៈ*** វារៈពោលអំពីឧប្បាទៈ

***៥.និរោធវារៈ*** វារៈពោលអំពីនិរោធ

***៦.ឧប្បាទនិរោធវារៈ*** វារៈពោលអំពីឧប្បាទៈ និងនិរោធ

***៧.ឧប្បជ្ជមាននិរោធវារៈ*** វារៈពោលអំពីឧប្បជ្ជមានៈ និងនិរោធ

***៨.ឧប្បជ្ជមានុប្បន្នវារៈ*** វារៈពោលអំពីឧប្បជ្ជមានៈ និងឧប្បន្នៈ

***៩.និរុជ្ឈមានុប្បន្នវារៈ*** វារៈពោលអំពីនិរុជ្ឈមានៈ និងឧប្បន្នៈ

***១០.ឧប្បន្នុប្បាទវារៈ*** វារៈពោលអំពីឧប្បន្នៈ និងឧប្បាទៈ

***១១.អតីតានាគតវារៈ*** វារៈពោលអំពីអតីត និងអនាគត

***១២_ឧប្បន្នុប្បជ្ជមានវារៈ*** *វារៈពោលអំពីឧប្បន្នៈ និងឧប្បជ្ជមានៈ*

***១៣_និរុទ្ធនិរុជ្ឈមានវារៈ*** *វារៈពោលអំពីនិរុទ្ធៈ និងនិរុជ្ឈមានៈ*

***១៤_អតិក្កន្តកាលវារៈ*** *វារៈពោលអំពីកាលដែលកន្លងផុត ។*

*បណ្ដាអន្តរវារៈទាំង ១៤ វារៈនេះ ក្នុង ៣ វារៈទាំងនេះ គឺ*

***_ឧប្បាទវារៈ*** *វារៈពោលអំពីការកើតឡើង*

***_និរោធវារៈ*** *វារៈពោលអំពីការរលត់*

***_ឧប្បាទនិរោធវារៈ*** *វារៈពោលអំពីការកើត និងការរលត់ ។*

*ដោយអាស្រ័យអនុលោម និងបដិលោម ទើបមានវារៈ ៦ គូ រួមត្រូវជា ១៨ គូ (១៨ យមកៈ) ។ ក្នុង* ***ឧប្បន្នុប្បាទវារៈ*** *បានយមកៈ ៤ (៤ គូ) គឺដោយអនុលោម ២ បដិលោម ២ ព្រោះអាស្រ័យកាលដែលជាអតីត និងអនាគត ។ ក្នុងវារៈ ១០ គឺ ៣ វារៈដ៏សេសដែលទ្រង់សម្ដែងទុកខាងដើម ៣ វារៈ ដែលសម្ដែងទុកក្នុងចន្លោះ និង ៤ វារៈ ដែលសម្ដែងទុកហើយ គឺវារៈទី ៧, ៨, ៩ និងវារៈចុងក្រោយ ដោយអនុលោម ១ បដិលោម ១ ធ្វើជាពីរចំណែក ទើបត្រូវជាយមកៈ ២០ (២០ គូ) ។*

*សូម្បីក្នុងអន្តរវារៈទាំងអស់ ១៤ វារៈ កំណត់បុច្ឆា ៨៤ ចាត់ជាយមកៈបាន ៨២ មានអត្ថ ១៦៨ ដោយប្រការដូច្នេះ ។ យមកៈ ១២៦*

រមែងមានក្នុងមហាវារៈទាំង ៣ គឺសុទ្ធិកបុគ្គលវារៈ សុទ្ធិកធម្មវារៈ និងសុទ្ធិកបុគ្គលធម្មវារៈ; ម្យ៉ាងទៀត ក្នុងសុទ្ធិកបុគ្គលវារៈមាន យ៉ាងណា, ក្នុងសុទ្ធិកធម្មវារៈ និងសុទ្ធិកបុគ្គលធម្មវារៈ ក៏មានយ៉ាងនោះដែរ ។

បណ្ឌិតគប្បីជ្រាបពាក្យបុច្ឆាជាទ្វេគុណអំពីយមកៈ និងអត្ថជាទ្វេគុណអំពីបុច្ឆានោះចុះ ។ ក៏ក្នុងចិត្តយមកៈនេះ មានយមកៈច្រើនពាន់ដោយយកវារៈទាំង ៣ នេះ គុណដោយបទ ១៦ បទ ដោយអំណាចនៃសរាគបទជាដើម និងគុណដោយបទ ២៦៦ បទ ដោយអំណាចនៃកុសលបទជាដើម ។ ក៏ព្រះបាលី លោកសង្ខេបទុកថា **“តតោ ទិគុណា បុច្ឆា តតោ ទិគុណា អត្ថា ច ហោន្តិ** = បុច្ឆាទ្វេគុណអំពីយមកៈនោះ អត្ថ (វិសជ្ជនា) ក៏ទ្វេគុណ អំពីបុច្ឆានោះដែរ” ដូច្នេះ, បណ្ឌិតគប្បីជ្រាបការកំណត់បាលីក្នុងចិត្តយមកៈនេះមុន ដូចពណ៌នាមកដូច្នេះ ៕

## ចប់មាតិកាឋបនវារៈ

## ពណ៌នាអំពីវិសជ្ជនាវារៈ (និទ្ទេស)

ឥឡូវនេះ ដើម្បីទ្រង់វិសជ្ជនាបទមាតិកាដោយលំដាប់តាមដែលតាំងទុក ទើបព្រះមានព្រះភាគទ្រង់ផ្តើមតាំងពាក្យថា **“យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ, តស្ស ចិត្តំ និរុជ្ឈិស្សតិ”** ជាដើម ។

បណ្តាបទទាំងនោះ បទថា **“ឧប្បជ្ជតិ** = កំពុងកើត**”** ព្រោះដល់ព្រមដោយឧប្បាទក្ខណៈ ។ បទថា **“ន និរុជ្ឈតិ** = មិនមែនកំពុងរលត់**”** ព្រោះនៅមិនទាន់ដល់និរោធខណៈ ។ ពីរបទថា **“តស្ស ចិត្តស្ស”** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា “ចាប់ដើមពីនោះ ចិត្តរបស់បុគ្គលនោះនឹងរលត់ មិនកើតពិតមែនឬ ?” ។ ពីរបទថា **“តេសំ ចិត្តំ”** សេចក្តីថា ឧប្បាទក្ខណៈនៃចុតិចិត្តដួងចុងក្រោយទាំងអស់ របស់ព្រះខីណាស្រពឯណា អ្នកមានវដ្តទុក្ខដែលកាត់ផ្តាច់ហើយ កំពុងប្រព្រឹត្តទៅ, ចុតិចិត្តរបស់ព្រះខីណាស្រពនោះឯង ឈ្មោះថា កំពុងកើត ព្រោះដល់ឧប្បាទៈ, មិនមែនកំពុងរលត់ ព្រោះនៅមិនទាន់ដល់ភង្គខណៈ ។ តែឥឡូវនេះ ចិត្តរបស់ព្រះខីណាស្រពទាំងនោះ ឈ្មោះថា នឹងរលត់ ព្រោះដល់ភង្គខណៈ, តពីនោះចិត្តដទៃ ឈ្មោះថា នឹងមិនកើតឡើង ព្រោះមិនបានធ្វើបដិសន្ធិ ។ បទថា **“ឥតរេសំ”** បានដល់ ចិត្តរបស់ព្រះសេក្ខៈ និងបុថុជ្ជនដ៏សេស វៀរព្រះខីណាស្រពដែលដល់ព្រមដោយបច្ឆិមចិត្ត ។ ពីរបទថា **“និរុជ្ឈិស្សតិ ចេវ ឧប្បជ្ជិស្សតិ ច”** សេចក្តីថា ចិត្តឯណា ដល់ឧប្បាទក្ខណៈ, ចិត្តនោះឯងនឹងរលត់ទៅ, ចំណែកចិត្តដទៃនឹងកើតផង និងរលត់ផង ក្នុងអត្តភាពនោះឬថា ក្នុងអត្តភាពដទៃ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់សំដៅយកចិត្តរបស់ព្រះខីណាស្រពនោះឯង ក្នុងបុច្ឆា និងវិសជ្ជនាទី ២ ទើបត្រាស់ថា

**"អាមន្តា"** ។ ពីរបទថា **"ឧប្បជ្ជតិ និរុជ្ឈិស្សតិ"** បានដល់ បច្ឆិមចិត្ត របស់ព្រះអរហន្តក្នុងភង្គខណៈខ្លះ ចិត្តកំពុងរលត់របស់បុគ្គលដ៏សេសខ្លះ ។ ក៏ចាប់ដើមពីចិត្តនោះមក នរណាមួយអាចពោលថា "ចិត្តរបស់ព្រះអរហន្ត នឹងមិនរលត់ឡើយ" ដូច្នេះ, តែមិនអាចពោលថា **"នឹងកើត"** ដូច្នេះ ឡើយ ។ នរណាមួយអាចពោលថា "ចិត្តរបស់បុគ្គលដ៏សេស នឹងកើត", និងមិនអាចពោលថា "នឹងមិនរលត់ឡើយ" ; ព្រោះហេតុនោះ ទើបព្រះ អង្គទ្រង់បដិសេធថា **"នោ"** ។

ក្នុងទុតិយបញ្ហា ចិត្តរបស់បុគ្គលណា នឹងមិនរលត់, តែនឹងកើត, បុគ្គលនោះឯង មិនមានមានទេ; ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់ហាម ដោយពាក្យថា **"នត្ថិ** (បដិក្ខេបវិសជ្ជនា)**"** ។

ពាក្យថា **"ឧប្បន្នំ"** នេះ ជាឈ្មោះរបស់ចិត្តដែលដល់ព្រមដោយ ការកើត ។ម្យ៉ាងទៀត ជាឈ្មោះរបស់ចិត្តដែលដល់ឧប្បាទៈហើយនៅមិន ទាន់រលត់ទៅ ។ ក្នុងវារៈនោះ ព្រះមានព្រះភាគទ្រង់សំដៅយកចិត្តដែលដល់ ព្រមដោយឧប្បាទៈ ទើបត្រាស់ថា **"អាមន្តា"** ។ ពាក្យថា **"តេសំ ចិត្តំ ឧប្បន្នំ"** ព្រះមានព្រះភាគទ្រង់សំដៅយកចិត្តដែលដល់ឧប្បាទៈហើយ នៅមិនទាន់រលត់ទៅ ។ ពាក្យថា **"អនុប្បន្នំ"** បានដល់ មិនទាន់ដល់ឧប្បាទៈ

ទេ ។ ក្នុងពាក្យថា **"តេសំ ចិត្តំ ឧប្បជ្ជិត្ថ"** នេះ សេចក្ដីថា ចិត្តរបស់បុគ្គលទាំងអស់ ជាបច្ចុប្បន្នក្ខណៈមុននោះឯង ឈ្មោះថា ធ្លាប់កើតឡើងហើយ ព្រោះកន្លងមកហើយនូវឧប្បាទក្ខណៈ ។

ពាក្យថា **"ឧប្បជ្ជិត្ថ ចេវ ឧប្បជ្ជតិ ច"** អធិប្បាយថា ឈ្មោះថា **ឧប្បជ្ជិត្ថ** = ធ្លាប់កើត ព្រោះដល់ហើយនូវឧប្បាទក្ខណៈ, ឈ្មោះថា **ឧប្បជ្ជតិ** = កំពុងកើត ព្រោះមិនទាន់កន្លងឧប្បាទក្ខណៈ ព្រោះភាវៈនៃបុគ្គលដែលចូលដល់និរោធសមាបត្តិ, ចិត្តធ្លាប់កើតឡើងហើយ ក្នុងកាលមុន អំពីនិរោធ, (និង) ព្រោះអសញ្ញសត្តបុគ្គល (ចិត្ត) ធ្លាប់កើតឡើងហើយ ក្នុងសញ្ញីភព ។

ពាក្យថា **"ឧប្បាទក្ខណេ អនាគតញ្ច"** បានដល់ ចិត្តក្នុងឧប្បាទ-ក្ខណៈ និងចិត្តក្នុងអនាគត ។

ចប់វិសជ្ជនាវារៈ

---

## ពណ៌នាអំពីអតិក្កន្តកាលវារៈ

ក្នុងអតិក្កន្តកាលវារៈ ពាក្យថា **"ឧប្បជ្ជមានំ ខណំ"** បានដល់ ឧប្បាទក្ខណៈ ។ ក្នុងវារៈនោះ ឧប្បាទក្ខណៈ មិនឈ្មោះថា កំពុងមាន ក៏ពិតមែនហើយ, ប៉ុន្តែ ព្រះមានព្រះភាគ ក៏បានត្រាស់យ៉ាងនោះ ព្រោះ

*ជាខណៈរបស់ចិត្តកំពុងកើត ។ ពាក្យថា* **“ខណំ វីតិក្កន្តំ អតិក្កន្តកាលំ”** *អធិប្បាយថា ក៏ឧប្បាទក្ខណៈនោះឯង ឈានកន្លងហើយមិនយូរ, ជាចិត្តឈានកន្លងហើយ ទើបរាប់ថា មានកាលដែលឈានកន្លងហើយ (អតិក្កន្តកាល) ។ ពាក្យថា* **“និរុជ្ឈមានំ ខណំ”** *បានដល់ និរោធក្ខណៈ ។ ក្នុងពាក្យនោះ និរោធក្ខណៈ មិនឈ្មោះថា កំពុងមាន ក៏ពិតមែនហើយ, ប៉ុន្តែក៏ត្រាស់យ៉ាងនោះ ព្រោះជាខណៈរបស់ចិត្តដែលកំពុងរលត់ ។ ពាក្យថា* **“ខណំ វីតិក្កន្តំ អតិក្កន្តកាលំ”** *សេចក្ដីថា ព្រះមានព្រះភាគរមែងត្រាស់សួរថា “ចិត្តរបស់បុគ្គលនោះ សូម្បីជាចិត្តឈានកន្លងនិរោធក្ខណៈយ៉ាងនេះ ក៏ឈ្មោះថា មានការឈានកន្លងហើយមែនឬ ?” ។ ក្នុងសេចក្ដីនោះ ព្រោះចិត្តក្នុងភង្គខណៈឈានកន្លងឧប្បាទក្ខណៈហើយ រាប់ថា មានកាល ឈានកន្លងហើយ, កាលបើចិត្តឈានកន្លងនិរោធក្ខណៈហើយ ក៏ឈ្មោះថា មានកាលឈានកន្លងហើយ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់វិសជ្ជនាថា “ក្នុងភង្គខណៈ ចិត្តឈានកន្លងឧប្បាទក្ខណៈ តែមិនឈានកន្លងភង្គខណៈទេ, ចិត្តដែលជាអតីត ឈានកន្លងឧប្បាទក្ខណៈផង ឈានកន្លងភង្គខណៈផង” ។*

***ក្នុងការវិសជ្ជនាបញ្ហាទី ២*** *ព្រោះចិត្តក្នុងអតីត ឈានកន្លងខណៈសូម្បីទាំងពីរ ទើបឈ្មោះថា មានកាលឈានកន្លងហើយ, ព្រោះហេតុ*

ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **"អតីតំ ចិត្តំ"** ។

***ក្នុងការវិសជ្ជនាបដិលោមបញ្ហា*** ក៏ព្រោះចិត្តក្នុងឧប្បាទក្ខណៈ និងចិត្តក្នុងអនាគត ជាចិត្តឈានកន្លងខណៈសូម្បីទាំងពីរ * គឺឧប្បាទក្ខណៈ និងភង្គខណៈ, តែមិនឈ្មោះថា មានកាលឈានកន្លងឡើយ ព្រោះភាវៈនៃខណៈទាំងនោះ នៅទាន់មិនទាន់ឈានកន្លង, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **"ឧប្បាទក្ខណេ ចិត្តំ អនាគតំ ចិត្តំ"** ដូច្នេះ; ក្នុងការវិសជ្ជនាបញ្ហាទី ២ ប្រាកដច្បាស់ហើយ; គប្បីជ្រាបសេចក្តីក្នុងការវិសជ្ជនាបញ្ហាទាំងពួង សូម្បីក្នុងធម្មវារៈដោយឧបាយនេះចុះ ។

បុគ្គលធម្មវារៈ ក៏មានគតិដូចធម្មវារៈនុ៎ះដែរ ។ សូម្បីមិស្សកវារៈទាំងអស់ ព្រះមានព្រះភាគទ្រង់សម្តែងបង្រួញទុកត្រឹមតែមាតិកាដោយន័យថា **"យស្ស សរាគំ ចិត្តំ"** ជាដើម ។ ចំណែកសេចក្តីពិស្តារ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយខាងក្រោយនុ៎ះចុះ ។ ក៏ក្នុងវារៈទាំងនោះរមែងមានបុច្ឆាដូចគ្នា ព្រោះជាបញ្ហាដែលគប្បីឲ្យពិស្តារយ៉ាងនេះថា **"យស្ស**

---

* សេចក្តីដែលថា "ជាចិត្តឈានកន្លងខណៈសូម្បីទាំងពីរ តែមិនឈ្មោះថា មានកាលឈានកន្លងហើយ" ដូច្នេះ ការវិវាទគ្នា ព្រោះចិត្តក្នុងឧប្បាទក្ខណៈ និងចិត្តក្នុងអនាគត នៅមិនទាន់ឈានកន្លងខណៈទាំងពីរ គឺឧប្បាទក្ខណៈ និងភង្គខណៈ ។

**សរាគំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ, តស្ស ចិត្តំ និរុជ្ឈិស្សតិ នុប្បជ្ជិស្សតិ** = *ចិត្តមានរាគៈរបស់បុគ្គលណា កំពុងកើត មិនមែនកំពុងរលត់, ចិត្តរបស់បុគ្គលនោះ នឹងរលត់ និងមិនកើតមែនឬ ?" ជាដើម តែព្រោះចិត្តមានរាគៈ មិនមែនជាបច្ឆិមចិត្តទេ, ព្រោះហេតុដូច្នោះ ការវិសជ្ជនា ទើបឈ្មោះថា មិនដូចគ្នា ព្រោះបញ្ហាថា "ចិត្តមានរាគៈរបស់បុគ្គលណា កំពុងកើត, មិនមែនកំពុងរលត់; ចិត្តរបស់បុគ្គលនោះ នឹងរលត់ និងមិនកើតមែនឬ ?" ដូច្នេះ; លោកប្រើពាក្យវិសជ្ជនាថា* **"នោ"** *ដោយប្រការដូច្នេះ វិសជ្ជនាបញ្ហានោះៗ គប្បីជ្រាបតាមការសមគួរនឹងបុច្ឆានោះៗ ដូច្នេះចុះ ៕*

ចប់អតិក្កន្តកាលវារៈ

**ចប់ចិត្តយមកៈ**

## ៩.ធម្មយមកៈ

## ១.ពណ៌នាអំពីបញ្ញត្តិឧទ្ទេសវារៈ

*ឥឡូវនេះ នឹងពណ៌នាធម្មយមកៈ ដែលព្រះមានព្រះភាគទ្រង់តាំងមាតិកានៃធម៌ទាំងឡាយ មានកុសលធម៌ជាដើមទាំងនោះឯង ដែលសម្តែងទុកក្នុងមូលយមកៈ ហើយសម្តែងពីចិត្តយមកៈ ។*

*ក្នុងធម្មយមកៈនេះ គប្បីជ្រាបការកំណត់ព្រះបាលីតាមន័យដែល*

ពោលទុកក្នុងខន្ធយមកៈនោះឯង; ក៏ក្នុងខន្ធយមកៈមាន ៣ មហាវារៈ មានបញ្ញត្តិវារៈជាដើម និងមានអន្តរវារៈដ៏សេស ដោយប្រការណា, ក្នុងធម្មយមកៈ ក៏មានដោយប្រការនោះដែរ ។

តែក្នុងធម្មយមកៈនេះ គប្បីជ្រាបថា លោកហៅបរិញ្ញាវារៈថា ភាវនាវារៈ ព្រោះមានព្រះបាលីជាអាគតស្ថានថា **"យោ កុសលធម្មំ ភាវេតិ, សោ អកុសលធម្មំ បជហតិ** = បុគ្គលណាចម្រើនកុសលធម៌, បុគ្គលនោះ ឈ្មោះថា លះអកុសលធម៌ឬ ?" ។

ក្នុងភាវនាវារៈនោះ អព្យាកតធម៌ ជាធម៌ដែលបុគ្គលមិនគួរចម្រើនផង, មិនគួរលះផង, ព្រោះហេតុនោះ ទើបលោកមិនលើកបទនោះឡើងសម្ដែង; ក៏ក្នុងបញ្ញត្តិវារៈនៃធម្មយមកៈនេះ គប្បីជ្រាបការរាប់យមកៈក្នុងវារៈទាំង ៤ នេះ គឺបទសោធនវារៈ, បទសោធនមូលចក្កវារៈ, សុទ្ធធម្មវារៈ និងសុទ្ធធម្មមូលចក្កវារៈ ដោយអំណាចនៃធម៌ទាំងឡាយ មានកុសលធម៌ជាដើម ៕

## ២.ពណ៌នាអំពីនិទ្ទេសនៃបញ្ញត្តិវារៈ

*ចំណែកក្នុងនិទ្ទេសនៃបញ្ញត្តិវារៈ ព្រះអង្គទ្រង់ត្រាស់ថា* **“អាមន្តា”** *ដូច្នេះ ព្រោះភាវៈនៃកុសលទាំងឡាយ ជាកុសលធម៌ដោយពិតប្រាកដ, ក្នុងបញ្ហាដែលថា* ***“កុសល ឈ្មោះថា កុសលធម៌ឬ ?”*** *ដូច្នេះ សូម្បីក្នុងពាក្យវិសជ្ជនាដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យវិសជ្ជនាថា* ***“ធម៌ទាំងឡាយដ៏សេស មិនឈ្មោះថា អកុសល តែឈ្មោះថា ធម៌”*** *អធិប្បាយថា ធម៌ទាំងឡាយដ៏សេស មិនជាអកុសលទេ, តែជាធម៌; គប្បីជ្រាបពាក្យវិសជ្ជនាទាំងអស់ តាមន័យនេះចុះ ៕*

## ៣.ពណ៌នាអំពីបវត្តិវារៈ

*ក៏ក្នុងអនុលោមន័យនៃបុគ្គលវារៈ បច្ចុប្បន្នកាល ក្នុងបវត្តិវារៈនេះ យមកៈ ៣ យ៉ាង គឺយមកៈដែលមានកុសលធម៌ជាមូល ២ យ៉ាង, មានអកុសលធម៌ជាមូលម្យ៉ាង រមែងមានក្នុងបញ្ហាថា* ***“កុសលធម៌រមែងកើតដល់បុគ្គលណា, អកុសលធម៌ ក៏រមែងកើតដល់បុគ្គលនោះ មែនឬ ?, ឬក៏អកុសលធម៌រមែងកើតដល់បុគ្គលណា, កុសលធម៌ ក៏រមែងកើតដល់បុគ្គលនោះ មែនឬ ?”*** *។*

ក្នុងបដិលោមន័យក្តី ក្នុងវារៈទាំងឡាយ មានឱកាសវារៈជាដើមក្តី ក៏មានន័យដូចគ្នានេះដែរ; បណ្ឌិតគប្បីជ្រាបការរាប់យមកៈ ដោយអំណាចនៃយមកៈទាំងឡាយ ៣ យ៉ាង ក្នុងវារៈទាំងពួង ត្រង់បវត្តិវារៈនេះ យ៉ាងនេះចុះ ។

ក៏ក្នុងការវិនិច្ឆ័យសេចក្តីក្នុងបវត្តិវារៈ គប្បីជ្រាបលក្ខណៈនេះ ដូចតទៅ ៖

ក្នុងបវត្តិមហាវារៈនៃធម្មយមកៈនេះ ពាក្យថា **"ឧប្បជ្ជន្តិ** = រមែងកើត, **និរុជ្ឈន្តិ** = រមែងរលត់" ក្នុងឧប្បាទៈ និងនិរោធវារៈទាំងនេះ រមែងមានកុសលធម៌ និងអកុសលធម៌ក្នុងបវត្តិកាលប៉ុណ្ណោះ មិនបានចុតិ និងបដិសន្ធិកាលទេ; តែថា អព្យាកតធម៌រមែងមាន ក្នុងកាលទាំង ៣ គឺបវត្តិ ចុតិ និងបដិសន្ធិ ។

លក្ខណៈណា រមែងមានក្នុងទីណាៗ គប្បីជ្រាបពាក្យវិនិច្ឆ័យរបស់លក្ខណៈនោះ ក្នុងទីនោះៗ យ៉ាងនេះ ។

គប្បីជ្រាបន័យមុខ (មុខន័យ) ក្នុងការវិនិច្ឆ័យនោះដូច្នេះ ៖

ពាក្យបដិសេធថា **"នោ** = មិនមែន" ដូច្នេះ ព្រះអង្គទ្រង់ធ្វើហើយ ព្រោះការមិនកើតឡើងក្នុងខណៈជាមួយគ្នារបស់កុសល និងអកុសល ។

ពាក្យថា **"អព្យាកតោ ច"** លោកពោលហើយដោយអំណាចនៃរូប

ដែលមានចិត្តជាសមុដ្ឋាន ។

បញ្ហាថា ***“កុសលធម៌រមែងមិនកើតឡើងក្នុងភូមិណា”*** នេះ លោកពោលសំដៅយកអសញ្ញីភព; ព្រោះហេតុដូច្នោះ ក្នុងបញ្ហានេះ ទើបលោកធ្វើពាក្យវិសជ្ជនាថា **“អាមន្តា = មែន”**; សូម្បីក្នុងពាក្យថា ***“រមែងកើតឡើង”*** នេះ ក៏លោកពោលសំដៅយកអសញ្ញីភពនោះដែរ; តែធ្វើការហាមឃាត់ថា ***“មិនមាន”*** ព្រោះមិនមានឋានកើតឡើងនៃអព្យាកតធម៌ទាំងឡាយ មានសេចក្ដីថា អព្យាកតធម៌កើតមានក្នុងទុកភូមិ ។

ពាក្យថា **“ទុតិយេ អកុសលេ** = កាលបើអកុសលទីពីរ” បានដល់ជវនចិត្តដួងទីពីរក្នុងនិក្កន្តិជវនៈដែលកើតឡើងហើយ ព្រោះរីករាយនូវភព ។

ពាក្យថា **“ទុតិយេ ចិត្តេ ខត្តមានេ** = កាលបើចិត្តដួងទីពីរកំពុងប្រព្រឹត្តទៅ” បានដល់ កាលបើភវង្គចិត្តដែលជាចិត្តដួងទីពីរ តពីបដិសន្ធិ-ចិត្ត កំពុងប្រព្រឹត្តទៅ;ម្យ៉ាងទៀត ពាក្យថា **“ទុតិយេ ចិត្តេ ខត្តមានេ”** បានដល់ កាលបើអាវជ្ជនចិត្តក្នុងភវនិក្កន្តិជវនៈ បានដល់កាលប្រព្រឹត្តទៅ ព្រោះធ្វើនូវភវង្គ មួយអន្លើដោយបដិសន្ធិឲ្យដូចគ្នា ដោយអំណាចនៃវិបាកចិត្ត ។ ពិតណាស់ អាវជ្ជនចិត្តនោះ ឈ្មោះថា **ទុតិយចិត្ត** = ចិត្តដួងទីពីរ, រាប់ពីវិបាកចិត្ត ព្រោះអាវជ្ជនចិត្តនោះ ជាកិរិយាចិត្តក្នុងអព្យាកតជាតិ, មានន័យថា អាវជ្ជនចិត្តជាចិត្តរបស់មនុស្សគ្រប់ជាតិ

*ជាមួយនឹងវិបាក ។*

*ពាក្យថា* **“យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ”** *លោកពោលសំដៅយកគោត្រភូចិត្ត (វោទានចិត្ត) ។*

*ពាក្យថា* **“កុសលា ធម្មា ឧប្បជ្ជិស្សន្តិ”** *លោកពោលសំដៅយកធម៌ទាំងឡាយ គឺមគ្គដ៏សេសទាំងនោះ ។*

*បញ្ហាថា* **“យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ, តស្ស ចិត្តស្ស ឧប្បាទក្ខណេ”** *លោកពោលដោយអំណាចនៃការកើតឡើងរបស់វោទានចិត្តនេះ; ក៏លក្ខណៈនេះ រមែងបាន (ប្រព្រឹត្តទៅ) សូម្បីក្នុងឧប្បាទ-ក្ខណៈនៃឱរិមចិត្ត បានដល់ ចិត្តដូចមុន អំពីវោទានចិត្តនោះ ដែលកើតឡើងហើយដោយអាវជ្ជនចិត្តដូចគ្នា នៃការកើតរបស់វោទានចិត្តនោះ ។*

*សូម្បីក្នុងនិរោធវារៈ លោកពោលហើយថា* **“នោ** = *មិនមែនទេ*” *ព្រោះភាវៈនៃកុសល និងអកុសលមិនរលត់ព្រមគ្នា; គប្បីជ្រាបពាក្យវិនិច្ឆ័យក្នុងទីទាំងពួង ដោយមុខន័យ (ឬនយមុខ) នេះ ដោយប្រការដូច្នេះ ៕*

**ចប់ធម្មយមកៈ ដោយបរិបូណ៌**

# ១០.ឥន្ទ្រិយយមកៈ

ឥឡូវនេះ នឹងពណ៌នា ***ឥន្ទ្រិយយមកៈ*** ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកក្នុងលំដាប់តអំពីធម្មយមកៈ ព្រោះទ្រង់រួបរួមធម៌ទាំងឡាយមានកុសលធម៌ជាដើម ដែលព្រះអង្គទ្រង់សម្ដែងហើយ ក្នុងមូលយមកៈទាំងនោះ ឲ្យជាចំណែកមួយ ដោយអំណាចនៃធម៌ដែលមាននៅក្នុងឥន្ទ្រិយ-យមកៈនោះ; គប្បីជ្រាបការកំណត់ព្រះបាលី ដោយន័យដែលពោលហើយក្នុងខន្ធយមកៈជាដើម ។

ក៏ទោះបីក្នុងឥន្ទ្រិយយមកៈនេះ មហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងអន្តរវារៈដែលនៅសល់ ក៏ដូចគ្នានឹង (ន័យ) ដែលមានមកហើយក្នុងយមកៈទាំងឡាយ មានខន្ធយមកៈជាដើម ព្រមទាំងប្រភេទនៃកាលជាដើម; ប៉ុន្តែ យមកៈទាំងឡាយមានច្រើនជាងធាតុយមកៈ ព្រោះឥន្ទ្រិយទាំងឡាយមានច្រើន; ក៏លោកមិនប្រកបយកជិវ្ហាយតនៈ និងកាយាយតនៈជាមួយចក្ខាយតនៈ និងចក្ខុធាតុ ក្នុងន័យដែលមានចក្ខាយតនៈ ព្រមទាំងចក្ខុធាតុជាមូលក្នុងបុគ្គលវារៈជាដើម ក្នុងពេលក្រោយ និងមិនកាន់យកយមកៈទាំងឡាយ មានជិវ្ហាយតនៈ និងកាយាយតនៈជាមូល យ៉ាងណា, សូម្បីក្នុងឥន្ទ្រិយយមកៈនេះ ក៏លោកមិនប្រកបជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយក្នុងន័យដែលមានចក្ខុន្ទ្រិយជាមូល និងមិនកាន់យកយមកៈទាំងឡាយ ដែល

*មានជីវិតិន្ទ្រិយ ព្រមទាំងកាយិន្ទ្រិយជាមូលយ៉ាងនោះ; គប្បីជ្រាបហេតុក្នុងការមិនកាន់យកយមកៈទាំងឡាយនោះ តាមន័យដែលលោកពោលទុកហើយ ក្នុងយមកៈនោះឯង ។*

*ចំណែក **មនិន្ទ្រិយ** គប្បីជ្រាបថា លោកប្រកបហើយដោយមូលទាំងឡាយ មានចក្ខុន្ទ្រិយជាមូលជាដើម យ៉ាងណា, សូម្បីជាមួយមូលទាំងឡាយ មានឥន្ទ្រិយជាមូលជាដើម ក៏យ៉ាងនោះដែរ; មនិន្ទ្រិយរមែងដល់នូវការប្រកប ព្រោះហេតុណា, ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនប្រកបដោយលំដាប់នៃបទដែលដាក់ទុកឡើយ, ប៉ុន្តែ ប្រកបទុកក្នុងទីបំផុតជាមួយមូលទាំងឡាយ មានចក្ខុន្ទ្រិយជាដើម សូម្បីទាំងអស់ ។*

*លោកប្រកបឥត្ថិន្ទ្រិយជាមួយចក្ខុន្ទ្រិយ ។ បុរិសិន្ទ្រិយជាមួយចក្ខុន្ទ្រិយ ។ ជីវិតិន្ទ្រិយជាមួយចក្ខុន្ទ្រិយ ។ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ មិនមានក្នុងបដិសន្ធិ ព្រោះហេតុនោះ ទើបលោកមិនកាន់យក ។*

*សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ លោកកាន់យកហើយក្នុងបដិសន្ធិ ព្រោះកើតមានព្រមជាមួយការកើតឡើង, ឥន្ទ្រិយ ៥ យ៉ាង មានសទ្ធិន្ទ្រិយជាដើម ក៏ដូចគ្នាដែរ; ឥន្ទ្រិយជាលោកុត្តរ ៣ យ៉ាង លោកមិនកាន់យក ព្រោះមិនមានក្នុងបដិសន្ធិ; ពួកឥន្ទ្រិយណាលោកកាន់យកហើយ ដោយអំណាចនៃឥន្ទ្រិយទាំងនោះ, គប្បីជ្រាបការរាប់យមកៈក្នុងន័យដែលមាន*

ចក្ខុន្ទ្រិយជាមូល ក្នុងឥន្ទ្រិយយមកៈនេះ ដោយប្រការដូច្នេះ; ក៏ក្នុងទីនេះ គប្បីជ្រាបការរាប់យមកៈក្នុងន័យដែលមានចក្ខុន្ទ្រិយ ជាមូលក្នុងទីនេះ យ៉ាងណា, ក្នុងទីទាំងពួង ក៏យ៉ាងនោះដែរ, គប្បីជ្រាបការកំណត់ព្រះបាលី ក្នុងវារៈទាំងឡាយយ៉ាងនេះជាមុនថា ក៏យមកៈណា ដែលព្រះមានព្រះភាគ ទ្រង់មិនកាន់យកហើយ, គួររាប់យកយមកៈទាំងឡាយ ដោយអំណាចនៃ យមកៈទាំងនោះ,ម្យ៉ាងទៀត ពេលរាប់ មិនគប្បីរាប់ដោយអំណាចនៃ មោឃបុច្ឆាឡើយ ៕

---

## ពណ៌នាអំពីបវត្តិវារៈ

ក៏ក្នុងការវិនិច្ឆ័យខ្លឹមសារនេះ គប្បីជ្រាបន័យមុខនេះ ដូចតទៅ ៖

ពាក្យថា **"សចក្ខុកានំ ន ឥត្ថីនំ"** លោកពោលហើយដោយ អំណាចនៃសត្វទាំងឡាយដែលមានរូប មានព្រហ្មបរិសជ្ជាជាដើម និង ដោយអំណាចនៃបុរិសភេទ និងអ្នកមិនមានភេទទាំងនោះ ។ ពិតមែនហើយ ឥន្ទ្រិយ រមែងមិនកើតឡើងដល់ព្រហ្មទាំងនោះទេ ។

ពាក្យថា **"សចក្ខុកានំ ន បុរិសានំ"** លោកពោលហើយដោយ អំណាចនៃរូបព្រហ្មផង នៃស្ត្រីភេទ និងបុគ្គលមិនមានភេទផង; ព្រោះថា បុរិសិន្ទ្រិយរមែងមិនកើតដល់រូបព្រហ្ម ស្ត្រី និងអ្នកមិនមានភេទទាំងនោះ ។

ពាក្យថា **"អចក្ខុកានំ ឧប្បជ្ជន្តានំ តេសំ ជីវិតិន្ទ្រិយំ ឧប្បជ្ជតិ"** លោកពោលសំដៅយកសត្វទាំងឡាយ ក្នុងឯកវោការភព ចតុវោការភព និងក្នុងកាមធាតុ ។

ពាក្យថា **"សចក្ខុកានំ វិនា សោមនស្សេន"** លោកពោលហើយដោយអំណាចនៃបុគ្គលដែលបដិសន្ធិដោយមហាវិបាកបដិសន្ធិ ៤ ដែលកើតព្រមដោយឧបេក្ខា ។

ពាក្យថា **"សចក្ខុកានំ វិនា ឧបេក្ខាយ"** លោកពោលហើយដោយអំណាចនៃបុគ្គលដែលបដិសន្ធិដោយសោមនស្ស ។

ពាក្យថា **"ឧបេក្ខាយ អចក្ខុកានំ"** លោកពោលហើយដោយអំណាចនៃអហេតុកបដិសន្ធិ ។

ពាក្យថា **"អហេតុកានំ"** លោកពោលហើយ ព្រោះការមិនមាននៃឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម ជាមួយអហេតុកបដិសន្ធិដែរ ។

ពិតណាស់ ក្នុងអហេតុកបដិសន្ធិ រមែងមិនមានសទ្ធា សតិ និងបញ្ញាជាប្រាកដ, តែសមាធិ និងវិរិយៈ រមែងមិនដល់ភាពជាឥន្ទ្រិយឡើយ ។

ពាក្យថា **"សហេតុកានំ អចក្ខុកានំ"** លោកពោលហើយដោយអំណាចនៃគព្ភសេយ្យកសត្វ និងព្រហ្មមិនមានរូប; ក៏ពួកសហេតុកៈដទៃឈ្មោះថា **អចក្ខុកោ** = មិនមានចក្ខុ រមែងមិនមាន ។

ពាក្យថា **“សចក្ខុកានំ អហេតុកានំ”** លោកពោលសំដៅយកសត្វក្នុងអបាយដោយអំណាចនៃទិបបាតិកៈ ។

ពាក្យថា **“សចក្ខុកានំ ញាណវិប្បយុត្តានំ”** លោកពោលទុកដោយអំណាចនៃសត្វដែលបដិសន្ធិដោយហេតុពីរក្នុងកាមធាតុ ។

ពាក្យថា **“សចក្ខុកានំ ញាណសម្បយុត្តានំ”** លោកពោលសំដៅយករូបព្រហ្មផង ទេវតា និងមនុស្សក្នុងកាមាវចរផង ។

ពាក្យថា **“ញាណសម្បយុត្តានំ អចក្ខុកានំ”** លោកពោលសំដៅយកអរូបព្រហ្ម និងតិហេតុកសត្វអ្នកកើតក្នុងគភ៌ ។

ក្នុងជីវិតិន្ទ្រិយមូល ពាក្យថា **“ទិនា សោមនស្សេន ឧប្បជ្ជន្តានំ”** លោកពោលសំដៅយកជីវិតិន្ទ្រិយ សូម្បីទាំងពីរយ៉ាង ។

ពាក្យថា **“បវត្តេ សោមនស្សវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ”** លោកពោលសំដៅយកអរូបជីវិតិន្ទ្រិយ ។

គប្បីជ្រាបការប្រកបជីវិតិន្ទ្រិយដោយអំណាចនៃបដិសន្ធិ និងបវត្តិ សូម្បីក្នុងទីទាំងពួង ដោយន័យនេះចុះ; សូម្បីក្នុងមូលទាំងឡាយ មានសោមនស្សិន្ទ្រិយជាមូលជាដើម គប្បីកាន់យកខ្លឹមសារដោយអំណាចនៃបដិសន្ធិ និងបវត្តិនុ៎ះដែរ ។ តែក្នុងបដិលោមន័យ ត្រង់និរោធវារៈ គប្បីជ្រាបការកើត និងការមិនកើត ការរលត់ និងការមិនរលត់ ក្នុងចុតិ បដិសន្ធិ

និងបវត្តិ សុម្បីទាំង ៣ កាល ដោយអំណាចនៃធម៌ទាំងនោះផង ពួកផ្សេង ផង តាមដែលមាន ។

ក្នុង *អនាគតវារៈ* ពាក្យថា **"ឯតេនេវ[*] ភាវេន"** ដូច្នេះ អធិប្បាយថា ដោយការកាន់យកបុរិសបដិសន្ធិនោះឯង, ព្រោះមិនដល់ ឈ្មោះជាឥត្ថីភាវៈ ក៏មាន ក្នុងលំដាប់ត្រឹមតែបុរិសភាវៈនោះឯង ។

ពាក្យវិសជ្ជនាថា **"កតិចិ ភវេ ឋស្សេត្វា បរិនិព្វាយិស្សន្តិ"** អធិប្បាយថា បុរសណាកាន់យកហើយនូវបដិសន្ធិក្នុងភពឯណាៗ ដែល មិនដល់ហើយនូវឥត្ថីភាវៈ នឹងបរិនិព្វានដូចគ្នា (សំដៅសេចក្តីថា កើតក្នុង ភពណា ដោយភេទណា នឹងបរិនិព្វានដោយភេទនោះ ក្នុងភពនោះ) ។

សូម្បីក្នុងបញ្ហាទីពីរ ក៏មានន័យដូចគ្នានេះដែរ; ក៏បទថា ***"មនិន្ទ្រិយ ដែលមិនធ្លាប់កើតក្នុងភង្គខណៈនៃឧបបត្តិចិត្តរបស់សុទ្ធាវាសព្រហ្ម"*** ដូច្នេះ ក្នុងអតីតវារៈ ដោយបច្ចុប្បន្ន (បច្ចុប្បន្នាតីតវារៈ) អធិប្បាយថា បណ្ឌិត មិនកាន់យកខ្លឹមសារ ដោយអំណាចនៃការឈានកន្លងឧប្បាទក្ខណៈដូចក្នុង ចិត្តយមកៈទេ, ប៉ុន្តែ គួរកាន់យកដោយអំណាចនៃការមិនធ្លាប់កើតឡើង ក្នុងភពនោះ; គប្បីជ្រាបការវិនិច្ឆ័យខ្លឹមសារក្នុងបវត្តិវារៈ សូម្បីទាំងអស់

---

[*] បាលីប្រើជា **ឯតេនេវ**, អដ្ឋកថាប្រើជា **ឯកេនេវ** ។

ដោយនយមុខនេះ ។

---

## ពណ៌នាអំពីបរិញ្ញាវារៈ

ក៏ក្នុង ***បរិញ្ញាវារៈ*** លោកសម្ដែងចក្ខុសោតយមកៈតែម្យ៉ាងប៉ុណ្ណោះ ក្នុងមូលទាំងឡាយ មានចក្ខុមូលជាដើម; ក៏ព្រោះលោកសម្ដែងឥន្ទ្រិយទាំងឡាយ ដែលបុគ្គលមិនគួរកំណត់ដឹង ដែលជាលោកិយអព្យាក្រឹតផង ដែលលាយឡំដោយលោកិយអព្យាក្រឹតផង សូម្បីដែលនៅសល់, ព្រោះហេតុនោះ ទើបលោកសម្ដែងឥន្ទ្រិយដែលលោកមិនបានសម្ដែងទាំងនោះ ដោយន័យនេះដូចគ្នាដែរ; ក៏ព្រោះអកុសលជាធម៌ដែលបុគ្គលគប្បីលះដោយចំណែកមួយ, កុសលគប្បីចម្រើនដោយចំណែកមួយ, លោកុត្តរជាអព្យាក្រឹត គឺបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់, ព្រោះហេតុនោះ ទើបលោកពោលថា ***“តែងតែលះទោមនស្សិន្ទ្រិយ ចម្រើនអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ធ្វើឱ្យជាក់ច្បាស់នូវអញ្ញាតាវិន្ទ្រិយ”*** ; ក៏អញ្ញិន្ទ្រិយ បុគ្គលគួរចម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ ក៏មាន, អញ្ញិន្ទ្រិយនោះ លោកកាន់យកដោយអំណាចនៃភាវនា (ការធ្វើឲ្យច្រើន) ប៉ុណ្ណោះ ។

ក្នុងពាក្យទាំងអស់នោះ ពាក្យថា **"ទ្វេ បុគ្គលា"** បានដល់ អ្នកព្រមព្រៀងដោយសកទាគាមី និងអរហត្តមគ្គ; ក្នុងបុគ្គលទាំងពីរនោះ ម្នាក់ទៀតឈ្មោះថា រមែងមិនលះទោមនស្សិន្ទ្រិយ ព្រោះមិនអាចកាត់ផ្តាច់បាន, ម្នាក់ទៀត ឈ្មោះថា រមែងមិនលះទោមនស្ស ព្រោះលោកលះទោមនស្សិន្ទ្រិយហើយ ។

បទថា **"ចក្ខុន្ទ្រិយំ ន បរិជានាតិ"** បានដល់ រមែងមិនដឹងសព្វ ព្រោះភាវៈនៃលោកមិនអាចញុំាងមគ្គដែលនៅមិនកើត ឲ្យកើតឡើងបាន ។ បណ្ឌិតគប្បីជ្រាបខ្លឹមសារក្នុងពាក្យវិសជ្ជនាទាំងពួង ដោយន័យនេះចុះ ៕

ចប់ឥន្ទ្រិយយមកៈ

## និគមគាថា *

***ដោយពាក្យមានប្រមាណប៉ុណ្ណេះ៖***

*ក៏បុរសស្ត្រីឯណា ដល់ព្រមដោយកិច្ច ស្ថិតនៅក្នុងឱវាទរបស់ព្រះសាស្តាសម្មាសម្ពុទ្ធអង្គណា បានធ្វើកិច្ចស្រេចហើយ, បុរសស្ត្រីនោះ កំណត់តាំងមាំក្នុងឱវាទរបស់ព្រះមហាមុនីទុកល្អហើយ រមែងជាអ្នកឈានកន្លង*

---

* ច្បាប់ខ្លះប្រើជា និគមនកថា ។

*អំណាចរបស់ស្ដេចយមរាជបាន ។*

*ព្រះសម្មាសម្ពុទ្ធជាទេព ខ្ពស់ជាងទេពទាំងពួង ទ្រង់មិនមានមន្ទិល ដែលនាំទៅកាន់អំណាចរបស់ស្ដេចយមរាជ ស្ដេចប្រថាប់នៅត្រង់កណ្ដាលទេវបរិស័ទដ៏ធំ ក្នុងទេវបុរី ទ្រង់ប្រកាសបករណ៍ឈ្មោះថា* **យមកៈ** *យ៉ាងណា ។*

*ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ប្រារព្ធអដ្ឋកថានៃបករណ៍យមកៈនោះ ដើម្បីសម្ដែងវិធីកំណត់ព្រះបាលី និងន័យរបស់អត្ថក្នុងពាក្យបុច្ឆា និងវិសជ្ជនា ។*

*ឥឡូវនេះ អដ្ឋកថានៃបករណ៍នេះឯង ដល់នូវការសម្រេចហើយ ដោយបែបផែនមានប្រមាណ ៥ ភាណវារៈ ដោយប្រាសចាកអន្តរាយជាច្រើនក្នុងលោកនេះ យ៉ាងណា ។*

*សូមសព្វសត្វទាំងឡាយ ចូរជាអ្នកមានការសម្រេចក្នុងហិតានុហិត-ប្រយោជន៍ ព្រមទាំងសេចក្ដីសុខ និងសូមឱ្យមនោរថទាំងអស់ របស់សព្វសត្វទាំងឡាយ ដល់នូវការសម្រេចយ៉ាងនោះចុះ ។*

**ចប់អដ្ឋកថាយមកៈ**

# បរមត្ថទីបនី

# មហាបដ្ឋានប្បករណ៍

## អារម្ភកថា

ទេវាតិទេវោ ទេវានំ ទេវទានវបូជិតោ
ទេសយិត្វា បករណំ យមកំ សុទ្ធសំយមោ ។
អត្ថតោ ធម្មតោ ចេវ គម្ភីរស្សាថ តស្ស យំ
អនន្តរំ មហាវីរោ សត្តមំ ឥសិសត្តមោ ។
បដ្ឋានំ នាម នាមេន នាមរូបនិរោធនោ
ទេសេសិ អតិគម្ភីរំ [*] នយមណ្ឌិតទេសនំ ។
ឥទានិ តស្ស សម្បត្តោ យស្មា សំវណ្ណនាក្កមោ
តស្មា តំ វណ្ណយិស្សាមិ តំ សុណាថ សមាហិតាតិ ។

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាទេព ក្រៃលែងជាងទេពនៃទេពទាំងឡាយ ជាអ្នកដែលទេវតា និងទានព (អសុរធម្មតា) ថ្វាយការបូជាហើយ; ទ្រង់មានព្រះសំវរៈដ៏បរិសុទ្ធ ទ្រង់មានព្រះវីរិយភាពដ៏ធំ ជាព្រះសម្មាសម្ពុទ្ធ ទ្រង់ស្វែងរកសម្មាសម្ពោធិញ្ញាណ ជាអង្គទី ៧* [*] ។

---

[*] ច្បាប់ខ្លះជា អតិគម្ភីរ ។

[*] ព្រះពុទ្ធអង្គនេះ រាប់ជាព្រះពុទ្ធអង្គទី ៧ តាំងអំពីព្រះពុទ្ធវិបស្សីជាដើមមក ( ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកក្កុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ និងព្រះគោតម) អដ្ឋកថាប្រើពាក្យថា “**ឥសិសត្តមោ** = ព្រះឥសីអង្គទី ៧” ។

*ទ្រង់រម្ងាប់ វិលត់នាម និងរូបបានហើយ; គ្រាទ្រង់សម្ដែងយមក-ប្បករណ៍ចប់ហើយ ទើបទ្រង់សម្ដែងបករណ៍ទី ៧ ដែលជាលំដាប់តអំពីយមកប្បករណ៍នោះ ទាំងដោយអត្ថ ទាំងដោយធម៌ ឱ្យឈ្មោះថា "បដ្ឋាន" ជាទេសនាដែលប្រដាប់ដោយន័យដ៏សែនជ្រាលជ្រៅក្រៃលែង ។*

*ឥឡូវនេះ ដល់លំដាប់នៃការពណ៌នាបដ្ឋានប្បករណ៍នោះហើយ, ព្រោះហេតុដូច្នោះ ខ្ញុំ(ព្រះពុទ្ធឃោសាចារ្យ) នឹងពណ៌នាបដ្ឋានប្បករណ៍នុ៎ះ សូមសាធុជនទាំងឡាយ តាំងចិត្តស្ដាប់ការពណ៌នានុ៎ះចុះ ។ល។*

## ពណ៌នាអំពីឧទ្ទេសវារៈ *

*សេចក្ដីតំណាលថា ក្នុង **អនុលោមប្បដ្ឋាន** ព្រះសម្មាសម្ពុទ្ធទ្រង់អាស្រ័យតិកៈ ២២ សម្ដែងឈ្មោះ **តិកប្បដ្ឋាន** ។ ទ្រង់អាស្រ័យទុកៈ ១០០ សម្ដែងឈ្មោះ **ទុកប្បដ្ឋាន** ។ តអំពីនោះ ទ្រង់រួមតិកៈ ២២ ចូលក្នុងទុកៈ ១០០ ហើយទ្រង់សម្ដែងឈ្មោះ **ទុកត្តិកប្បដ្ឋាន** ។ បន្ទាប់មក ទ្រង់រួមទុកៈ ១០០ ចូលក្នុងតិកៈ ២២ ទៀត ហើយទ្រង់សម្ដែងឈ្មោះ **តិកទុកប្បដ្ឋាន** ។ ម្យ៉ាងទៀត ទ្រង់បន្ថែម តិកៈចូលក្នុងតិកៈប៉ុណ្ណោះ*

* អធិប្បាយមាតិកា ។

ហើយទ្រង់សម្ដែងឈ្មោះ ***តិកត្តិកប្បដ្ឋាន*** ។ ទ្រង់បន្ថែមទុកៈចូលក្នុងទុកៈប៉ុណ្ណោះ ហើយទ្រង់សម្ដែងឈ្មោះ ***ទុកទុកប្បដ្ឋាន*** ។ ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

**“តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**
**ទុកំ តិកញ្ចេវ តិកំ ទុកញ្ច**
**តិកំ តិកញ្ចេវ ទុកំ ទុកញ្ច**
**ឆ អនុលោមម្ហិ នយា សុគម្ភីរា ។**

ក្នុង ***អនុលោមប្បដ្ឋាន*** មាននយ័ដ៏ជ្រាលជ្រៅក្រៃលែង ៦ ន័យ គឺតិកប្បដ្ឋានដ៏ប្រសើរ ទុកប្បដ្ឋានដ៏ឧត្ដម ទុកត្តិកប្បដ្ឋាន តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាន និងទុកទុកប្បដ្ឋាន” ។

សូម្បីក្នុង ***បច្ចនីយប្បដ្ឋាន*** ក៏ទ្រង់សម្ដែងបដ្ឋានដោយន័យ ៦ សូម្បីក្នុងបច្ចនីយយ៉ាងនេះ គឺទ្រង់អាស្រ័យតិកៈ ២២ សម្ដែងឈ្មោះ តិកប្បដ្ឋាន, ទ្រង់អាស្រ័យទុកៈ ១០០ សម្ដែងឈ្មោះទុកប្បដ្ឋាន, ទ្រង់បន្ថែមតិកៈ ២២ ចូលក្នុងទុកៈ ១០០ ហើយទ្រង់សម្ដែងឈ្មោះ ទុកត្តិកប្បដ្ឋាន, ទ្រង់បន្ថែមទុកៈ ១០០ ចូលក្នុងតិកៈ ២២ ហើយទ្រង់សម្ដែងឈ្មោះតិកទុកប្បដ្ឋាន, ទ្រង់បន្ថែមតិកៈចូលក្នុងតិកៈប៉ុណ្ណោះ ហើយទ្រង់សម្ដែងឈ្មោះតិកត្តិក-

បដ្ឋាន, ទ្រង់បន្ថែមទុកៈចូលក្នុងទុកៈប៉ុណ្ណោះ ហើយទ្រង់សម្ដែងឈ្មោះ ទុកទុកបដ្ឋាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា ៖

**“តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**

**ទុកំ តិកញ្ចេវ តិកំ ទុកញ្ច**

**តិកំ តិកញ្ចេវ ទុកំ ទុកញ្ច**

**ឆ បច្ចនីយម្ហិ នយា សុគម្ភីរា ។**

ក្នុង ***បច្ចនីយបដ្ឋាន*** មានន័យដ៏ជ្រាលជ្រៅក្រៃលែង ៦ ន័យ គឺតិកបដ្ឋានដ៏ប្រសើរ ទុកបដ្ឋានដ៏ឧត្តម ទុកត្តិកបដ្ឋាន តិកទុកបដ្ឋាន តិកត្តិកបដ្ឋាន និងទុកទុកបដ្ឋាន” ។ សូម្បីក្នុង ***អនុលោមបច្ចនីយបដ្ឋាន*** តអំពីនោះទៅ ក៏ទ្រង់សម្ដែងន័យ ៦ ដោយឧបាយនេះដូចគ្នាដែរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

**“តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**

**ទុកំ តិកញ្ចេវ តិកំ ទុកញ្ច**

**តិកំ តិកញ្ចេវ ទុកំ ទុកញ្ច**

**ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា ។**

ក្នុង ***អនុលោមបច្ចនីយបដ្ឋាន*** មានន័យដ៏ជ្រាលជ្រៅក្រៃលែង ៦

ន័យ គឺតិកប្បដ្ឋានដ៏ប្រសើរ ទុកប្បដ្ឋានដ៏ឧត្ដម ទុកត្តិកប្បដ្ឋាន តិកទុក-ប្បដ្ឋាន តិកត្តិកប្បដ្ឋាន និងទុកទុកប្បដ្ឋាន" ។

តអំពីនោះ ក្នុង ***បច្ចនីយានុលោមប្បដ្ឋាន*** ក៏ទ្រង់សម្ដែងន័យ ៦ ទាំងនេះដូចគ្នាដែរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

**"តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**
**ទុកំ តិកញ្ចេវ តិកំ ទុកញ្ច**
**តិកំ តិកញ្ចេវ ទុកំ ទុកញ្ច**
**ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភីរា ។**

ក្នុង ***បច្ចនីយានុលោមប្បដ្ឋាន*** មានន័យដ៏ជ្រាលជ្រៅក្រៃលែង ៦ ន័យ គឺតិកប្បដ្ឋានដ៏ប្រសើរ ទុកប្បដ្ឋានដ៏ឧត្ដម ទុកត្តិកប្បដ្ឋាន តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាន និងទុកទុកប្បដ្ឋាន" ។

ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា "បដ្ឋាន គឺ ក្នុងអនុលោមន័យ មានបដ្ឋាន ៦, ក្នុងបច្ចនីយន័យ មានបដ្ឋាន ៦, ក្នុង អនុលោមបច្ចនីយន័យ មានបដ្ឋាន ៦, ក្នុងបច្ចនីយានុលោមន័យ មាន បដ្ឋាន ៦ ដូចពោលមកហើយ ឈ្មោះថា ***បដ្ឋានមហាបករណ៍*** ដែលជាទី

ប្រជុំនៃសមន្តប្បដ្ឋាន ២៤” ។ ក្នុងបដ្ឋាននោះ ព្រះមានព្រះភាគត្រាស់ថា “បករណ៍ជាទីរួមនៃសមន្តប្បដ្ឋាន ២៤ នេះ ឈ្មោះថា បដ្ឋានមហាបករណ៍ ដោយអំណាចនៃការប្រជុំរួមនៃសមន្តប្បដ្ឋាន ២៤ ពួកណា” ដូច្នេះ, អ្នកសិក្សា គប្បីជ្រាបអត្ថនៃឈ្មោះរបស់បដ្ឋានទាំងនោះ និងបករណ៍នេះ យ៉ាងនេះ ជាមុនសិនចុះ ។

***សួរថា*** ឈ្មោះថា ***បដ្ឋាន*** ព្រោះអត្ថថា ដូចម្តេច ?

ឆ្លើយថា ព្រោះអត្ថថា ជាបច្ច័យមានប្រការផ្សេងៗ (នានប្បការ-បច្ចយដ្ឋេន) ។ ពិតមែនហើយ អក្សរ ***ប*** រមែងសម្តែងអត្ថថា មានប្រការផ្សេងៗ ។

***ឋាន***សព្ទ រមែងសម្តែងអត្ថថា ជាបច្ច័យ ។

មែនពិត បច្ច័យ លោកហៅថា ឋាន ក្នុងពាក្យទាំងឡាយ មានជាដើមថា “ភាពជាអ្នកឈ្លាសក្នុងឋាន និងមិនមែនឋាន” ។ បណ្តាបដ្ឋានទាំង ២៤ នេះ (បច្ច័យ) តែម្យ៉ាងៗ ក៏ឈ្មោះថា ***បដ្ឋាន*** ដែរ ព្រោះព្រះមានព្រះភាគទ្រង់សម្តែងទុកដោយអំណាចនៃបច្ច័យ មានប្រការផ្សេងៗ ដោយប្រការដូច្នេះ ។ បករណ៍ទាំងអស់នោះ អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា ***បដ្ឋាន*** ព្រោះជាទីរួមនៃបដ្ឋានទាំងនេះ ។

ម្យ៉ាងទៀត ***សួរថា*** ឈ្មោះថា ***បដ្ឋាន*** ព្រោះអត្ថថា ដូចម្តេច ?

*ឆ្លើយថា ព្រោះអត្ថថា ចែក (វិភជ្ជនដ្ឋេន) ។*

*ពិតណាស់ បដ្ឋាន ប្រាកដដោយអត្ថថា ចែក ក្នុងទីដែលមានមកថា “ការបញ្ញត្ត ការតែងតាំង ការបើកបង្ហាញ ការចែក ការធ្វើឲ្យច្បាស់”* [១២] *។ បណ្ដាបដ្ឋានទាំង ២៤ នេះ (បច្ច័យ) តែម្យ៉ាងៗ ក៏ឈ្មោះថា* ***បដ្ឋាន*** *ដែរ ព្រោះព្រះមានព្រះភាគទ្រង់ចែកធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើម ដោយប្រការដូច្នេះ, បករណ៍ទាំងអស់នេះ អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា* ***បដ្ឋាន*** *ព្រោះជាទីប្រជុំនៃបដ្ឋានទាំងនេះ ។*

*ម្យ៉ាងវិញទៀត* ***សួរថា*** *ឈ្មោះថា* ***បដ្ឋាន*** *ព្រោះអត្ថថា ដូចម្ដេច ?*

*ឆ្លើយថា ព្រោះអត្ថថា តាំងនៅទូទៅ (ផ្សាយទៅ) (បដ្ឋិតដ្ឋេន) អធិប្បាយថា ដោយអត្ថថា ដើរទៅ ។ ពិតមែនហើយ ក្នុងអាគតស្ថានថា* **“គោដ្ឋា បដ្ឋិតគាវោ** *= គោដើរទៅអំពីទីនៅរបស់គោ”* [១៣] *។ សព្ទថា* **បដ្ឋិតគាវោ** *= គោដើរទៅ លោកអាចារ្យពោលដោយបដ្ឋានណា, បដ្ឋាននោះ ដោយអត្ថ បានដល់ ការដើរទៅ ។ បណ្ដាបដ្ឋានទាំង ២៤ នេះ (បច្ច័យ) តែម្យ៉ាងៗ ក៏ឈ្មោះថា* ***បដ្ឋាន*** *ដែរ ព្រោះមានការដើរ*

---

[១២] ម. ឧ. ។

[១៣] ម. មូ. ។

*ដែលប្រព្រឹត្តទៅដោយអំណាចនៃការទាក់ទងគ្នា ព្រោះបានន័យដែលមានសេចក្ដីពិស្ដារក្នុងធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដែលចែកចេញជាប្រភេទ មានហេតុប្បច្ច័យជាដើម នៃព្រះសព្វញ្ញុតញ្ញាណ ដែលមានការដើរទៅមិនជាប់គ្នាក្នុងបករណ៍ទាំងឡាយ មានធម្មសង្គណីបករណ៍ជាដើម ដែលមានន័យមិនពិស្ដារពេក ដូចពណ៌នាមកដូច្នេះ ។*

*បករណ៍ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា* ***បដ្ឋាន*** *ព្រោះជាទីប្រជុំនៃបដ្ឋានទាំងនេះ ។*

*ក្នុងបដ្ឋានទាំង ៦ នេះ នឹងសម្ដែងបដ្ឋានទីមួយ ក្នុងអនុលោមប្បដ្ឋានជាមុនសិន ៖*

*ឈ្មោះថា តិកប្បដ្ឋាន ព្រោះព្រះមានភាគទ្រង់សម្ដែងដោយអំណាចនៃតិកមាតិកា ។ គប្បីជ្រាបការចែកបទតិកប្បដ្ឋាននោះ (វិគ្រោះ) ដូច្នេះ បដ្ឋាននៃតិកៈទាំងឡាយ មាននៅក្នុងបករណ៍នេះ ព្រោះហេតុនោះ បករណ៍នេះ ឈ្មោះថា តិកប្បដ្ឋាន ។ អធិប្បាយថា បច្ច័យមានប្រការផ្សេងៗនៃតិកៈទាំងឡាយ មានដល់ទេសនានេះ ព្រោះហេតុនោះ ទេសនានេះ ឈ្មោះថា តិកប្បដ្ឋាន ។ ក្នុងវិកប្បទីពីរ សេចក្ដីថា បដ្ឋាននៃតិកៈទាំងឡាយនោះឯង ឈ្មោះថា តិកប្បដ្ឋាន, អធិប្បាយថា ការចែកតិកៈទាំងឡាយដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើម ។ ក្នុងវិកប្បទីបី សេចក្ដីថា*

បដ្ឋាន គឺតិកៈទាំងឡាយ ដែលបានសេចក្ដីពិស្ដារ ព្រោះចែកចេញទៅដោយប្រភេទនៃហេតុប្បច្ច័យជាដើម ឈ្មោះថា តិកប្បដ្ឋាន, អធិប្បាយថាភូមិជាទីដើរទៅដោយការទាក់ទងគ្នានៃព្រះសព្វញ្ញុតញ្ញាណ ។ សូម្បីក្នុងទុកប្បដ្ឋានជាដើម ក៏មានន័យដូចគ្នានេះដែរ ។ អ្នកសិក្សា កាលបើជ្រាបនូវបដ្ឋានទាំង ៦ ក្នុងអនុលោមយ៉ាងនេះហើយ គួរជ្រាបសូម្បីនៅក្នុងបច្ចនីយៈជាដើម ដោយឧបាយនេះចុះ ។ ក៏ព្រោះតែបដ្ឋានទាំងនេះដោយគ្រប់ចំនួន គឺក្នុងអនុលោម, ក្នុងបច្ចនីយៈ, ក្នុងអនុលោមបច្ចនីយៈនិងក្នុងបច្ចនីយានុលោម ន័យនីមួយៗ មាន ៦ ទើបរួមជា ២៤, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា ***“សមន្តប្បដ្ឋាន ២៤”*** ។

បករណ៍ជាទីរួមនៃសមន្តប្បដ្ឋាន ២៤ នោះ ឈ្មោះថា ***បដ្ឋាន-មហាបករណ៍*** ដោយអំណាចជាទីប្រជុំនៃសមន្តប្បដ្ឋាន ពោលគឺទុកប្បដ្ឋានទាំង ២៤ នេះ មានប្រការដូច្នេះ ។

បដ្ឋាននេះ ព្រះមានព្រះភាគត្រាស់ហៅថា “តិកប្បដ្ឋាន ។ល។ តិកត្តិកប្បដ្ឋាន ទុកទុកប្បដ្ឋាន” ព្រោះព្រះអង្គទ្រង់សម្ដែងដោយអាស្រ័យតិកៈជាដើមណា, ដើម្បីនឹងសម្ដែងបច្ច័យដែលជាហេតុឲ្យព្រះអង្គទ្រង់ចែកតិកៈជាដើមនោះ ដោយមិនឲ្យជាប់ទាក់ទិនជាមួយនឹងតិកៈជាដើមនោះ ទើបត្រាស់សម្ដែងវារៈ ឈ្មោះថា ***មាតិកានិក្ខេបវារៈ*** នៃបដ្ឋាននោះជាមុន តាំងអំពីខាងដើម ៕

## ពណ៌នាអំពីបច្ចយវិភង្គវារៈ

*ពាក្យថា **បច្ចយវិភង្គវារៈ** ជាឈ្មោះនៃមាតិកានិក្ខេបវារៈនោះឯង ។ បច្ចយវិភង្គវារៈនោះ មាន ២ គឺដោយឧទ្ទេស និងនិទ្ទេស ។ វារៈនេះ គឺ* **ហេតុប្បច្ចយោ ។ ល ។ អវិគតប្បច្ចយោ** *ជាឧទ្ទេសនៃបច្ចយវិភង្គវារៈ ៕*

---

## ១.ពាក្យថា ហេតុប្បច្ច័យ

*គួរជ្រាបការវិនិច្ឆ័យ ក្នុងបច្ច័យទាំងនោះ ដូចតទៅនេះ ៖*

***ហេតុនោះផង ជាបច្ច័យផង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា*** **ហេតុប្បច្ច័យ** *។ អធិប្បាយថា ជាបច្ច័យ ព្រោះជាហេតុ, ព្រះមានព្រះភាគទ្រង់ត្រាស់ថា “ជាបច្ច័យ ព្រោះសេចក្តីជាហេតុ” ដូច្នេះ ។ ក្នុងអារម្មណប្បច្ច័យជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងបណ្តាបច្ច័យទាំងនោះ ពាក្យថា “**ហេតុ**” នេះ ជាឈ្មោះនៃការណៈ និងឫសគល់ដែលជាចំណែកប្រកបនៃពាក្យសម្តី ។ ពិតមែនហើយ ចំណែកប្រកបនៃពាក្យសម្តីរបស់ពពួកជនក្នុងលោកគេហៅថា **ហេតុ** ក្នុងពាក្យទាំងឡាយ មានជាដើមថា “បដិញ្ញា ជាហេតុ” ។ ចំណែកក្នុងសាសនា (ពាក្យប្រៀនប្រដៅ) **ការណៈ** ហៅថា **ហេតុ** ក្នុងពាក្យទាំងឡាយថា “ធម៌ទាំងឡាយ*

មានហេតុជាដែនកើត" ជាដើម [១៤] ។ ***ឫសគល់*** ហៅថា ***ហេតុ*** ក្នុងពាក្យជាដើមថា "កុសលហេតុ មាន ៣, អកុសលហេតុ មាន ៣" [១៥], ក្នុងហេតុប្បច្ច័យនេះ សំដៅយកហេតុដែលជាឫសគល់នោះ ។

ក្នុងពាក្យថា "**បច្ចយោ**" នេះ មានអត្ថនៃពាក្យ (វិចនត្ថៈ) ដូច្នេះ ៖

ផលរមែងប្រព្រឹត្តទៅអាស្រ័យធម៌នេះ, ព្រោះហេតុដូច្នោះ ធម៌នេះឈ្មោះថា ***បច្ច័យ***, អធិប្បាយថា ប្រព្រឹត្តទៅដោយមិនបដិសេធធម៌នោះ * ។ ពិតមែនហើយ ធម៌ណាតាំងនៅ ឬកើតឡើង ព្រោះមិនបដិសេធនូវធម៌ណា, ធម៌នោះ លោកពោលថា ជាបច្ច័យដល់ធម៌នោះ ។ ប៉ុន្តែ ដោយលក្ខណៈធម៌ដែលជួយឧបការៈ ឈ្មោះថា បច្ច័យ ។ ព្រោះថា ធម៌ណាជួយឧបការៈដល់ការតាំងនៅ ឬការកើតឡើងនៃធម៌ណា, ធម៌នោះ លោកហៅថា ជាបច្ច័យដល់ធម៌នោះ ។ មានពាក្យជាដើមថា ***បច្ច័យ ហេតុ ការណៈ និទាន សម្ភវៈ បភវៈ***, បើពោលដោយសេចក្តី គឺដូចគ្នា, ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។

***ក៏ពោលដោយសង្ខេប ឈ្មោះថា ហេតុ ព្រោះអត្ថថា ជាឫសគល់***

---

[១៤] វិនយ. មហាវគ្គ/៦ ។

[១៥] អភិ. ។

* **បដិច្ច ឯតស្មា ឯតេតីតិ បច្ចយោ, អប្បច្ចក្ខាយ នំ វត្តតិ ។**

*(មូលផ្អែន), ឈ្មោះថា បច្ច័យ ព្រោះអត្ថថា ជួយឧបការៈ (ឧបការផ្អែន) ព្រោះហេតុដូច្នោះ ធម៌ដែលជួយឧបការៈ ព្រោះអត្ថថា ជាឫសគល់ ទើបឈ្មោះថា ហេតុប្បច្ច័យ ។*

ពិតមែនហើយ មានសេចក្តីអធិប្បាយនៃអាចារ្យទាំងឡាយថា ហេតុនោះ ក៏បានដល់ធម៌ដែលគាត់តែងកុសលជាដើម ឲ្យសម្រេចភាវៈជាកុសលជាដើម ប្រៀបដូចគ្រាប់ស្រូវសាលីជាដើម ឲ្យសម្រេចជាស្រូវសាលីជាដើម និងពណ៌នៃកែវមណីជាដើម ឲ្យសម្រេចជាពន្លឺនៃកែវមណីជាដើមដូច្នោះ, អធិប្បាយថា កាលបើដូច្នេះ ភាពជាហេតុប្បច្ច័យ រមែងមិនសម្រេចក្នុងរូបដែលមានហេតុនោះ ជាសមុដ្ឋានឡើយ ។ ព្រោះថាហេតុនោះ មិនបានឲ្យរូបទាំងនោះ សម្រេចភាវៈជាកុសលជាដើមទេ, ប៉ុន្តែឈ្មោះថា មិនជាបច្ច័យ មិនបានឡើយ ។

ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ទុកថា “ហេតុជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងដល់រូបដែលមានហេតុនោះ ជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ” ។ ***ម្យ៉ាងទៀត វៀរចាកហេតុនោះ អហេតុកចិត្ត ក៏សម្រេចជាអព្យាកតធម៌បាន និងសូម្បីសហេតុកចិត្ត ក៏សម្រេចភាវៈជាកុសលជាដើមបាន ដោយអាស្រ័យយោនិសោមនសិការជាដើម***, ហេតុដែលសម្បយុត្ត មិនទាក់ទិនដងទេ ។ ប្រសិនបើ បណ្តា

ហេតុដែលសម្បយុត្ត គប្បីជាកុសលជាដើមបាន តាមសភាពខ្លួនឯង, បណ្ដាធម៌ដែលសម្បយុត្តដោយហេតុនោះ ក៏ត្រូវទាក់ទិនគ្នាដោយហេតុ, អលោភៈ គួរជាកុសល ឬអព្យាក្រឹត ក៏បាន ។ ប៉ុន្តែ ព្រោះតែបានដោយប្រការទាំងពីរ, ព្រោះហេតុដូច្នោះ អលោភៈ គប្បីជាកុសល ឬអព្យាក្រឹតក្នុងធម៌ទាំងឡាយ តាមដែលប្រកប ។ ដោយប្រការដូចបានពោលមកហើយនេះ ចាំបាច់ត្រូវមើលភាវៈជាកុសលជាដើម សូម្បីក្នុងហេតុទាំងឡាយទៀត ***កាលបើមិនកាន់យកអត្ថ គឺឫសគល់នៃហេតុ ទាក់ទិនជាមួយនឹងការឱ្យធម៌ទាំងឡាយ សម្រេចភាពជាកុសលជាដើម កាន់យកដោយអំណាចនៃការឱ្យសម្បយុត្តធម៌ សម្រេចនូវការតាំងមាំដោយល្អ រមែងមិនខុសអ្វីឡើយ*** ។ ពិតមែនហើយ ធម៌ទាំងឡាយដែលបានហេតុប្បច្ច័យហើយ រមែងតាំងមាំដោយល្អ ប្រៀបដូចដើមឈើដែលមានឫសដុះចេញហើយ ។ ចំណែកធម៌ដែលមិនមានហេតុ រមែងមិនតាំងមាំដោយល្អឡើយ ប្រៀបដូចជាសារាយ ដែលជាពូជដុះនៅក្នុងទឹកជាដើម ។ ធម៌ដែលជួយឧបការៈដោយអត្ថថា ជាឫសគល់ គឺជាធម៌ដែលមានឧបការៈ ដោយឲ្យសម្រេចនូវការតាំងមាំដោយល្អ អ្នកសិក្សាគប្បីជ្រាបថា ***ជាហេតុប្បច្ច័យ*** ដោយប្រការដូច្នេះ ៕

## ២.ពាក្យថា អារម្មណប្បច្ច័យ

*គួរជ្រាបការអធិប្បាយក្នុងបច្ច័យដទៃៗទៀត តអំពីនោះ ធម៌ដែលជួយឧបការៈដោយសេចក្ដីជាអារម្មណ៍ ឈ្មោះថា* **អារម្មណប្បច្ច័យ** ។

អារម្មណប្បច្ច័យនោះ មាន ៦ យ៉ាង ដោយអំណាចនៃរូបារម្មណ៍ជាដើម ធម៌ណាមួយដែលមិនមែនជាអារម្មណ៍ មិនមានឡើយ, ព្រោះព្រះអង្គទ្រង់ផ្ដើមទុកថា ***"រូបាយតនៈជាបច្ច័យដល់ចក្ខុវិញ្ញាណធាតុ"*** ជាដើម ហើយបញ្ចប់ដោយពាក្យថា ***"ធម៌ទាំងឡាយណាៗ គឺចិត្ត និងចេតសិកប្រារព្ធ ធម៌ណាៗ កើតឡើង ធម៌នោះៗ ជាបច្ច័យដល់ធម៌នោះៗ ដោយអំណាចនៃអារម្មណប្បច្ច័យ"*** ។ ម្យ៉ាងទៀត ដូចបុរសទុព្វលចាប់តោងឈើច្រត់ ឬខ្សែ ហើយទើបក្រោកឈរឡើងបាន យ៉ាងណា, ធម៌ គឺចិត្តនិងចេតសិក ក៏ដូច្នោះដែរ ត្រូវប្រារព្ធអារម្មណ៍ មានរូបារម្មណ៍ជាដើម ទើបកើតឡើង និងតាំងនៅបាន; ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយ ដែលជាអារម្មណ៍របស់ចិត្ត និងចេតសិក សូម្បីទាំងអស់ គប្បីជ្រាបថា ជាអារម្មណប្បច្ច័យ ៕

..............................................

## ៣.ពាក្យថា អធិបតិប្បច្ច័យ

*ធម៌ជួយឧបការៈ ដោយអត្ថថា ជាធំ ឈ្មោះថា អធិបតិប្បច្ច័យ ។*

អធិបតិប្បច្ច័យនោះ មាន ២ យ៉ាង ***គឺសហជាតាធិបតិប្បច្ច័យ និង អារម្មណាធិបតិប្បច្ច័យ*** ។

ក្នុងពីរយ៉ាងនេះ ធម៌ ៤ យ៉ាង គឺឆន្ទៈ វិរិយៈ ចិត្តៈ និងវីមំសា អ្នកសិក្សាគប្បីជ្រាបថា ជាសហជាតាធិបតិប្បច្ច័យ ព្រោះព្រះបាលីថា ***"ឆន្ទាធិបតី ជាបច្ច័យដោយអំណាចនៃអធិបតិប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយឆន្ទៈ និងដល់រូបដែលមានឆន្ទៈនោះជាសមុដ្ឋាន ដោយអំណាចនៃអធិបតិប្បច្ច័យ"*** ជាដើម, ឯអធិបតិប្បច្ច័យនោះ រមែងមិនកើតឡើងក្នុងពេលជាមួយគ្នាឡើយ ។ ពិតមែនហើយ ក្នុងពេលណា ចិត្តធ្វើឆន្ទៈឲ្យជាធុរៈ គឺឲ្យជាប្រធានប្រព្រឹត្តទៅ, ក្នុងពេលនោះ ឆន្ទៈ ជាអធិបតី, ប៉ុន្តែ វិរិយៈ ចិត្តៈ និងវីមំសា ក្រៅអំពីនេះ មិនជាអធិបតីផងទេ, សូម្បីក្នុងអធិបតី ដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។

ចំណែកអរូបធម៌ទាំងឡាយ (គឺចិត្ត និងចេតសិក) ធ្វើធម៌ណាឲ្យធ្ងន់ រមែងប្រព្រឹត្តទៅ, ធម៌នោះ ឈ្មោះថា ជាអារម្មណាធិបតិប្បច្ច័យដល់អរូបធម៌ (គឺចិត្ត និងចេតសិក) ទាំងនោះ; ព្រោះហេតុនោះ ទើបព្រះមាន

ព្រះភាគត្រាស់ថា ***“ធម៌ណាៗ គឺចិត្ត និងចេតសិកធម៌ទាំងឡាយ ធ្វើធម៌ណាៗ ឱ្យធ្ងន់ កើតឡើង, ធម៌នោះៗ ជាបច្ច័យដល់ធម៌នោះៗ ដោយអំណាចនៃអធិបតិប្បច្ច័យ”*** ។

---

## ៤.ពាក្យថា អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ

***ធម៌ដែលជួយឧបការៈ ដោយមិនមានចន្លោះ ឈ្មោះថា អនន្តរប្បច្ច័យ*** ។

***ធម៌ដែលជួយឧបការៈ ដោយមិនមានចន្លោះដ៏ល្អ ឈ្មោះថា សមនន្តរប្បច្ច័យ*** ។ បច្ច័យទាំងពីរនេះ ដោយច្រើនអាចារ្យទាំងឡាយ អធិប្បាយចេញមិនបានរហ័សឡើយ ។

ចំណែកសារៈក្នុងបច្ច័យទាំងពីរ មានដូច្នេះ ៖ ពិតមែនហើយការកំណត់ចិត្តនេះបានថា “មនោធាតុ មានក្នុងលំដាប់នៃចក្ខុវិញ្ញាណ, មនោវិញ្ញាណធាតុ មានក្នុងលំដាប់នៃមនោធាតុ” ជាដើម ។ ការកំណត់នោះ រមែងសម្រេចបាន ដោយអំណាចនៃចិត្តដែលកើតឡើងមុនប៉ុណ្ណោះ មិនមែនដោយប្រការដទៃឡើយ; ព្រោះហេតុដូច្នោះ ធម៌ដែលអាចឲ្យចិត្តុប្បាទ ដ៏សមគួរដល់ខ្លួន កើតឡើងក្នុងលំដាប់របស់ខ្លួនៗ ឈ្មោះថា អនន្តរ-

*ប្បច្ច័យ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ក៏ឈ្មោះថា អនន្តរប្បច្ច័យ បានដល់ ចក្ខុវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ជាបច្ច័យដល់មនោធាតុ និងធម៌ដែលសម្បយុត្តដោយមនោធាតុនោះ ដោយអំណាចនៃអនន្តរប្បច្ច័យ" ជាដើម ។ ធម៌ណាជាអនន្តរប្បច្ច័យ, ធម៌នោះឯង ជាសមនន្តរប្បច្ច័យដែរ ។ ពិតណាស់ បច្ច័យពីរយ៉ាងនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ប្រៀបដូចឧបចយៈ និងសន្តតិ និងដូចពាក្យពីរម៉ាត់ថា* ***អធិវចនៈ*** *(ពាក្យហៅឈ្មោះ) និង* ***និរុត្តិ*** *(ភាសាពាក្យនិយាយ) ។ ប៉ុន្តែ កាលបើពោលដោយសេចក្តីហើយ មិនមានអ្វីប្លែកផ្សេងគ្នាឡើយ ។*

*ទោះបីការយល់ឃើញរបស់អាចារ្យទាំងឡាយដែលថា "ឈ្មោះថា* ***អនន្តរប្បច្ច័យ*** *ព្រោះមិនមានចន្លោះនៃកាលដ៏យូរ, ឈ្មោះថា* ***សមនន្តរប្បច្ច័យ*** *ព្រោះមិនមានចន្លោះនៃកាល (ធម្មតា)" ដូច្នេះ ក៏ដោយ, មតិនោះ ក៏រមែងខុសអំពីព្រះបាលីជាដើមថា "នេវសញ្ញានាសញ្ញាយតនកុសល ជាបច្ច័យដោយអំណាចនៃសមនន្តរប្បច្ច័យ ដល់ផលសមាបត្តិរបស់បុគ្គលអ្នកចេញពីនិរោធ" ។ សូម្បីពាក្យណា ដែលអាចារ្យទាំងឡាយពោលទុកក្នុងបច្ច័យទាំងពីរនោះថា "ភាពអង់អាចក្នុងការញុំាងធម៌ទាំង-*

ទ្បាយ ឲ្យកើតឡើង នៅមិនទាន់សាបសូន្យទេ, ប៉ុន្តែ ធម៌ទាំងឡាយនៅមិនទាន់កើតឡើង ក្នុងលំដាប់ដោយល្អ ព្រោះត្រូវកម្លាំងភាវនាហាមទុក" , សូម្បីពាក្យនោះ ក៏ឲ្យសម្រេចមិនបានដល់ការមិនមានចន្លោះនៃកាលនោះឯង ។ ពិតមែនហើយ ខ្ញុំសូមពោលទុកត្រឹមតែប៉ុណ្ណេះថា "ការមិនមានចន្លោះនៃកាល ក្នុងបច្ច័យទាំងពីរនោះ រមែងមិនមាន ព្រោះកម្លាំងនៃភាវនា" ; ព្រោះហេតុដូច្នោះ ភាវៈជាសមនន្តរប្បច្ច័យ ទើបមិនត្រូវ; ពិតមែនហើយ ធម៌ទាំងនោះ នឹងជាសមនន្តរប្បច្ច័យ ព្រោះមិនមានចន្លោះនៃកាលវេលា; ព្រោះហេតុដូច្នោះ អ្នកសិក្សាកុំប្រកាន់មាំពេក គួរជឿសេចក្ដីផ្សេងគ្នា ក្នុងបច្ច័យទាំងពីរនោះ ដោយព្យញ្ជនៈប៉ុណ្ណោះ, កុំប្រកាន់ជឿថា ផ្សេងគ្នាដោយសេចក្ដីឡើយ ។ គឺដូចម្ដេច ? គឺយ៉ាងនេះ ចន្លោះនៃធម៌ទាំងនោះ មិនមាន ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា ***អនន្តរៈ*** (មិនមានចន្លោះ) ។ សេចក្ដីមិនមានចន្លោះដោយល្អ ព្រោះមិនមានការតាំងនៅនៃធម៌ទាំងនោះ ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា ***សមនន្តរៈ*** (មិនមានចន្លោះដោយល្អ) ព្រោះមិនមានការតាំងនៅ ៕

..................................................

## ៦.ពាក្យថា សហជាតបច្ច័យ

*ធម៌ដែលកើតឡើងជួយជាឧបការៈ ដោយអំណាចនៃការញុំាងធម៌ដទៃឱ្យកើតឡើងព្រមគ្នា ដូចជាដួងប្រទីប ជាឧបការៈដល់ពន្លឺ ឈ្មោះថា* **សហជាតបច្ច័យ** ។

*សហជាតបច្ច័យនេះ មាន ៦ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម ។ សមពិតដូចព្រះមានព្រះភាគត្រាស់ទុកថា "អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសហជាតបច្ច័យ, មហាភូតរូប ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសហជាតបច្ច័យ, ក្នុងបដិសន្ធិ-ខណៈ នាម និងរូបជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសហជាត-បច្ច័យ ។ ល ។ ធម៌ គឺចិត្ត និងចេតសិក ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតបច្ច័យ ។ ល ។ មហាភូតរូបជាបច្ច័យដល់ឧបាទាយរូប ដោយអំណាចនៃសហជាតបច្ច័យ ។ ល ។ ក្នុងកាលខ្លះ រូបធម៌ជាបច្ច័យដល់អរូបធម៌ ដោយអំណាចនៃសហជាត-បច្ច័យ, ក្នុងកាលខ្លះ មិនជាបច្ច័យដោយអំណាចនៃសហជាតបច្ច័យទេ" ។ ពាក្យនេះ លោកពោលសំដៅយកចំពោះហទយវត្ថុប៉ុណ្ណោះ ៕*

..................................................

## ៧.ពាក្យថា អញ្ញមញ្ញប្បច្ច័យ

***ធម៌ដែលជួយឧបការៈ ដោយការឧបត្ថម្ភដល់គ្នានឹងគ្នា ឱ្យកើតឡើង និងទល់ទ្រទ្រង់គ្នានឹងគ្នាទុក ដូចជន្ទល់ឈើបីដែលជួយទល់ទ្រទ្រង់គ្នានឹងគ្នាទុក ឈ្មោះថា* អញ្ញមញ្ញប្បច្ច័យ** ។

*អញ្ញមញ្ញប្បច្ច័យនេះ មាន ៣ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម; សមពិតដូចព្រះមានព្រះភាគត្រាស់ទុកថា "អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ, មហាភូតរូប ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ។ ល ។ ក្នុងខណៈនៃបដិសន្ធិ នាម និងរូប ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃ **អញ្ញមញ្ញ-ប្បច្ច័យ**"*៕

---

## ៨.ពាក្យថា និស្សយប្បច្ច័យ

***ធម៌ដែលជួយឧបការៈ ដោយសេចក្តីជាទីអាស្រ័យ ប្រៀបដូចជាផែនដី និងផ្ទាំងសំពត់ជាដើម ជាទីទទួលរងនូវដើមឈើ និងចិត្តកម្មជាដើម ឈ្មោះថា* និស្សយប្បច្ច័យ** ។

*និស្សយប្បច្ច័យនោះ គប្បីជ្រាបតាមន័យដែលបានពោលហើយ*

ក្នុងសហជាតប្បច្ច័យយ៉ាងនេះថា "អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃនិស្សយប្បច្ច័យ" ។ ប៉ុន្តែក្នុងនិស្សយប្បច្ច័យនេះ លោកចែកទុក ៦ ចំណែក យ៉ាងនេះថា "ចក្ខាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណ-ធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ដោយអំណាចនៃនិស្សយប្បច្ច័យ ។ ល ។ កាយាយតនៈ ជាបច្ច័យដល់កាយវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយកាយវិញ្ញាណធាតុនោះ ដោយអំណាចនៃនិស្សយប្បច្ច័យ ។ មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាហើយប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យដល់មនោធាតុ មនោវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយមនោធាតុ និងមនោវិញ្ញាណធាតុនោះ ដោយអំណាចនៃនិស្សយប្បច្ច័យ ៕

---

## ៩.ពាក្យថា ឧបនិស្សយប្បច្ច័យ

ចំណែកក្នុងបទថា "**ឧបនិស្សយប្បច្ចយោ**" នេះ មានពាក្យអធិប្បាយដូចតទៅនេះ ៖

ក៏ឈ្មោះថា ***និស្សយៈ*** ព្រោះអត្ថថា ដែលផលរបស់ខ្លួនចូលទៅអាស្រ័យ គឺមិនបដិសេធផលរបស់ខ្លួន ព្រោះផលមានការអាស្រ័យហេតុ

នោះ ប្រព្រឹត្តទៅ ។ ទីអាស្រ័យដ៏មានកម្លាំង ឈ្មោះថា ឧបនិស្ស័យ ដូចសេចក្តីទុក្ខតាមផ្លូវចិត្តយ៉ាងខ្លាំង ឈ្មោះថា ឧបាយាសៈដូច្នោះដែរ ។ ពាក្យនេះ ជាឈ្មោះរបស់ហេតុដ៏មានកម្លាំង ។

ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ***ធម៌ដែលជួបឧបការៈដោយសេចក្តីជាហេតុដ៏មានកម្លាំង ឈ្មោះថា ឧបនិស្សយប្បច្ច័យ*** ។

***ឧបនិស្សយប្បច្ច័យនោះ មាន ៣ យ៉ាង គឺអារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ*** ។

បណ្តាឧបនិស្ស័យ ៣ យ៉ាងនេះ អារម្មណូបនិស្ស័យ ទ្រង់ចែកទុកមិនឲ្យផ្សេងគ្នាជាមួយនឹងអារម្មណាធិបតី ដោយន័យមានជាដើមយ៉ាងនេះថា "បុគ្គលឲ្យទាន សមាទានសីល និងរក្សាឧបោសថ រមែងពិចារណាកម្មនោះឲ្យធ្ងន់, រមែងពិចារណាកម្មដែលធ្លាប់សន្សំមកហើយ ឲ្យធ្ងន់, ចេញអំពីឈានហើយ ពិចារណាឈានឲ្យធ្ងន់ ។ ព្រះសេក្ខៈរមែងពិចារណាគោត្រភូឲ្យធ្ងន់, ពិចារណាវោទានៈឲ្យធ្ងន់, ព្រះសេក្ខៈចេញចាកមគ្គហើយ ពិចារណាមគ្គឲ្យធ្ងន់" ។ បណ្តាកុសលធម៌ មានការឲ្យទានជាដើមនោះ, ធម៌ គឺចិត្តនិងចេតសិក ធ្វើអារម្មណ៍ណា ឲ្យធ្ងន់ កើតឡើង, អារម្មណ៍នោះ ចាត់ថាជាអារម្មណ៍ដ៏មានកម្លាំង ក្នុងអារម្មណ៍ទាំងឡាយ សម្រាប់ចិត្ត និងចេតសិក

ទាំងនោះ ដោយការកំណត់យ៉ាងដាក់លាក់ ។ អ្នកសិក្សា គប្បីជ្រាប សេចក្ដីផ្សេងគ្នានៃអារម្មណាធិបតី និងអារម្មណូបនិស្ស័យយ៉ាងនេះ ៖

ឈ្មោះថា ***អារម្មណាធិបតី*** ព្រោះអត្ថថា ត្រឹមតែជាធម៌ដែលចិត្ត និងចេតសិក គប្បីធ្វើឲ្យធ្ងន់, ឈ្មោះថា ***អារម្មណូបនិស្ស័យ*** ព្រោះអត្ថថា ជាហេតុញ៉ាំងចិត្ត និងចេតសិកឲ្យមានកម្លាំង ។

សូម្បី ***អនន្តរូបនិស្ស័យ*** ក៏ទ្រង់ចែកទុកមិនឲ្យផ្សេងគ្នាពីអនន្តរប្បច្ច័យដែរ ដោយន័យជាដើមថា "កុសលក្ខន្ធទាំងឡាយ ដែលកើតឡើងមុនៗ ជាបច្ច័យដល់កុសលក្ខន្ធ ដែលកើតឡើងក្រោយៗ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ" ; ប៉ុន្តែ ក្នុងនិក្ខេបៈនៃមាតិកា មានការតាំងបច្ច័យទាំងពីរនោះឲ្យប្លែកគ្នា ព្រោះអនន្តរប្បច្ច័យ មានមកហើយដោយន័យជាដើមថា "ចក្ខុវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ជាបច្ច័យដល់មនោធាតុ និងធម៌ដែលសហគតៈដោយមនោធាតុនោះ ដោយអំណាចនៃអនន្តរប្បច្ច័យ" ឯឧបនិស្សយប្បច្ច័យ មានមកហើយ ដោយន័យជាដើមថា "កុសលធម៌ដែលកើតឡើងមុនៗ ជាបច្ច័យដល់កុសលធម៌ដែលកើតឡើងក្រោយៗ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ" ។ សូម្បីនិក្ខេបៈនៃមាតិកានោះ កាលបើពោលដោយអត្ថសេចក្ដីហើយ ក៏ត្រូវគ្នា

តែម្យ៉ាង ។ ទោះបីដូច្នោះ អ្នកសិក្សា ក៏គប្បីជ្រាបថា ឈ្មោះថា អនន្តរ-បច្ច័យ ព្រោះអាចញ៉ាំងចិត្តុប្បាទដែលសមគួរឲ្យកើតឡើងក្នុងលំដាប់របស់ខ្លួនៗ និងឈ្មោះថា អនន្តរូបនិស្សយបច្ច័យ ព្រោះចិត្តដែលកើតមុនមានកម្លាំង ក្នុងការញ៉ាំងចិត្តដូងក្រោយឲ្យកើតឡើង ។ ម្យ៉ាងទៀតដូចជាក្នុងហេតុបច្ច័យជាដើម ទោះបីវៀរចាកធម៌ប្រភេទខ្លះចេញ ចិត្តក៏រមែងកើតឡើងបាន យ៉ាងណា, វៀរចាកចិត្តដែលជាប់តគ្នានៃខ្លួនចេញ ចិត្តនឹងកើតឡើងបាន មិនមែនដូច្នោះទេ, ព្រោះហេតុដូច្នោះ ទើបឈ្មោះថាជាបច្ច័យមានកម្លាំង ។

គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃអនន្តរបច្ច័យ និងអនន្តរូបនិស្សយ-បច្ច័យទាំងពីរនោះ យ៉ាងនេះ ៖

ឈ្មោះថា ***អនន្តរបច្ច័យ*** ដោយអំណាចនៃការញ៉ាំងចិត្តដែលសមគួរឲ្យកើតឡើង ក្នុងលំដាប់របស់ខ្លួនៗ, ឈ្មោះថា អនន្តរូបនិស្សយបច្ច័យដោយអំណាចជាហេតុដ៏មានកម្លាំង ដោយប្រការដូច្នេះ ។

ចំណែកបកតូបនិស្ស័យ មានអធិប្បាយដូចតទៅនេះ ៖

ឧបនិស្ស័យដែលបុគ្គលធ្វើទុកក្នុងកាលមុន ឈ្មោះថា បកតូប-និស្ស័យ ។ ក៏ឈ្មោះថា បកតៈ (វត្ថុដែលធ្លាប់ធ្វើកន្លងមកហើយ) បានដល់ធម៌មានសទ្ធា និងសីលជាដើម ដែលបុគ្គលឲ្យសម្រេចហើយ ក្នុងសន្តាន

របស់ខ្លួន ឬរដូវ និងភោជនជាដើម ដែលបុគ្គលចូលទៅសេពហើយ ។

ម្យ៉ាងទៀត ឧបនិស្ស័យដោយប្រក្រតីនោះឯង ឈ្មោះថា ***បកតូ-បនិស្ស័យ,*** អធិប្បាយថា ជាបច្ច័យដែលមិនប្រឡំគ្នាជាមួយ ***អារម្មណ-ប្បច្ច័យ*** និង ***អនន្តរប្បច្ច័យ*** ឡើយ ។

ពិតមែនហើយ អ្នកសិក្សាគប្បីជ្រាបប្រភេទមានប្រការមិនមែនតិចនៃបកតូបនិស្សយប្បច្ច័យនោះ ដោយន័យជាដើមថា “ក៏ឈ្មោះថា ***បកតូប-និស្ស័យ*** បានដល់ បុគ្គលចូលទៅអាស្រ័យសទ្ធា ទើបឲ្យទាន, សមាទាន-សីល, រក្សាឧបោសថ, ធ្វើឈាន, វិបស្សនា, មគ្គ, អភិញ្ញា និងញុំាងសមាបត្តិឲ្យកើតឡើង; ចូលទៅអាស្រ័យសីលៈ, សុតៈ, ចាគៈ និងបញ្ញាទើបឲ្យទាន ។ ល ។ ធ្វើសមាបត្តិឲ្យកើតឡើង; សទ្ធា, សីលៈ, សុតៈ, ចាគៈ និងបញ្ញា ជាបច្ច័យដោយអំណាចនៃឧបនិស្សយប្បច្ច័យដល់សទ្ធា, សីលៈ, សុតៈ, ចាគៈ និងបញ្ញា” ។ ធម៌មានសទ្ធាជាដើមនេះ ដែលបុគ្គលធ្វើទុកក្នុងកាលមុន ឈ្មោះថា ជាឧបនិស្ស័យ ព្រោះអត្ថថា ជាហេតុមានកម្លាំង (ពលវការណជ្ជេន) ព្រោះហេតុដូច្នោះ ទើបឈ្មោះថា បកតូ-បនិស្ស័យ ដោយប្រការដូច្នេះឯង ៕

## ១០.ពាក្យថា បុរេជាតប្បច្ច័យ

*ធម៌ដែលជួយឧបការៈដោយការកើតឡើងមុន ហើយនៅប្រព្រឹត្តទៅឈ្មោះថា* **បុរេជាតប្បច្ច័យ** ។

*បុរេជាតប្បច្ច័យនោះ មាន ១១ យ៉ាង ដោយអំណាចនៃវត្ថុអារម្មណ៍ និងហទយវត្ថុ ក្នុងបញ្ចទ្វារ; ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ចក្ខាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ ។ ល ។ កាយាយតនៈ ជាបច្ច័យដល់កាយវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយកាយវិញ្ញាណធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ, រូបាយតនៈ ។ ល ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណធាតុ ។ ល ។ កាយវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយកាយវិញ្ញាណធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ, រូបាយតនៈ ។ ល ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យដល់មនោធាតុ និងធម៌ដែលសម្បយុត្តដោយមនោធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ ។ មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណា ប្រព្រឹត្តទៅ, រូបនោះ ជាបច្ច័យដល់មនោធាតុ និងធម៌ដែលសម្បយុត្តដោយមនោធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ, គ្រាខ្លះ*

ជាបច្ច័យដល់មនោវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយមនោ-វិញ្ញាណធាតុនោះ ដោយអំណាចនៃបុរេជាតប្បច្ច័យ, គ្រាខ្លះ ក៏មិនជាបច្ច័យដោយអំណាចនៃបុរេជាតប្បច្ច័យទេ” ៕

## ១១.ពាក្យថា បច្ឆាជាតប្បច្ច័យ

*អរូបធម៌ ជាធម៌ជួយឧបការៈ ដោយអត្ថថា ទំនុកបម្រុង (ឧបត្ថម្ភ-កផ្លេន) ដល់រូបធម៌ដែលកើតមុន ដូចជាចេតនាដែលប្រាថ្នានូវអាហារ ជួយឧបត្ថម្ភសរីរៈកូនត្មាតទុក ឈ្មោះថា* **បច្ឆាជាតប្បច្ច័យ** ។

ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា “ធម៌ គឺចិត្តនិងចេតសិកដែលកើតក្រោយៗ ជាបច្ច័យដល់កាយនេះ ដែលកើតមុនដោយអំណាចនៃបច្ឆាជាតប្បច្ច័យ” ៕

## ១២.ពាក្យថា អាសេវនប្បច្ច័យ

*ធម៌ដែលជួយឧបការៈ ដើម្បីឱ្យធម៌ទាំងឡាយ ដែលកើតជាប់តគ្នាមានភាពរហ័សរហួន និងមានកម្លាំង ដោយអត្ថថា សេពដដែលៗ (អាសេវ-*

***នផ្លេន) ប្រៀបដូចជាការប្រកបសេចក្ដីព្យាយាម ពេលដំបូងៗ ក្នុងការសិក្សាទន្ទេញមេរៀនជាដើម ឈ្មោះថា អាសេវនប្បច្ច័យ*** ។

*អាសេវនប្បច្ច័យនោះ មាន ៣ យ៉ាង ដោយអំណាចនៃកុសលជវន អកុសលជវន និងកិរិយាជវន ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "កុសលធម៌ដែលកើតឡើងមុនៗ ជាបច្ច័យដល់កុសលធម៌ដែលកើតឡើងក្រោយៗ ដោយអំណាចនៃអាសេវនប្បច្ច័យ ។ ល ។ កិរិយាអព្យាកតធម៌ ដែលកើតមុនៗ ជាបច្ច័យដល់កិរិយាអព្យាកតធម៌ ដែលកើតក្រោយៗ ដោយអំណាចនៃអាសេវនប្បច្ច័យ"*៕

---

## ១៣.ពាក្យថា កម្មប្បច្ច័យ

***ធម៌ដែលជួយឧបការៈ ដោយសេចក្ដីជាកិរិយា គឺសេចក្ដីព្យាយាម (បយោគៈ) នៃចិត្ត ឈ្មោះថា កម្មប្បច្ច័យ*** ។

*កម្មប្បច្ច័យនេះ មាន ២ យ៉ាង គឺកុសលចេតនា និងអកុសលចេតនាដែលកើតក្នុងខណៈផ្សេងគ្នា និងចេតនាទាំងអស់ ដែលកើតព្រមគ្នា ។ សមដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកថា "កុសលកម្ម និងអកុសលកម្ម ជាបច្ច័យដល់វិបាកក្ខន្ធ និងកម្មជរូប ដោយអំណាចនៃកម្មប្បច្ច័យ ។ ចេតនាជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយចេតនា និងដល់រូបដែលមាន*

ចេតនានោះជាសមុដ្ឋាន ដោយអំណាចនៃកម្មប្បច្ច័យ"។

## ១៤.ពាក្យថា វិបាកប្បច្ច័យ

***ធម៌ គឺវិបាកដែលជួយឧបការៈដោយមិនឧស្សាហ៍ ព្រោះសេចក្តីមិនមានឧស្សាហ៍ ឈ្មោះថា វិបាកប្បច្ច័យ*** ។

វិបាកប្បច្ច័យនុ៎ះ រមែងជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល ដល់កម្មជរូបក្នុងបដិសន្ធិកាល និងដល់ធម៌ដែលសម្បយុត្តដោយវិបាកចិត្តនោះ ក្នុងកាលទាំងអស់ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ខន្ធ ១ ដែលជា ***វិបាកាព្យាកតៈ*** ជាបច្ច័យដល់ខន្ធ ៣ និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃវិបាក-ប្បច្ច័យ ។ល។ ខន្ធ ១ ដែលជាវិបាកាព្យាកតៈក្នុងខណៈបដិសន្ធិ ជាបច្ច័យដល់ខន្ធ ៣ ដោយអំណាចនៃវិបាកប្បច្ច័យ ។ល។ ខន្ធ ៣ ជាបច្ច័យដល់ខន្ធ ១ ដោយអំណាចនៃវិបាកប្បច្ច័យ ។ល។ ខន្ធ ២ ជាបច្ច័យដល់ខន្ធ ២ និងដល់កម្មជរូប (កដត្តារូប) ដោយអំណាចនៃវិបាកប្បច្ច័យ ។ ខន្ធទាំងឡាយ ជាបច្ច័យដល់វត្ថុរូប ដោយអំណាចនៃវិបាកប្បច្ច័យ"។

## ១៥.ពាក្យថា អាហារប្បច្ច័យ

***អាហារ ៤ ជាធម៌ជួយឧបការៈ ដោយអត្ថថា ជួយឧបត្ថម្ភដល់រូប និងនាម ឈ្មោះថា អាហារប្បច្ច័យ*** ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគបានត្រាស់ទុកថា “កពឡិង្ការាហារ ជាបច្ច័យដល់កាយនេះ ដោយអំណាចនៃអាហារប្បច្ច័យ ។ នាមាហារ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្ត និងដល់រូបដែលមាននាមាហារ និងធម៌ដែលសម្បយុត្តដោយនាមាហារនោះជាសមុដ្ឋាន ដោយអំណាចនៃអាហារប្បច្ច័យ” ។ ចំណែកក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ទុកថា “អាហារដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធទាំងឡាយដែលសម្បយុត្ត និងដល់កម្មជរូប ក្នុងខណៈបដិសន្ធិ ដោយអំណាចនៃអាហារប្បច្ច័យ” ៕

---

## ១៦.ពាក្យថា ឥន្ទ្រិយប្បច្ច័យ

***ឥន្ទ្រិយ ២០ វៀរឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយចេញ ជួយឧបការៈ ដោយអត្ថថា ជាធំក្រៃលែង ឈ្មោះថា ឥន្ទ្រិយប្បច្ច័យ*** ។

បណ្ដាឥន្ទ្រិយទាំងនេះ ឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ, ដែលនៅសល់ ជាបច្ច័យដល់រូបធម៌ និងអរូបធម៌ ។

សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ចក្ខុន្ទ្រិយ ។ល។ កាយិន្ទ្រិយ ជាបច្ច័យដល់ចក្ខុវិញ្ញាណធាតុ ។ល។ កាយវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយឥន្ទ្រិយនោះ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ រូបជីវិតិន្ទ្រិយជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ អរូបឥន្ទ្រិយជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងរូបដែលមានឥន្ទ្រិយនោះជាសមុដ្ឋាន ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ" ។ ប៉ុន្តែ ក្នុងបញ្ហាវារៈថា "ឥន្ទ្រិយដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់កម្មជរូប ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ក្នុងខណៈបដិសន្ធិ"៕

................................

## ១៧.ពាក្យថា ឈានប្បច្ច័យ

***អង្គឈាន ៧ ដែលផ្សេងគ្នាដោយកុសលជ្ឈានជាដើម វៀរសុខវេទនា និងទុក្ខវេទនាដែលប្រព្រឹត្តទៅតាមផ្លូវកាយ ក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ជួយឧបការៈ ដោយអត្ថថា ចូលទៅសម្លឹងអារម្មណ៍ (ឧបនិជ្ឈាយនដ្ឋេន) ឈ្មោះថា ឈានប្បច្ច័យ*** ។

សមដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកថា "អង្គឈាន ៧ ជាបច្ច័យ ដល់ធម៌ដែលសម្បយុត្ត និងរូបដែលមានអង្គឈាននោះជា

សមុដ្ឋាន ដោយអំណាចនៃឈានប្បច្ច័យ" ។ ចំណែកក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ទុកថា "អគ្គឈានដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងដល់កម្មជរូប ក្នុងបដិសន្ធិខណៈ ដោយអំណាចនៃឈានប្បច្ច័យ"៕

---

## ១៨.ពាក្យថា មគ្គប្បច្ច័យ

***អង្គមគ្គ ១២ ដែលផ្សេងគ្នាដោយកុសលមគ្គជាដើម ជួយឧបការៈដោយអត្ថថា ជាហេតុនាំទៅ (និយ្យានផ្ទួន) ក្នុងផ្លូវណាមួយ ឈ្មោះថា*** **មគ្គប្បច្ច័យ** ។

សមដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកថា "អគ្គមគ្គជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយមគ្គ និងដល់រូបដែលមានអគ្គមគ្គនោះជាសមុដ្ឋាន ដោយអំណាចនៃមគ្គប្បច្ច័យ" ។ ចំណែកក្នុងបញ្ហាវារៈ ព្រះមានព្រះភាគត្រាស់ទុកថា "អគ្គមគ្គដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងកម្មជរូប ក្នុងបដិសន្ធិខណៈ ដោយអំណាចនៃមគ្គ-ប្បច្ច័យ" ។ ប៉ុន្តែ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទាំងពីរនេះ គប្បីជ្រាបថា រមែងមិនបានក្នុងទ្វិបញ្ចវិញ្ញាណចិត្ត និងអហេតុកចិត្ត តាមដែលពោលមក

*ហើយទេ (សំដៅដល់ទ្វិបញ្ចវិញ្ញាណ មិនជាឈានប្បច្ច័យ, អហេតុកចិត្ត មិនមែនជាមគ្គប្បច្ច័យ) ៕*

---

## ១៩.ពាក្យថា សម្បយុត្តប្បច្ច័យ

***អរូបធម៌ដែលជួយឧបការៈ ដោយការប្រកបរួមគ្នា គឺមានវត្ថុដូចគ្នា មានអារម្មណ៍ដូចគ្នា កើតឡើងក្នុងខណៈជាមួយគ្នា និងរលត់ព្រមគ្នា ឈ្មោះថា សម្បយុត្តប្បច្ច័យ*** ៕

*សមដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកថា "អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសម្បយុត្តប្បច្ច័យ"៕*

---

## ២០.ពាក្យថា វិប្បយុត្តប្បច្ច័យ

***រូបធម៌ដែលជួយឧបការៈ ដោយការមិនចូលដល់នូវភាវៈដែលមានវត្ថុជាមួយគ្នាជាដើមជា វិប្បយុត្តប្បច្ច័យ ដល់អរូបធម៌, សូម្បីក្នុងរូបធម៌ក៏ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ដែរ*** ៕

*វិប្បយុត្តប្បច្ច័យនោះ មាន ៣ យ៉ាង គឺសហជាតវិប្បយុត្ត បច្ឆាជាតវិប្បយុត្ត និងបុរេជាតវិប្បយុត្ត ។ សមពិតដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ថា "កុសលក្ខន្ធដែលកើតព្រមគ្នា ជាបច្ច័យដល់រូប*

ដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ ។ កុសលក្ខន្ធ ដែលកើតក្រោយៗ ជាបច្ច័យដល់កាយនេះ ដែលកើតមុន ដោយអំណាចនៃ វិប្បយុត្តប្បច្ច័យ” ។ ចំណែកក្នុងសហជាតវិភង្គនៃអព្យាកតបទ ព្រះមាន ព្រះភាគត្រាស់ទុកថា “ក្នុងខណៈបដិសន្ធិ ខន្ធទាំងឡាយដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ; ខន្ធទាំងឡាយ ជាបច្ច័យដល់វត្ថុរូប ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ, វត្ថុរូប ជាបច្ច័យ ដល់ខន្ធទាំងឡាយ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ” ។ ចំណែកបុរេជាត គប្បីជ្រាបដោយអំណាចនៃវត្ថុ មានចក្ខុន្ទ្រិយវត្ថុជាដើម; សមដូចដែល ព្រះមានព្រះភាគត្រាស់ទុកថា “ចក្ខាយតនៈដែលកើតមុន ជាបច្ច័យដល់ ចក្ខុវិញ្ញាណ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ ។ ល ។ កាយាយតនៈ ដែលកើតមុន ជាបច្ច័យដល់កាយវិញ្ញាណ ដោយអំណាចនៃវិប្បយុត្ត-ប្បច្ច័យ; វត្ថុជាបច្ច័យដល់វិបាកាព្យាកតក្ខន្ធ, កិរិយាអព្យាកតក្ខន្ធ, កុសលក្ខន្ធ និងអកុសលក្ខន្ធ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ”៕

---

## ២១.ពាក្យថា អត្ថិប្បច្ច័យ

***ធម៌ដែលជួយឧបការៈ ដោយអត្ថថា ជួយឧបត្ថម្ភដល់ធម៌ដូចគ្នា***

*ដោយភាវៈដែលនៅមានការកើតឡើងចំពោះមុខជាលក្ខណៈ ឈ្មោះថា* **អត្ថិប្បច្ច័យ** *។ ក្នុងអត្ថិប្បច្ច័យនេះ ព្រះមានព្រះភាគទ្រង់តាំងមាតិកាទុក ៧ យ៉ាង គឺអរូបក្ខន្ធ ១ មហាភូតរូប ១ នាមរូប ១ ចិត្តចេតសិក ១ មហាភូតរូប ១ អាយតនៈ ១ និងវត្ថុ ១ ។ សមដូចព្រះអង្គត្រាស់ទុកថា "អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃអត្ថិប្បច្ច័យ ។ មហាភូតរូប ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃអត្ថិប្បច្ច័យ ។ ក្នុងបដិសន្ធិខណៈ នាមរូបជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃអត្ថិប្បច្ច័យ; ធម៌ គឺចិត្ត និងចេតសិក ជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអត្ថិប្បច្ច័យ; មហាភូតរូប ជាបច្ច័យដល់ឧបាទាយរូប ដោយអំណាចនៃអត្ថិប្បច្ច័យ; ចក្ខាយតនៈ ។ល។ កាយាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណធាតុ ។ល។ កាយវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តនោះ ដោយអំណាចនៃអត្ថិប្បច្ច័យ; រូបាយតនៈ ។ល។ ផោដ្ឋព្វាយតនៈ ជាបច្ច័យដល់មនោធាតុ និងធម៌ដែលសម្បយុត្តដោយមនោធាតុនោះ ដោយអំណាចនៃអត្ថិប្បច្ច័យ; មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ, រូបនោះ ជាបច្ច័យដល់មនោធាតុ និងមនោវិញ្ញាណធាតុ ព្រមទាំងធម៌ដែលសម្បយុត្តជាមួយមនោធាតុ និងមនោវិញ្ញាណធាតុនោះ ដោយអំណាចនៃអត្ថិប្បច្ច័យ"* ។ *ចំណែកក្នុងបញ្ហាវារៈ ព្រះមានព្រះភាគ*

*ទ្រង់ត្រាស់ទុកថា* **“សហជាតំ បុរេជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ”** *ហើយទ្រង់អធិប្បាយទុកក្នុងសហជាតប្បច្ច័យមុន ដោយន័យជាដើមថា “ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣ និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃអត្ថិប្បច្ច័យ” ។ ក្នុងបុរេជាតប្បច្ច័យ ទ្រង់អធិប្បាយដោយអំណាចនៃចក្ខុបសាទជាដើម ដែលកើតមុន ។ ក្នុងបច្ឆាជាតប្បច្ច័យ ទ្រង់អធិប្បាយទុកដោយអំណាចនៃចិត្ត និងចេតសិកដែលកើតខាងក្រោយ ជាបច្ច័យដល់កាយនេះ ដែលកើតមុន ។ ចំណែកក្នុងអាហារប្បច្ច័យ និងឥន្ទ្រិយ-ប្បច្ច័យ ទ្រង់អធិប្បាយទុកយ៉ាងនេះថា “កវឡិង្ការាហារ ជាបច្ច័យដល់កាយនេះ ដោយអំណាចនៃអត្ថិប្បច្ច័យ; រូបជីវិតិន្ទ្រិយ ជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃអត្ថិប្បច្ច័យ”* ៕

---

## ២២. ពាក្យថា នត្ថិប្បច្ច័យ

***អរូបធម៌ដែលរលត់ទៅដោយមិនមានចន្លោះ ជួយឧបការៈ ដោយការឱ្យឱកាសដល់អរូបធម៌ ដែលនឹងកើតក្នុងលំដាប់នៃខ្លួនប្រព្រឹត្តទៅ ឈ្មោះថា*** **នត្ថិប្បច្ច័យ** ។

*សមដូចព្រះមានព្រះភាគត្រាស់ទុកថា “ធម៌ គឺចិត្ត និងចេតសិក*

ដែលរលត់ទៅ ដោយមិនមានចន្លោះ ជាបច្ច័យដល់ធម៌ គឺចិត្ត និងចេតសិក ដែលកើតឡើងចំពោះមុខ ដោយអំណាចនៃនត្ថិប្បច្ច័យ"។

---

## ២៣.ពាក្យថា វិគតប្បច្ច័យ

ធម៌ដែលជានត្ថិប្បច្ច័យនោះឯង ឈ្មោះថា **វិគតប្បច្ច័យ** ព្រោះជួយឧបត្ថម្ភដោយភាវៈដែលប្រាសចាកទៅ; ដូចព្រះមានព្រះភាគត្រាស់ទុកថា "ធម៌ គឺចិត្ត និងចេតសិកដែលប្រាសចាកទៅ ដោយមិនមានចន្លោះ ជាបច្ច័យដល់ធម៌ គឺចិត្ត និងចេតសិក ដែលកើតឡើងចំពោះមុខ ដោយអំណាចនៃវិគតប្បច្ច័យ"។

---

## ២៤.ពាក្យថា អវិគតប្បច្ច័យ

ធម៌ដែលជាអត្ថិប្បច្ច័យនោះឯង អ្នកសិក្សាគប្បីជ្រាបថា ឈ្មោះថា **អវិគតប្បច្ច័យ** ព្រោះជួយឧបត្ថម្ភដោយភាវៈដែលនៅមិនទាន់ប្រាសទៅ ។

ប៉ុន្តែ ព្រះមានព្រះភាគត្រាស់បច្ច័យគូនេះទុក ក៏ដោយអំណាចនៃវេនេយ្យសត្វដែលនឹងគប្បីណែនាំយ៉ាងនោះ ដោយលម្អនៃទេសនាវិលាស ដូចដែលត្រាស់សហេតុកទុកៈទុកហើយ ក៏នៅត្រាស់ហេតុសម្បយុត្តទុកៈ

ជាដើមទុកទៀត; ក៏ដើម្បីមិនឲ្យប្រទូំក្នុងបច្ច័យទាំង ២៤ នេះ អ្នកសិក្សា គប្បីជ្រាបសេចក្តីវិនិច្ឆ័យដោយធម៌ ដោយកាល ដោយការចែក ដោយប្រការផ្សេងៗ និងដោយបច្ចយុប្បន្ន ។

បណ្តាបទទាំងនោះ បទថា **“ធម្មតោ** = ដោយធម៌” សេចក្តីថា ក្នុងបណ្តាបច្ច័យទាំង ២៤ នោះ ***ហេតុប្បច្ច័យ*** បានដល់ ចំណែកមួយនៃនាមធម៌ ក្នុងបណ្តានាមធម៌ និងរូបធម៌ទាំងឡាយ ។ ***អារម្មណប្បច្ច័យ*** បានដល់ នាមធម៌ និងរូបធម៌ទាំងអស់ ព្រោះមិនមានបញ្ញត្តិ ។ ក្នុង ***អធិបតិ-ប្បច្ច័យ សហជាតាធិបតិប្បច្ច័យ*** បានដល់ ចំណែកមួយនៃនាមធម៌ ។ កម្មប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ក៏ដូចគ្នាដែរ ។ ***អារម្មណាធិបតិ-ប្បច្ច័យ*** បានដល់ ធម៌ដែលជាអារម្មណ៍ទាំងអស់ ដែលចិត្ត និងចេតសិក គប្បីធ្វើឲ្យធ្ងន់ ។ ***អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវន-ប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ*** បានដល់ នាមធម៌តែប៉ុណ្ណោះ ។ សូម្បីនឹងពោលថា ជាចំណែកមួយនៃនាមធម៌ ក៏បាន ព្រោះមិនបានសង្គ្រោះនិព្វានចូលផងទេ ។ បុរេជាតប្បច្ច័យ ជាចំណែកមួយនៃរូបធម៌ ។ បច្ច័យដែលនៅសល់ បានទាំងនាមធម៌ ទាំងរូបធម៌ ដោយអំណាចនៃធម៌តាមដែលគួរនឹងបាន ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យដោយធម៌ក្នុងអធិការនេះ ដូចពណ៌នាមកហើយចុះ ។

បទថា **"កាលតោ** = *ដោយកាល"* សេចក្តីថា ៖

បណ្តាបច្ច័យទាំងនេះ ***បច្ច័យ ១៥*** ជាបច្ចុប្បន្នកាល ។

***បច្ច័យ ៥*** ជាអតីតកាល ។

***បច្ច័យ ១*** អាស្រ័យកាលទាំងពីរ ។

***បច្ច័យ ៣*** ប្រព្រឹត្តទៅក្នុងកាលទាំង ៣ និងផុតចាកកាលផងដែរ ។

ពិតមែនហើយ បណ្តាបច្ច័យទាំងនុ៎ះ ***បច្ច័យទាំង ១៥ នេះ*** គឺហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ***ជាបច្ចុប្បន្នកាល*** ប៉ុណ្ណោះ ។

***បច្ច័យទាំង ៥ នេះ*** គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ***ជាអតីតកាល*** ប៉ុណ្ណោះ ។

ចំណែក ***បច្ច័យ ១*** គឺកម្មប្បច្ច័យ អាស្រ័យកាលទាំងពីរ ដែលជា ***បច្ចុប្បន្ន និងអតីត*** ។

***បច្ច័យ ៣ ដ៏សេសទាំងនេះ*** គឺអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ ***ប្រព្រឹត្តទៅក្នុងកាលទាំង ៣*** ក៏បាន, ជាកាលវិមុត្ត

*ក៏បាន ព្រោះសង្គ្រោះនិព្វាន និងបញ្ញត្តិចូលផង ។*

*អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យ* ***ដោយកាល*** *ក្នុងបច្ច័យទាំងនេះ ដូចបានពណ៌នាមកហើយ ។ ចំណែកពីរបទនេះថា* **“នានប្បការភេទគោបច្ចយុ-ប្បន្នគោ”** *នឹងមានសេចក្តីច្បាស់លាស់ហើយ ក្នុងនិទ្ទេសវារៈ ៕*

**ចប់ឧទ្ទេសវារៈ**

# បច្ចយនិទ្ទេស

## ១. ពណ៌នាអំពីនិទ្ទេសនៃហេតុប្បច្ច័យ

*ឥឡូវនេះ ដើម្បីនឹងសម្តែងពង្រីកសេចក្តីនៃបច្ច័យទាំងអស់នេះ តាមលំដាប់បច្ច័យដែលបានលើកឡើងហើយ ទើបព្រះមានព្រះភាគត្រាស់ពាក្យមានជាដើមថា “ឈ្មោះថា* ***ហេតុប្បច្ច័យ*** *បានដល់* ***ហេតុជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងដល់រូបដែលមានហេតុ និងធម៌ដែលសម្បយុត្តជាមួយនឹងហេតុនោះ ជាសមុដ្ឋាន ដោយអំណាចនៃហេតុប្បច្ច័យ”*** *។ បណ្តាបច្ច័យទាំង ២៤ នោះ ព្រះមានព្រះភាគទ្រង់លើកហេតុប្បច្ច័យនេះឡើងសម្តែងមុនបច្ច័យណាៗ ទាំងអស់ ហើយក៏ទ្រង់ចែកទៅតាមលំដាប់ដែលទ្រង់តាំងទុក ។ សូម្បីក្នុងបច្ច័យដែលនៅសល់ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់លើកបទដែលគួរចែកឡើងមុន នឹងធ្វើការវិសជ្ជនា*

ដោយន័យដូចគ្នានេះដែរ ។ ចំណែកសម្ពន្ធបទ (បទដែលទាក់ទងគ្នា) ក្នុងអធិការនេះថា បច្ច័យណាដែលព្រះមានព្រះភាគទ្រង់លើកឡើង ក្នុងខទ្ទេសនៃបច្ច័យថា **"ហេតុបច្ចយោ"** ដូច្នេះ, បច្ច័យនោះ អ្នកសិក្សាគប្បីជ្រាបដោយនិទ្ទេសយ៉ាងនេះថា "ហេតុ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងដល់រូប ដែលមានហេតុនោះជាសមុដ្ឋាន ដោយអំណាចនៃហេតុ-បច្ច័យ" ។ អ្នកសិក្សា គប្បីជ្រាបសម្ពន្ធ និងការវិសជ្ជនាបទដែលគួរចែកដោយបច្ច័យទាំងអស់ ដោយឧបាយនេះចុះ ។

ឥឡូវនេះ មានសំណួរថា ក្នុងពាក្យថា **"ហេតុ ហេតុសម្ប-យុត្តកានំ"** នេះ ព្រះមានព្រះភាគមិនត្រាស់ថា **"ហេតុសម្បយុត្តកានំ"** ដូច្នេះទេ, ប៉ុន្តែត្រាស់ថា **"ហេតុ ហេតុសម្បយុត្តកានំ"** ដូច្នេះវិញ តើព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះជាការកំណត់បច្ច័យ និងបច្ចយុប្បន្ន ។ ពិតមែនហើយ កាលព្រះមានព្រះភាគត្រាស់ថា **"ហេតុសម្បយុត្តកានំ"** ការកំណត់បច្ច័យថា ធម៌ឈ្មោះនោះ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តដោយហេតុ ដោយអំណាចនៃហេតុប្បច្ច័យដូច្នេះ នរណាមួយក៏ជ្រាបមិនបាន ។ ម្យ៉ាងទៀត ព្រោះមិនកាន់យកនូវសេចក្តីថា ធម៌ទាំងឡាយដែលសម្បយុត្តដោយហេតុ ឈ្មោះថា **ហេតុសម្បយុត្តកានំ** គប្បីមាន

សេចក្ដីថា ហេតុ ជាបច្ច័យដល់ធម៌ពួកណាមួយ ដែលសម្បយុត្តគ្នា ដោយអំណាចនៃហេតុប្បច្ច័យ ។ កាលបើដូច្នេះ សូម្បីចក្ខុវិញ្ញាណចិត្តជាដើម ដែលមិនប្រកបដោយហេតុ ក៏ឈ្មោះថា **សម្បយុត្តកា** = ប្រកបជាមួយគ្នា, ទាំងធម៌ មានកុសលធម៌ជាដើម ដែលប្រកបដោយហេតុ ក៏ឈ្មោះថា សម្បយុត្តដែរ ។ បណ្ដាបច្ចយុប្បន្នទាំងនោះ កាលព្រះមានព្រះភាគត្រាស់ថា ហេតុនេះ ជាបច្ច័យដល់ធម៌ឈ្មោះនោះ ដែលសម្បយុត្តគ្នា ការកំណត់ធម៌ ដែលជាបច្ចយុប្បន្ន នរណាមួយ ក៏ដឹងមិនបាន ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់កំណត់ទាំងបច្ច័យ ទាំងបច្ចយុប្បន្ន ទើបត្រាស់ថា **“ហេតុ ហេតុសម្បយុត្តកានំ** = ហេតុជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ” ។

សេចក្ដីនេះ មានអធិប្បាយថា ហេតុដែលសម្បយុត្ត ជាបច្ច័យដល់ធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដែលសម្បយុត្តដោយហេតុ ដោយអំណាចនៃហេតុប្បច្ច័យ ។ សូម្បីក្នុងពាក្យនោះ ព្រះមានព្រះភាគ ក៏មិនត្រាស់ថា **“បច្ចយោ”** តែម្យ៉ាងទេ, ត្រាស់ថា **“ហេតុប្បច្ចយេន”** ដូច្នេះវិញ ដើម្បីបដិសេធភាវៈនៃហេតុជាបច្ច័យដោយប្រការដទៃ ។ ពិតមែនហើយ ហេតុនេះ ជាបច្ច័យដោយអំណាចនៃហេតុប្បច្ច័យក៏បាន ដោយ

អំណាចនៃសហជាតប្បច្ច័យជាដើមក៏បាន ។ ព្រះមានព្រះភាគត្រាស់ពាក្យថា **"ហេតុប្បច្ចយេន"** ទុកក្នុងអធិការនោះ ក៏ដើម្បីបដិសេធនូវភាវៈនៃហេតុនេះ ជាបច្ច័យដោយប្រការដទៃ មានសហជាតប្បច្ច័យជាដើម ។

***សួរថា*** កាលបើដូច្នេះ ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគមិនត្រាស់ថា **"តំសម្បយុត្តកានំ"** , តែបែរមកជាត្រាស់ថា **"ហេតុ-សម្បយុត្តកានំ"** ដូច្នេះទៅវិញ ?

ឆ្លើយថា ព្រោះបច្ច័យដែលនឹងត្រូវអធិប្បាយ នៅមិនប្រាកដ ។

ពិតមែនហើយ កាលព្រះមានព្រះភាគត្រាស់ថា **"តំសម្បយុត្តកានំ** = ធម៌ទាំងឡាយនោះ និងឈ្មោះថា **តំសម្បយុត្តកា** ដោយធម៌ដែលជាហេតុ យ៉ាងណា, ធម៌ដែលជាហេតុយ៉ាងនោះ ព្រះមានព្រះភាគ ក៏ទ្រង់បញ្ជាក់ថា ធម៌ឈ្មោះនេះ នៅមិនប្រាកដ; ព្រោះភាវៈនៃធម៌នោះ នៅមិនប្រាកដ បណ្ឌិតនឹងហៅធម៌ដែលសម្បយុត្តដោយហេតុយ៉ាងណានោះថា **'តំសម្បយុត្តកានំ"** ដូច្នេះ, ដើម្បីនឹងសម្តែងហេតុយ៉ាងនោះ ដោយសង្ខេប ទើបព្រះមានព្រះភាគត្រាស់ថា **"ហេតុសម្បយុត្តកានំ"** ។

ចំណែកក្នុងពាក្យថា **"តំសមុដ្ឋានានំ"** នេះ ព្រះមានព្រះភាគទ្រង់ប្រើសព្ទថា **"តំ"** នោះ ព្រោះបច្ច័យដែលគួរអធិប្បាយប្រាកដហើយ ។

*ពិតមែនហើយ ក្នុងអធិការនេះ មានសេចក្តីថា ហេតុទាំងនោះផង ធម៌ដែលសម្បយុត្តដោយហេតុផង ជាសមុដ្ឋាននៃរូបទាំងនេះ ព្រោះហេតុដូច្នោះ រូបទាំងនេះ ទើបឈ្មោះថា មានហេតុ និងធម៌ដែលសម្បយុត្ត ដោយហេតុជាសមុដ្ឋានដូច្នេះ ។ ហេតុ ជាបច្ច័យដល់រូបទាំងនោះ ដែលមានហេតុ និងធម៌ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន, អធិប្បាយថា ដល់រូបដែលកើតអំពីហេតុ និងធម៌ដែលសម្បយុត្តដោយហេតុ ។ ទ្រង់កាន់យករូបដែលមានចិត្តជាសមុដ្ឋាន ដោយពាក្យនេះ ។* ***សួរថា*** *ក៏រូបនោះ រមែងកើតឡើង សូម្បីដោយធម៌ដទៃអំពីចិត្ត ក៏បានឬ ? ឆ្លើយថា កើតឡើងបាន ។ ពិតមែនហើយ សូម្បីចិត្ត និងចេតសិកទាំងអស់ កើតព្រមគ្នាហើយ ទើបឲ្យរូបកើតឡើងបាន (វៀរចាកចិត្ត គឺចេតសិក) ។ ប៉ុន្តែ ព្រះមានព្រះភាគ ត្រាស់ដោយលោកិយធម្មទេសនាថា រូបដែលមានចិត្តជាសមុដ្ឋាន តាមវិធីនោះ ព្រោះសភាពនៃចិត្តជាធំ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា “ធម៌ គឺចិត្ត និងចេតសិក ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតបច្ច័យ” ។*

***សួរថា*** *បើដូច្នោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងអធិការនេះថា* “**តំសមុដ្ឋានានំ**” *ដូច្នេះ មិនត្រាស់ថា* “**ចិត្តសមុដ្ឋានានំ**” *ដូច្នេះទេ ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះសង្គ្រោះរូបដែលមិនមានចិត្តជាសមុដ្ឋាន*

ចូលមកផងទេ ។ ពិតមែនហើយ ក្នុងបញ្ហាវារៈ មានអាគតស្ថានថា “ហេតុដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តដោយហេតុ និងដល់កម្មជរូបក្នុងខណៈបដិសន្ធិ ដោយអំណាចនៃហេតុប្បច្ច័យ” ។ ព្រះមានព្រះភាគមិនត្រាស់ថា **“ចិត្តសមុដ្ឋានានំ”** ដូច្នេះទេ, ប៉ុន្តែ ទ្រង់ត្រាស់ថា **“តំសមុដ្ឋានានំ”** ទុកក្នុងអធិការនេះ ក៏ដើម្បីនឹងសង្គ្រោះកម្មជរូបនុ៎ះទុកផង ។

បទនោះ មានសេចក្តីថា ហេតុទាំងនោះ និងធម៌ដែលសម្បយុត្តដោយហេតុ សូម្បីនឹងមិនអាចញ៉ាំងចិត្តជរូបឲ្យកើតបានមែន, ប៉ុន្តែ ក៏ចាត់ជាសមុដ្ឋាននៃរូបទាំងនោះ ដោយអំណាចនៃសហជាតប្បច្ច័យជាដើមដែរ, ព្រោះហេតុនោះ រូបទាំងនោះ ទើបឈ្មោះថា មានហេតុ និងធម៌ដែលសម្បយុត្ត ដោយហេតុនោះ ជាសមុដ្ឋាន ។ ហេតុជាបច្ច័យដល់កម្មជរូបទាំងនោះ ដែលមានហេតុ និងធម៌ដែលសម្បយុត្តដោយហេតុនោះ ជាសមុដ្ឋាន ។ ហេតុជាបច្ច័យដល់ចិត្តជរូបក្នុងបវត្តិកាល និងដល់កម្មជរូបក្នុងបដិសន្ធិកាល ដោយអំណាចនៃហេតុប្បច្ច័យ ។ សូម្បីអត្ថក្នុងអាគតស្ថានថា **“តំសមុដ្ឋានានំ”** ដូច្នេះ ក្នុងបទដទៃៗ អ្នកសិក្សា ក៏គប្បីជ្រាបសេចក្តីអធិប្បាយ ដោយឧបាយនេះចុះ ។

***សួរថា*** ក៏ព្រោះហេតុអ្វី ហេតុនេះ ទើបជាហេតុប្បច្ច័យដល់កម្មជ-

រូប ក្នុងបដិសន្ធិកាលតែម្យ៉ាង, ម្ដេចមិនជាហេតុប្បច្ច័យក្នុងបវត្តិកាលផង ?

ឆ្លើយថា ព្រោះកម្មជរូប មានការប្រព្រឹត្តទៅជាប់ទាក់ទងនឹងចិត្ត ក្នុងបដិសន្ធិកាល ។ ពិតមែនហើយ ក្នុងបដិសន្ធិកាល ***កម្មជរូបមានការប្រព្រឹត្តទៅជាប់ទាក់ទងជាមួយនឹងចិត្ត គឺរមែងកើតឡើង និងតាំងនៅបាន ដោយអំណាចនៃចិត្ត ។ ព្រោះថា ក្នុងខណៈនោះ ចិត្តមិនអាចញ៉ាំង ចិត្តជរូបឱ្យកើតឡើងបានទេ ។ រូបទាំងនោះ សូម្បីវៀរចិត្តចេញ ក៏មិនអាចកើតឡើង និងតាំងនៅបានដែរ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា "នាម និងរូប រមែងកើត ព្រោះវិញ្ញាណជាបច្ច័យ, កាលវិញ្ញាណនោះ តាំងនៅ ទើបនាម និងរូបកើតឡើងបាន"***[១៦] ។

ប៉ុន្តែ ក្នុងបវត្តិកាល កម្មជរូបទាំងនោះ ទោះបីចិត្តនៅមានក្តី ក៏មានតែការប្រព្រឹត្តទៅជាប់ទាក់ទងដោយកម្មប៉ុណ្ណោះ, មិនជាប់ទាក់ទងដោយចិត្តទេ ។ម្យ៉ាងទៀត សម្រាប់បុគ្គលអ្នកចូលនិរោធ សូម្បីមិនមាន ចិត្តកើត ក៏កម្មជរូបនៅតែកើតឡើងបានដែរ ។

***សួរថា*** ព្រោះហេតុអ្វី បានជាក្នុងបដិសន្ធិខណៈ ចិត្តមិនអាចញ៉ាំង ចិត្តជរូបឲ្យកើតឡើងបាន ?

---

[១៦] សំ. និ. ។

ឆ្លើយថា ***ព្រោះមានកម្លាំងខ្សោយ ដោយត្រូវកម្លាំងកម្មបន្សាត់ទៅ និងនៅមិនទាន់មានទីអាស្រ័យដ៏មាំទាំ*** ។ ***ពិតមែនហើយ ក្នុងបដិសន្ធិកាល ចិត្តនោះ ត្រូវកម្លាំងកម្មបន្សាត់ទៅ និងឈ្មោះថា នៅមិនទាន់មានទីអាស្រ័យដ៏មាំទាំ ព្រោះនៅមិនទាន់មានវត្ថុរូបដែលជាបុរេជាតប្បច្ច័យ ព្រោះហេតុនោះ ទើបឈ្មោះថា មានកម្លាំងខ្សោយ*** ។

ព្រោះហេតុដូច្នោះ ទើបបដិសន្ធិចិត្ត មិនអាចញ៉ាំងរូបឲ្យកើតឡើងបាន ប្រៀបដូចជាមនុស្សដែលគ្រាន់តែធ្លាក់ទៅក្នុងជ្រោះ មិនអាចសម្ដែងសិល្បៈណាៗបានឡើយ ។ ក៏កម្មជរូបប៉ុណ្ណោះ តាំងនៅក្នុងឋាននៃរូបដែលមាន ចិត្តជាសមុដ្ឋានសម្រាប់បុគ្គលនោះ ។ ឯចិត្តនោះ ក៏តាំងនៅក្នុងឋានជាពូជនៃកម្មជរូបប៉ុណ្ណោះ ។ ចំណែកកម្មប្រៀបបីដូចជាស្រែ, កិលេសប្រៀបបីដូចជាទឹក សម្រាប់កម្មជរូបនោះ; ព្រោះហេតុដូច្នោះ ក្នុងខណៈបដិសន្ធិ រូបកាយរមែងកើតឡើងបាន ដោយអានុភាពរបស់ចិត្ត ប្រៀបដូចជាកាល មានដីស្រែ ទឹក និងដើមឈើ (គ្រាប់ពូជ) រមែងដុះឡើងបាន ដោយអានុភាពនៃគ្រាប់ពូជ ក្នុងកាលកើតឡើងគ្រាដំបូង ។ ទោះបីវៀរចាកចិត្ត កម្មជរូប ក៏រមែងប្រព្រឹត្តទៅបាន ព្រោះកម្មប្រៀបដូចជាគ្រាប់ពូជអស់ហើយ ដើមឈើក៏ចម្រើនធំឡើងបាន ដោយអានុភាពនៃដីនិងទឹកនុ៎ះ

៦៨ ។ សមពិតដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកថា **"*កម្ម* ប្រៀបដូចដីស្រែ, *វិញ្ញាណ* ប្រៀបដូចជាពូជ, *តណ្ហា* ប្រៀបដូចជាជ័រ"**[១៧] ។ ៦ សេចក្ដីនេះ អ្នកសិក្សាគប្បីកាន់យកដោយអំណាចនៃឱកាស(ភូមិ) ប៉ុណ្ណោះ; ពិតមែនហើយ ឱកាសមាន ៣ គឺឱកាសនៃនាម, ឱកាសនៃរូប ឱកាសនៃនាម និងរូប ។ បណ្ដាឱកាសទាំង ៣ នោះ ***អរូបភព*** ឈ្មោះថា ***ឱកាសនៃនាម*** ។ ព្រោះឈ្មោះថា ក្នុងអរូបភពនោះ អរូបធម៌ប៉ុណ្ណោះរមែងកើតឡើង ដោយវៀរនូវរូបជាបច្ច័យ សូម្បីត្រឹមតែហទយវត្ថុ (ក៏ពុំមានដែរ) ។

***អសញ្ញីភព*** ឈ្មោះថា ***ឱកាសនៃរូប;*** ព្រោះថា ក្នុងអសញ្ញីភពនុ៎ះ រូបធម៌រមែងកើតឡើងដោយវៀរនូវនាមជាបច្ច័យ សូម្បីត្រឹមតែបដិសន្ធិចិត្ត (ក៏គ្មានដែរ) ។

***បញ្ចវោការភព*** ឈ្មោះថា ***ឱកាសនៃនាម និងរូប*** ព្រោះក្នុងបញ្ចវោការភពនុ៎ះ ក្នុងបដិសន្ធិកាល បើវៀរត្រឹមតែវត្ថុរូប នាមធម៌រមែងកើតឡើងមិនបាន និងបើវៀរបដិសន្ធិចិត្តចេញ រូបធម៌ដែលកើតអំពីកម្ម រមែងកើតឡើងមិនបានដូចគ្នា, ព្រោះរូបធម៌ និងនាមធម៌ រមែងកើត

---

[១៧] អំ. តិក. ។

ឡើងព្រមគ្នា ។

ម្យ៉ាងទៀត ដូចក្នុងរាជវាំងដែលមានម្ចាស់ក្សាក់សារត្រួតពិនិត្យ គឺមានមនុស្សចាំយាមទ្វារ វៀរចាកពាក្យបញ្ជារបស់ព្រះរាជាចេញហើយនរណាមួយ នឹងចូលមុនមិនបានឡើយ, ប៉ុន្តែក្រោយពីបានទទួលនូវការអនុញ្ញាត ទោះបី ជាវៀរចាកពាក្យបញ្ជា ក៏ចូលទៅបាន ដោយអានុភាពនិងពាក្យបញ្ជា ក្នុងកាលមុនយ៉ាងណា, ក្នុងបញ្ចវោការភព វៀរចាកបដិសន្ធិវិញ្ញាណ ដែលមានសហជាតប្បច្ច័យជាដើមជាបច្ច័យ រូបដែលកើតឡើងគ្រាដំបូង ដោយអំណាចនៃបដិសន្ធិ មិនមាន; ប៉ុន្តែ ខាងក្រោយ បដិសន្ធិកាល សូម្បីវៀរបដិសន្ធិវិញ្ញាណ ដែលមានអានុភាពនៃសហជាតប្បច្ច័យជាដើមជាបច្ច័យចេញ រូបដែលកើតដោយអំណាចនៃកម្មក្នុងកាលមុន រមែងប្រព្រឹត្តទៅបាន ព្រោះតែកម្មនោះឯង ។ ចំណែកអសញ្ញីភព រមែងមិនជាឱកាសនៃអរូប ព្រោះហេតុដូច្នោះ ក្នុងអសញ្ញីភពនោះ វៀរចាកនាមដែលជាបច្ច័យចេញ រូបក៏រមែងប្រព្រឹត្តទៅបាន ព្រោះជាភូមិ (ទីកើត) របស់សត្វដែលមិនមានសញ្ញា ប្រៀបដូចជាផ្ទះទំនេរដែលមិនមានម្ចាស់ ឬផ្ទះរបស់ខ្មួនមនុស្សរមែងចូលទៅបានដូច្នោះ ។ សូម្បីអរូបភព រមែងមិនជាឱកាសនៃរូប ព្រោះហេតុដូច្នោះ ក្នុងអរូបភពនោះ វៀរចាករូបដែលជាបច្ច័យចេញហើយ នាមធម៌រមែងប្រព្រឹត្តទៅបាន ព្រោះជាភូមិរបស់សត្វអ្នកដឹងច្បាស់ ។ ក៏បញ្ចវោការភព ជាឱកាសនៃរូប និងនាម ព្រោះហេតុដូច្នោះ បដិសន្ធិកាល

ក្នុងបញ្ចវោការភពនេះ វៀរចាកនាមដែលជាបច្ច័យហើយ រូបដែលនឹងកើតឡើងបាន រមែងមិនមាន ។ ដោយហេតុនេះ បដិសន្ធិចិត្ត ទើបជាបច្ច័យដល់កម្មជរូបក្នុងបដិសន្ធិកាលប៉ុណ្ណោះ, មិនជាបច្ច័យក្នុងបវត្តិកាល ដូចបានពណ៌នាមកហើយនេះឯងទេ ។

***សួរថា*** កាលព្រះមានព្រះភាគត្រាស់ថា "ហេតុជាបច្ច័យដល់ធម៌ដែលកើតឡើងព្រមគ្នាជាមួយហេតុ ដោយអំណាចនៃហេតុប្បច្ច័យ" សេចក្តីទាំងអស់នេះ ក៏ទ្រង់កាន់យកហើយ មិនមែនឬ ?, កាលបើដូច្នេះ ពាក្យថា "ហេតុ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងរូបដែលមានហេតុនោះ ជាសមុដ្ឋាន" ដូច្នេះនេះ ព្រះអង្គទ្រង់កាន់យកទៀត ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះទ្រង់បដិសេធបច្ច័យនៃកម្មជរូបជាដើម ក្នុងបវត្តិកាល ។ ពិតមែនហើយ កាលបើដូច្នោះ កម្មជរូប និងរូបដែលមានឧតុ និងអាហារជាសមុដ្ឋានពួកណា កើតឡើងក្នុងខណៈមួយ ជាមួយនឹងហេតុក្នុងបវត្តិកាល ហេតុត្រូវជាហេតុប្បច្ច័យដល់រូបទាំងនោះបាន, ប៉ុន្តែថា ហេតុមិនបានជាបច្ច័យដល់រូបទាំងនោះទេ, ព្រោះហេតុដូច្នោះ អ្នកសិក្សា គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកពាក្យនោះផង ក៏ដើម្បីបដិសេធនូវភាវៈនៃហេតុជាបច្ច័យដល់កម្មជរូបជាដើមនោះ (ក្នុងបវត្តិកាល) ។

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យក្នុងហេតុប្បច្ច័យនេះ ដោយអំណាច នៃបទទាំងនេះថា “ **នានប្បការភេទតោ** = ដោយការចែក មានប្រការផ្សេងៗ, **បច្ចយុប្បន្នតោ** = ដោយបច្ចយុប្បន្ន” ដូចតទៅ ៖

បទថា “**នានប្បការភេទតោ**” មានអធិប្បាយថា ឈ្មោះថា ហេតុនេះ ពោលដោយជាតិ មាន ៤ យ៉ាង គឺកុសលជាតិ អកុសលជាតិ វិបាកជាតិ និងកិរិយាជាតិ ។ បណ្ដាជាតិ ៤ យ៉ាងនេះ កុសលហេតុ ពោលតាមលំដាប់នៃភូមិ មាន ៤ ដោយចែកជាកាមាវចរភូមិជាដើម ។

អកុសលហេតុ ជាកាមាវចរតែម្យ៉ាង ។ វិបាកហេតុ មាន ៤ យ៉ាង ដោយចែកជាកាមាវចរជាដើម ។ កិរិយាហេតុ មាន ៣ គឺ កាមាវចរ រូបាវចរ និងអរូបាវចរ ។ បណ្ដាហេតុទាំងនោះ កាមាវចរ-កុសលហេតុ ពោលដោយឈ្មោះ មាន ៣ ដោយអំណាចនៃអលោភហេតុជាដើម ។ សូម្បីក្នុងរូបាវចរកុសលហេតុជាដើម ក៏មានន័យដូចគ្នានេះដែរ ។ អកុសលហេតុ មាន ៣ ដោយអំណាចនៃលោភហេតុជាដើម ។ ចំណែកវិបាកហេតុ កិរិយាហេតុ ម្យ៉ាងៗ មាន ៣ ដោយអំណាចនៃអលោភហេតុជាដើម ។ ចំណែកការចែកហេតុនោះៗ ដោយប្រការផ្សេងៗ រមែងមានដោយអំណាចនៃការប្រកបជាមួយនឹងចិត្តនោះៗ ។ អ្នកសិក្សាគប្បីជ្រាបនូវសេចក្ដីវិនិច្ឆ័យ ដោយប្រការផ្សេងៗ ក្នុងហេតុនេះ ប៉ុណ្ណេះ

សិនចុះ ។

បទថា **“បច្ចយុប្បន្នគោ”** មានសេចក្តីថា អ្នកសិក្សាគប្បីជ្រាបនូវការវិនិច្ឆ័យយ៉ាងនេះថា ធម៌ទាំងនេះ រមែងកើតឡើង ព្រោះបច្ច័យនេះ, ហេតុនោះ បច្ច័យនេះ ទើបឈ្មោះថា ជាបច្ច័យដល់នាមធម៌ទាំងនេះ ។ បណ្តាបច្ច័យទាំងនោះ គប្បីជ្រាបនូវវិនិច្ឆ័យក្នុងហេតុប្បច្ច័យនេះជាមុនសិន ៖

***កាមាវចរកុសលហេតុ*** ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្ត ជាមួយនឹងខ្លួន ព្រមទាំងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងកាមភព និងរូបភពទាំងឡាយ ។ ក្នុងអរូបភព ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។

***រូបាវចរកុសលហេតុ*** ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងកាមភព និងរូបភពប៉ុណ្ណោះ ។

***អរូបាវចរកុសលហេតុ*** ដូចគ្នានឹងកាមាវចរកុសលហេតុទាំងឯង ។

***លោកុត្តរកុសលហេតុ និងអកុសលហេតុ*** ក៏ដូចគ្នាដែរ ។

***ចំណែកកាមាវចរវិបាកហេតុ*** ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងខ្លួន តែក្នុងកាមភពប៉ុណ្ណោះ ជាហេតុប្បច្ច័យដល់កម្មជរូបក្នុងបដិសន្ធិ-កាល និងជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល ។

***រូបាវចរវិបាកហេតុ*** ជាហេតុប្បច្ច័យដល់ធម៌មានប្រការដូចពោល

*ហើយ ក្នុងរូបភពនោះឯង ។* ***អរូបាវចរវិបាកហេតុ*** *ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាក្នុងអរូបភពប៉ុណ្ណោះ ។* ***លោកុត្តរវិបាកហេតុ*** *ជាហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា និងដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងកាមភព និងរូបភព ជាហេតុប្បច្ច័យដល់អរូបធម៌ក្នុងអរូបភពប៉ុណ្ណោះ ។ ចំណែកក្នុង* ***កិរិយាហេតុ*** *មានន័យជាបច្ច័យដូចនឹងកុសលហេតុ ក្នុងភូមិទាំង ៣ ដែរ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងហេតុប្បច្ច័យនេះ ដូចបានពណ៌នាមកដូច្នេះឯង ៕*

ចប់និទ្ទេសនៃហេតុប្បច្ច័យ

## ២.ពណ៌នាអំពីនិទ្ទេសនៃអារម្មណប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបនូវការវិនិច្ឆ័យ* ***ក្នុងនិទ្ទេសនៃអារម្មណប្បច្ច័យ*** *ដូចតទៅនេះ ៖*

*បទថា* **“រូបាយតនំ”** *បានដល់ អាយតនៈ ពោលគឺរូប ។ សូម្បីក្នុងធម៌ដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ បទថា* **“ចក្ខុវិញ្ញាណធាតុយា** *= ដល់ធាតុ គឺចក្ខុវិញ្ញាណ” ។ សូម្បីក្នុងបទដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ បទថា* **“តំសម្បយុត្តកានំ** *= ដល់ខន្ធ ៣ ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ” , អធិប្បាយថា រូបាយតនៈ ជា*

បច្ច័យដល់ខន្ធ ៤ ដែលអាស្រ័យចក្ខុបសាទ សូម្បីទាំងអស់ ដោយអំណាចនៃអារម្មណប្បច្ច័យ ។ ក្នុងធម៌ដទៃក្រៅពីនេះ ក៏មានន័យដូចគ្នានេះដែរ ។

បទថា **“មនោធាតុយា”** សេចក្តីថា អាយតនៈ ៥ មានរូបាយតនៈជាដើម ជាបច្ច័យដល់មនោធាតុទាំង ៣ ព្រមទាំងធម៌ដែលសម្បយុត្តដោយអំណាចនៃអារម្មណប្បច្ច័យ, ប៉ុន្តែ មិនបានប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នាទេ ។ ពីរបទថា **“សព្វេ ធម្មា”** សេចក្តីថា អាយតនៈ ៥ មានរូបាយតនៈជាដើមទាំងនេះផង, ញេយ្យធម៌ទាំងអស់ ដែលនៅសល់ផង ជាបច្ច័យដល់មនោវិញ្ញាណធាតុ ព្រមទាំងធម៌ដែលសម្បយុត្តដ៏សេស វៀរធាតុទាំង ៦ * នេះចេញ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

ដោយពាក្យថា **“យំ យំ ធម្មំ អារព្ភ”** ជាដើមនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ធម៌ពួកណាដែលត្រាស់ថា ជាអារម្មណ៍នៃវិញ្ញាណធាតុទាំង ៧ នេះ, ធម៌ទាំងនោះ ជាអារម្មណប្បច្ច័យដល់ធាតុទាំងនោះ ក្នុងខណៈដែលធ្វើឲ្យជាអារម្មណ៍កើតឡើង ។ សូម្បីធម៌ទាំងនោះ នឹងជាយ៉ាងនោះ ក៏ពិតមែន, ប៉ុន្តែ ក៏មិនបានជាអារម្មណប្បច្ច័យ ក្នុងគ្រាជាមួយគ្នា

---

* បានដល់ វៀរវិញ្ញាណធាតុ ៦ គឺចក្ខុវិញ្ញាណធាតុ ។ល។ មនោវិញ្ញាណធាតុ ។

ឡើយ, ព្រោះថា ធម៌ណាៗ ប្រារព្ធនូវធម៌ណាៗ កើតឡើង, ធម៌នោះៗ ជាអារម្មណប្បច្ច័យដល់ធម៌នោះៗ ចំពោះតែម្យ៉ាងៗ ប៉ុណ្ណោះ ។

បទថា **"ឧប្បជ្ជន្តិ"** អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដូចពាក្យថា "ទឹករមែងហូរទៅ, ភ្នំរមែងតាំងនៅ" ដោយអំណាចនៃការនិយាយក្រសោបទៅដល់កាលទាំងអស់ ។ ដោយបទនោះរមែងសម្រេចសេចក្ដីថា ធម៌ពួកណា ប្រារព្ធនូវធម៌ពួកណា កើតឡើងហើយ, ធម៌ពួកណា ប្រារព្ធនូវធម៌ពួកណា នឹងកើតឡើង, ធម៌ទាំងអស់នោះកើតឡើងហើយ នឹងកើតឡើង ដោយអំណាចនៃអារម្មណប្បច្ច័យប៉ុណ្ណោះ ។ ពាក្យថា **"ចិត្តចេតសិកា ធម្មា"** នេះ ជាការអធិប្បាយដោយសង្ខេបនូវធម៌ដែលព្រះអង្គត្រាស់ទុកថា **"យេ យេ ធម្មា** = ធម៌ទាំងឡាយណាៗ" ។ ពាក្យថា **"តេ តេ ធម្មា"** គឺធម៌ដែលជា អារម្មណ៍ទាំងឡាយនោះៗ ។ ពីរបទថា **"តេសំ តេសំ"** បានដល់ ធម៌ គឺចិត្ត និងចេតសិកទាំងឡាយនោះៗ ។ ពណ៌នាបាលីក្នុងអធិការនេះ មានត្រឹមតែប៉ុណ្ណោះ ។

ឈ្មោះថា អារម្មណ៍នេះ ពោលដោយចំណែកៗ មាន ៦ យ៉ាង គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ។ បណ្ដាអារម្មណ៍ទាំងនោះ អារម្មណ៍ដែលនៅសល់ វៀរបញ្ញត្តិ

ចេញ ពោលដោយភូមិ មាន ៤ គឺកាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ និងលោកុត្តរភូមិ ។ បណ្ដាអារម្មណ៍ដែលរាប់បញ្ចូល ក្នុងភូមិទាំង ៤ នេះ អារម្មណ៍ដែលជាកាមាវចរ មាន ៥ យ៉ាង ដោយចែកជាកុសល អកុសល វិបាក កិរិយា និងរូប ។ ឯអារម្មណ៍ដែលជារូបាវចរ និងអរូបាវចរម្យ៉ាងៗ មាន ៣ ដោយចែកជាកុសល វិបាក និងកិរិយា ។ អារម្មណ៍ដែលជាលោកុត្តរភូមិ មាន ៣ ដោយចែកជាកុសល វិបាក និងនិព្វាន ។ ម្យ៉ាងទៀត អារម្មណ៍ទាំងអស់នេះ មាន ៧ យ៉ាង ដោយចែកជាកុសល អកុសល វិបាក កិរិយា រូប និព្វាន និងបញ្ញត្តិ ។ បណ្ដាអារម្មណ៍ ៧ យ៉ាងនោះ កាលបើពោលដោយភូមិ អារម្មណ៍ដែលជាកុសលមាន ៤, អារម្មណ៍ដែលជាអកុសល ជាកាមាវចរតែម្យ៉ាង, អារម្មណ៍ដែលជាវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤, អារម្មណ៍ដែលជាកិរិយាប្រព្រឹត្តទៅក្នុងភូមិ ៣, រូបប្រព្រឹត្តទៅក្នុងភូមិមួយ គឺជាកាមាវចរភូមិប៉ុណ្ណោះ, សូម្បីនិព្វាន ក៏ប្រព្រឹត្តទៅក្នុងភូមិមួយ គឺលោកុត្តរភូមិប៉ុណ្ណោះ, ដែលជាបញ្ញត្តិផុតចាកភូមិ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ ដោយការចែកមានប្រការផ្សេងៗ ក្នុងអារម្មណប្បច្ច័យនេះ ដូចបានពណ៌នាមកនេះ ។

ក្នុងអារម្មណ៍ដែលផ្សេងគ្នាយ៉ាងនេះ អារម្មណ៍ដែលជាកាមាវចរ-កុសល រមែងជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នោះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា និងរូបាវចរ-

កិរិយា ។ អារម្មណ៍ដែលជារូបាវចរកុសល រមែងជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នោះ ត្រឹមតែ ៥ ពួក គឺវៀរកាមាវចរវិបាក, អារម្មណ៍ដែលជាលោកុត្តរ ជាអារម្មណប្បច្ច័យដល់កុសល និងកិរិយាប៉ុណ្ណោះ ដោយកុសល និងកិរិយានោះ ជាកាមាវចរ និងរូបាវចរ ។ អារម្មណ៍ដែលជាអកុសល រមែងជាបច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល រូបាវចរ-កុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា និងរូបាវចរកិរិយា ។ អារម្មណ៍ដែលជាកាមាវចរវិបាក ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរ-កិរិយា និងរូបាវចរកិរិយា ។ អារម្មណ៍ដែលជារូបាវចរវិបាក រមែងជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៥ នេះ គឺកាមាវចរកុសល រូបាវចរ-កុសល អកុសល កាមាវចរកិរិយា និងរូបាវចរកិរិយា ។ សូម្បីអារម្មណ៍ដែលជាអរូបាវចរវិបាក ក៏ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៥ នេះដែរ ។ អារម្មណ៍ដែលជាលោកុត្តរវិបាក ជាអារម្មណប្បច្ច័យដល់កុសល និងកិរិយាប៉ុណ្ណោះ ដោយកុសល និងកិរិយានោះ ជាកាមាវចរ និងរូបាវចរ ។ អារម្មណ៍ដែលជាកាមាវចរកិរិយា ក៏ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរ-

កិរិយា និងរូបាវចរកិរិយា ។ បណ្ដាធម៌ទាំង ៦ នេះ អារម្មណ៍ដែលជារូបាវចរកិរិយា ក៏ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៥ វៀរកាមាវចរវិបាកចេញ ។ អារម្មណ៍ដែលជាអរូបាវចរកិរិយា ក៏ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺធម៌ទាំង ៥ ពួក (ខាងលើ) នោះ បូកនឹងអរូបាវចរ-កិរិយា ។ អារម្មណ៍ គឺរូប បានដល់ រូបក្ខន្ធដែលមានសមុដ្ឋាន ៤ ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល រូបាវចរកុសល អកុសល កាមាវចរវិបាក កាមាវចរកិរិយា និងរូបាវចរកិរិយា ។ អារម្មណ៍ គឺនិព្វាន ជាអារម្មណប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល រូបាវចរកុសល លោកុត្តរកុសល លោកុត្តរវិបាក កាមាវចរកិរិយា និងរូបាវចរកិរិយា ។

អាចារ្យពួកខ្លះ មិនកាន់យករូបាវចរកុសល និងរូបាវចរកិរិយាទេ; ពាក្យនោះ អ្នកសិក្សាគប្បីពិចារណាដោយកន្លែងដែលត្រូវ និងគួរចុះ ។ ចំណែកអារម្មណ៍ជាបញ្ញត្តិ ដែលមានប្រការផ្សេងៗ ជាអារម្មណប្បច្ច័យដល់ធម៌ ទាំង ៩ នេះ គឺកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣, អកុសល, រូបាវចរវិបាក អរូបាវចរវិបាក និងកិរិយាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បណ្ដាអារម្មណ៍ទាំងនោះ អារម្មណ៍ណាៗ ជាបច្ច័យដល់ធម៌ណា ៗ, ធម៌នោះៗ ឈ្មោះថា ជាបច្ចយុប្បន្ននៃអារម្មណ៍នោះៗ ។ អ្នកសិក្សា គប្បី

*ជ្រាបវិនិច្ឆ័យដោយធម៌ដែលជាបច្ចយុប្បន្នក្នុងអារម្មណប្បច្ច័យ ដូចពណ៌នាមកដូច្នេះឯង ៕*

ចប់និទ្ទេសនៃអារម្មណប្បច្ច័យ

.....................................................................

## ៣.ពណ៌នាអំពីនិទ្ទេសនៃអធិបតិប្បច្ច័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង **និទ្ទេសនៃអធិបតិប្បច្ច័យ** ដូចតទៅ ៖*

*បទថា* “ **ឆន្ទាធិបតិ** ” *បានដល់ អធិបតី គឺឆន្ទៈ ។ ពាក្យថា ឆន្ទាធិបតីនេះ ជាឈ្មោះនៃកត្តុកម្យតាឆន្ទៈ (ឆន្ទៈ គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ) កើតឡើងក្នុងវេលាដែលចិត្តញ៉ាំងឆន្ទៈឲ្យធ្ងន់ ឲ្យជាធំ ។ សូម្បីក្នុងបទដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។*

***សួរថា*** *ព្រោះហេតុអ្វីបានជាក្នុងនិទ្ទេសនៃអធិបតិប្បច្ច័យនេះ ព្រះមានព្រះភាគមិនត្រាស់ថា “អធិបតី ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយអធិបតី ” ដូចក្នុងនិទ្ទេសនៃហេតុប្បច្ច័យដែលត្រាស់ទុកថា “ហេតុ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ” , (តែ) ទ្រង់សម្តែងទេសនាដោយន័យជាដើមថា “ឆន្ទាធិបតី ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយឆន្ទៈឬ ?” ដូច្នេះវិញ ឆ្លើយថា ព្រោះអធិបតីមិនមានក្នុងខណៈជាមួយគ្នា*

ទេ ។ ពិតមែនហើយ ក្នុងន័យមុន ហេតុ ២ ឬ ៣ ជាហេតុប្បច្ច័យក្នុងខណៈជាមួយគ្នាបាន ព្រោះមិនលះឧបការៈ ដោយអត្ថថា ជាឫសគល់ (មូលដ្ឋេន) ។ ប៉ុន្តែ អធិបតីជាឧបការៈ ដោយអត្ថថា ជាធំ (ជេដ្ឋដ្ឋេន) និងធម៌ជាច្រើនដែលឈ្មោះថា ជាធំ ក្នុងខណៈជាមួយគ្នាមិនបាន; ព្រោះហេតុដូច្នោះ ធម៌ពួកនោះ សូម្បីកើតឡើងគ្រាជាមួយគ្នា និងជាអធិបតិ-ប្បច្ច័យ ក្នុងខណៈជាមួយគ្នា ក៏រមែងមិនបាន ព្រោះភាវៈនៃអធិបតិប្បច្ច័យមិនមានក្នុងខណៈជាមួយគ្នានោះទេ ។ ក្នុងនិទ្ទេសនៃអធិបតិប្បច្ច័យនេះ ព្រះមានព្រះភាគទ្រង់សម្តែងដូចដែលពោលមកហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសហជាតាធិបតីយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងអារម្មណាធិបតីទៀត ទើបទ្រង់ផ្តើមពាក្យថា **“យំ យំ ធម្មំ គរុំ កត្វា”** ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **“យំ យំ ធម្មំ”** គឺនូវធម៌ដែលជាអារម្មណ៍ណាៗ ។ ពីរបទថា **“គរុំ កត្វា”** បានដល់ ធ្វើឲ្យធ្ងន់ គឺឲ្យធ្ងន់ណែន ឲ្យជាធម្មជាតិដែលគួរបាន មិនគួរលះបង់ មិនគួរមើលងាយ ដោយអំណាចនៃការគោរព និងការកោតក្រែង ឬដោយអំណាចនៃការពេញចិត្ត ។ ពាក្យថា **“តេ តេ ធម្មា”** គឺធម៌ដែលគួរធ្វើឲ្យធ្ងន់នោះៗ ។ ពាក្យថា **“តេសំ តេសំ”** គឺធម៌ដែលធ្វើឲ្យធ្ងន់ទាំងនោះៗ ។

បទថា **“ អធិបតិប្បច្ចយេន ”** គឺជាបច្ច័យដោយអំណាចនៃអារម្មណាធិបតិ-ប្បច្ច័យ ។ ពណ៌នាបាលីក្នុងអធិការនេះ មានត្រឹមតែប៉ុណ្ណេះ ។

ចំណែកឈ្មោះថា ***អធិបតីនេះ មាន ២ យ៉ាង គឺសហជាតាធិបតី និង អារម្មណាធិបតី*** ។ ក្នុងអធិបតី ២ យ៉ាងនោះ សហជាតាធិបតី មាន ៤ យ៉ាង ដោយអំណាចនៃឆន្ទៈជាដើម ។ ក្នុង ៤ យ៉ាងនោះ ចំពោះអធិបតីមួយៗ កាលបើពោលដោយភូមិ ម្យ៉ាងៗ មាន ៤ មានកាមាវចរភូមិជាដើម ។ បណ្ដាអធិបតីដែលជាកាមាវចរភូមិជាដើមនោះ អធិបតីដែលជាកាមាវចរ មាន ៣ យ៉ាង គឺកុសល អកុសល និងកិរិយា ។ ប៉ុន្តែកាលបើពោលដល់អកុសល រមែងមិនមានវីមំសាធិបតីទេ ។ អធិបតីដែលជារូបាវចរ និងអរូបាវចរ ម្យ៉ាងៗ មាន ២ គឺជាកុសល និងកិរិយា ។ អធិបតីដែលជាលោកុត្តរ មាន ២ យ៉ាង គឺជាកុសល និងវិបាក; ប៉ុន្តែកាលបើពោលដោយជាតិ អារម្មណាធិបតី មាន ៦ យ៉ាង គឺកុសល អកុសល វិបាក កិរិយា រូប និងនិព្វាន ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ក្នុងអធិការនេះ ដូចពណ៌នាមកនេះ ។

ក្នុងសហជាតាធិបតីដែលប្លែកផ្សេងគ្នា ដូចបានពណ៌នាមកហើយនេះ អធិបតី ពោលគឺ ***កាមាវចរកុសល និងកិរិយា*** ជាអធិបតិប្បច្ច័យដល់ធម៌

ដែលសម្បយុត្តជាមួយនឹងខ្លួន និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងវេលាដែលសហជាតធម៌ធ្វើអធិបតីដទៃ មានឆន្ទៈជាដើម ឲ្យជាធំកើតឡើងក្នុងចិត្តុប្បាទ ដែលប្រកបដោយហេតុ ២ និងហេតុ ៣ ។ សូម្បីក្នុងអធិបតីពោលគឺ ***រូបាវចរកុសល និងកិរិយា*** ក៏មានន័យដូចគ្នានេះដែរ ។ ក៏ក្នុងអធិការនេះ បានចំពោះតែអធិបតីដែលជារូបាវចរកុសល និងកិរិយាប៉ុណ្ណោះ; ព្រោះថា ធម៌ទាំងនោះ រមែងកើតឡើង ដោយមិនប្រាសចាកសហជាតាធិបតី ។ ចំណែកអធិបតី ពោលគឺ ***រូបាវចរកុសល និងកិរិយា*** ក៏ដូចគ្នានឹងអធិបតីដែលជារូបាវចរ ក្នុងបញ្ចវោការភពដែរ ។ ប៉ុន្តែ ក្នុងចតុវោការភព រមែងជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។ អធិបតីជាកាមាវចរទាំងអស់ ដែលកើតឡើងក្នុងចតុវោការភពនោះ ក៏ដូចគ្នាដែរ ។ អធិបតីជាលោកុត្តរ ទាំងខាងកុសល ទាំងខាងវិបាក រមែងជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នានឹងរូប ដែលមានចិត្តជាសមុដ្ឋានតែម្យ៉ាង ក្នុងបញ្ចវោការភព ។ ក្នុងចតុវោការភព ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ។

អកុសល ជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្តដោយពិតប្រាកដក្នុងមិច្ឆត្តនិយតចិត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋានក្នុងកាមភព ។

អកុសលដែលជាអនិយតធម៌ (ឲ្យផលមិនច្បាស់លាស់ក្នុងលំដាប់នៃចុតិចិត្ត) ជាអធិបតិប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងរូបដែលមានចិត្ត

ជាសមុដ្ឋានទាំងនោះ ក្នុងវេលាដែលខ្លួនជាអធិបតី ក្នុងកាមភព និងរូបភព ។ ជាអធិបតិប្បច្ច័យ ដល់អរូបធម៌ក្នុងអរូបភពប៉ុណ្ណោះ ។ នេះជាន័យក្នុងសហជាតាធិបតិប្បច្ច័យ ។

**ចំណែកក្នុងអារម្មណាធិបតិប្បច្ច័យ មានអធិប្បាយដូចតទៅនេះ ៖**

កាមាវចរកុសល ជាអារម្មណាធិបតិប្បច្ច័យ ដល់ធម៌ទាំងពីរពួកនេះ គឺកាមាវចរកុសល និងអកុសលដែលសហគតៈដោយលោភៈ ។ ន័យក្នុងអារម្មណាធិបតិប្បច្ច័យដែលជាកុសល សូម្បីក្នុងរូបាវចរ និងអរូបាវចរ ក៏មានន័យដូចគ្នានេះដែរ ។

ចំណែកអារម្មណាធិបតីដែលជាលោកុត្តរកុសល ជាអារម្មណាធិបតិប្បច្ច័យដល់កុសលញ្ញាណសម្បយុត្ត និងកិរិយាញាណសម្បយុត្តដែលជាកាមាវចរ ។ ឈ្មោះថា អារម្មណាធិបតីជាអកុសល ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា ចិត្តុប្បាទដែលសហគតៈដោយលោភចិត្តុប្បាទនោះ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។

ចំណែកអារម្មណាធិបតី ផ្នែកខាងវិបាកដែលជាកាមាវចរ រូបាវចរ និងអរូបាវចរ ជាអារម្មណាធិបតិប្បច្ច័យ ដល់អកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។

អារម្មណាធិបតីដែលជាលោកុត្តរវិបាក ជាអារម្មណាធិបតិប្បច្ច័យដល់មហាកុសលញ្ញាណសម្បយុត្ត និងមហាកិរិយាញាណសម្បយុត្តប៉ុណ្ណោះ ។

*បើពោលដោយប្រភេទដែលជាកាមាវចរជាដើម អារម្មណាធិបតីដែលជាកិរិយាទាំង ៣ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។ អារម្មណាធិបតីដែលជារូបក្ខន្ធ ពោលគឺរូបដែលកើតអំពីសមុដ្ឋានទាំង ៤ ជាអារម្មណាធិបតិប្បច្ច័យដល់អកុសលដែលសហគតៈដោយលោភៈប៉ុណ្ណោះ ។ និព្វាន ជាអារម្មណាធិបតិប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺមហាកុសលញ្ញាណសម្បយុត្ត, មហាកិរិយាញាណសម្បយុត្ត ដែលជាកាមាវចរ, លោកុត្តរកុសល និងលោកុត្តរវិបាក ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយបច្ចុប្បន្នក្នុងអារម្មណាធិបតិប្បច្ច័យនេះ យ៉ាងនេះឯង ៕*

ចប់និទ្ទេសនៃអធិបតិប្បច្ច័យ

............................................................

## ៤.៣ពណ៌នាអំពីនិទ្ទេសនៃអនន្តរប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុង **និទ្ទេសនៃអនន្តរប្បច្ច័យ** ដូចតទៅ ៖*

*បទថា* **“មនោធាតុយា”** *បានដល់ វិបាកមនោធាតុ ។ បទថា* **“មនោវិញ្ញាណធាតុយា”** *បានដល់ អហេតុកវិបាកមនោវិញ្ញាណធាតុ ដែលធ្វើសន្តីរណកិច្ច គឺកិច្ចពិចារណាអារម្មណ៍ ។ តអំពីនោះទៅ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់មនោវិញ្ញាណធាតុ ដែលធ្វើវោដ្ឋព្វនៈ ជវនៈ តទាលម្ពណៈ*

និងភវង្គ, ទើបព្រះអដ្ឋកថាចារ្យត្រាស់សង្ខេបទេសនា ដោយសម្ដែងន័យទុកថា ធាតុទាំងនោះ សូម្បីមិនបានត្រាស់ទុក ក៏ពិតមែន, ប៉ុន្តែ អ្នកសិក្សាគប្បីជ្រាបបានដោយន័យនេះចុះ ។ ក៏ធាតុទាំងនោះ (ធាតុណា) ដែលព្រះមានព្រះភាគទ្រង់សង្ខេបចូលក្នុងន័យទី ៦ មានជាដើមថា **"បុរិមា បុរិមា កុសលា ធម្មា"** អ្នកសិក្សាគប្បីជ្រាបថា ព្រះអដ្ឋមិនត្រាស់ទុកក្នុងអធិការនេះទៀតទេ ។

បណ្ដាបទទាំងនោះ ពីរបទថា **"បុរិមា បុរិមា"** អ្នកសិក្សា គប្បីជ្រាបធម៌ គឺកុសលជវនដែលរលត់ទៅដោយមិនមានចន្លោះ ក្នុងទ្វារទាំង ៦ ។

ពីរបទថា **"បច្ឆិមានំ បច្ឆិមានំ"** បានដល់ ធម៌ គឺអកុសលជវនដែលកើតឡើងជាប់តគ្នាទៅនោះឯង ។ បទថា **"កុសលានំ"** បានដល់ កុសលចិត្តប្រភេទដូចគ្នា ។ ចំណែកបទថា **"អព្យាកតានំ"** នេះ បានដល់ អព្យាក្រឹតដែលជាអនន្តរប្បច្ច័យដល់កុសលនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃតទាលម្ពណៈ ភវង្គ និងផលសមាបត្តិ ដែលកើតក្នុងលំដាប់នៃកុសល ។ បទថា **"អព្យាកតានំ"** ក្នុងអកុសលមូលកៈ បានដល់ អព្យាក្រឹតដែលជាតទាលម្ពណៈ និងភវង្គប៉ុណ្ណោះ ។ បទថា **"អព្យាកតានំ"** ក្នុងអព្យាកតមូលកៈ បានដល់ អព្យាក្រឹតដែលជាកិរិយា និងវិបាកដែលប្រព្រឹត្តទៅដោយអំណាចនៃអាវជ្ជនៈ និងជវនៈ ឬដោយអំណាចនៃភវង្គ ។ ន័យនេះ រមែងប្រើបានសូម្បីក្នុងវីថិចិត្តដែលប្រព្រឹត្តទៅ តាំងអំពីកិរិយាមនោធាតុដែលធ្វើ

វោដ្ឋព្វនកិច្ច រហូតដល់មនោវិញ្ញាណធាតុមែនពិត ។ បទថា **“កុសលានំ”** បានដល់ កុសលជវនដួងទីមួយ ដែលកើតតអំពីវោដ្ឋព្វនចិត្ត ក្នុងបញ្ចទ្វារ និង ដែលកើតតអំពីអាវជ្ជនចិត្តក្នុងមនោទ្វារ ។ សូម្បីក្នុងបទថា **“អកុសលានំ”** ក៏មានន័យដូចគ្នានេះដែរ ។ បទថា **“យេសំ យេសំ”** នេះ ជាគ្រឿង កំណត់ដោយសង្ខេប នូវធម៌ដែលជាអនន្តរប្បច្ច័យទាំងអស់ ។ ពណ៌នាបាលី ក្នុងនិទ្ទេសនៃអនន្តរប្បច្ច័យនេះប៉ុណ្ណេះចុះ ។ ក៏ឈ្មោះថា អនន្តរប្បច្ច័យ នេះ អ្នកសិក្សាគប្បីជ្រាបថា បានដល់ អរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងភូមិ ៤ វៀរនិព្វានចេញ ។ អនន្តរប្បច្ច័យនោះ ចែកដោយអំណាចនៃ ជាតិ បាន ៤ គឺកុសល អកុសល វិបាក និងកិរិយា ។ ក្នុង ៤ ជាតិ នោះ អនន្តរប្បច្ច័យដែលជាកុសល មាន ៤ យ៉ាង គឺជាប្រភេទនៃកាមាវចរ ជាដើម ។ អកុសល ជាកាមាវចរតែម្យ៉ាង ។ វិបាក ប្រព្រឹត្តទៅក្នុងភូមិ ទាំង ៤ ។ ចំណែកអនន្តរប្បច្ច័យដែលជាកិរិយា ប្រព្រឹត្តទៅក្នុងភូមិ ៣ ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ក្នុងអនន្តរ-ប្បច្ច័យ ដូចពណ៌នាមកហើយ ។ ក្នុងអនន្តរប្បច្ច័យដែលចែកបានដូចសម្តែង មកហើយនោះ ***ជាកាមាវចរកុសល*** ជាអនន្តរប្បច្ច័យដល់កាមាវចរកុសល ដែលដូចគ្នានឹងខ្លួនប៉ុណ្ណោះ; ចំណែកកាមាវចរកុសលដែលជាញាណសម្បយុត្ត ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៣ នេះ គឺរូបាវចរកុសល អរូបាវចរកុសល និងលោកុត្តរកុសល ។

***កាមាវចរកុសល*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺកាមាវចរ-វិបាក រូបាវចរវិបាក អរូបាវចរវិបាក និងលោកុត្តរវិបាក ។*

***រូបាវចរកុសល*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៣ នេះ គឺរូបាវចរ-កុសល កាមាវចរវិបាកញាណសម្បយុត្ត និងរូបាវចរវិបាក ។*

***អរូបាវចរកុសល*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ ដោយប្លែកគ្នា គឺវិបាក * ទាំងពីរនោះ និងកុសល * ព្រមទាំងវិបាករបស់ខ្លួន ។ ក្នុងអធិការនេះ កាលបើពោលដោយពិសេស* ***នេវសញ្ញានាសញ្ញាយតន-កុសល*** *ជាអនន្តរប្បច្ច័យដល់លោកុត្តរវិបាក ពោលគឺអនាគាមិផល ។* ***លោកុត្តរកុសល*** *ជាអនន្តរប្បច្ច័យដល់លោកុត្តរវិបាកប៉ុណ្ណោះ ។* ***អកុសល*** *ជាអនន្តរប្បច្ច័យដល់អកុសល កុសលវិបាក និងអកុសលវិបាក ដោយមិនប្លែកគ្នាទេ ។ កាលបើពោលដោយប្លែកគ្នា ក្នុងអធិការនេះ អកុសលដែលសម្បយុត្តដោយសុខវេទនា និងឧបេក្ខាវេទនា ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺកុសលវិបាក អកុសលវិបាក រូបាវចរវិបាក និងអរូបាវចរវិបាក ។*

---

* កាមវិបាក និងរូបវិបាក ។

* អរូបកុសល និងអរូបវិបាក ។

***កាមាវចរវិបាក*** *ជាអនន្តរប្បច្ច័យដល់កាមាវចរវិបាក, វិបាកជាញាណសម្បយុត្ត ឬញាណវិប្បយុត្ត ជាអនន្តរប្បច្ច័យដល់កាមាវចរកិរិយាអាវជ្ជនចិត្ត ។*

*ម្យ៉ាងទៀត ក្នុងអនន្តរប្បច្ច័យនេះ* ***មហាវិបាកញាណសម្បយុត្ត*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺកាមាវចរវិបាក អាវជ្ជនចិត្ត រូបាវចរវិបាក និងអរូបាវចរវិបាក ដែលកើតឡើងដោយអំណាចនៃបដិសន្ធិ ។*

***រូបាវចរវិបាក*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺសហេតុកកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក និងកាមាវចរកិរិយាអាវជ្ជនចិត្ត ។*

***អរូបាវចរវិបាក*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៣ នេះ គឺតិហេតុកកាមាវចរវិបាក អរូបាវចរវិបាក និងកិរិយាអាវជ្ជនចិត្តដែលជាកាមាវចរ ។*

***លោកុត្តរវិបាក*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺតិហេតុកកាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក និងលោកុត្តរវិបាក ។*

***កាមាវចរកិរិយា*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៩ នេះ គឺកាមាវចរកុសល អកុសល វិបាកចិត្តទាំង ៤ ភូមិ និងកិរិយាចិត្តទាំង ៣ ភូមិ ។*

***រូបាវចរកិរិយា*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៣ នេះ គឺតិហេតុកកាមាវចរវិបាក រូបាវចរវិបាក និងរូបាវចរកិរិយា ។*

***អរូបាវចរកិរិយា*** *ជាអនន្តរប្បច្ច័យដល់ធម៌ទាំង ៥ នេះ គឺតិហេតុក-កាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាក លោកុត្តរវិបាក និង អរូបាវចរកិរិយា ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយធម៌ ដែលជាបច្ចយុប្បន្នៈ និងក្នុងអនន្តរប្បច្ច័យនេះ យ៉ាងនេះចុះ ៕*

ចប់និទ្ទេសនៃអនន្តរប្បច្ច័យ

## ៥.ពណ៌នាអំពីនិទ្ទេសនៃសមនន្តរប្បច្ច័យ

*និទ្ទេសនៃ* ***សមនន្តរប្បច្ច័យ*** *ដូចគ្នានឹងអនន្តរប្បច្ច័យនេះដែរ ។ ក៏ បច្ច័យទាំង ២ នេះ ទូលំទូលាយណាស់, ព្រោះហេតុដូច្នោះ គប្បីកំណត់ កាន់យកសេចក្តីពិស្តារនៃបច្ច័យទាំង ២ នោះ ដោយអំណាចនៃការកើត ឡើងរបស់ចិត្តទាំងអស់ចុះ ៕*

ចប់និទ្ទេសនៃសមនន្តរប្បច្ច័យ

## ៦.ពណ៌នាអំពីនិទ្ទេសនៃសហជាតប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***សហជាតប្បច្ច័យ*** *តទៅ ៖*

*បទថា* **“អញ្ញមញ្ញំ** *= ដល់គ្នានឹងគ្នា” ។ ក្នុងបទនេះ ព្រះមាន ព្រះភាគទ្រង់សម្តែងថា* ***“ធម៌ទាំងនោះ ជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុង***

*ខណៈជាមួយគ្នា"* ។ បទថា **"ឱក្កន្តិក្ខណេ"** គឺក្នុងខណៈបដិសន្ធិ ក្នុងបញ្ចវោការភព ។ ពិតមែនហើយ ក្នុងខណៈនោះ នាម និងរូបកើតឡើង ដូចឈានចុះ គឺដូចរត់ទៅ បានដល់ ដូចមកអំពីលោកដទៃ ហើយចូលមកកាន់លោកនេះ ព្រោះហេតុដូច្នោះ ខណៈនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **"ឱក្កន្តិក្ខណេ** = ខណៈឈានចុះ" ។ ក្នុងអធិការនេះ ពាក្យថា ***"រូប"*** ព្រះមានព្រះភាគទ្រង់សំដៅយកហទយវត្ថុប៉ុណ្ណោះ ។ ពិតណាស់ ហទយវត្ថុនោះ រមែងផ្តល់ប្រយោជន៍ ដើម្បីជាសហជាតប្បច្ច័យនូវគ្នានឹងគ្នាដល់នាម, ឯនាម ក៏ផ្តល់ប្រយោជន៍ដើម្បីជាសហជាតប្បច្ច័យនូវគ្នានឹងគ្នា ដល់ហទយវត្ថុនោះ ។ បទថា **"ចិត្តចេតសិកា"** គឺខន្ធ ៤ ក្នុងបវត្តិកាល ។ ក្នុងបទថា **"សហជាតប្បច្ចយេន"** នេះ រូបដែលមានចិត្តជាសមុដ្ឋាន រមែងមិនផ្តល់ប្រយោជន៍ដើម្បីជាបច្ច័យដល់ចិត្ត និងចេតសិកទេ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា **"អញ្ញមញ្ញំ"** ដូច្នេះឡើយ ។ ឧបាទាយរូប ក៏មិនផ្តល់ប្រយោជន៍ដើម្បីជាបច្ច័យដល់មហាភូតរូបដូចគ្នាដែរ ។ ពាក្យថា ***"រូបធម៌ជាបច្ច័យដល់អរូបធម៌"*** គឺហទយវត្ថុ ជាបច្ច័យដល់នាមខន្ធ ៤ ។ ពីរបទថា **"កិញ្ចិ កាលេ"** គឺក្នុងកាលគ្រាខ្លះ ។ បទថា **"សហជាតប្បច្ចយេន"** ទ្រង់ត្រាស់សំដៅដល់

បដិសន្ធិកាល ។ បទថា **“នសហជាតបច្ចយេន”** ទ្រង់ត្រាស់សំដៅដល់ បវត្តិកាល ។

សហជាតបច្ច័យនេះ តាំងទុកដោយចំណែក ៦ ដូច្នេះ គឺនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសហជាតបច្ច័យជាដើម ។ ក្នុង ៦ ចំណែកនោះ ៣ ចំណែកត្រាស់ដោយអំណាចជា ***សហជាតបច្ច័យ*** ដល់គ្នានឹងគ្នា, ៣ ចំណែកទៀត មិនបានត្រាស់ដោយអំណាចជាសហជាត-បច្ច័យដល់គ្នានឹងគ្នាឡើយ ។

បណ្ដាសហជាតបច្ច័យ ៦ ចំណែកនោះ មានតែអរូបធម៌ប៉ុណ្ណោះ ជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុងចំណែកទី ១ ។

ចំពោះរូបធម៌តែម្យ៉ាង ជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុងចំណែកទី ២ ។

នាម និងរូប ជាបច្ច័យ និងជាបច្ចយុប្បន្នក្នុងចំណែកទី ៣ ។

អរូប ជាបច្ច័យ, រូប ជាបច្ចយុប្បន្ន ក្នុងចំណែកទី ៤ ។

រូបប៉ុណ្ណោះ ជាបច្ច័យ និងជាបច្ចយុប្បន្ន ក្នុងចំណែកទី ៥ ។

រូប ជាបច្ច័យ, អរូប ជាបច្ចយុប្បន្ន ក្នុងចំណែកទី ៦ ។

ពណ៌នាបាលីក្នុងសហជាតបច្ចយនិទ្ទេសមានប្រមាណប៉ុណ្ណោះ ។

សហជាតប្បច្ច័យនេះ ចែកដោយជាតិ មាន ៥ ជាតិ គឺកុសលជាតិ អកុសលជាតិ វិបាកជាតិ កិរិយាជាតិ និងរូបជាតិ ។ ក្នុងជាតិទាំង ៥ នោះ កុសលចាត់តាមភូមិ មាន ៤ ភូមិ, អកុសល មាន ១ ភូមិ, វិបាក មាន ៤ ភូមិ, កិរិយា មាន ៣ ភូមិ, រូប មានតែកាមាវចរភូមិម្យ៉ាងប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងសហជាតប្បច្ច័យនេះ ដោយការចែកជាប្រការផ្សេងៗ ត្រឹមតែប៉ុណ្ណេះ ។

ក្នុងសហជាតប្បច្ច័យដែលចែកហើយយ៉ាងនេះ សូម្បីកុសលប្រព្រឹត្តទៅបាន ៤ ភូមិ ជាសហជាតប្បច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួននោះឯង និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ អកុសល ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងសហជាតប្បច្ច័យនេះ ចិត្តណា កើតក្នុងអរូបភូមិ, ចិត្តនោះ ជាសហជាតប្បច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ៕

***កាមាវចរវិបាក និងរូបាវចរវិបាក*** ជាសហជាតប្បច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋានន៉ុះឯង និងដល់ធម៌ដែលសម្បយុត្តគ្នា ។ ក្នុងសហជាតប្បច្ច័យនេះ ចិត្តណា ឲ្យរូបកើតមិនបាន, ចិត្តនោះ ជាសហជាតប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។ ចិត្តណា កើតឡើងក្នុងបដិសន្ធិកាល, ចិត្តនោះ ជាសហជាតប្បច្ច័យដល់កម្មជរូបដែរ ។ ***អរូបាវចរវិបាក*** ជាសហជាតប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។

***លោកុត្តរវិបាក*** ជាសហជាតប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងរូប ដែលមានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភព, ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។ ***កាមាវចរកិរិយា និងអរូបាវចរកិរិយា*** ជាសហជាតប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងរូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ។ ក្នុងចតុវោការភព ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ។ ***រូបាវចរកិរិយា*** ជាសហជាតប្បច្ច័យដោយចំណែកមួយ ដល់ធម៌ដែលសម្បយុត្តនឹងរូប ដែលមានចិត្តជាសមុដ្ឋាន ។ ចំពោះរូបដែលកើតឡើងអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលមានកម្មជាសមុដ្ឋាន មហាភូតរូប ១ ជាបច្ច័យដោយសហជាតប្បច្ច័យដល់មហាភូតរូប ៣, មហាភូតរូប ៣ ជាបច្ច័យដោយសហជាតប្បច្ច័យដល់មហាភូតរូប ១, មហាភូតរូប ២ ជាបច្ច័យដោយសហជាតប្បច្ច័យដល់មហាភូតរូប ២, មហាភូតរូប ជាបច្ច័យដល់ឧបាទាយរូប ដោយអំណាចនៃសហជាតប្បច្ច័យ ។ ក្នុងខណៈបដិសន្ធិរបស់កាមាវចរ និងរូបាវចរ វត្ថុរូបជាបច្ច័យដល់វិបាកក្ខន្ធ ដោយអំណាចនៃសហជាតប្បច្ច័យដែរ ។ ចំណែកក្នុងរូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន មហាភូតរូបជាបច្ច័យដល់គ្នានឹងគ្នា និងដល់ឧបាទាយរូបដោយអំណាចនៃសហជាតប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងសហជាតប្បច្ច័យនេះ យ៉ាងនេះចុះ ៕

ចប់និទ្ទេសនៃសហជាតប្បច្ច័យ

## ៧. ពណ៌នាអំពីនិទ្ទេសនៃអញ្ញមញ្ញបច្ច័យ

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ ***អញ្ញមញ្ញបច្ច័យ*** តទៅ ៖

ព្រះបាលីមានមកហើយ ដោយអំណាចនៃចំណែកបីខាងដើម របស់សហជាតបច្ចយនិទ្ទេស, ការពណ៌នាបាលីនោះ ដូចគ្នានឹងការដែលបានពោលហើយ ក្នុងសហជាតបច្ចយនិទ្ទេសនុ៎ះឯង ព្រោះហេតុដូច្នោះ ទើបខ្ញុំមិនកាន់យកទៀតឡើយ ។

អញ្ញមញ្ញបច្ច័យនេះ ពោលដោយអំណាចនៃជាតិ បែកចេញបាន ៥ គឺកុសល អកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនេះ កុសលពោលដោយភូមិ មាន ៤ យ៉ាង ។ អធិប្បាយទាំងអស់ ដូចគ្នានឹងសហជាតបច្ច័យខាងលើដែរ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ ដោយការបែក មានប្រការផ្សេងៗ ក្នុងអញ្ញមញ្ញបច្ចយនិទ្ទេសនេះ ដូចបានពណ៌នាមកហើយ ។

ក្នុងអញ្ញមញ្ញបច្ច័យដែលបែកហើយយ៉ាងនេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួន ដោយអំណាចនៃអញ្ញមញ្ញបច្ច័យ ។ អកុសល ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកក្នុងវិបាក ***កាមាវចរវិបាក និងរូបាវចរវិបាក*** ជាអញ្ញមញ្ញបច្ច័យដល់វត្ថុរូប ក្នុងបដិសន្ធិកាល, ជាអញ្ញមញ្ញបច្ច័យដល់សម្បយុត្តធម៌ ក្នុង

*បវត្តិកាល ។ **អរូបាវចរវិបាក និងលោកុត្តរវិបាក** ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួនប៉ុណ្ណោះ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ។ សូម្បីកិរិយាចិត្តទាំងអស់ ក៏ជាអញ្ញមញ្ញប្បច្ច័យដល់ធម៌ ដែលសម្បយុត្តគ្នាប៉ុណ្ណោះដែរ, ចំពោះរូបដែលកើតអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលកើតអំពីកម្ម មហាភូតរូប ១ ជាបច្ច័យដល់មហាភូតរូប ៣ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ, មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ, មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ។ ក្នុងខណៈបដិសន្ធិរបស់កាមាវចរនិងរូបាវចរ វត្ថុរូបជាបច្ច័យដល់វិបាកក្ខន្ធ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ។ ក្នុងរូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន មហាភូតរូបប៉ុណ្ណោះ ជាបច្ច័យដល់មហាភូតរូប ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យសូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអញ្ញមញ្ញប្បច្ច័យនេះ ដូច្នេះឯង ៕*

## ចប់និទ្ទេសនៃអញ្ញមញ្ញប្បច្ច័យ

## ៤.ពណ៌នាអំពីនិទ្ទេសនៃនិស្សយប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***និស្សយប្បច្ច័យ*** *តទៅ ៖*

*ព្រះមានព្រះភាគ កាលទ្រង់សម្ដែងន័យរបស់សហជាតនិស្សយ-ប្បច្ច័យ ដោយអំណាចនៃចំណែកទី ៥ ខាងដើម របស់សហជាតប្បច្ចយ-និទ្ទេសរួចហើយ ដើម្បីនឹងទ្រង់សម្ដែងន័យរបស់បុរេជាតនិស្សយប្បច្ច័យ ដោយចំណែកទី ៦ ទៀត ទើបផ្ដើមពាក្យថា* **“ចក្ខាយតនំ ចក្ខុវិញ្ញាណ-ធាតុយា”** *ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា* **“យំ រូបំ និស្សាយ”** *ព្រះមានព្រះភាគត្រាស់សំដៅដល់វត្ថុរូប ។ ពិតមែនហើយ ចិត្តទាំង ៧៥ នោះ គឺមនោធាតុ ៣ មនោវិញ្ញាណធាតុ ៧២ វៀរអរូបវិបាកចេញ អាស្រ័យហទយវត្ថុនោះប្រព្រឹត្តទៅ ។ ពណ៌នាបាលីក្នុងអធិការនេះ មានត្រឹមតែប៉ុណ្ណេះ ។*

*និស្សយប្បច្ច័យពោលដោយអំណាចនៃជាតិ ចែកចេញជា ៥ ជាតិ មានកុសលជាតិជាដើម ។ ក្នុង ៥ យ៉ាងនោះ កុសលពោលដោយភូមិ មាន ៤, អកុសល មានតែភូមិមួយប៉ុណ្ណោះ, វិបាក មាន ៤ ភូមិ, កិរិយា មាន ៣ ភូមិ, រូប មានភូមិ ១ ប៉ុណ្ណោះ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ក្នុងនិស្សយប្បច្ច័យនេះ ដូចពណ៌នាមកនេះហើយ ។*

ក្នុងនិស្សយប្បច្ច័យដែលចែកហើយយ៉ាងនេះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តគ្នា និងរូបដែលមានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភព ដោយអំណាចនៃនិស្សយប្បច្ច័យ ។ អកុសលក៏មានន័យដូចគ្នានេះដែរ ។ ក្នុងនិស្សយប្បច្ច័យនេះ ចិត្តណាកើតឡើងក្នុងអរូបភព, ចិត្តនោះ ជានិស្សយប្បច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ។

***កាមាវចរវិបាក និងរូបាវចរវិបាក*** ជានិស្សយប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា និងរូបដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល, ជានិស្សយ-ប្បច្ច័យដល់កម្មជរូបក្នុងបដិសន្ធិកាល ។ ***អរូបាវចរវិបាក*** ជានិស្សយប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។ ***លោកុត្តរវិបាក*** ជានិស្សយប្បច្ច័យដល់ធម៌ដែលសម្បយុត្ត និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការ-ភព, ជានិស្សយប្បច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។

***កាមាវចរកិរិយា និងអរូបាវចរកិរិយា*** ជានិស្សយប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា និងរូបដែលមានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភព ។ ជា បច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ក្នុងចតុវោការភព ។ ***រូបាវចរកិរិយា*** ជានិស្សយប្បច្ច័យដោយចំណែកមួយ ដល់ធម៌ដែលសម្បយុត្តគ្នា និងរូបដែលមានចិត្តជាសមុដ្ឋានក្នុងបញ្ចវោការភព ។

ចំពោះរូបដែលកើតអំពីសមុដ្ឋានទាំង ៤ ក្នុងរូបដែលមានកម្មជា

*សមុដ្ឋាន មហាភូតរូប ១ ជានិស្សយប្បច្ច័យដល់មហាភូតរូប ៣, មហាភូតរូប ៣ ជានិស្សយប្បច្ច័យដល់មហាភូតរូប ១, មហាភូតរូប ២ ជានិស្សយប្បច្ច័យដល់មហាភូតរូប ២, មហាភូតរូប ជានិស្សយប្បច្ច័យដល់ឧបាទាយរូប, ក្នុងបញ្ចវោការភព វត្ថុរូប ជានិស្សយប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺកុសលក្នុងភូមិទាំង ៤, អកុសល, វិបាកក្នុងភូមិ ៣ ដ៏សេស វៀរអរូបវិបាក ទុំបញ្ចវិញ្ញាណចិត្តចេញ និងកិរិយាក្នុងភូមិ ៣ ។*

*អាយតនៈ ៥ មានចក្ខាយតនៈជាដើម ជានិស្សយប្បច្ច័យដល់វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ព្រមទាំងសម្បយុត្តធម៌ ។ ចំណែកក្នុងរូបដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន មហាភូតរូបជាបច្ច័យដល់មហាភូតរូប និងជាបច្ច័យដល់ឧបាទាយរូប ដោយអំណាចនៃនិស្សយប្បច្ច័យ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្នក្នុងនិស្សយប្បច្ច័យនេះ ដូច្នេះចុះ ៕*

ចប់និទ្ទេសនៃនិស្សយប្បច្ច័យ

..........................................

## ៩.ពណ៌នាអំពីនិទ្ទេសនៃឧបនិស្សយប្បច្ច័យ

*អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ឧបនិស្សយប្បច្ច័យ*** *ដូចតទៅ ៖*

ពាក្យថា **“បុរិមា បុរិមា** = *កើតមុនៗ”* សេចក្ដីថា រមែងបានធម៌ដែលរលត់ទៅមុន ក្នុងលំដាប់ដោយល្អក្នុងអនន្តរូបនិស្សយប្បច្ច័យ ។ ធម៌ដែលកើតមុន រមែងបានដោយអំណាចនៃវីថិផ្សេងគ្នា ក្នុងអារម្មណូប-និស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ បច្ច័យទាំងបីនោះ (គឺឧបនិស្សយៈទាំងឡាយ) រមែងបានក្នុងកុសលបទ ដោយកុសលបទ ។ ចំណែក ***ធម៌ដែលរលត់ទៅមុនក្នុងលំដាប់ដោយល្អ*** រមែងមិនបានក្នុងអកុសលបទ ជាមួយនឹងកុសលបទទេ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា “កុសលធម៌ ជាបច្ច័យដល់អកុសលធម៌ ដោយអំណាចនៃឧបនិស្សយប្បច្ច័យប្រភេទខ្លះ” ។ ពិតមែនហើយ ពាក្យនេះព្រះមានព្រះភាគទ្រង់ត្រាស់សំដៅដល់ន័យនេះថា “កុសលធម៌ ជាបច្ច័យដល់អកុសលធម៌ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ គឺអារម្មណូប-និស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។

ដែលជា ***អារម្មណូបនិស្សយប្បច្ច័យ*** បានដល់ បុគ្គលឲ្យទានសមាទានសីល រក្សាឧបោសថ រមែងត្រេកអររីករាយយ៉ាងខ្លាំងក្លា កាលត្រេកអររីករាយយ៉ាងខ្លាំងក្លាហើយ សេចក្ដីស្រើបស្រាល (រាគៈ) រមែងកើតឡើង, ទិដ្ឋិរមែងកើតឡើង, រមែងត្រេកអររីករាយនូវកម្មដែលធ្លាប់ប្រព្រឹត្តមកអំពីមុន, កាលត្រេកអររីករាយយ៉ាងខ្លាំងហើយ សេចក្ដីស្រើប

ស្រោលរមែងកើតឡើង, ទិដ្ឋិរមែងកើតឡើង; បុគ្គលចេញចាកឈាន រមែងត្រេកអររីករាយចំពោះឈាននោះយ៉ាងធ្ងន់, កាលត្រេកអររីករាយយ៉ាងធ្ងន់ រាគៈរមែងកើតឡើង, ទិដ្ឋិរមែងកើតឡើង ។

ដែលជា ***បកតូបនិស្សយប្បច្ច័យ*** បានដល់ បុគ្គលចូលទៅអាស្រ័យសទ្ធា ញ៉ាំងមានះឲ្យកើតឡើង, ប្រកាន់មាំនូវទិដ្ឋិ; អាស្រ័យសីលៈ សុតៈ ចាគៈ និងបញ្ញា ញ៉ាំងមានះឲ្យកើតឡើង, ប្រកាន់មាំនូវទិដ្ឋិ; សទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា ជាបច្ច័យដល់រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងការប្រាថ្នា ដោយអំណាចនៃឧបនិស្សយប្បច្ច័យ” ។ ធម៌ពួកបីរមែងបានក្នុងអព្យាកតបទជាមួយនឹងកុសលបទ; ក្នុងអកុសលបទជាមួយនឹងអកុសលបទ ក៏មានន័យដូចគ្នានេះដែរ ។ ប៉ុន្តែ ធម៌ដែលរលត់ទៅមុនដោយមិនមានចន្លោះយ៉ាងល្អ រមែងមិនបានក្នុងកុសលបទជាមួយនឹងអកុសលបទទេ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ***“អកុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយអំណាចនៃឧបនិស្សយប្បច្ច័យប្រភេទខ្លះ”*** ។ ពិតមែនហើយ ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សំដៅដល់បកតូបនិស្សយប្បច្ច័យប៉ុណ្ណោះ ដែលមានមកហើយក្នុងបញ្ហាវារៈដោយន័យជាដើមថា ***“អកុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយ***

*អំណាចនៃឧបនិស្សយប្បច្ច័យ”* ។

*ដែលជា **បកតូបនិស្សយប្បច្ច័យ** បានដល់ បុគ្គលអាស្រ័យ រាគៈ រមែងឲ្យទាន, សមាទានសីល, រក្សាឧបោសថ, ញុំាងឈាន, វិបស្សនា, មគ្គ, អភិញ្ញា និងសមាបត្តិ ឲ្យកើតឡើង; ចូលទៅអាស្រ័យទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្ដីប្រាថ្នា ទើបឲ្យទាន ។ ល ។ ទើបឲ្យសមាបត្តិកើតឡើង; រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងការប្រាថ្នា ជាបច្ច័យដល់ សទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ។ បុគ្គលកាលសម្លាប់សត្វហើយ រមែងឲ្យទានដើម្បីលុបលាងនូវកម្មចេញ”* ។

*ប៉ុន្តែ អកុសល មិនជាអារម្មណូបនិស្សយប្បច្ច័យដល់កុសលទេ ។*

***សួរថា** ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះសភាវៈនៃកុសលនោះ នឹងធ្វើអកុសលនោះ ឲ្យមានកម្លាំងខ្លាំងហើយប្រព្រឹត្តទៅមិនបាន (កុសលនឹងធ្វើអកុសលឲ្យជាអារម្មណាធិបតីមិនបាន) ។ ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបថា អនន្តរូបនិស្សយប្បច្ច័យ រមែងមិនបានដូចអារម្មណូបនិស្សយប្បច្ច័យដែរ ។ ក្នុងអព្យាកតបទ និងអកុសលបទ រមែងមិនបានចំពោះអារម្មណូបនិស្សយប្បច្ច័យឡើយ ។ ព្រោះថា អព្យាកតធម៌រមែងមិនធ្វើអកុសលឲ្យជាអារម្មណ៍យ៉ាងធ្ងន់ឡើយ ។ ព្រោះមានលក្ខណៈជាអនន្តរប្បច្ច័យ, ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ ទើបព្រះមានព្រះភាគមិនទ្រង់ត្រាស់ថា **“ភេសជ្ជំ”***

*ទេ ។ ប៉ុន្តែ ឧបនិស្សយប្បច្ច័យទាំងបី រមែងបានក្នុងន័យបី គឺក្នុង អព្យាកតបទ ជាមួយនឹងអព្យាកតបទ, កុសលបទ ជាមួយនឹងអព្យាកតបទ, អកុសលបទ ជាមួយនឹងអព្យាកតបទ ។ ពីរបទនេះ គឺ* **បុគ្គលោបិ សេនាសនម្បិ** *ពោលគឺបុគ្គលក្តី សេនាសនៈក្តី ព្រះមានព្រះភាគទ្រង់ត្រាស់ ដោយអំណាចនៃបកតូបនិស្សយប្បច្ច័យ ។ ពិតមែនហើយ បុគ្គល និង សេនាសនៈទាំងពីរនេះ ជាបច្ច័យដ៏មានកម្លាំង ដល់ការប្រព្រឹត្តទៅនៃ* ***កុសល និងអកុសល*** *។ ឯភាវៈនៃបុគ្គល និងសេនាសនៈនោះ ជាបច្ច័យក្នុងអធិការ នេះ អ្នកសិក្សា គប្បីជ្រាបដោយអំណាចនៃបច្ច័យដោយអមៗ ។ ពណ៌នា បាលី ក្នុងឧបនិស្សយប្បច្ច័យនេះ មានតែប៉ុណ្ណេះ ។*

*ក៏ឈ្មោះថា* ***ឧបនិស្សយប្បច្ច័យ*** *បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុង ភូមិ ៤ ទាំងអស់ ព្រមជាមួយនឹងបញ្ញត្តិប្រភេទខ្លះ ។ ប៉ុន្តែ កាលបើពោល ដោយវិភាគ មាន ៣ យ៉ាង ដោយអំណាចនៃអារម្មណូបនិស្សយប្បច្ច័យ ជាដើម ។ បណ្តាឧបនិស្សយប្បច្ច័យ ៣ យ៉ាងនោះ* ***អារម្មណូបនិស្សយ-ប្បច្ច័យ មិនប្លែកផ្សេងអំពីអារម្មណាធិបតិប្បច្ច័យទេ*** *ព្រោះហេតុដូច្នោះ អ្នកសិក្សា គប្បីកាន់យកដោយការចែកមានប្រការផ្សេងៗ តាមន័យ ដែលខ្ញុំពោលហើយអំពីខាងដើមនោះឯង,* ***អនន្តរូបនិស្សយប្បច្ច័យ មិនផ្សេង អំពីអនន្តរប្បច្ច័យទេ,*** *សូម្បីអនន្តរូបនិស្សយប្បច្ច័យនោះ អ្នកសិក្សាគប្បី*

កាន់យកដោយការចែកមានប្រការផ្សេងៗ តាមន័យដែលខ្ញុំពោលហើយក្នុងខាងដើមដូចគ្នាចុះ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ននៃបច្ច័យទាំងពីរនោះ តាមន័យដែលខ្ញុំពោលទុកហើយក្នុងអធិបតិប្បច្ច័យ និងអនន្តរប្បច្ច័យទាំងនោះឯង ។ ក៏កាលបើពោលដោយអំណាចនៃជាតិ ***បកតូបនិស្សយប្បច្ច័យ មាន ៥ យ៉ាង*** គឺកុសលជាតិ អកុសលជាតិ វិបាកជាតិ កិរិយាជាតិ និងរូបជាតិ ។ ឯបកតូបនិស្សយ-ប្បច្ច័យដែលចែកដោយអំណាចនៃជាតិ មានកុសលជាតិជាដើម បើពោលដោយប្រភេទនៃធម៌ដែលកើតក្នុងភូមិផ្សេងៗ ហើយ មានច្រើនណាស់ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងឧបនិស្សយប្បច្ច័យយ៉ាងនេះសិនចុះ ។

ក្នុង ***បកតូបនិស្សយប្បច្ច័យ*** ដែលបានចែកហើយ ដូចខ្ញុំពោលមកនេះ, កុសលដែលប្រព្រឹត្តទៅក្នុងភូមិបី ជាបកតូបនិស្សយប្បច្ច័យដល់ធម៌ទាំង ៤ នេះ គឺដល់កុសលក្នុងភូមិ ៤, អកុសល, វិបាក និងកិរិយា ។ លោកុត្តរធម៌ មិនមែនជាបកតូបនិស្សយប្បច្ច័យដល់អកុសលធម៌តែម្យ៉ាងទេ ។ ប៉ុន្តែ ជាបច្ច័យដល់អកុសលរបស់បុគ្គលដទៃបាន ដោយន័យថា "លោកុត្តរធម៌ដែលអាចារ្យរបស់ខ្ញុំឲ្យកើតឡើងហើយ" ជាដើម, ឬដោយន័យនេះថា "លោកុត្តរធម៌នឹងកើតឡើងដល់បុគ្គលណា, ព្រោះញុំាងសេចក្តី

*ឬសូម្បីឲ្យកើតឡើងក្នុងវិមោក្ខដ៏កំពូលរបស់បុគ្គលនោះ អកុសលធម៌ជាបកតូប-និស្សយប្បច្ច័យដល់ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់" ។ ម្យ៉ាងទៀត វិបាកដែលប្រព្រឹត្តទៅក្នុងភូមិបី ក៏ជាបកតូបនិស្សយប្បច្ច័យដល់ខន្ធ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដូចគ្នាដែរ ។ ក្នុង* ***លោកុត្តរវិបាក*** *ផលខាងក្រោយបីមិនមែនជាបកតូបនិស្សយប្បច្ច័យដល់អកុសលប៉ុណ្ណោះទេ ។ ផលខាងលើគឺអរហត្តផល ក៏មិនមែនជាបកតូបនិស្សយប្បច្ច័យ សូម្បីដល់កុសលឡើយ ។ តាមន័យមុននុ៎ះឯង លោកុត្តរធម៌ដែលកើតដល់បុគ្គលណាមួយ, លោកុត្តរវិបាកទាំងអស់ ក្នុងសន្តានរបស់បុគ្គលនោះ ជាបកតូបនិស្សយ-ប្បច្ច័យ ដល់អរូបក្ខន្ធ មានកុសលជាដើមទាំងអស់ ។ បកតូបនិស្ស័យពោលគឺកិរិយា ជាបច្ច័យដល់ខន្ធ មានអកុសលក្ខន្ធជាដើម ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បកតូបនិស្ស័យ គឺរូប ក៏មានន័យដូចគ្នានេះដែរ ។ ប៉ុន្តែ* ***រូប*** *ខ្លួនឯង មិនបានជាឧបនិស្សយប្បច្ច័យ តាមន័យដែលមានមកហើយក្នុងមហាបករណ៍ ឈ្មោះថា បដ្ឋាននេះទេ ។ បើតាមបរិយាយដែលមានមកហើយក្នុងព្រះសូត្រ ក៏គួរ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយធម៌ដែលជាបច្ចុប្បន្ន ក្នុងឧបនិស្សយប្បច្ច័យនេះ ដូចពណ៌នាមកហើយចុះ ៕*

**ចប់និទ្ទេសនៃឧបនិស្សយប្បច្ច័យ**

## ១០.ពណ៌នាអំពីនិទ្ទេសនៃបុរេជាតប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***បុរេជាតប្បច្ច័យ*** *តទៅ ៖*

*ឈ្មោះថា* ***បុរេជាត*** *ក្នុងពាក្យថា* **បុរេជាតប្បច្ចយោ** *នេះ* ***ជាបច្ច័យដល់ធម៌ណា, ត្រូវកើតមុនធម៌នោះ គឺកន្លងហួសជាតិក្ខណៈ (ឧប្បាទក្ខណៈ) ទៅដល់ឋិតិខណៈហើយ*** *។*

*ពាក្យថា* **“ចក្ខាយតនំ”** *ជាដើម ព្រះមានព្រះភាគទ្រង់ត្រាស់ ដោយអំណាចនៃវត្ថុបុរេជាតប្បច្ច័យ ។ ពាក្យថា* **“រូបាយតនំ”** *ជាដើម ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃអារម្មណបុរេជាតប្បច្ច័យ ។ ពាក្យថា* **“កិញ្ចិ កាលំ បុរេជាតប្បច្ចយេន** *= គ្រាខ្លះ ជាបច្ច័យ ដោយអំណាចនៃបុរេជាតប្បច្ច័យ” ព្រះអង្គទ្រង់ត្រាស់សំដៅដល់បវត្តិកាល ។ ពាក្យថា* **“កិញ្ចិ កាលំ បុរេជាតប្បច្ចយេន** *= គ្រាខ្លះ ក៏មិនជាបច្ច័យ ដោយអំណាចនៃបុរេជាតប្បច្ច័យទេ” ទ្រង់ត្រាស់សំដៅយកបដិសន្ធិកាល ។ បាលីនេះ មានមកហើយដោយអំណាចនៃវត្ថុ និងអារម្មណ៍ ក្នុងបញ្ចទ្វារទាំងអស់ មិនបានមានមកដោយអំណាចនៃវត្ថុក្នុងមនោទ្វារទេ, តែក្នុងបញ្ហាវារៈ បានអារម្មណបុរេជាតប្បច្ច័យ សូម្បីក្នុងមនោទ្វារផង ព្រោះបាលីមានមកហើយថា “ព្រះសេក្ខៈ ឬបុថុជ្ជន រមែងឃើញច្បាស់នូវចក្ខុ ជា*

អារម្មណ៍ដែលកើតមុន ដោយសេចក្ដីជា **'អនិច្ចំ ទុក្ខំ អនត្តា"** ។ ចំណែកក្នុងទីនេះ ទ្រង់សម្ដែងទេសនាដោយអំណាចនៃធម៌ដែលមានចំណែកនៅសល់ ។ ពណ៌នាបាលីក្នុងបុរេជាតប្បច្ចយនិទ្ទេស មានត្រឹមតែប៉ុណ្ណេះ ។

បុរេជាតប្បច្ច័យនេះ មានតែរូបសុទ្ធៗ ។ ***ឯរូបនោះ បានដល់រូបរូប* ១៨ ប៉ុណ្ណោះ*** (រូបដែលបែកធ្លាយ ព្រោះបច្ច័យដែលជាសត្រូវ មានត្រជាក់ និងក្ដៅជាដើម) ***ដែលកន្លងហួសឧប្បាទក្ខណៈហើយ ចូលដល់ឋិតិខណៈ*** ។ រូបទាំងអស់ មាន ២ យ៉ាង គឺជាវត្ថុបុរេជាតប្បច្ច័យ និងអារម្មណបុរេជាតប្បច្ច័យ ។ ក្នុងពីរយ៉ាងនេះ រូបនេះ គឺចក្ខាយតនៈ ។ ល ។ កាយាយតនៈ វត្ថុរូប ឈ្មោះថា ***វត្ថុបុរេជាត***; រូបនៅសល់ទាំង ១២ ដែលមានមក និងមិនមានមកក្នុងបាលី គឺរូប សំឡេង ក្លិន រស ធាតុ ៤ ឥន្ទ្រិយ ៣ (គឺភាវរូប ២ និងជីវិតរូប ១) កវឡិង្ការាហារ ១ ឈ្មោះថា ***អារម្មណបុរេជាត*** ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការបែក មានប្រការផ្សេងៗ ក្នុងបុរេជាតប្បច្ច័យនេះ ដូចបានពណ៌នាមកហើយចុះ ។

---

* ***រូបរូប*** សំដៅដល់ និប្ផន្នរូប ១៨ ។

ក៏ក្នុងបុរេជាតប្បច្ច័យដែលចែកបានរួចហើយ ដូចដែលខ្ញុំសម្តែងមកនេះ ចក្ខាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណចិត្ត ២ ដួង ដោយអំណាចនៃបុរេជាតប្បច្ច័យ, អាយតនៈ ៤ ក្រៅអំពីនេះ ក៏ដូចគ្នា គឺជាបុរេជាតប្បច្ច័យដល់សោតវិញ្ញាណចិត្ត ២ ដួងជាដើមដែរ ។ វត្ថុរូបជាបុរេជាតប្បច្ច័យ ដល់ចិត្ត និងចេតសិក ដែលជាកុសល អកុសល និងអព្យាក្រឹត ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ នៅសល់ពីនេះ វៀរចាកទ្វិបញ្ចវិញ្ញាណចិត្ត និងអរូប-វិបាក ៤ ចេញ ។ អារម្មណ៍ ៥ មានរូបារម្មណ៍ជាដើម ជាបុរេជាត-ប្បច្ច័យដោយចំណែកមួយ ដល់ទ្វិបញ្ចវិញ្ញាណចិត្តផង និងដល់មនោធាតុ ៣ ផង ។ រូបរូបទាំង ១៨ យ៉ាងនោះ ជាបុរេជាតប្បច្ច័យដល់ធម៌ទាំង ៦ នេះ គឺកាមាវចរកុសល អភិញ្ញាកុសល ដែលកើតអំពីរូបាវចរ អកុសល និងកាមាវចរវិបាក ដែលកើតឡើងជាតទារម្មណ៍ កាមាវចរកិរិយា និងអភិញ្ញាកិរិយាដែលកើតអំពីរូបាវចរ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យសូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងបុរេជាតប្បច្ច័យនេះ ដូច្នេះចុះ ៕

ចប់និទ្ទេសនៃបុរេជាតប្បច្ច័យ

.............................................

## ១១.ពណ៌នាអំពីនិទ្ទេសនៃបច្ឆាជាតប្បច្ច័យ

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **បច្ឆាជាតប្បច្ច័យ** តទៅ ៖

*បទថា* **“បច្ឆាជាតា”** *សេចក្ដីថា ធម៌ដែលកើតខាងក្រោយ នឹងជាបច្ច័យដល់កាយណា, និងត្រូវកើតឡើងក្នុងកាលដែលកាយនោះ កើតឡើងហើយតាំងនៅ ។ បទថា* **“បុរេជាតស្ស”** *គឺជាបច្ច័យដល់ធម៌ដែលកើតឡើងមុនឧប្បាទក្ខណៈរបស់បច្ចយធម៌ទាំងនោះ កន្លងហួសខណៈកើត ទៅដល់ខណៈតាំងនៅ ។ ពីរបទថា* **“ឥមស្ស កាយស្ស”** *គឺជាបច្ច័យដល់កាយនេះ ពោលគឺមហាភូតរូប និងឧបាទាយរូប ដែលកើតអំពីសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ។ ក្នុងសេចក្ដីនេះ ពាក្យថា “កាយដែលកើតអំពីសមុដ្ឋាន ៣” អ្នកសិក្សា គប្បីជ្រាបនូវកាយនៃព្រហ្មបារិសជ្ជាជាដើម ព្រោះមិនមានអាហារជាសមុដ្ឋាន ។ នេះជាការអធិប្បាយបាលីក្នុងអធិការនេះ ។*

*ឈ្មោះថា* ***បច្ឆាជាតប្បច្ច័យ*** *នេះ ពោលដោយសង្ខេប បានដល់អរូបក្ខន្ធ ក្នុងភូមិ ៤ ដ៏សេស វៀរចាកអរូបវិបាកចេញ ។ បច្ឆាជាតប្បច្ច័យនោះ ពោលដោយអំណាចនៃជាតិ មាន ៤ ជាតិ ដោយចែកជាកុសល អកុសល វិបាក និងកិរិយា ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងបច្ឆាជាតប្បច្ច័យនេះ ដូចសម្ដែងមកហើយ ។*

*ក្នុងបច្ឆាជាតប្បច្ច័យដែលចែកបានរួចហើយ ដូចខ្ញុំបានសម្ដែងមកនេះ កុសលដែលកើតឡើងក្នុងភូមិ ៤ និងអកុសលក្នុងបញ្ចវោការភព ជាបច្ឆា-*

ជាតប្បច្ច័យដល់រូបកាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលកន្លង ហួសឧប្បាទក្ខណៈមកដល់ឋិតិខណៈ ។ សូម្បីក្នុងចំណែកវិបាក កាមាវចរ-វិបាក និងរូបាវចរវិបាកដ៏សេស វៀរវិបាកដែលធ្វើបដិសន្ធិកិច្ច ជាបច្ឆា-ជាតប្បច្ច័យដោយចំណែកមួយ, សូម្បីក្នុងលោកុត្តរវិបាក ដែលកើតឡើង ក្នុងបញ្ចវោការភព ក៏ជាបច្ឆាជាតប្បច្ច័យដល់រូបកាយនោះដូចគ្នាដែរ ។ កិរិយាចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចំពោះការកើតឡើងក្នុងបញ្ចវោការភព ប៉ុណ្ណោះ ជាបច្ឆាជាតប្បច្ច័យដល់កាយ មានប្រការដូចពោលមកហើយ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងបច្ឆាជាតប្បច្ច័យនេះ ដូចបានពណ៌នាមកហើយនេះឯង ៕

ចប់និទ្ទេសនៃបច្ឆាជាតប្បច្ច័យ

.............................................

## ១២.ពណ៌នាអំពីនិទ្ទេសនៃអាសេវនប្បច្ច័យ

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ ***អាសេវនប្បច្ច័យ*** តទៅ ៖

ក្នុងន័យទាំងអស់ថា **“ បុរិមា បុរិមា ”** អ្នកសិក្សាគប្បីជ្រាបថា បានដល់ ធម៌ដែលរលត់ទៅតាមលំដាប់ដោយល្អ ។ ***សួរថា*** ព្រោះហេតុអ្វី បានជាក្នុងអធិការនេះ ព្រះមានព្រះភាគទ្រង់មិនធ្វើនិទ្ទេសព្រមទាំងធម៌ ដែលមានជាតិផ្សេងគ្នា ដោយន័យជាដើមថា “កុសលធម៌ដែលកើតមុនៗ

ជាបច្ច័យដល់អព្យាកតធម៌ដែលកើតក្រោយៗ” ដូចក្នុងអនន្តរប្បច្ច័យទៅ ? ឆ្លើយថា ព្រោះធម៌ទាំងឡាយ មិនអាចញុំាងធម៌ទាំងឡាយដទៃ ឲ្យកាន់យកគតិរបស់ខ្លួនបាន ។ ពិតមែនហើយ ធម៌ដែលមានជាតិផ្សេងគ្នា កាលនឹងញុំាងធម៌ដែលមានជាតិខុសគ្នា ឲ្យសម្រេចសេចក្ដីជាធម៌រហ័សរហួន និងមានកម្លាំង ដោយគុណ គឺអាសេវនៈ មិនអាចញុំាងធម៌ទាំងនោះ ឲ្យកាន់យកគតិរបស់ខ្លួន ពោលគឺភាវៈជាកុសលជាដើមបានទេ ។ ព្រោះហេតុដូច្នោះ អ្នកសិក្សា គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនធ្វើនិទ្ទេស ព្រមទាំងធម៌ដែលមានជាតិខុសគ្នាទាំងនោះឡើយ ទ្រង់ធ្វើនិទ្ទេសរួមជាមួយនឹងធម៌ដែលមានជាតិដូចគ្នា និងធម៌ដែលអាចញុំាងធម៌ដទៃ ឲ្យកាន់យកគតិរបស់ខ្លួន ពោលគឺភាវៈជាកុសលជាដើម ជាពិសេសទៅ ដោយភាវៈដែលមានកម្លាំងខ្លាំងជាងរវៀសរវៃជាង ព្រោះអាសេវនៈ ពោលគឺការសន្សំទុក ។ ***សួរថា*** កាលបើដូច្នេះ ហេតុអ្វី ទើបទ្រង់មិនកាន់យកវិបាកាព្យាកតៈផងទៅ ? ឆ្លើយថា ព្រោះមិនមានអាសេវនៈ ។ ***ពិតមែនហើយ វិបាក គឺភាវៈដ៏ផ្ចិនដោយអំណាចនៃកម្ម ជាសភាវៈដែលត្រូវកម្មធ្វើឱ្យប្រែប្រួលទៅ រមែងប្រព្រឹត្តទៅ យ៉ាងណា, ការព្យាយាម (ក្នុងការឱ្យផល) នឹងអស់កម្លាំង វិបាកនោះ ទើបមិនអាចឱ្យវិបាកដទៃកាន់យក គឺទទួលយកសភាពរបស់ខ្លួន ហើយកើតឡើងដោយគុណ គឺអាសេវនៈបាន ទាំងវិបាក (ថ្មី) ក៏មិនបាន***

***កាន់យកអានុភាពរបស់ វិបាកចាស់ដែលកើតឡើងបានដែរ ។ ប៉ុន្តែ វិបាកត្រូវកម្លាំងកម្មបន្សាត់ទៅ កើតឡើងហាក់បីដូចជាធ្លាក់ទៅ ព្រោះហេតុនោះ ក្នុងវិបាកទាំងអស់ ទើបមិនមានអាសេវនៈ ព្រោះភាវៈនៃវិបាក មិនមានអាសេវនៈដូចពោលមកហើយ ទើបព្រះមានព្រះភាគទ្រង់មិនកាន់យក (ក្នុងអធិការនៃអាសេវនប្បច្ច័យនេះ) ទេ*** ។ វិបាកនេះ សូម្បីនឹងកើតក្នុងលំដាប់នៃកុសល អកុសល និងកិរិយា ក៏រមែងមិនបានទទួលនូវគុណ គឺអាសេវនៈ ព្រោះមានការប្រព្រឹត្តទៅ ដោយអាស្រ័យកម្ម ព្រោះហេតុដូច្នោះ ធម៌មានកុសលធម៌ជាដើម ទើបមិនជាអាសេវនប្បច្ច័យដល់វិបាកនោះឡើយ ។ ម្យ៉ាងទៀត កុសលធម៌ ជាដើមទាំងនេះ មិនជាអាសេវនប្បច្ច័យដល់វិបាកទេ ព្រោះមានជាតិផ្សេងគ្នា ក៏បាន ។ ក៏កាលបើពោលដោយភូមិ ឬអារម្មណ៍ហើយ ធម៌ទាំងឡាយ ឈ្មោះថា មានជាតិផ្សេងគ្នា រមែងមិនមាន ។ ព្រោះហេតុដូច្នោះ កាមាវចរកុសល និងកិរិយា ទើបជាអាសេវនប្បច្ច័យដល់មហគ្គតកុសល មហគ្គតកិរិយា និងអនុលោមតាមកុសលដែលមានសង្ខារជាអារម្មណ៍ និងដល់គោត្រភូកុសល ដែលមាននិព្វានជាអារម្មណ៍បាន; ពណ៌នាបាលីក្នុងនិទ្ទេសនៃអាសេវនប្បច្ច័យមានតែប៉ុណ្ណេះ ។ អាសេវនប្បច្ច័យនេះ ដោយជាតិ មាន ៣ ប៉ុណ្ណោះ គឺកុសល អកុសល និងកិរិយាព្យាកតៈ ។ ក្នុង ៣ យ៉ាងនេះ កុសលពោលដោយភូមិ មាន

៣ គឺកាមាវចរភូមិ រូបាវចរភូមិ និងអរូបាវចរភូមិ ។ អកុសលជាកាមាវចរប៉ុណ្ណោះ, កិរិយាព្យាកតៈ មាន ៣ ភូមិ គឺកាមាវចរភូមិ រូបាវចរភូមិ និងអរូបាវចរភូមិ; ឈ្មោះថា អាសេវនប្បច្ច័យដែលជាលោកុត្តរ មិនមានទេ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ក្នុងអាសេវនប្បច្ច័យនេះ ដូចពោលមកហើយ ។ ក្នុងអាសេវនប្បច្ច័យដែលចែកហើយ ដូចបានពោលមកនេះ ***កាមាវចរ-កុសល*** ជាអាសេវនប្បច្ច័យដល់កាមាវចរកុសល ដែលកើតក្នុងលំដាប់នៃខ្លួន ។ ក្នុងអាសេវនប្បច្ច័យ ***កាមាវចរកុសល*** ដែលជាញាណសម្បយុត្តជាអាសេវនប្បច្ច័យដល់ពួកធម៌ទាំងនេះ គឺរូបាវចរកុសល អរូបាវចរកុសល លោកុត្តរកុសល ដែលមានវេទនាដូចខ្លួនដែរ ។ ចំណែក ***រូបាវចរកុសល*** ជាអាសេវនប្បច្ច័យ ដល់រូបាវចរកុសលប៉ុណ្ណោះ ។ ***អរូបាវចរកុសល*** ជាអាសេវនប្បច្ច័យ ដល់អរូបាវចរកុសលប៉ុណ្ណោះ ។ ***អកុសល*** ក៏ជាអាសេវនប្បច្ច័យ ដល់អកុសលដូចគ្នាដែរ ។ ចំណែកកិរិយាធម៌ ពោលគឺ ***កាមាវចរកិរិយា*** ជាអាសេវនប្បច្ច័យដល់កាមាវចរកិរិយា ។ ធម៌ ពោលគឺកាមាវចរកិរិយាណា ជាញាណសម្បយុត្ត, ធម៌នោះ ជាអាសេវនប្បច្ច័យដល់ធម៌ទាំងនេះ គឺរូបាវចរកិរិយា អរូបាវចរកិរិយា ដែលមានវេទនាដូចនឹងខ្លួនដែរ ។ ***រូបាវចរកិរិយា*** ជាអាសេវនប្បច្ច័យ ដល់រូបាវចរកិរិយា

*ប៉ុណ្ណោះ ។ **អរូបាវចរកិរិយា** ជាអាសេវនប្បច្ច័យ ដល់អរូបាវចរកិរិយាប៉ុណ្ណោះ ។ ចំណែកវិបាក ជាអាសេវនប្បច្ច័យដល់ធម៌យ៉ាងណាមួយ ឬធម៌ណាៗ នឹងជាអាសេវនប្បច្ច័យដល់វិបាក រមែងមិនមាន; អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចុប្បន្ន ក្នុងអាសេវន-ប្បច្ច័យនេះ ដូចពោលមកដូច្នេះហោង ៕*

ចប់និទ្ទេសនៃអាសេវនប្បច្ច័យ

..................................

## ១៣.ពណ៌នាអំពីនិទ្ទេសនៃកម្មប្បច្ច័យ

*អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យក្នុងនិទ្ទេសនៃ **កម្មប្បច្ច័យ** គទៅ ៖*

*បទថា* **“កម្មំ”** *បានដល់* ***ចេតនាកម្ម*** *នោះឯង ។ ពីរបទថា* **“កដត្តា ច រូបានំ** *= រូបដែលកើតឡើង ព្រោះត្រូវកម្មធ្វើ (សាង) ឡើង” ។ បទថា* **“កម្មប្បច្ចយេន”** *សេចក្តីថា ដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យ ដែលអាចឲ្យផលរបស់ខ្លួនកើតឡើងបាន ក្នុងទីបំផុតនៃកោដិកប្បមិនមែនតិច ។* ***ពិតមែនហើយ កុសលកម្ម និងអកុសលកម្ម រមែងមិនឱ្យផលក្នុងខណៈដែលខ្លួនប្រព្រឹត្តទៅ; បើនឹងគប្បីឱ្យផល (ក្នុងខណៈនោះ) មែន, បុគ្គលធ្វើកុសលកម្មយ៉ាងណាដែលជាហេតុឱ្យចូលដល់***

*ទេវលោក, ក៏នឹងគប្បីក្លាយជាទេវតាក្នុងខណៈនោះតែម្តង ដោយអានុភាពនៃកម្មនោះឯង ។ ក៏កម្មនោះ ដែលបុគ្គលធ្វើទុកក្នុងខណៈណា, សូម្បីនឹងមិនមាននៅក្នុងខណៈដទៃអំពីនោះ រមែងញុំាងផលឱ្យកើតឡើង ក្នុងកាលដែលបុគ្គលគប្បីចូលដល់បច្ចុប្បន្ន ឬបន្ទាប់អំពីនោះ ក្នុងពេលមានការប្រកបព្រមនៃបច្ច័យដ៏សេស ព្រោះជាសភាវៈដែលកម្មធ្វើទុកស្រេចហើយ* ប្រៀបដូចការហាត់ធ្វើសិប្បៈគ្រាដំបូង សូម្បីអស់ផុតទៅហើយ (ទីបំផុត) ក៏ឲ្យកើតការធ្វើសិប្បៈគ្រាក្រោយៗ ក្នុងកាលដទៃបាន; ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា ***“នានាក្ខណិកកម្មប្បច្ច័យ”*** ។ ពីរបទថា **“ចេតនាសម្បយុត្តកានំ ធម្មានំ”** សេចក្តីថា ចេតនាយ៉ាងណាមួយ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួន ។ ដោយបទថា **“ តំសមុដ្ឋានានំ ”** នេះ ព្រះមានព្រះភាគទ្រង់កាន់យកកម្មជរូប ក្នុងបដិសន្ធិខណៈដែរ ។ ពាក្យថា **“កម្មប្បច្ចយេន”** នេះ ត្រាស់សំដៅដល់ចេតនាដែលកើតព្រមគ្នា ។ ពិតមែនហើយ បណ្តាធម៌ទាំងឡាយ មានកុសលធម៌ជាដើម ចេតនាយ៉ាងណាមួយ ជួយឧបការៈដល់ធម៌ដ៏សេស ដោយភាពជាកិរិយា ពោលគឺសេចក្តីព្យាយាមនៃចិត្ត ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា ***“សហជាតកម្មប្បច្ច័យ”*** ។

ពណ៌នាបាលីក្នុងកម្មប្បច្ច័យនេះ ប៉ុណ្ណោះសិនចុះ ។ កម្មប្បច្ច័យនេះ ***ដោយអត្ថ*** បានដល់ ចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ប៉ុណ្ណោះ; ព្រោះថា ចេតនានោះ ពោលដោយប្រភេទនៃជាតិ ចែកចេញជា ៤ ជាតិ គឺកុសលជាតិ អកុសលជាតិ វិបាកជាតិ និងកិរិយាជាតិ ។ ក្នុង ៤ ជាតិនោះ កុសលជាតិពោលដោយភូមិ មាន ៤ ដោយអំណាចនៃ កាមាវចរភូមិជាដើម ។ អកុសលជាតិ មាន ១ ភូមិប៉ុណ្ណោះ; វិបាកជាតិ មាន ៤ ភូមិ, កិរិយាជាតិ មាន ៣ ភូមិ ។ អ្នកសិក្សា គប្បីជ្រាប វិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងកម្មប្បច្ច័យ ដូចពោល មកហើយ ។ ក្នុង ***កម្មប្បច្ច័យ*** មានការចែកបាន ដូចពោលមកហើយ, ***កាមាវចរកុសលចេតនា*** ដែលកើតព្រមគ្នា ជាបច្ច័យដល់ធម៌ ដែលសម្បយុត្ត ជាមួយនឹងខ្លួន និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព, ក្នុង ចតុវោការភព ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយនឹងខ្លួនតែម្យ៉ាង ប៉ុណ្ណោះ ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។ ***ចំណែកចេតនាដែល កើតឡើងហើយ រលត់ទៅ*** ជាបច្ច័យដល់វិបាកក្ខន្ធរបស់ខ្លួន និងកម្មជរូប ដោយនានាក្ខណិកកម្មប្បច្ច័យ ។ ឯចេតនានោះ ជាបច្ច័យក្នុងបញ្ច-វោការភពប៉ុណ្ណោះ, មិនជាបច្ច័យក្នុងភពដទៃទេ ។ ***រូបាវចរកុសលចេតនា***

***ដែលកើតព្រមគ្នា*** ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ដោយចំណែកមួយ ។ ប៉ុន្តែ ***រូបាវចរកុសលចេតនាដែលកើតឡើងហើយ រលត់ទៅ*** ជាបច្ច័យដល់វិបាករបស់ខ្លួន និងកម្មជរូប ដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យ ។ ***អរូបាវចរកុសលចេតនា និងលោកុត្តរកុសលចេតនា ដែលកើតព្រមគ្នា*** ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួន និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព, ក្នុងចតុវោការភព ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយនឹងខ្លួនតែម្យ៉ាង ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។ ***ឯចេតនាទាំងពីរនោះ ដែលកើតឡើងហើយ រលត់ទៅ*** ជាបច្ច័យដល់វិបាកក្ខន្ធរបស់ខ្លួនៗ ដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យ ។ ***អកុសលចេតនាដែលកើតព្រមគ្នា*** ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព, ក្នុងចតុវោការភព ជាបច្ច័យដល់អរូបក្ខន្ធតែប៉ុណ្ណោះ ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។ ***អកុសលចេតនានោះ ដែលកើតឡើងហើយ រលត់ទៅ*** ជាបច្ច័យដល់វិបាកក្ខន្ធ និងកម្មជរូបដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យ ។ វិបាកចេតនាប៉ែកខាងកាមាវចរ និងរូបាវចរ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួន និងជាបច្ច័យដល់ចិត្តជរូបក្នុងបវត្តិកាល ដល់កម្មជរូបក្នុង

*បដិសន្ធិកាល ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។* ***អរូបាវចរវិបាក-ចេតនា*** *ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួនតែម្យ៉ាង ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។* ***លោកុត្តរវិបាកចេតនា*** *ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួន និងរូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ច-វោការភព, ក្នុងចតុវោការភព ជាបច្ច័យដល់អរូបធម៌ប៉ុណ្ណោះ ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។* ***កិរិយាចេតនា*** *ដែលកើតក្នុងភូមិទាំងបី ជាបច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូបក្នុងបញ្ចវោការភព ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។ កិរិយាចេតនាដែលកើតក្នុងអរូបភព ជាបច្ច័យដល់អរូបធម៌តែប៉ុណ្ណោះ ដោយអំណាចនៃសហជាតកម្មប្បច្ច័យ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ* ***សូម្បីដោយធម៌*** *ដែលជាបច្ចយុប្បន្ន ក្នុងកម្មប្បច្ច័យនេះ ដូចពោលមកហើយនេះឯង ៕*

ចប់និទ្ទេសនៃកម្មប្បច្ច័យ

## ១៤. ពណ៌នាអំពីនិទ្ទេសនៃវិបាកប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***វិបាកប្បច្ច័យ*** *តទៅ ៖*

*សូម្បីរូបដែលកើតអំពីកម្ម ក៏មិនឈ្មោះថា វិបាកដែរ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* **“ វិបាកា ”** *ហើយត្រាស់ថា*

**“ចត្តារោ ខន្ធា”** ក្នុងព្រះបាលីថា **“វិបាកា ចត្តារោ ខន្ធា”** ។ បាលីនេះមានមក ដោយអំណាចវិបាកប្បច្ច័យនៃអរូបធម៌ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ប៉ុន្តែ ក្នុងបញ្ហាវារៈរមែងបានវិបាកប្បច្ច័យ សូម្បីដល់ចិត្តជរូប និងកម្មជរូបដែរ ព្រោះព្រះបាលីមានមកហើយថា “ខន្ធ ១ ដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធ ៣ និងរូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចនៃវិបាកប្បច្ច័យ ។ ខន្ធ ១ ដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធ ៣ និងកម្មជរូប ក្នុងខណៈបដិសន្ធិ ដោយអំណាចនៃវិបាកប្បច្ច័យ” ។ ប៉ុន្តែក្នុងអធិការនេះ ព្រះមានព្រះភាគទ្រង់បានទេសនាទុក ដោយអំណាចនៃធម៌ដែលមានចំណែកនៅសល់ ។ ពណ៌នាបាលីក្នុងវិបាកប្បច្ច័យនេះ មានត្រឹមតែប៉ុណ្ណោះ ។ វិបាកប្បច្ច័យនេះ ជាវិបាកធម៌ ដោយជាតិ មានត្រឹមតែមួយជាតិ (គឺវិបាកជាតិ), ដោយប្រភេទនៃភូមិ ចែកបានជា ៤ ភូមិ ដោយអំណាចនៃកាមាវចរភូមិជាដើម ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងវិបាកប្បច្ច័យដូចពោលមកហើយនេះចុះ ។ ក្នុងវិបាកប្បច្ច័យដែលបានចែក ដូចអធិប្បាយមកហើយ កាមាវចរវិបាក និងរូបាវចរវិបាក ជាវិបាកប្បច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន និងជាវិបាកប្បច្ច័យដល់ចិត្តជរូបក្នុងបវត្តិកាល ជាវិបាកប្បច្ច័យដល់កម្មជរូប ក្នុងបដិសន្ធិកាល ។ ***អរូបាវចរវិបាក*** ជាវិបាកប្បច្ច័យដល់ធម៌

*ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ។ **លោកុត្តរវិបាក** ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នានឹងចិត្តជរូប ក្នុងបញ្ចវោការភព, ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា ក្នុងចតុវោការភពប៉ុណ្ណោះ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យសូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងវិបាកប្បច្ច័យនេះ ដូច្នេះឯង ៕*

ចប់និទ្ទេសនៃវិបាកប្បច្ច័យ

....................

## ១៥.ពណ៌នាអំពីនិទ្ទេសនៃអាហារប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អាហារប្បច្ច័យ** តទៅ ៖*

*ឱជាក្នុងរូបដែលកើតក្នុងសន្តតិ* [*] *៤ ឈ្មោះថា **អាហារ** ក្នុងពាក្យថា* **“កពឡីការោ អាហារោ”** *។ ក៏ព្រោះអាហារនេះ បុគ្គលធ្វើឲ្យជាដុំហើយ បរិភោគលេបចូលទៅប៉ុណ្ណោះ ទើបធ្វើកិច្ចនៃអាហារបាន, ដែលនៅខាងក្រៅ មិនអាចធ្វើកិច្ចនៃអាហារបានទេ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគមិនទ្រង់ត្រាស់ថា* **“អាហារោ”** *ទេ, ទ្រង់ត្រាស់ថា* **“កពឡីការោ អាហារោ”** *ដូច្នេះវិញ ។ម្យ៉ាងទៀត ពាក្យថា* **“កពឡីការោ”** *នេះ*

---

[*] រូបដែលកើតអំពីសមុដ្ឋាន ៤ គឺ កម្ម ចិត្ត ឧតុ និងអាហារ ។

ត្រឹមតែជាឈ្មោះនៃអាហារប៉ុណ្ណោះ ព្រោះជាវត្ថុដែលបុគ្គលគប្បីធ្វើឲ្យជាដុំៗ ហើយបរិភោគលេបចូលទៅ ។ អាហារ គឺផស្សៈ ចេតនា និងវិញ្ញាណ ឈ្មោះថា **នាមាហារ** ។ រូបដែលមានកម្មជាសមុដ្ឋាន ព្រះមានព្រះភាគទ្រង់កាន់យកហើយ ក្នុងពាក្យថា **“ កំសមុដ្ឋានានំ ”** នេះ ។ សមពិតដូចពុទ្ធដីកាដែលព្រះអង្គត្រាស់ទុកក្នុងបញ្ហាវារៈថា “ក្នុងខណៈ បដិសន្ធិ អាហារដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត នឹងរូបដែលកើតអំពីកម្ម ដោយអំណាចនៃអាហារប្បច្ច័យ ” ។ ពណ៌នាបាលីក្នុងអាហារប្បច្ច័យ មានត្រឹមតែប៉ុណ្ណេះ ។ ក៏អាហារប្បច្ច័យនេះ ដោយសង្ខេប បានដល់ ធម៌ ៤ យ៉ាងប៉ុណ្ណោះ គឺកពឡិង្ការាហារ ផស្សាហារ ចេតនាហារ និងវិញ្ញាណាហារ ។ ក្នុងអាហារ ៤ យ៉ាងនេះ នាមាហារ ៣ ដែលនៅសល់ វៀរកពឡិង្ការាហារចេញ ពោលដោយអំណាចនៃជាតិ ចែកបាន ៤ ជាតិ គឺជាកុសល អកុសល វិបាក និងកិរិយា ។ ពោលដោយប្រភេទនៃភូមិ នាមាហារទាំងនេះ ចែកបានច្រើនយ៉ាងទៀត គឺកុសលចែកបាន ៤ ភូមិ, អកុសល ១ ភូមិ, វិបាក ៤ ភូមិ និងកិរិយា ៣ ភូមិ ។ ចំណែកកពឡិង្ការាហារដោយជាតិ ជាអព្យាក្រឹត, ដោយភូមិ ជាកាមាវចរតែម្យ៉ាង ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងអាហារប្បច្ច័យនេះ ដូចពោលមកហើយ ។

ក្នុងអាហារប្បច្ច័យដែលចែក ដូចបានពោលមកហើយនេះ អាហារដែលជាកុសល ៣ យ៉ាង ក្នុងភូមិទាំង ៤ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួន និងរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ដោយអំណាចនៃអាហារប្បច្ច័យ, អាហារដែលនៅសល់ វៀររូបាវចរវិញ្ញាណចេញ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាតែប៉ុណ្ណោះ ក្នុងអរូបភព ដោយអំណាចនៃអាហារប្បច្ច័យ ។ សូម្បីក្នុងអាហារដែលជាអកុសល ក៏មានន័យដូចគ្នានេះដែរ ។ អាហារដែលជាវិបាកទាំង ៤ ភូមិ ជាអាហារប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាក្នុងទីទាំងពួង ។ ក្នុងអធិការនេះ កាមាវចរវិបាក និងរូបាវចរវិបាកដែលកើតក្នុងបញ្ចវោការភព ជាអាហារប្បច្ច័យដល់ចិត្តជរូបក្នុងបវត្តិកាល, ដល់កម្មជរូបក្នុងបដិសន្ធិកាល ។ អាហារដែលជាលោកុត្តរ-វិបាក ជាអាហារប្បច្ច័យដល់ចិត្តជរូបតែម្យ៉ាង ។ អាហារដែលកើតក្នុងអរូបភព រមែងមិនជាបច្ច័យដល់រូបឡើយ ។ អាហារដែលជាកិរិយាទាំង ៣ ភូមិ ជាអាហារប្បច្ច័យដល់ធម៌ ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ច-វោការភព ។ អាហារដែលជាកាមាវចរ និងអរូបាវចរ ជាអាហារប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ក្នុងអរូបភព ។ កពឡិង្ការាហារដែលកើតឡើងក្នុងសន្តតិ ៤ ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដោយមិនប្លែកគ្នាថា ជាបច្ច័យដល់កាយនេះ ក៏ពិតមែន, ប៉ុន្តែ កាលបើពោលដោយប្លែកគ្នា ក្នុងអធិការនេះ កពឡិង្ការាហារនេះ ជាសភាវៈឲ្យកើតរូប ដែលមានអាហារ

*ជាសមុដ្ឋាន ដោយជនកសត្តិ និងតាមរក្សារូបដែលមាន អាហារជាសមុដ្ឋាន ដោយអនុបាលកសត្តិ ដោយអំណាចនៃអាហារប្បច្ច័យ, អធិប្បាយថា (កពឡិង្ការាហារ) ជាបច្ច័យដល់សន្តតិរូបដែលមានសមុដ្ឋាន ៣, ដែលនៅសល់ ដោយអំណាចនៃអាហារប្បច្ច័យ ព្រោះចិញ្ចឹមរូបទុក ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអាហារប្បច្ច័យនេះ ដូចបានពណ៌នាមកហើយ ៕*

ចប់និទ្ទេសនៃអាហារប្បច្ច័យ

............................................

## ១៦.ពណ៌នាអំពីនិទ្ទេសនៃឥន្ទ្រិយប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឥន្ទ្រិយប្បច្ច័យ** តទៅ ៖*

*បទថា* **“ចក្ខុន្ទ្រិយំ”** *ឥន្ទ្រិយ គឺចក្ខុ ។ បទថា* **“ឥន្ទ្រិយប្បច្ចយេន”** *សេចក្តីថា ចក្ខុន្ទ្រិយជាដើមនោះ ខ្លួនឯងកើតមុន ហើយជាបច្ច័យដល់អរូបធម៌តាំងអំពីកើត ទៅរហូតដល់រលត់ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ សូម្បីក្នុងសោតិន្ទ្រិយជាដើម ក៏មានន័យដូចគ្នានេះដែរ ។ សូម្បី **អរូប-ជីវិតិន្ទ្រិយ** ក៏ព្រះមានព្រះភាគទ្រង់សង្គ្រោះចូលក្នុងពាក្យថា **ឥន្ទ្រិយដែលមិនមានរូប** នេះដែរ ។*

ក្នុងពាក្យថា **“ តំសមុដ្ឋានានំ ”** នេះ ទ្រង់សង្គ្រោះ សូម្បីកម្មជរូប ដោយន័យដែលពោលហើយអំពីខាងដើម ។ សមពិតដូចពុទ្ធតម្រាស់ ដែលព្រះអង្គត្រាស់ទុកក្នុងបញ្ហាវារៈដូច្នេះថា “ឥន្ទ្រិយដែលជាវិបាកាព្យាកតៈ ជាបច្ច័យ ដល់ខន្ធដែលសម្បយុត្តនឹងកម្មជរូបក្នុងខណៈបដិសន្ធិ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ” ។ វណ្ណនាបាលីក្នុងនិទ្ទេសនៃឥន្ទ្រិយប្បច្ច័យនេះ មានត្រឹមតែប៉ុណ្ណេះ ។

***ឥន្ទ្រិយប្បច្ច័យ*** នេះ គឺឥន្ទ្រិយ ២០ គត់ វៀរឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយចេញ ។

***ពិតមែនហើយ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ជាកំណើតនៃភេទស្រី និងភេទប្រុស ក៏ពិតមែន. ប៉ុន្តែ ក្នុងកាលដែលនៅជាកលលៈជាដើម សូម្បីកាលឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំងនោះ នឹងមាន ក៏មិនសម្រេចសេចក្តីជាឥន្ទ្រិយ-ប្បច្ច័យដល់ភេទស្រី និងភេទប្រុសទាំងនោះបានឡើយ; ព្រោះភេទប្រុស និងភេទស្រី នៅមិនទាន់មាន ទាំងមិនជាឥន្ទ្រិយប្បច្ច័យដល់ធម៌ពួកដទៃឡើយ*** ។

ពិតមែនហើយ ធម៌ដែលជាឥន្ទ្រិយប្បច្ច័យ និងឈ្មោះថា មិនសម្រេចនូវភាវៈជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលមិនប្លែកគ្នា ក្នុងខណៈដែលខ្លួនមាន រមែងមិនមាន; ព្រោះហេតុដូច្នោះ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង

នោះ ទើបមិនជាឥន្ទ្រិយប្បច្ច័យទេ ។

***ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំងនេះ ជាពូជនៃភេទស្រី និងភេទប្រុសពួកណា, ដោយបរិយាយ ដែលមានមកក្នុងព្រះសូត្រ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំងនោះ រាប់ថា ជាបកតូបនិស្សយប្បច្ច័យដល់ភេទស្រី និងភេទប្រុសទាំង នោះផងដែរ*** ។

*ឥន្ទ្រិយប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបថា បានដល់ ឥន្ទ្រិយ ២០ គត់ ។ ឥន្ទ្រិយប្បច្ច័យនោះ ដោយជាតិ ចែកចេញជា ៥ ជាតិ គឺកុសល អកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនេះ កុសល ពោល ដោយអំណាចនៃភូមិ មាន ៤, អកុសល ជាកាមាវចរភូមិតែម្យ៉ាង, វិបាក មាន ៤ ភូមិ, កិរិយា មាន ៣ ភូមិ, រូប ជាកាមាវចរភូមិប៉ុណ្ណោះ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងឥន្ទ្រិយប្បច្ច័យនេះ ដូច្នេះចុះ ។*

*ក្នុងឥន្ទ្រិយប្បច្ច័យដែលចែកហើយយ៉ាងនេះ* ***បច្ច័យ គឺឥន្ទ្រិយដែលជាកុសល*** *ទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្ត និងដល់រូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបញ្ចវោការភព ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ, ឥន្ទ្រិយដែលជាអកុសល ក៏ដូចគ្នាដែរ ។ កុសល និងអកុសលដែលនៅសល់ វៀររូបាវចរកុសលចេញ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា*

ក្នុងអរូបភព ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។

***ឥន្ទ្រិយដែលជាវិបាក*** ទាំង ៤ ភូមិ ជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា ដោយចំណែកមួយ ។ បណ្ដាឥន្ទ្រិយដែលជាវិបាកទាំងនេះ ឥន្ទ្រិយដែលជាកាមាវចរវិបាក និងរូបាវចរវិបាក កាលកើតក្នុងបញ្ចវោការភព ជាបច្ច័យដល់ចិត្តជរូប ក្នុងបវត្តិកាល និងដល់កម្មជរូបក្នុងបដិសន្ធិកាល ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ ឥន្ទ្រិយដែលជាលោកុត្តរវិបាក ជាបច្ច័យដល់ចិត្តជរូបតែម្យ៉ាង ។ ឥន្ទ្រិយដែលជាលោកុត្តរវិបាក ដែលកើតឡើងក្នុងអរូបភព មិនជាបច្ច័យដល់រូបឡើយ ។

***ឥន្ទ្រិយដែលជាកិរិយា*** ទាំង ៣ ភូមិ ជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ចវោការភព ។ ចំណែកឥន្ទ្រិយដែលជាកាមាវចរកិរិយា និងអរូបាវចរកិរិយា រមែងសម្រេចសេចក្ដីជាឥន្ទ្រិយប្បច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាក្នុងអរូបភពប៉ុណ្ណោះ ។

ក្នុងរូបឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម ចក្ខុន្ទ្រិយជាបច្ច័យដល់ចក្ខុវិញ្ញាណចិត្ត ២ ព្រមទាំងធម៌ដែលសម្បយុត្តគ្នាក្នុងចំណែកកុសលវិបាក និងអកុសលវិបាក ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ សោតិន្ទ្រិយជាដើម ក៏ជាឥន្ទ្រិយប្បច្ច័យ ដល់សោតវិញ្ញាណជាដើម យ៉ាងនោះដែរ ។

***រូបជីវិតិន្ទ្រិយ ជាបច្ច័យដល់រូបដែលកើតរួមជាមួយនឹងខ្លួន ក្នុងឋិតិខណៈ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ សេចក្ដីជាសហជាតប្បច្ច័យរមែងមិនមានដល់រូបជីវិតិន្ទ្រិយនោះទេ ។***

*អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយធម៌ដែលជាបច្ចុប្បន្នក្នុងឥន្ទ្រិយប្បច្ច័យយ៉ាងនេះឯង ៕*

ចប់និទ្ទេសនៃឥន្ទ្រិយប្បច្ច័យ

## ១៧.១ពណ៌នាអំពីនិទ្ទេសនៃឈានប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ឈានប្បច្ច័យ*** *តទៅ ៖*

*បទថា* **“ឈានង្គានិ”** *បានដល់* ***អង្គឈាន ៧ ពោលគឺវិតក្កៈ វិចារៈ បីតិ សោមនស្ស ទោមនស្ស ឧបេក្ខា និងចិត្តេកគ្គតា ដែលកើតឡើងក្នុងចិត្តដែលនៅសល់ ដោយវៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ចេញ*** *។ ក៏ព្រោះពួកនៃវិញ្ញាណ ៥ ត្រឹមតែជាការធ្លាក់ទៅ (នៃចិត្តក្នុងអារម្មណ៍) ឧបេក្ខា សុខ និងទុក្ខ សូម្បីនឹងមាននៅក្នុងចិត្តទាំងនោះ ក៏ព្រះមានព្រះភាគទ្រង់មិនលើកឡើងថា ជាអង្គឈានទេ ព្រោះមិនមានការចូលទៅសម្ងឹងអារម្មណ៍ ។ បណ្តាអង្គឈានទាំងនោះ សូម្បីអង្គឈានក្នុងអហេតុកចិត្តដែលនៅសល់ ក៏ព្រះមានព្រះភាគទ្រង់មិនលើកឡើង (ថាជាឈានប្បច្ច័យ) ដែរ ព្រោះត្រូវកាត់ដាច់ទៅហើយ; ប៉ុន្តែ ការប្រមូលធម៌ (ធម្មសង្គហៈ) ក្នុងអធិការនេះ ទ្រង់លើកឡើងទុកដែរ ។*

*សូម្បីក្នុងបទថា* **“តំសមុដ្ឋានានំ”** *នេះ អ្នកសិក្សាគប្បីជ្រាបថា*

ព្រះមានព្រះភាគទ្រង់សង្គ្រោះយកកម្មជរូប ។ សមពិតដូចព្រះអង្គត្រាស់ទុកក្នុងបញ្ហាវារៈថា "ក្នុងបដិសន្ធិខណៈ អង្គឈានដែលជាវិបាកាព្យាកតៈជាបច្ច័យដល់ខន្ធដែលសម្បយុត្តនឹងកម្មជរូប ដោយអំណាចនៃឈានប្បច្ច័យ" ។ ពណ៌នាបាលីក្នុងអធិការនេះ មានត្រឹមតែប៉ុណ្ណេះ ។ ឈានប្បច្ច័យនេះ គឺអង្គឈាន ៧ ចែកដោយប្រភេទនៃជាតិមាន ៤ គឺកុសល អកុសល វិបាក និងកិរិយា, ពោលដោយអំណាចនៃភូមិម្តងទៀត ចែកបាន ១២ ភូមិ គឺកុសល ៤, អកុសល ១, វិបាក ៤ និងកិរិយា ៣ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងឈានប្បច្ច័យនេះ ដូចពោលមកហើយ ។

ក្នុងឈានប្បច្ច័យដែលចែកចេញយ៉ាងនេះ អង្គឈានដែលជាកុសលទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ចវោការភព ដោយអំណាចនៃឈានប្បច្ច័យ ។ អង្គឈានដែលនៅសល់ វៀរអង្គឈានដែលជារូបាវចរចេញ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ក្នុងអរូបភព ដោយអំណាចនៃឈានប្បច្ច័យ ។ សូម្បីក្នុងអកុសលជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ***អង្គឈានដែលជាកាមាវចរវិបាក និងរូបាវចរ-វិបាក*** ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបវត្តិកាល, ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងកម្មជរូប ក្នុងបដិសន្ធិកាល ។

***អង្គឈានដែលជាអរូបវិបាក*** *ជាឈានប្បច្ច័យដល់ធម៌ ដែលសម្បយុត្តគ្នា (ក្នុងអរូបភព) ប៉ុណ្ណោះ, ឯលោកុត្តរវិបាកដែលកើតក្នុងអរូបភព ក៏ដូចគ្នាដែរ ។ ប៉ុន្តែ ក្នុងបញ្ចវោការភព អង្គឈានដែលជាលោកុត្តរវិបាកនោះ ជាបច្ច័យដល់ចិត្តជរូប ដោយអំណាចនៃឈានប្បច្ច័យ ។ អង្គឈានដែលជាកិរិយាទាំង ៣ ភូមិ ជាឈានប្បច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ចវោការភព ។ អង្គឈានដែលកើតក្នុងអរូបភព ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា ដោយអំណាចនៃឈានប្បច្ច័យប៉ុណ្ណោះ ។ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងឈានប្បច្ច័យនេះ ដូចបានពោលមកហើយនុ៎ះឯង ៕*

ចប់និទ្ទេសនៃឈានប្បច្ច័យ

.........................................

## ១៨.ពណ៌នាអំពីនិទ្ទេសនៃមគ្គប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***មគ្គប្បច្ច័យ*** *តទៅ ៖*

*បទថា* **“មគ្គង្គានិ”** *បានដល់* ***អង្គមគ្គទាំង ១២ នេះ គឺបញ្ញា វិតក្កៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ វីរិយៈ សតិ សមាធិ មិច្ឆាទិដ្ឋិ មិច្ឆា-សង្កប្បៈ មិច្ឆាវាយាមៈ និងមិច្ឆាសមាធិ ដែលកើតឡើងក្នុងចិត្តដ៏សេស វៀរអហេតុកចិត្តុប្បាទចេញ ។ ព្រះមានព្រះភាគទ្រង់មិនលើកអង្គមគ្គ ក្នុង***

*អហេតុកចិត្ត (ជាមគ្គប្បច្ច័យ) ទេ ព្រោះភាវៈនៃមគ្គជាធម៌កើតខាងក្រោយហេតុ* ។ ទ្រង់សង្គ្រោះកម្មជរូប ក្នុងបទថា “**តំសមុដ្ឋានានំ**” នេះ ។ សមពិតដូចព្រះតម្រាស់ដែលព្រះអង្គត្រាស់ទុកក្នុងបញ្ហាវារៈថា “***អង្គមគ្គដែលជាវិបាកាព្យាកតៈ ក្នុងខណៈបដិសន្ធិ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តនឹងកម្មជរូប ដោយអំណាចនៃមគ្គប្បច្ច័យ***” ។ ពណ៌នាបាលីក្នុងអធិការនេះ មានតែត្រឹមប៉ុណ្ណេះ ។

មគ្គប្បច្ច័យនេះ បានដល់ អង្គមគ្គ ១២ បែងចែកដោយប្រភេទនៃជាតិ មាន ៤ មានកុសលជាតិជាដើម ។ ឯកុសលជាតិជាដើមនេះ ចែកដោយភូមិ មាន ១២ មានកាមាវចរភូមិជាដើម ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ដូចបានពោលមកហើយ ។

ក្នុងមគ្គប្បច្ច័យដែលចែកបានយ៉ាងនេះ អង្គមគ្គដែលជាកុសលទាំង ៤ ភូមិ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ចវោការភព ដោយអំណាចនៃមគ្គប្បច្ច័យ ។ អង្គមគ្គដែលនៅសល់ វៀរអង្គមគ្គដែលជារូបាវចរចេញ ជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នាក្នុងអរូបភព ដោយអំណាចនៃមគ្គប្បច្ច័យ, អធិប្បាយទាំងអស់ លោកធ្វើឲ្យពិស្តារហើយ ដូចក្នុងឈានប្បច្ច័យដែរ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌

ដែលជាបច្ចុប្បន្ន ក្នុងមគ្គប្បច្ច័យនេះ ដូចពោលមកហើយទុំះឯង ។

ចប់និទ្ទេសនៃមគ្គប្បច្ច័យ

.................

## ១៩.ពណ៌នាអំពីនិទ្ទេសនៃសម្បយុត្តប្បច្ច័យ

បាលីក្នុងនិទ្ទេសនៃ ***សម្បយុត្តប្បច្ច័យ*** មានសេចក្តីភ្លឺច្បាស់ហើយ ។ ឈ្មោះថា សម្បយុត្តប្បច្ច័យនេះ ពោលដោយសង្ខេប បានដល់ អរូបក្ខន្ធទាំងអស់ ។ ដោយប្រភេទចែកបានច្រើនយ៉ាង គឺដោយជាតិ មានកុសលជាតិជាដើម ដោយភូមិ មានកាមាវចរភូមិជាដើម ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយការចែក មានប្រការផ្សេងៗ ក្នុងសម្បយុត្តប្បច្ច័យនេះ ដូចបានពោលមកហើយចុះ ។

ក្នុងសម្បយុត្តប្បច្ច័យដែលបានចែកហើយយ៉ាងនេះ បណ្តាកុសលក្ខន្ធទាំង ៤ ភូមិ ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣ ដោយអំណាចនៃសម្បយុត្តប្បច្ច័យ, ខន្ធ ៣ ជាបច្ច័យដល់ខន្ធ ១, ខន្ធ ២ ជាបច្ច័យដល់ខន្ធ ២ ។ កុសលក្ខន្ធទាំងអស់ ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃសម្បយុត្តប្បច្ច័យ មានប្រការដូច្នេះ; សូម្បីក្នុងអកុសលវិបាកក្ខន្ធ និងកិរិយាខន្ធ ក៏មានន័យដូចគ្នានេះដែរ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌

*ដែលជាបច្ចយុប្បន្ន ក្នុងសម្បយុត្តប្បច្ច័យនេះ ដូចបានពណ៌នាមកហើយ ។*

ចប់និទ្ទេសនៃសម្បយុត្តប្បច្ច័យ

---

## ២០. ពណ៌នាអំពីនិទ្ទេសនៃវិប្បយុត្តប្បច្ច័យ

*អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***វិប្បយុត្តប្បច្ច័យ*** *តទៅ ៖*

*ពាក្យថា* ***រូបធម៌ជាវិប្បយុត្តប្បច្ច័យដល់អរូបធម៌*** *នេះ គប្បីជ្រាបដោយអំណាចនៃហទយវត្ថុ និងចក្ខុន្ទ្រិយជាដើមមុនៗ ; ពិតមែនហើយ រូបធម៌ទាំង ៦ យ៉ាងនេះឯង ជាវិប្បយុត្តប្បច្ច័យដល់អរូបក្ខន្ធ ។* ***សូម្បីដល់ធម៌ដែលជាអារម្មណ៍ មានរូបាយតនៈជាដើម ជាវិប្បយុត្តនឹងគ្នា*** *(ជាមួយចក្ខាយតនៈជាដើម)* ***ក៏ពិតមែន; ប៉ុន្តែ ក៏មិនចាត់ជាវិប្បយុត្តប្បច្ច័យដែរ*** *។*

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា* ***ព្រោះមិនមានការទាក់ទិនគ្នា ក្នុងរឿងសម្បយោគ ។ អរូបក្ខន្ធទាំងឡាយកើតឡើង ដូចចេញមកអំពីខាងក្នុងនៃរូបដែលជាទីអាស្រ័យ មានចក្ខុបសាទជាដើម*** *។ ការទាក់ទិនក្នុងចក្ខុបសាទជាដើមនោះទើបមាន ទោះអរូបក្ខន្ធទាំងនោះ នឹងសម្បយុត្ត ឬវិប្បយុត្តជាមួយចក្ខុបសាទជាដើមនោះ ក៏ដោយ ។ ចំណែកធម៌ដែលមានអារម្មណ៍ ត្រឹមតែជា*

អារម្មណ៍នៃចិត្តដែលកើតឡើង ព្រោះអាស្រ័យវត្ថុរូបប៉ុណ្ណោះ, ព្រោះហេតុនោះ ការទាក់ទិនដល់រឿងសម្បយោគ ក្នុងរូបាយតនៈជាដើមនោះ ទើបមិនមាន ។ រូបាយតនៈជាដើមនោះ មិនចាត់ជាវិប្បយុត្តប្បច្ច័យទេ ព្រោះមិនមានការទាក់ទិនក្នុងរឿងសម្បយោគ ដោយប្រការដូច្នេះ ។ អ្នកសិក្សាគប្បីជ្រាបសេចក្ដីជាវិប្បយុត្តប្បច្ច័យនេះ ក្នុងហទយវត្ថុជាដើមផងចុះ ។ សមពិតដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបញ្ហាវារៈថា "វត្ថុរូបជាបច្ច័យដល់កុសលក្ខន្ធ និងអកុសលក្ខន្ធ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ, ចក្ខាយតនៈ ។ ល ។ កាយាយតនៈ ជាបច្ច័យដល់ចក្ខុវិញ្ញាណ ។ ល ។ កាយវិញ្ញាណ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ ។ វត្ថុរូបជាបច្ច័យដល់ខន្ធដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ" ។

ពាក្យថា ***"អរូបធម៌ ជាបច្ច័យដល់រូបធម៌ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ"*** នេះ អ្នកសិក្សា គប្បីជ្រាបដោយអំណាចនៃខន្ធ ៤ ។ ពិតមែនហើយ ក្នុងអរូបធម៌ ខន្ធ ៤ ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ដែលជាសហជាត និងបុរេជាត, ចំណែកនិព្វាន សូម្បីជាអរូបធម៌ ក៏មិនជាបច្ច័យដល់រូបដោយអំណាចនៃវិប្បយុត្តប្បច្ច័យដែរ ។ ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ទុកថា "ប្រកបដោយខន្ធ ៤ មិនប្រកបដោយខន្ធ ៤ (គឺសម្បយុត្ត

*បុរិប្បយុត្ត ប្រើជាមួយនាមក្ខន្ធ ៤)”* [១៨] ។ អ្នកសិក្សា គប្បីជ្រាបថា ចំពោះខន្ធ ៤ ប៉ុណ្ណោះ ជាវិប្បយុត្តប្បច្ច័យដោយប្រការដូច្នេះ ។ សមពិត ដូចពុទ្ធដីកាដែលព្រះអង្គត្រាស់ទុកក្នុងបញ្ហាវារៈថា “ កុសលក្ខន្ធ ***ដែលជាសហជាត*** ជាបច្ច័យដល់ចិត្តជរូប ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ, កុសលក្ខន្ធ ***ដែលជាបច្ឆាជាត*** ជាបច្ច័យដល់កាយនេះ ដែលកើតមុន ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ; ក្នុងខណៈបដិសន្ធិ ខន្ធដែលជាវិបាកាព្យាកតៈ ជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ, ខន្ធទាំងឡាយ ជាបច្ច័យ ដល់ហទយវត្ថុ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ” ។ អ្នកសិក្សា គប្បីជ្រាបនូវការពណ៌នាបាលី ក្នុងអធិការនេះ ដូច្នេះចុះ ។

ឈ្មោះថា វិប្បយុត្តប្បច្ច័យនេះ ដោយសង្ខេប បានដល់ រូបធម៌ និងអរូបធម៌ដែលកំពុងប្រព្រឹត្តទៅក្នុងបញ្ចវោការភព ។ បណ្តារូបធម៌ និងអរូបធម៌ទាំងនោះ រូបធម៌ចែកបាន ៦ យ៉ាង ដោយអំណាចនៃហទយ-វត្ថុ និងចក្ខុបសាទជាដើម, អរូបធម៌ដែលកើតក្នុងបញ្ចវោការភព ចែកបាន ៤ ជាតិ គឺកុសល អកុសល វិបាក និងកិរិយា ។ អរូបធម៌នោះ ចែកដោយភូមិ បាន ១១ ភូមិ គឺកុសល ៤ អកុសល ១ វិបាក ៣ និង កិរិយា ៣ ដោយអំណាចនៃកាមាវចរភូមិជាដើម ។ ប៉ុន្តែ អរូបវិបាក

---

[១៨] អភិ. ធាតុកថា ។

មិនជាវិប្បយុត្តប្បច្ច័យឡើយ ។ អ្នកសិក្សាគប្បីជ្រាបដោយការចែក មានប្រការផ្សេងៗ ក្នុងវិប្បយុត្តប្បច្ច័យនេះ ដូចបានពណ៌នាមកដូច្នេះចុះ ។

ក្នុងវិប្បយុត្តប្បច្ច័យដែលបានចែកហើយយ៉ាងនេះ កុសល និង អកុសលទាំង ៤ ភូមិ ដែលកើតក្នុងបញ្ចវោការភព ជាបច្ច័យដល់ចិត្តជរូប ដែលកើតឡើងព្រមជាមួយនឹងខ្លួន ដោយអំណាចនៃសហជាតវិប្បយុត្ត-ប្បច្ច័យ ។ ជាបច្ច័យដល់រូបកាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលកើតមុន កន្លងហួសឧប្បាទក្ខណៈ មកដល់ឋិតិខណៈ ដោយអំណាច នៃបច្ឆាជាតវិប្បយុត្តប្បច្ច័យ ។

ពាក្យថា ***"រូបកាយដែលមានសមុដ្ឋាន ៣"*** ក្នុងទីនេះ អ្នកសិក្សា គប្បីជ្រាបថា បានដល់ កាយនៃព្រហ្មបារិសជ្ជាជាដើម ព្រោះមិនមានអាហារ ជាសមុដ្ឋាន ។

កាមាវចរវិបាក និងរូបាវចរវិបាក ជាបច្ច័យដល់ចិត្តជរូប ក្នុង បវត្តិកាល និងដល់កម្មជរូប ក្នុងបដិសន្ធិកាល ដោយអំណាចនៃសហជាត-វិប្បយុត្តប្បច្ច័យ លោកុត្តរវិបាកជាបច្ច័យដល់ចិត្តជរូបតែម្យ៉ាង ។ វិបាក ទាំង ៣ ភូមិនេះ (កាមភូមិ រូបភូមិ និងលោកុត្តរភូមិ) ជាបច្ច័យដល់កាយ ដែលមានសមុដ្ឋាន ៤ និង ៣ ដែលកើតមុន ដោយអំណាចនៃបច្ឆាជាត-វិប្បយុត្តប្បច្ច័យ ។

*កិរិយាទាំង ៣ ភូមិ ជាបច្ច័យដល់ចិត្តជរូប ដោយអំណាចនៃសហជាតវិប្បយុត្តប្បច្ច័យ, (កិរិយាទាំង ៣ ភូមិ) ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលកើតមុន ដោយអំណាចនៃបច្ឆាជាតវិប្បយុត្តប្បច្ច័យ ។*

*ចំណែកក្នុងវត្ថុរូប ៦ យ៉ាងនោះ វត្ថុរូបជាបច្ច័យដល់កាមាវចរវិបាក និងរូបាវចរវិបាក ក្នុងខណៈបដិសន្ធិ ដោយអំណាចនៃសហជាតវិប្បយុត្តប្បច្ច័យ, ជាបច្ច័យដល់កុសលទាំង ៤ ភូមិ, អកុសល ១ ភូមិ, វិបាកទាំង ៣ ភូមិ, វៀរវិញ្ញាណចិត្ត ១០ និងកិរិយាចិត្តទាំង ៣ ភូមិ ដែលកើតឡើងក្នុងបវត្តិកាល ដោយអំណាចនៃបុរេជាតវិប្បយុត្តប្បច្ច័យ ។ ចក្ខាយតនៈជាដើម ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ដោយអំណាចនៃបុរេជាតវិប្បយុត្តប្បច្ច័យ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្ន ក្នុងអធិការនេះ ដូចបានពណ៌នាមកហើយនេះឯង៕*

**ចប់និទ្ទេសនៃវិប្បយុត្តប្បច្ច័យ**

.................................................................

## ២១.ពណ៌នាអំពីនិទ្ទេសនៃអត្ថិប្បច្ច័យ

*អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***អត្ថិប្បច្ច័យ*** *តទៅ ៖*

ព្រះមានព្រះភាគទ្រង់សម្ដែងអត្ថិប្បច្ច័យ ដោយអំណាចនៃសហជាត ដោយពាក្យថា **“ចត្តារោ ខន្ធា”** ជាដើម ។ ទ្រង់សម្ដែងអត្ថិប្បច្ច័យ ដោយអំណាចនៃបុរេជាត ដោយពាក្យថា **“ចក្ខាយតនំ”** ជាដើម ។ ក្នុងពាក្យថា **“យំ រូបំ និស្សាយ”** នេះ ទ្រង់សម្ដែងអត្ថិប្បច្ច័យ ដោយអំណាចនៃធម៌ដែលជា ***សហជាត និងបុរេជាត*** ។ បាលីនេះមានមកហើយ ដោយអំណាចនៃអត្ថិប្បច្ច័យ រួមទាំងធម៌ដែលជាសហជាត និងបុរេជាតនោះឯង ដោយប្រការដូច្នេះ ។

ប៉ុន្តែ ***ក្នុងបញ្ហាវារៈ*** បានអត្ថិប្បច្ច័យ ដោយអំណាចនៃអាហារ និងឥន្ទ្រិយ ដែលជាបច្ឆាជាត ព្រោះព្រះបាលីមានមកហើយ ដោយអំណាចនៃធម៌ទាំងនេះ គឺសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ ប៉ុន្តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ទេសនាដោយអំណាចនៃធម៌ដែលមានចំណែកសល់ ។ ពណ៌នាបាលីក្នុងអធិការនេះ មានត្រឹមតែប៉ុណ្ណេះ ។

***ឈ្មោះថា អត្ថិប្បច្ច័យនេះ មាន ២ យ៉ាង គឺដោយអញ្ញមញ្ញប្បច្ច័យ និងមិនមែនអញ្ញមញ្ញប្បច្ច័យ*** ។ ក្នុង ២ យ៉ាងនោះ អត្ថិប្បច្ច័យដែលជាអញ្ញមញ្ញៈ មាន ៣ យ៉ាង គឺអរូបជាមួយអរូប, រូបជាមួយរូប, រូប និងអរូប ជាមួយរូប និងអរូប ។ ពិតមែនហើយ ក្នុងពាក្យថា ***“ខន្ធ ៤ ជាអត្ថិប្បច្ច័យដល់អរូប”*** នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់អរូប ជាបច្ច័យ

*ដល់គ្នានឹងគ្នា ដោយអំណាចនៃការកើតឡើងនៃចិត្តទាំងអស់ ។ ក្នុងពាក្យថា* **"ចត្តារោ មហាភូតា"** *នេះ ទ្រង់ត្រាស់ដល់រូបជាបច្ច័យជាមួយនឹងរូប ដោយអំណាចនៃការបន្តរបស់រូបទាំងអស់ ។ ក្នុងពាក្យថា* **"ឱក្កន្តិក្ខណេ នាមរូបំ"** *នេះ ត្រាស់ដល់រូប និងអរូប ជាមួយរូប និងអរូប ជាបច្ច័យដល់គ្នានឹងគ្នា ដោយអំណាចនៃខន្ធដែលធ្វើកិច្ចបដិសន្ធិ ជាមួយនឹងវត្ថុរូប ។ អត្ថិប្បច្ច័យដែលមិនមែនជាអញ្ញមញ្ញៈ មាន ៣ យ៉ាង គឺអរូប ជាអត្ថិប្បច្ច័យដល់រូប, រូប ជាអត្ថិប្បច្ច័យដល់រូប, រូប ជាអត្ថិប្បច្ច័យដល់អរូប ។ ពិតមែនហើយ ក្នុងពាក្យថា* **"ចិត្តចេតសិកា ធម្មា"** *នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់អរូប ជាបច្ច័យដល់រូប ដោយអំណាចនៃបច្ឆាជាតភាព ។ ក្នុងពាក្យថា* **"មហាភូតា ឧបាទាយរូបានំ"** *នេះ ទ្រង់ត្រាស់ដល់រូបជាបច្ច័យដល់រូប ដោយអំណាចនៃការបន្តរបស់រូបទាំងអស់ ។ ក្នុងពាក្យមានជាដើមថា* **"ចក្ខាយតនំ ចក្ខុវិញ្ញាណធាតុយា"** *ព្រះមានព្រះភាគទ្រង់ត្រាស់ថា រូប ជាបច្ច័យដល់អរូប ដោយអំណាចនៃអត្ថិប្បច្ច័យ ដោយអំណាចនៃវត្ថុ និងអារម្មណ៍ ។ម្យ៉ាងទៀត ឈ្មោះថា* ***អត្ថិប្បច្ច័យនេះ ពោលដោយសង្ខេប បានដល់ បច្ចុប្បន្នធម៌ដែលកំពុងប្រព្រឹត្តទៅ គឺនាម និងរូបដែលដល់នូវខណៈទាំង ៣ ក៏ត្រូវដែរ ។***

អត្ថិប្បច្ច័យនោះ ពោលដោយប្រភេទនៃជាតិ ចែកចេញជា ៥ គឺកុសល អកុសល វិបាក កិរិយា និងរូប ។ ក្នុង ៥ ជាតិនោះ អត្ថិ-ប្បច្ច័យដែលជាកុសល មាន ២ យ៉ាង គឺសហជាត និងបច្ឆាជាត, អកុសល វិបាក និងកិរិយា ក៏មានន័យដូចគ្នានេះដែរ ។ បណ្តាអត្ថិប្បច្ច័យដែលជាកុសលជាដើមនោះ កុសលចែកចេញជា ៤ ភូមិ ដោយអំណាចនៃកាមាវចរភូមិជាដើម ។ អកុសលជាកាមាវចរតែម្យ៉ាង ។ វិបាកប្រព្រឹត្តទៅទាំង ៤ ភូមិ ។ កិរិយាប្រព្រឹត្តទៅក្នុងភូមិ ៣, អត្ថិប្បច្ច័យគឺរូប ជាកាមាវចរតែម្យ៉ាង ។ អត្ថិប្បច្ច័យ គឺរូបនោះ មាន ២ យ៉ាង ដោយអំណាចនៃសហជាត និងបុរេជាត ។ ក្នុង ២ យ៉ាងនេះ វត្ថុ ៥ និងអារម្មណ៍ ៥ ជាបុរេជាតតែម្យ៉ាង ។ ហទយវត្ថុ ជាសហជាត ក៏បាន, ជាបុរេជាត ក៏បាន; ចំណែកអាហារ និងឥន្ទ្រិយ មកហើយក្នុងបញ្ហាវារៈរមែងមិនបានការចែកជាសហជាតជាដើមទេ ។ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យដោយការចែកមានប្រការផ្សេងៗ ក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។

ក៏ក្នុងអត្ថិប្បច្ច័យដែលទ្រង់ចែកទុកយ៉ាងនេះ សូម្បីកុសលទាំង ៤ ភូមិ ដែលកើតព្រមគ្នា ជាអត្ថិប្បច្ច័យ ។ ក្នុងបញ្ចវោការភព ខន្ធទាំងឡាយជាបច្ច័យដល់គ្នានឹងគ្នា ដោយន័យជាដើមថា “ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣” , និងជាបច្ច័យដល់ចិត្តជរូប ដោយអំណាចនៃអត្ថិប្បច្ច័យ ។ ចំណែក

សហជាតកុសលដែលនៅសល់ វៀររូបាវចរកុសលចេញ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ក្នុងអរូបភពដោយអំណាចនៃអត្ថិ-ប្បច្ច័យ ។ កុសលដែលជាបច្ឆាជាតទាំង ៤ ភូមិ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ក្នុងបញ្ចវោការភព ដោយអំណាចនៃអត្ថិប្បច្ច័យ ។ សូម្បីក្នុងអកុសលជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពិតមែនហើយ អកុសលដែលជាសហជាតនោះ សូម្បីជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបញ្ចវោការភព និងជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្តគ្នាប៉ុណ្ណោះ ក្នុងចតុវោការភព ដោយអំណាចនៃអត្ថិប្បច្ច័យ ។ អកុសលដែលជាបច្ឆាជាតអកុសល ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ក្នុងបញ្ចវោការភព ដោយអំណាចនៃអត្ថិប្បច្ច័យ ។

ក៏ដោយសេចក្តីជាវិបាក អត្ថិប្បច្ច័យដែលជាកាមាវចរវិបាក និងរូបាវចរវិបាក ជាបច្ច័យដល់ខន្ធទាំងឡាយ និងដល់កម្មជរូប ក្នុងខណៈបដិសន្ធិយ៉ាងពិតប្រាកដ ដោយអំណាចនៃ ***សហជាតត្ថិប្បច្ច័យ*** ។ ប៉ុន្តែ ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្តនឹងចិត្តជរូប ក្នុងបវត្តិកាល ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ, ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដែលមកដល់ឋិតិខណៈហើយ ដោយអំណាចនៃ ***បច្ឆាជាតត្ថិប្បច្ច័យ*** ។

ប៉ុន្តែ ***អរូបាវចរវិបាក និងលោកុត្តរវិបាក*** ដែលកើតក្នុងអរូបភព ជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយនឹងខ្លួនប៉ុណ្ណោះ ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ ។ លោកុត្តរវិបាកក្នុងបញ្ចវោការភព ជាបច្ច័យដល់ខន្ធដែលសម្បយុត្តជាមួយខ្លួន និងដល់ចិត្តជរូប ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដោយអំណាចនៃបច្ឆាជាតត្ថិប្បច្ច័យ ។ ***ដោយសេចក្តីជាកិរិយា*** អត្ថិប្បច្ច័យដែលជារូបាវចរកិរិយា ជាបច្ច័យដល់ខន្ធដែលសម្បយុត្តនឹងចិត្តជរូប ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ, ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដោយអំណាចនៃ ***បច្ឆាជាតត្ថិប្បច្ច័យ*** ។ ប៉ុន្តែ កាមាវចរកិរិយា និងអរូបាវចរកិរិយា ជាបច្ច័យដល់ខន្ធដែលសម្បយុត្តគ្នាប៉ុណ្ណោះ ក្នុងអរូបភព និងជាបច្ច័យ សូម្បីដល់ចិត្តជរូប ក្នុងបញ្ចវោការភព ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ ។ ជាបច្ច័យដល់កាយដែលមានសមុដ្ឋាន ៤ និងសមុដ្ឋាន ៣ ដោយអំណាចនៃ ***បច្ឆាជាតត្ថិប្បច្ច័យ*** ដែរ ។

ធម៌ គឺរូប ជាអត្ថិប្បច្ច័យ ៤ បច្ច័យ គឺសហជាត បុរេជាត អាហារ និងឥន្ទ្រិយ ។ ក្នុងបច្ច័យ ៤ នោះ អត្ថិប្បច្ច័យ គឺរូបដែលជាសហជាត មាន ៤ យ៉ាង ដោយអំណាចនៃសមុដ្ឋាន ។ ក្នុងសមុដ្ឋាន ៤ នោះ រូបដែលមានកម្មជាសមុដ្ឋាន ជាសហជាតត្ថិប្បច្ច័យយ៉ាងនេះ គឺមហាភូត-

*រូប ១ ជាបច្ច័យដល់មហាភូតរូប ៣, មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១, មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២, មហាភូតរូប ជាបច្ច័យដល់ឧបាទាយរូប ដោយអំណាចនៃ* ***សហជាតត្ថិប្បច្ច័យ*** *។ វត្ថុរូបក្នុងខណៈបដិសន្ធិ ជាបច្ច័យដល់កាមាវចរវិបាក និងរូបាវចរវិបាកក្ខន្ធ ដោយអំណាចនៃសហជាតត្ថិប្បច្ច័យ ។ រូបដែលមានសមុដ្ឋាន ៣ ដ៏សេស ជាបច្ច័យដោយអំណាចនៃសហជាតត្ថិប្បច្ច័យយ៉ាងនេះ គឺមហាភូតរូប ១ ជាបច្ច័យដល់មហាភូតរូប ៣, មហាភូតរូប ៣ ជាបច្ច័យដល់មហាភូតរូប ១, មហាភូតរូប ២ ជាបច្ច័យដល់មហាភូតរូប ២, មហាភូតរូប ជាបច្ច័យដល់ឧបាទាយរូប ។ ចំណែកបុរេជាតត្ថិប្បច្ច័យ មាន ២ យ៉ាង គឺវត្ថុបុរេជាត និងអារម្មណបុរេជាត ។ ទាំងពីរយ៉ាងនេះ អ្នកសិក្សាគប្បីជឿកាន់យកតាមន័យដែលខ្ញុំពោលហើយ ក្នុងបុរេជាតត្ថិប្បច្ច័យអំពីខាងដើម ។* ***សូម្បីអាហារត្ថិប្បច្ច័យ*** *គប្បីប្រកបតាមន័យដែលបានប្រកបហើយ ក្នុងកវឡិង្ការាហារប្បច្ច័យអំពីខាងដើមដែរ ។* ***ក៏អាហារត្ថិប្បច្ច័យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា អត្ថិប្បច្ច័យ ក្នុងអធិការនេះ ដោយសេចក្ដីជាបច្ច័យ ក្នុងខណៈដែលខ្លួននៅមិនទាន់រលត់ទៅ*** *។ សូម្បី* ***រូបជីវិតិន្ទ្រិយ*** *ក៏គប្បីកាន់យកតាមន័យដែលខ្ញុំពោលហើយ ក្នុងការអធិប្បាយ រូបជីវិតិន្ទ្រិយ និងក្នុងឥន្ទ្រិយប្បច្ច័យខាងដើមស្រាប់ ។ ក្នុង*

*ទីនេះ រូបជីវិតិន្ទ្រិយនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា អត្ថិប្បច្ច័យ ដោយសេចក្ដីជាបច្ច័យ ក្នុងខណៈដែលខ្លួននៅមិនទាន់រលត់ទៅ ។ អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយធម៌ដែលជាបច្ចយុប្បន្នក្នុងអធិការនេះ ដូច្នេះឯង ៕*

ចប់និទ្ទេសនៃអត្ថិប្បច្ច័យ

.......................................................

## ២២.ពណ៌នាអំពីនិទ្ទេសនៃនត្ថិប្បច្ច័យ

*អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***នត្ថិប្បច្ច័យ*** *តទៅ ៖*

*បទថា* **“សមនន្តរនិរុទ្ធា** *= ធម៌ទាំងឡាយដែលរលត់ទៅ ដោយមិនមានរវាងចន្លោះ”* *បានដល់ ធម៌ដែលមិនមានចន្លោះ ដោយចិត្តុប្បាទដទៃ គឺរលត់ទៅជាលំដាប់ដ៏ល្អ ។ បទថា* **“បដុប្បន្នានំ** *= កើតឡើងចំពោះមុខ (បច្ចុប្បន្ន)”* *, ព្រោះបទនេះ ព្រះមានព្រះភាគទ្រង់ញ៉ាំងភាវៈនៃនត្ថិប្បច្ច័យ ឲ្យសម្រេច ព្រោះអត្ថថា ផ្ដល់ឱកាសដល់នត្ថិប្បច្ច័យ (គឺធម៌ដែលនឹងកើតខាងក្រោយហើយប្រព្រឹត្តទៅ) ។ ពិតមែនហើយ កាលបើធម៌ដែលកើតមុន មិនផ្ដល់ឱកាសឲ្យដល់ធម៌ដែលកើតខាងក្រោយ ប្រព្រឹត្តទៅដោយអំណាចនៃការដែលខ្លួនឯងរលត់ទៅ ភាវៈនៃធម៌ខាងក្រោយទាំងនោះ នឹងកើតឡើងចំពោះមុខ ក៏មិនគួរមាន ។ ពណ៌នាបាលីក្នុងអធិការនេះ*

មានត្រឹមប៉ុណ្ណោះ ។ ពាក្យដែលនៅសល់ទាំងអស់ អ្នកសិក្សាគប្បីជ្រាប តាមន័យដែលខ្ញុំពោលហើយក្នុងអនន្តរប្បច្ច័យនុ៎ះឯង ។

ពិតមែនហើយ លក្ខណៈរបស់បច្ច័យប៉ុណ្ណោះ ជាការប្លែកគ្នារវាង អនន្តរប្បច្ច័យ និងនត្ថិប្បច្ច័យនេះ ។ ប៉ុន្តែ សេចក្ដីផ្សេងគ្នានៃបច្ច័យ និង បច្ចយុប្បន្ន មិនមានឡើយ ។ម្យ៉ាងទៀត ក្នុងបច្ច័យទាំងពីរនោះ ព្រះ មានព្រះភាគទ្រង់សម្ដែងបច្ច័យ និងបច្ចយុប្បន្ន ដោយសរុបទុក មានន័យ ជាដើមថា "ចក្ខុវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុ នោះ ជាបច្ច័យដល់មនោធាតុ" ។ ក្នុងទីនេះ ទ្រង់សម្ដែងធម៌ទាំងអស់នោះ ជាទូទៅ ដោយអំណាចនៃការរលត់ទៅ និងការកើតឡើងថា "ធម៌ គឺចិត្ត និងចេតសិកដែលរលត់ទៅតាមលំដាប់ដោយល្អ ជាបច្ច័យដល់ធម៌ គឺចិត្ត និងចេតសិកដែលកើតឡើងចំពោះមុខ"៕

ចប់និទ្ទេសនៃនត្ថិប្បច្ច័យ

.....................................

## ២៣.ពណ៌នាអំពីនិទ្ទេសនៃវិគតប្បច្ច័យ

ក្នុងនិទ្ទេសនៃ ***វិគតប្បច្ច័យ*** បទថា **"សមនន្តរវិគតា"** គឺប្រាសចាក ទៅតាមលំដាប់ដោយល្អ ។ ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា

*“វិគតប្បច្ច័យ ជាបច្ច័យដោយភាវៈដែលខ្លួនឯង ប្រាសចាកទៅ”* ។ *នត្ថិប្បច្ច័យ និងវិគតប្បច្ច័យនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ, ឯសេចក្តីវិញ មិនផ្សេងគ្នាឡើយ ៕*

ចប់និទ្ទេសនៃវិគតប្បច្ច័យ

........................

## ២៤.ពណ៌នានិទ្ទេសនៃអវិគតប្បច្ច័យ

*ពាក្យជាដើមថា* **“ចក្ខុំ ខន្ធា”** *ក្នុងនិទ្ទេសនៃ* ***អវិគតប្បច្ច័យ*** *អ្នកសិក្សា គប្បីជ្រាបនូវសេចក្តីដោយអាការទាំងពួង តាមន័យដែលបានខ្ញុំពោលហើយ ក្នុងនិទ្ទេសនៃអត្ថិប្បច្ច័យ ។ ពិតណាស់ បច្ច័យនេះ (អវិគតប្បច្ច័យ) និងអត្ថិប្បច្ច័យ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ, ឯសេចក្តីមិនផ្សេងគ្នាទេ ៕*

ចប់និទ្ទេសនៃអវិគតប្បច្ច័យ

---

# បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះបញ្ចបករណ៍ តតិយភាគ ១១ ចប់

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)